ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង

# សៀវភៅជំនួយគ្រូ
# មត្តេយ្យសិក្សាសហគមន៍

## សម្រាប់ខែទី៥ និងទី៦



ឧបត្ថម្ភដោយ

អង្គការគាំពារកុមារភៀសខ្លួន

特定非営利活動法人
幼い難民を考える会
CYR
CARING FOR YOUNG REFUGEES

ខែឧសភា ឆ្នាំ២០២៤

# សមាសភាពគណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង និងដឹកនាំ

| | |
|---|---|
| ១. លោក ស៊ឹម ប្រិម | ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ឆ្នាំង |
| ២. លោកស្រី ចាន់ ស្រី | នាយិកាអង្គការគាំពារកុមារខ្មែរ |
| ៣. លោកស្រី ស៊ុំ សុភ័ក្រ្ត | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ឆ្នាំង |
| ៤. លោកស្រី អ៊ុម សុផានី | ទីប្រឹក្សាបច្ចេកទេសផ្នែកអប់រំកុមារតូច អង្គការ CYK |

## ២. គណៈកម្មការនិពន្ធខ្លឹមសារ និងរៀបរៀង

| | |
|---|---|
| ១. លោកស្រី នៅ និមល | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ២. លោក ឯម ស៊ីនួន | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តពោធិ៍សាត់ |
| ៣. លោក អេត អូ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ |
| ៤. លោក ហម វណ្ណារិទ្ធ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល |
| ៥. លោក ហែម ចន្ទី | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពត |
| ៦. លោកស្រី លន់ សត្យា | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៧. លោកស្រី ប៊ួយ សំអឿន | មន្ត្រីការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៨. លោកស្រី ប៉ាង ទីម៉េត | មន្ត្រីការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៩. លោកស្រី តេង ផានី | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង |
| ១០. លោកស្រី ញ៉ែម សៀងថៃ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង |
| ១១. លោក ជៀន វណ្ណៈ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង |
| ១២. លោកស្រី មុំ ចរិយា | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង |
| ១៣. លោកស្រី ផូ សុម៉ាលី | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង |
| ១៤. លោកស្រី ខាត់ ផល្លាប | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង |
| ១៥. លោក ទេស សារិ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកជលគិរី ខេត្តកំពង់ឆ្នាំង |

## ៣. គណៈកម្មការកុំព្យូទ័រ និងរចនាបថ

| | |
|---|---|
| ១. លោក ហម វណ្ណារិទ្ធ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល |
| ២. លោក ហែម ចន្ទី | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពត |
| ៣. លោក ជៀន វណ្ណៈ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង |

## ៤. គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

| | |
|---|---|
| ១.លោកស្រី ស៊ុំ សុភក្ត្រ័ | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ២. លោកស្រី អ៊ុម សុផានី | ទីប្រឹក្សាបច្ចេកទេសផ្នែកអប់រំកុមារតូច អង្គការ CYK |
| ៣. លោកស្រី នៅ និមល | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៤. លោក ឯម ស៊ីនួន | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តពោធិ៍សាត់ |
| ៥. លោក អេត អូ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ |
| ៦. លោក ហែម ចន្ទី | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពត |
| ៧. លោកស្រី លន់ សត្យា | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |

# ការណែនាំអនុវត្តជារួម

សៀវភៅនេះមានគោលបំណង ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់គ្រូមត្តេយ្យសិក្សាសហគមន៍ដែលត្រូវមានឯកសារគ្រប់គ្រាន់និងសម្បូរបែបក្នុងការដឹកនាំសកម្មភាពបង្រៀន និងរៀនឱ្យមានលក្ខណៈជាថ្នាក់កុមារមេត្រី ស្របតាមគោលវិធីសាស្ត្រចម្រុះ។ ម្យ៉ាងទៀតសៀវភៅនេះបានជួយដល់គ្រូឱ្យមានភាពងាយស្រួលពីដំណើរការនៃការបង្រៀន ការរៀបចំកិច្ចតែងការបង្រៀនជាពិសេសការកំណត់វត្ថុបំណងទៅតាមមេរៀននីមួយៗ ការប្រើប្រាស់សម្ភារឧបទេសសម្រាប់គ្រូ និងកុមារ ការរៀបចំកុមារធ្វើសកម្មភាព និងយល់កាន់តែច្បាស់ពីខ្លឹមសារមេរៀន ទៅតាមមុខវិជ្ជា និងរបៀបលេងល្បែងទៅតាមមុខវិជ្ជាទាំង៥ ដែលគ្រូត្រូវផ្ទេរចំណេះដឹងឱ្យកុមារ ហើយកុមារមានលទ្ធភាពទទួលបានពេញលេញនូវសុខុមាលភាពរាងកាយ និងផ្លូវចិត្ត ស្មារតីសាមគ្គី មានភាពម្ចាស់ការ ការទទួលខុសត្រូវ សមត្ថភាពពិចារណា ការដោះស្រាយបញ្ហា មានស្មារតីស្រឡាញ់បរិស្ថាន និងការចូលរួមរបស់កុមារ ។

ចំពោះចំនួនថ្ងៃដែលបានរៀបចំនៅក្នុងសៀវភៅនេះគឺយកតាមចំនួនថ្ងៃក្នុងប្រតិទិនសិក្សាឆ្នាំ២០២៣-២០២៤ ដែលមានចំនួន ២០១ថ្ងៃត្រូវរៀន។ ប៉ុន្តែបើគ្រូត្រូវរៀបចំកម្មវិធីសិក្សាទៅតាមឆ្នាំនីមួយៗអាចជ្រើសរើសមេរៀនក្នុងសៀវភៅនេះយកទៅរៀបចំទៅតាមលំដាប់លំដោយក្នុងខែ នៃឆ្នាំ និងអាចបន្ថែមមេរៀន ឬប្តូរមេរៀនទៅតាមគំនិតច្នៃប្រឌិតរបស់គ្រូម្នាក់ៗ ធ្វើយ៉ាងណាឱ្យបានសម្រេចលទ្ធផលដូចគ្នា។

សៀវភៅនេះមិនមែនជាកិច្ចតែងតែងការបង្រៀនទេ ព្រោះសរសេរតែពីដំណើរការបង្រៀននៅជំហានទី៣ (មេរៀនថ្មី) ប៉ុណ្ណោះ ដូចនេះគ្រូនៅតែរក្សាការសរសេរកិច្ចតែងការបង្រៀន និងផែនការបង្រៀនប្រចាំថ្ងៃដដែល។

ចំពោះការប្រើប្រាស់សម្ភារឧបទេសសម្រាប់គ្រូ និងសម្រាប់កុមារ ការរៀបចំកុមារធ្វើសក្មភាព និងវិធីសាស្ត្រនៃការបង្រៀន ដែលបានកំណត់ទៅតាមមេរៀននីមួយៗក្នុងសៀវភៅនេះ ពេលយកទៅអនុវត្តគ្រូអាចបត់បែនបានតាមស្ថានភាពជាក់ស្តែងទៅតាមសាលានីមួយៗ និងតាមមេរៀននៃមុខវិជ្ជានីមួយៗ។

ចំពោះការធ្វើចលនាទៅតាមខ្លឹមសារនៃបទចម្រៀងក្នុងមុខវិជ្ជាចិត្តចលភាព និងការធ្វើកាយវិការ ទៅតាមខ្លឹមសារនៃបទចម្រៀងក្នុងមុខវិជ្ជាសិក្សាសង្គម គ្រូអាចបត់បែនទៅតាមគំនិតច្នៃប្រឌិតរបស់គ្រូម្នាក់ៗ គ្រាន់តែធ្វើយ៉ាងណាឱ្យស្របទៅតាមខ្លឹមសារនៃបទចម្រៀងនីមួយៗ។

បើករណីមេរៀននៅក្នុងមុខវិជ្ជាណាមួយ ពេលពង្រឹងចំណេះដឹង (ជំហាន៤) គ្រូនាំកុមារធ្វើសកម្មភាព ហើយត្រូវមានសម្ភារសម្រាប់ប្រើប្រាស់នោះគ្រូត្រូវបន្ថែមឈ្មោះនិងចំនួនសម្ភារទៅក្នុងចំណុចនៃការរៀបចំសម្ភារ។

សៀវភៅជំនួយគ្រូដែលក្រុមការងារបានរៀបចំនេះមិនទាន់បានល្អប្រសើរនៅឡើយ មានមេរៀនក្នុងមុខវិជ្ជាខ្លះ សរសេរមិនទាន់បានទៅតាមលំដាប់លំដោយពីដំណើរការបង្រៀននោះទេ ដោយសារពេលវេលាមិនសមស្របទៅតាមចំនួនមេរៀនក្នុងកម្មវិធីសិក្សា ដូច្នេះបើមានមេរៀនក្នុងមុខវិជ្ជាណាមួយដែលមើលទៅហើយពិបាកយល់នោះ គ្រូអាចកែតម្រូវបានឱ្យប្រសើរជាងនេះ ពិសេសឱ្យតែកុមារបានទទួលចំណេះដឹងស្របទៅតាមវត្ថុបំណងនៃមេរៀននីមួយៗ។

សៀវភៅជំនួយគ្រូមត្តេយ្យសិក្សាសហគមន៍ ដែលក្រុមការងារបានរៀបចំនេះមិនមែនជាបទពិសោធន៍ល្អសម្រាប់គ្រូយកធ្វើជាគំរូតាមនោះទេ គ្រាន់តែជាសៀវភៅយោងសម្រាប់គ្រូយកទៅបានជាគំនិតដោយគួបផ្សំទៅនឹងគំនិតច្នៃប្រឌិតរបស់គ្រូម្នាក់ៗ ដើម្បីឱ្យការងារបង្រៀន និងរៀនបានកាន់តែល្អប្រសើរបន្ថែមទៀត ជាពិសេសកុមារទាំងអស់រៀនមានគុណភាពដូចគ្នាៗ ដើម្បីជាមូលដ្ឋានគ្រឹះរឹងមាំ ត្រៀមខ្លួនចូលរៀននៅសាលាបឋមសិក្សាមិនទត្រួតថ្នាក់ និងមិនបោះបង់ការសិក្សាឡើយ។

# ឯកសារយោង

១. សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ទាំង៥មុខវិជ្ជា របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០២២
២. សៀវភៅការផលិតសម្ភារៈល្បែង សម្រាប់កុមារតូច របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០២៤
៣. សៀវភៅណែនាំ សម្រាប់គ្រូបង្រៀន មត្តេយ្យសិក្សា ស្តីពីសម្ភារៈជំនួយបន្ថែម របស់ក្រសួងអប់រំ ឆ្នាំ២០១៨
៤. ឯកសារ សម្រាប់មត្តេយ្យសិក្សាសហគមន៍ របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០០៦
៥. កម្មវិធីសិក្សាលម្អិត សម្រាប់មត្តេយ្យសិក្សាសហគមន៍ របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០២១
៦. សៀវភៅរឿងនិទាន របស់អង្គការគាំពារកុមារខ្មែរ (CYK)
៧. ចម្រៀងកុមារមត្តេយ្យ ភាគ១ និងភាគ២ របស់អង្គការគាំពារកុមារខ្មែរ (CYK) បោះពុម្ពឆ្នាំ ២០១២
៨. សៀវភៅកំណាព្យ និងពាក្យបណ្តៅសម្រាប់មត្តេយ្យសិក្សា បោះពុម្ពឆ្នាំ ២០០៧






រឿង
ទីណូ ស្រួច និង ផ្លែត្រសក់
ឆ្នាំ ២០១០


រឿង
ទីណូនិងស្បែកជើង
ឆ្នាំ ២០១០


រឿង
សម្លាញ់បីនាក់
ឆ្នាំ ២០១០


រឿង
កូនទន្សាយចេះស្តាប់បង្គាប់
ឆ្នាំ ២០១០


រឿង
ប្រាជ្ញាទីណូ
ឆ្នាំ ២០១០


កំណាព្យ
សម្រាប់មត្តេយ្យសិក្សា
ឆ្នាំ ២០០៧




សួនកំណាព្យកុមារ


ពាក្យបណ្តៅ
សម្រាប់មត្តេយ្យសិក្សា
ឆ្នាំ ២០០៧


អាគីឆ្កែខ្ញុំ
ចម្រៀងកុមារមត្តេយ្យ ភាគ១

# កម្មវិធីសិក្សាខែទី៥

## កម្មវិធីសិក្សាប្រចាំខែទី៥ (១២ថ្ងៃ)

| ម៉ោង | ថ្ងៃទី១ ចន្ទ | ថ្ងៃទី២ អង្គារ | ថ្ងៃទី៣ ពុធ | ថ្ងៃទី៤ សុក្រ | ថ្ងៃទី៥ សៅរ៍ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ហាត់ប្រាណតាមបទចម្រៀង៖ "ធ្មង ស្គាំ" | ហាត់ប្រាណតាមរឿងនិទាន៖ "យើងនាំគ្នាទៅលេងបុណ្យចូលឆ្នាំខ្មែរ" | ចលនាមូលដ្ឋាន៖ "បោះ" -បោះបាល់ចូលកន្ត្រក -បោះកងចូលដប -បោះបាល់ឱ្យគ្នាទៅវិញទៅមក | ចលនាចរន្ត៖ "ដើរ រត់ លោត បោះ" -ដើរបត់បែនតាមខ្សែ -រត់ទៅរកទី -លោតជើង២ទៅមុខ -បោះបាល់ចូលកន្ត្រក | ល្បែងចលនា៖ "លាក់កន្សែង" |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ គោរពចាស់ទុំ (ពេលដើរជិតចាស់ៗត្រូវអោនៗនិងដោះមួក) | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ត" | វិទ្យាសាស្ត្រ<br>ល្បែង៖ ធ្វើចំណាត់ថ្នាក់ក្រុមអាហារ | បុរេគណិត<br>ល្បែង៖ ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១ដល់១៣ | ភាសាខ្មែរ<br>ល្បែង៖ គូសភ្ជាប់តួអក្សរទៅនឹងពាក្យរៀនរួច | បុរេគណិត<br>ល្បែង៖គូសភ្ជាប់លេខដូចគ្នា |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ចម្រៀង៖ដើរឬដេក (ពេលទី១) | សិក្សាសង្គម<br>គំនូរ៖ ព្រះអាទិត្យ | សិក្សាសង្គម<br>សកម្មភាពកសាង៖រៀបវត្ថុតូចៗបិទលើផ័ត្រ | សិក្សាសង្គម<br>ល្បែង៖ទាយលំដាប់អក្សរ | សិក្សាសង្គម<br>រឿងនិទាន៖ មើមឆៃថាវដ៏ធំ |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>សង្កេត៖អាហារបីក្រុម | បុរេគណិត<br>សម្គាល់៖ចំនួននិងលេខពី១ដល់១៣ | ភាសាខ្មែរ<br>ល្បែង៖ទះដៃតាមចំនួនព្យាង្គពី២ទៅ៤ព្យាង្គ | វិទ្យាសាស្ត្រ<br>សន្ទនា៖វត្ថុធាតុដើមនៃចំណីអាហារ | ភាសាខ្មែរ<br>កំណាព្យ៖អាហារបីក្រុម |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ ចាក់ទឹកដូង |

| ម៉ោង | ថ្ងៃទី៦ ចន្ទ | ថ្ងៃទី៧ អង្គារ | ថ្ងៃទី៨ ពុធ | ថ្ងៃទី៩ សុក្រ | ថ្ងៃទី១០ សៅរ៍ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ហាត់ប្រាណតាមបទចម្រៀង៖ "ធ្វេង ស្តាំ" (រំលឹក) | ហាត់ប្រាណតាមរឿងនិទាន៖ "យើងនាំគ្នាទៅលេងបុណ្យចូលឆ្នាំខ្មែរ" (រំលឹក) | ចលនាមូលដ្ឋាន៖ "បោះ"<br>-បោះបាល់ចូលរាងការេ<br>-បោះបាល់ឬវត្ថុបន្តគ្នា<br>-បោះបាល់ឬវត្ថុឱ្យចំទិសដៅ | ចលនាចរន្ត៖ "ដើរ រត់ លោត បោះ"<br>-ដើរបត់បែនតមខ្សែ<br>-រត់ទៅរកទី<br>-លោតជើង២ទៅមុខ<br>-បោះបាល់ចូលកន្ត្រក (រំលឹក) | ល្បែងចលនា៖ "បោះអង្គុញ" |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀននិងភូមិ) | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ថ" | វិទ្យាសាស្ត្រ<br>សន្ទនា៖ សារៈសំខាន់នៃការញ៉ាំចំណីអាហារ | បុរេគណិត<br>សម្គាល់៖ខ្ពស់និងទាប | ភាសាខ្មែរ<br>ល្បែង៖ប្រព័ន្ធគ្រួសារម្ហូបអាហារ | បុរេគណិត<br>ល្បែង៖បន្ថែមនិងបន្ថយចំនួនពី១ដល់១០(រំលឹក) |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ចម្រៀង៖ដើរឬដេក (ពេលទី២) | សិក្សាសង្គម<br>គំនូរ៖ផាត់ពណ៌រូបព្រះអាទិត្យ | សិក្សាសង្គម<br>សកម្មភាពកសាង៖ដេរតាមទម្រង់រូបម្ជុក | សិក្សាសង្គម<br>ល្បែង៖ទាយលំដាប់អក្សរ (រំលឹក) | សិក្សាសង្គម<br>រឿងនិទាន៖បុណ្យចូលឆ្នាំខ្មែរ (និទាន) |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>សង្កេត៖បុណ្យចូលឆ្នាំខ្មែរ | បុរេគណិត<br>ល្បែង៖ភ្លើងឆេះលើភ្នំលេខពី៩ដល់១៣ | ភាសាខ្មែរ<br>ល្បែង៖សង្កេតរួចគូសវង់រូបដែលដូចគ្នា | វិទ្យាសាស្ត្រ<br>ល្បែង៖ស្ល សម្លកកូរ | ភាសាខ្មែរ<br>ល្បែង៖បំពេញតួអក្សរតាមចន្លោះពី ច ដល់ ណ |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ ចាក់ទឹកដូង(រំលឹក) |

| ម៉ោង | ថ្ងៃទី១១ ចន្ទ | ថ្ងៃទី១២ អង្គារ |
|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | |
| ៧៖១០-៧៖៤០ | ហាត់ប្រាណតាមបទចម្រៀង៖ "សារិកាកែវពត់ប្រាណ" (រំលឹក) | ហាត់ប្រាណតាមរឿងនិទាន៖ តាយាយនាំគ្នាទៅមើលស្រែ |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និង បង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀងបទ "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ត្រូវចូលគេងឱ្យបានទៀងទាត់ពេលវេលា (រំលឹក) | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>គំនូរ៖ គូរចម្លងតាមគំរូតួអក្សរ ញ ដ ណ | វិទ្យាសាស្ត្រ<br>ពិសោធន៍៖ វត្ថុរលាយក្នុងទឹក យឺត លឿន |
| ៨៖៤០-៨៖៥០ | **ចេញលេង** | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ចម្រៀង៖ មេរៀនសង្កេត (ពេលទី១) | សិក្សាសង្គម<br>គំនូរ៖ គូររូបផ្ទៃត្រ |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>សង្កេត៖ រដូវប្រាំង | បុរេគណិត<br>គំនូរ៖ គូរចម្លងតាមគំរូលេខ ៩ និងលេខ១០ |
| ៩៖៥០-១០៖០០ | **ចេញលេង** | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

# ដំណើរការបង្រៀនតាមកម្មវិធី

# សកម្មភាពបង្រៀន ប្រចាំខែទី ៥
# ថ្ងៃទី១
ម៉ោងទី១ (រយៈពេល ៣០នាទី)
## មុខវិជ្ជា៖ ចិត្តចលភាព
## ហាត់ប្រាណតាមបទចម្រៀង៖ ឆ្វេង-ស្តាំ

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីរបៀបធ្វើចលនាលើកជើងឆ្វេង ជើងស្តាំហើយបោះជើងបានត្រឹមត្រូវ
- កុមារធ្វើចលនាដើរលើកជើងឆ្វេង បោះដៃស្តាំ លើកជើងស្តាំ បោះដៃឆ្វេង បោះដៃស្តាំ ទៅមុខទៅក្រោយតាមបទចម្រៀងបានត្រឹមត្រូវ
- បណ្តុះស្មារតីកុមារឱ្យមានភាពរហ័សរហួន ស្វាហាប់ ធ្វើចលនាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** រៀបកុមារឱ្យឈរជារង្វង់

**៤. ដំណើរការបង្រៀន៖ អនុវត្តក្នុងជំហ៊ានទី៣**
- គ្រូឱ្យកុមារឈរជារង្វង់ ហើយគ្រូឈរចំកណ្តាលរង្វង់
- គ្រូនាំកុមារទាំងអស់ធ្វើចលនាគ្រាប់តាមខ្យល់បក់លើកដៃទាំងពីរឡើងលើរទៅឆ្វេង រទៅស្តាំ បត់ទៅមុខបត់ទៅក្រោយធ្វើ ២ ទៅ ៣ដង
- គ្រូច្រៀងឱ្យកុមារស្តាប់ និងធ្វើចលនាឱ្យកុមារមើលតាមបទចម្រៀងរហូត១ចប់
- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងទាំងអស់គ្នាអាស្រ័យតាមពេលវេលា(២ឬ៣ចប់)
- កូនៗធ្វើចលនាអម្បាញ់មិញហាត់ឬទេ? បើហាត់ដើម្បីធ្វើឱ្យមានកម្លាំងកូនត្រូវញ៉ាំទាំងអស់គ្នា តែទឹកនោះគឺទឹកដាំពុះ វាក្តៅដើម្បីញ៉ាំបានកូនត្រូវផ្លុំឱ្យត្រជាក់សិន (កុមារដកដង្ហើមវែងៗ ២ ទៅ ៣ ដង) ពេលធ្វើ ចលនាយកកាន់កែវទឹកហើយញ៉ាំទាំងអស់គ្នាឮ អឹកៗៗៗ
- ថ្ងៃនេះកូនរៀនមុខវិជ្ជាចិត្តចលភាពអំពី ហាត់ប្រាណតាមបទចម្រៀង ចំណងជើង "ឆ្វេង-ស្តាំ"គ្រូឱ្យកុមារថាតាម១នាក់ ២នាក់តាមក្រុម
- គ្រូឱ្យកុមារឈរជារង្វង់នៅមុខថ្នាក់រៀនគ្រូឈរចំកណ្តាលរង្វង់
- គ្រូនាំកុមារធ្វើចលនាគ្រាប់តាមសត្វហើរ(៤ដង ទៅ ៥ដង)
- បន្ទាប់មកគ្រូលើកដៃឆ្វេងឡើងលើហើយសួរកុមារថា តើគ្រូលើកដៃខាងណា? ហើយបន្តលើកដៃស្តាំហើយសួរ ទៅកុមារទៀត(ដៃឆ្វេង ដៃស្តាំ)
- គ្រូប្រាប់ចំណងជើង ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាចិត្តចលភាព ចំណងជើង ហាត់ប្រាណតាមបទចម្រៀង "ឆ្វេង ស្តាំ"
- គ្រូនាំកុមារអានចំណងជើងទាំងអស់គ្នា(២ដង ទៅ ៣ដង)
- គ្រូច្រៀងនឹងធ្វើចលនាឱ្យកុមារស្តាប់ និងសង្កេតមើលទៅតាមខ្លឹមសារនៃបទចម្រៀងរហូតដល់ចប់ (១ចប់ ឬ ២ចប់)
- គ្រូច្រៀង និងប្រាប់ពីរបៀបធ្វើចលនាតាមខ្លឹមសារនៃបទចម្រៀងម្តង១វគ្គៗ (ច្រៀងបណ្តើរធ្វើចលនាបណ្តើរបង្ហាញកុមារ)

- ឆ្វេងស្តាំចាំឱ្យស្ទាត់( កូនលើកជើងឆ្វេង ហើយដៃស្តាំកូនបោះទៅមុខ នឹងដៃឆ្វេងកូនបោះទៅក្រោយ រួចដាក់ជើងឆ្វេងចុះហើយលើកជើងស្តាំ រួចកូនបោះដៃឆ្វេងទៅមុខ និងបោះដៃស្តាំទៅក្រោយ(ធ្វើដូចដំណើរពូកងទ័ព)(ត្រង់ពាក្យថា ១.កូនលើកជើងឆ្វេងបោះ ពាក្យថា ២.កូនលើកជើងស្តាំបោះដាក់ជិតគ្នា)

+**បញ្ជាក់៖** គ្រូនាំកុមារច្រៀង និងធ្វើចលនាបន្តគ្នារហូតពីវគ្គទី ១ ២ ៣ ៤ (ធ្វើចលនាដដែលៗដូចចលនា វគ្គទី ១)

- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងពីដើមដល់ចប់ សាចុះ សាឡើង (២ចប់ ទៅ ៣ចប់ អាស្រ័យពេលវេលា)
- គ្រូនិយាយ បន្ទាប់ពីហាត់ធ្វើចលនារួច កូនហត់ឬទេ? បើហត់កូនៗផ្តុំទឹកក្តៅញុំាទាំងអស់គ្នា(ដកដង្ហើមចូលឱ្យវែងរួចបញ្ចេញខ្យល់ផ្លុំ ៣ដង រួចញុំា)។

## របៀបធ្វើចលនា

- ឆ្វេង ស្តាំ ចាំឱ្យស្ទាត់១-២ ពួកយើងប្រយ័ត្នដើរឱ្យត្រូវជើង១-២= កុមារបង់បោយដៃដើរទៅមុខដោយចាប់ឈានជើងឆ្វេងទៅមុន ពេល១-២ ត្រូវឈប់ហើយទះដៃពីរដង
- ឆ្វេង ស្តាំត្រូវចាំពួកយើង១-២ ដើរឱ្យត្រូវជើងកុំឱ្យច្រឡំ ១-២= កុមារបង់បោយដៃដើរត្រឡប់ក្រោយដោយចាប់ឈានជើងឆ្វេងទៅមុន ពេល១-២ ត្រូវឈប់ហើយទះដៃពីរដង (ពេលច្រៀងលើកទី២ ធ្វើដូចគ្នា ប៉ុន្តែគ្រាន់តែ១-២ ត្រូវឈប់ហើយគោះជើងពីរដង ដោយចាប់គោះជើងឆ្វេងមុន)

អត្ថបទចម្រៀង "**ឆ្វេង-ស្តាំ**"

| | |
|---|---|
| -ឆ្វេង ស្តាំ ចាំឱ្យស្ទាត់១-២ | ពួកយើងប្រយ័ត្នដើរឱ្យត្រូវជើង១-២ |
| ឆ្វេង ស្តាំត្រូវចាំពួកយើង១-២ | ដើរឱ្យត្រូវជើងកុំឱ្យច្រឡំ ១-២។ |

**ម៉ោងទី ២ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចេះគោរពចាស់ទុំ( ពេលដើរជិតចាស់ៗត្រូវឱននិងដោះមួក)

- គ្រូនិទានរឿងខ្លី៖ ថ្ងៃមួយគ្រូបានទៅចូលរួមបុណ្យនៅក្នុងភូមិ ពេលគ្រូនិងចាស់ៗកំពុងអង្គុយស្តាប់លោកសូត្រធម៌ស្រាប់តែមានកុមារីម្នាក់រត់មកក៏ឈប់នៅពីមុខរោងបុណ្យហើយសម្លឹងរកកន្លែងអង្គុយ។ មួយសន្ទុះមកគេក៏ឃើញនៅមុខចាស់ៗអង្គុយមានកន្លែងមួយទំនេរ ស្រាប់តែគេក៏លើកដៃសំពះសូមលោកយាយលោកតាដើម្បីសុំផ្លូវដើរទៅខាងមុខរកកន្លែងអង្គុយ។ ពេលលោកយាយលោកតាបើកផ្លូវឱ្យដើរកុមារីនោះបានដើរឱនៗរហូតដល់កន្លែងក៏អង្គុយសំពះស្តាប់លោកដែរ។ ពេលចប់បុណ្យគ្រូបានដើរត្រឡប់មកផ្ទះវិញមកដល់ពាក់កណ្តាលផ្លូវក៏ឃើញលោកតាពីរនាក់កំពុងឈរជជែកគ្នាលេងនៅក្រោមដើមឈើជិតផ្លូវ ស្រាប់តែមានកុមារាម្នាក់ពាក់មួកហើយក៏ដើរមកជិតលោកតាដែលកំពុងជជែកគ្នាលេង គេក៏បានដោះមួកចេញហើយលើកដៃសំពះជម្រាបសួរលោកតា សួរសុខទុក្ខលោកតា និងជម្រាបលាលោកតាបន្តដំណើរទៅមុខទៀត។

- គ្រូសួរកុមារ៖ កូនៗគិតមើលតើកុមារទាំងពីរនាក់នេះធ្វើដូច្នេះត្រឹមត្រូវឬទេ? ហេតុអ្វី? ជាកូនល្អឬទេ? កូនធ្វើតាមមិត្តភក្តិទាំងពីរនាក់នេះឬទេ?
- គ្រូបញ្ជាក់បន្ថែម៖ ដូច្នេះកូនៗទាំងអស់គ្នាពេលដើរជិតចាស់ៗ ត្រូវដើរឱនៗ ពេលកូនមានពាក់មួកដើរជិតចាស់ៗ ត្រូវដោះមួកចេញ គោរពពួកគាត់។
- គ្រូឱ្យកុមារអនុវត្ត ដោយឱ្យកុមារមួយក្រុមធ្វើជាចាស់ៗ និងកុមារមួយក្រុមធ្វើជាកុមារ

* គ្រូប្រាប់ពីសកម្មភាពដែលត្រូវរៀនក្នុងមួយព្រឹក រួចឱ្យកុមារថាតាម(ជាក្រុម រួចទាំងអស់គ្នា)។

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### សម្គាល់តួអក្សរ៖ "ត"

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ "ត" បានត្រឹមត្រូវ
- កុមារកំណត់បានពីរូបរាងឈ្មោះអក្សរ"ត" និងរកពាក្យថ្មីផ្តើមចេញពីអក្សរ"ត" បានត្រឹមត្រូវ
- កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្តើមពីអក្សរ"ត"។

**២. សម្ភារបង្រៀន៖**

- ផ្ទាំងរូបភាព តា តុ តៅ
- ប័ណ្ណពាក្យ តា តុ តៅ និងល្បះ តាតំដាំតៃ
- ប៊ិក ហ្វឺត ស្កុត (កាត់រៀបចំឱ្យហើយ)

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀន៖អនុវត្តក្នុងជំហ៊ានទី៣**

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "តា" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញប័ណ្ណពាក្យ "តា" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"តុ" ដោយលោស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញប័ណ្ណពាក្យ "តុ" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "តៅ" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "តៅ" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្តិពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "តៅ" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន ហើយបង្ហាញ

បណ្ណពាក្យ"តៅ" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង

- គ្រូបង្ហាញឃ្លា "តាតំដាំតៃ" អានឱ្យកុមារស្ដាប់រួចយកបិទពីក្រោមពាក្យនាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្ដាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្ដាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ) សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអំបាញ់មិញឮសូរដូចម្ដេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

**+ ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលកុមារឡើងមកគូសជុំវង់វិញអក្សរមានរាងដូចគ្នាច្រើន បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារគូសវង់ដើម្បីផ្ទៀងផ្ទាត់ពីចំនួនច្រើន។

**+ ប្រាប់ឈ្មោះតួអក្សរ៖**

- សួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)គ្រូបង្ហាញអក្សរចល័ត "ត" រួចសួរកុមារអក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"ត" យ៉ាងធំនៅជ្រុងក្ដារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"ត" នាំកុមារអានអក្សរ"ត" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀនរួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

**+ ប្រៀបធៀបអក្សរស្រដៀង៖**

- គ្រូសរសេរអក្សរ " ត ក គ ភ " នៅលើក្ដារខៀន
- គ្រូអានអក្សរ "ត ក គ ភ " ឱ្យកុមារស្ដាប់ និងសង្កេត
- សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

**+ រកពាក្យថ្មីផ្ដើមពីអក្សរ "ត" ៖**

- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្ដាប់សូរឱ្យកុមាររកពាក្យថ្មីដែលផ្ដើមពីអក្សរ"ត" គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្ដារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវនាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្ដងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"ត" ឬទេ? បើត្រឹមត្រូវគ្រូគូសវង់ជុំវិញពាក្យនោះ។ បើពាក្យខុសគ្រូមិនត្រូវធ្វើអ្វីទាំងអស់។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ ដើរ ឬដេក (ពេលទី១)

### ១. វត្ថុបំណង៖

- កុមារប្រាប់បានពីអត្ថន័យ និងរបៀបធ្វើកាយវិការតាមបទចម្រៀងដើរ ឬដេកបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងដើរ ឬដេកបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងចម្រៀង សហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។

### ២. សម្ភារបង្រៀន៖

- ផ្ទាំងក្រដាសធំ សរសេរខ្លឹមបទចម្រៀងដើរ ឬដេកសម្រាប់បិទលើក្តារខៀន
- ស្កុត ហែកត្រៀមទុកជាស្រេច

### ៣. ការរៀបចំកុមារ៖ អង្គុយជាអក្សរ អ៊ុយ "U"

### ៤. ដំណើរការបង្រៀន៖ អនុវត្តក្នុងជំហ៊ានទី៣

- គ្រូបំផុសសំណួរ និងឱ្យកុមារឆ្លើយ និងធ្វើបង្ហាញ៖ ពេលកូនដើរ ឬដេក ឬអង្គុយ ឬឈរ តើកូនត្រូវដើរ ឬដេក ឬអង្គុយ ឬឈរ បែបណាទើបត្រឹមត្រូវ ? ដូច្នេះកូនទាយទៅមើលថា ថ្ងៃនេះ គ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះ គ្រូនឹងបង្រៀនកូននូវមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "ដើរ ឬដេក"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់ និងសរសេរមុខវិជ្ជា និងចំណងជើងដាក់លើក្តារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូយកផ្ទាំងក្រដាសខ្លឹមសារចម្រៀងបិទលើក្តារខៀន រួចច្រៀង និងធ្វើកាយវិការឱ្យកុមារស្តាប់ និងមើលមួយចប់
- គ្រូនាំកុមារអានពាក្យពិបាកនៅក្នុងអត្ថបទចម្រៀងដែលគ្រូគូសសម្គាល់លើខ្លឹមសារផ្ទាំងអត្ថបទចម្រៀង (តម្រង់ ញញឹម សង្ឃឹម ក្លាហាន )ជាក្រុម និងទាំងអស់គ្នា រួចប្រាប់ពីអត្ថន័យរបស់ពាក្យទៅកាន់កុមារ និងនាំកុមារអានតាមទាំងអស់គ្នាផងដែរ( តម្រង់ មានន័យថាធ្វើឱ្យត្រង់, ញញឹម មានន័យថាសើចដោយក្តីរីករាយ , សង្ឃឹម មានន័យថាការគិតថានឹងទទួលបាន, ក្លាហានមានន័យថា ហ៊ាន)
- គ្រូសួរកុមារ៖ កូនដឹងទេថា តើចម្រៀង"ដើរ ឬដេក"នេះ ចង់និយាយពីអ្វី? បើកុមារមិនអាចឆ្លើយបាន គ្រូត្រូវប្រាប់កុមារពីអត្ថន័យបទចម្រៀង ដោយប្រាប់កុមារថា៖ ចម្រៀងនេះមានន័យថា ពេលកូនដើរ ឬដេក ឈរ ឬអង្គុយ កូនត្រូវធ្វើឱ្យត្រង់ខ្លួន ហើយត្រូវញញឹមរួសរាយ មិនត្រូវក្រឡេមក្រឡឹម ងាកចុះឡើង ហើយត្រូវហ៊ានឆ្លើយឆ្លងនៅពេលដែលមានអ្នកសួរ ឬនិយាយជាមួយកូន។
- គ្រូអានអត្ថបទចម្រៀងជាពាក្យរាយឱ្យកុមារស្តាប់ម្តងមួយឃ្លាៗ រួចឱ្យកុមារអានតាមម្តងមួយក្រុម រួចទាំងអស់គ្នា
- គ្រូធ្វើសំឡេង ណាយ ណាយ ណាយៗៗ ទៅតាមចង្វាក់នៃបទចម្រៀងឱ្យកុមារស្តាប់ មួយចប់នៃបទចម្រៀង។

- គ្រូនាំកុមារធ្វើសំឡេង ណាយ ណាយ ណាយៗៗ ទៅតាមចង្វាក់នៃបទចម្រៀងដែលគ្រូបានធ្វើជាគំរូឱ្យស្តាប់(ម្តងមួយក្រុមៗរួចទាំងអស់គ្នា) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀង ម្តងមួយឃ្លាៗ រហូតដល់ចប់បទចម្រៀង(ម្តងមួយក្រុមរួចទាំងអស់គ្នាឱ្យបាន១ ឬ២ចប់)
- គ្រូច្រៀងតិចៗ ម្តងមួយឃ្លាៗ កុមារច្រៀងឮៗ ម្តងមួយឃ្លាៗតាមគ្រូ រហូតចប់បទចម្រៀង(ម្តងមួយក្រុម ឬទាំងអស់គ្នា) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសារឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

## ខ្លឹមសារ និងរបៀបធ្វើកាយវិការ

**+អត្ថបទចម្រៀង៖ ដើរ ឬដេក (ពេលទី១)**

ដើរ ឬដេកដងខ្លួនឱ្យត្រង់ ត្រូវតម្រង់ទាន់ខ្លួននៅក្មេង
ទោះអង្គុយឬមួយឈរលេង យើងក្មេងៗឈរឱ្យត្រង់ខ្លួន
មុខញញឹមសង្ឃឹមជានិច្ច កុំបែរគេចលបមើលក្រោយខ្នង
ងើបមុខឡើងនិយាយឆ្លើយឆ្លង ទើបអ្នកផងគេហៅក្លាហាន។

**+របៀបធ្វើកាយវិការ៖**

- "ដើរឬដេកដងខ្លួនឱ្យត្រង់"ធ្វើកាយវិការដើរនៅមួយកន្លែងដូចពូកងទ័ព ហើយយកម្រាមផ្ទុំផ្តេកក្រោមថ្គាមខាងស្តាំ រួចយកដៃទម្លាក់ចុះមកវិញឱ្យស្របនឹងដងខ្លួនដោយផ្តុំជើងឈរនៅស្ងៀមឱ្យត្រង់ដូចតម្រង់ជួរ
- "ត្រូវតម្រង់ទាន់ខ្លួននៅក្មេង" ធ្វើកាយវិការដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលើកយកម្រាមចង្អុលមករលាស់ចង្អុលចុះទៅឆ្វេងទៅស្តាំ
- "ទោះអង្គុយឬមួយឈរលេងយើងក្មេងៗឈរឱ្យត្រង់ខ្លួន" ធ្វើកាយវិការ ជុចជង្គង់បន្តិចដូចជាកាអង្គុយរួចងើបមកវិញដោយឈរឱ្យត្រង់ខ្លួន។
- "មុខញញឹមសង្ឃឹមជានិច្ច" ធ្វើកាយវិការ ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលើកម្រាមចង្អុល មកចង្អុលមាត់ហើយញញឹមបណ្តើរ
- "កុំបែរគេចលបមើលក្រោយខ្នង" ធ្វើកាយវិការ ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលើករាចុះចំឡើង ក្បាលធ្វើងាកទៅក្រោយម្តងទៅងាកទៅឆ្វេង ម្តងងាកទៅស្តាំ
- "ងើបមុខឡើងនិយាយសាសង ទើបអ្នកផងគេហៅក្លាហាន" ធ្វើកាយវិការ ទម្លាក់ដៃទាំងសងខាងឱ្យស្របនឹងដងខ្លួន មុខបែរឱ្យត្រង់ហើយងើយឡើងបន្តិច រួចទាញមេដៃឆ្វេងចង្អុលមកលើទ្រូងរួចបោះទៅមុខត្រង់ឱ្យលះ។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ វិទ្យាសាស្ត្រ

## សង្កេតៈ អាហារបីក្រុម

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីអាហារទាំងបីក្រុម( ថាមពល សាងសង់ ការពារ ) បានត្រឹមត្រូវ
- កុមារសង្កេតនិងរៀបរាប់បានពីអាហារទាំងបីក្រុម( ថាមពល សាងសង់ ការពារ ) បានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់មានបម្រុងប្រយ័ត្នក្នុងការសង្កេត ដោយភាពសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** ផ្ទាំងរូបភាព(អាហារបីក្រុម)៩ផ្ទាំង

**៣. ការរៀបចំកុមារៈ** កុមារក្នុងថ្នាក់ទាំងអស់អង្គុយជាអក្សរ "ប" កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារៈកូនដឹងទេ តើថ្ងៃនេះគ្រូបានអ្វីផ្ញើកូនៗទាំងអស់គ្នា?
- គ្រូអោយកុមារមើលមកលើតុទាំងអស់គ្នាគ្រូបង្ហាញឡាំងមួយដែលដាក់ផ្ទាំងរូបភាពអាហារបីក្រុមមកដាក់លើតុពីមុខកុមារ
- គ្រូអោយកុមារទាយតើនៅក្នុងឡាំងនោះមានអ្វីខ្លះ?ថាតើមានរូបភាពអ្វីខ្លះ?
- គ្រូអោយកុមារ១នាក់ឡើងមកយកបណ្ណរូបភាពចេញពីក្នុងឡាំង រួចផ្ទៀងផ្ទាត់ទៅនឹងលទ្ធផលដែលកុមារបានទាយ បើមានកុមារណាទាយត្រូវគ្រូត្រូវលើកសរសើរកុមារដោយពាក្យសំដី( កូនដែលឆ្លើយត្រូវកូនពិតជាឆ្លាតហើយពូកែទៀត បន្តែកូនដែលឆ្លើយមិនទាន់ត្រូវក៏ឆ្លាតដែរដែលក្លាហានហ៊ានឆ្លើយនឹងសំនួររបស់គ្រូ)
- គ្រូបញ្ជាក់ប្រាប់កុមារៈរូបភាពទាំងនេះហៅថា អាហារបីក្រុម រួចនាំកុមារអាន
- គ្រូសួរកុមារៈកូនដឹងទេថាតើគ្រូយកបណ្ណរូបភាពទាំងនេះមកអោយកូនទាំងអស់គ្នាធ្វើអ្វី?
- គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ
- គ្រូអោយកូនៗអនុវត្តតាមក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពនេះចំនួន៣ផ្ទាំងពេលក្រុមកូននីមួយៗបានផ្ទាំងរូបភាពនេះហើយ កូនត្រូវដាក់ចំកណ្តាលរង្វង់ ហើយនាំគ្នាសង្កេតមើលរូបទាំងអស់នោះហើយពិភាក្សាគ្នាលើរូបនីមួយៗមានឈ្មោះអ្វី?សម្គាល់អ្វីខ្លះ ពេលកូននាំគ្នាសង្កេតកូនកុំដណ្តើមគ្នា កុំដកផ្ទាំងរូបភាពនេះចុះឡើង បើកូនអង្គុយបញ្ច្រាសរូបកូនត្រូវបង្វិលផ្ទាំងរូបភាពអោយត្រឹមត្រូវដើម្បីអោយកូនបានមើលច្បាស់ទាំងអស់គ្នា។ហើយបើកូនណាស្គាល់ជួយប្រាប់ទៅមិត្តភក្តិដែលមិនស្គាល់ផង ហើយកូនត្រូវរកមិត្តភក្តិណាម្នាក់ឡើងនិយាយប្រាប់ពីអ្វីដែលពួកកូនបានស្គាល់
- ពេលកូនៗពិភាក្សាគ្នាចប់គ្រប់ក្រុមហើយត្រូវនាំគ្នាទៅអង្គុយនៅតាមក្រុមធំវិញដោយយកសម្ភារៈទៅរៀងៗខ្លួនវិញ
- អោយកុមារម្នាក់ឡើងនិយាយពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានទេអោយមិត្តភក្តិជួយបំពេញបន្ថែម បន្តែបើនិយាយមិនបានពេញលេញទេនោះគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្តងទៀត
- រៀបចំកុមារជាក្រុមអោយអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូអោយតំណាងក្រុមនីមួយៗមកយកសម្ភារៈទៅនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមទាំងអស់ដើម្បីជួយក្រុមណាដែលមិនទាន់យល់ច្បាស់

- ពេលក្រុមនីមួយៗត្រូវបានបញ្ចប់ការងារគ្រូវអោយពួកគេទៅអង្គុយនៅក្រុមធំវិញដោយយកផ្ទាំងរូបភាពទៅវិញដើម្បីឡើងរាយការណ៍
- គ្រូអោយតំណាងក្រុមនីមួយៗទៅនិយាយប្រាប់មិត្តភក្តិនឹងគ្រូពីលទ្ធផលដែលពួកគេបានពិភាក្សាគ្នា (ម្តង១ក្រុមៗ)ដោយលើកផ្ទាំងរូបភាពចង្អុលបង្ហាញឈ្មោះរូបម្តង១ៗ
- គ្រូត្រូវកែតម្រូវពាក្យដែលពួកគេនិយាយមិនទាន់បានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ រួចនាំកុមារអាននៅពាក្យទាំងនោះទាំងអស់គ្នា
- គ្រូសរុបពីលទ្ធផលរបស់កុមារគ្រប់ក្រុមបន្ទាប់ពីបានស្តាប់ពួកគេនិយាយចប់។
- គ្រូត្រូវផ្តល់ចំណេះដឹងថ្មីបន្ថែមតាមរយៈ៖
  - គ្រូបង្ហាញផ្ទាំងរូបភាពអោយសង្កេតជារួម អោយកុមារបានមើលឃើញទាំងអស់គ្នាបន្ទាប់មកគ្រូចង្អុលនិងប្រាប់ឈ្មោះរូបម្តង១ៗនូវរូបណាដែលកុមារមិនស្គាល់រួចអោយកុមារថាតាមជាក្រុម និងទាំងអស់គ្នា
  - គ្រូបំផុសសំណួរ៖ តើរូបភាពទាំងនេះគេប្រើសម្រាប់សម្គាល់អ្វីខ្លះ ?បើកុមារមិនអាចឆ្លើយបានគ្រូត្រូវប្រាប់(អាហារបីក្រុមមាន ថាមពល សាងសង់ ការពារ)។ រួចនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា
  - គ្រូប្រាប់ពីអត្ថប្រយោជន៍នៃការញ៉ាំអាហារទាំងបីក្រុម(អាហារទាំងបីក្រុមនេះពេលកូនញ៉ាំទៅធ្វើអោយកូនមានសុខភាពល្អ)
- គ្រូយកផ្ទាំងរូបភាពនោះបិទលើក្តាខៀនរួចនាំកុមារអានឈ្មោះនៃរូបនីមួយៗដោយគ្រូចង្អុលផង ប្រាប់ឈ្មោះផង(អាហារថាមពល អាហារសាងសង់ អាហារការពារ)
- គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់អ្វីខ្លះ ?ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជា វិទ្យាសាស្ត្រអំពី សង្កេតអាហារបីក្រុម(ថាមពល សាងសង់ ការពារ)
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន(ជាក្រុមនិងទាំងអស់គ្នា២ឫ៣ដង)។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### *ល្បែងសេរី

### ១. វត្ថុបំណង៖

- កុមារប្រាប់បានពីរបៀបលេងល្បែងទៅតាមចំណង់ចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារជ្រើសរើសល្បែងលេងទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារ សប្បាយរីករាយ សហការគ្នាក្នុងការលេងមានចិត្តអំណត់។

**២. ការរៀបចំសម្ភារ៖** សម្ភារមាននៅតាមជ្រុងថ្នាក់រៀននិងក្រៅថ្នាក់

### ៣. ការរៀបចំកុមារ៖

- កុមារអង្គុយជាអក្សរអ៊ុយ "U" និងក្រុមតូច
- កុមារអង្គុយទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេម្នាក់ៗក្នុងថ្នាក់និងក្រៅថ្នាក់

### ៤. ដំណើរការបង្រៀន៖(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារៈ កូនទាំងអស់គ្នាចង់លេងល្បែងឬទេ? បើកូនចង់លេង តើកូននាំគ្នាលេងល្បែងអ្វីខ្លះ? ដូច្នេះគ្រូនិងឱ្យកូនទាំងអស់គ្នាលេងទៅតាមចំណង់ចំណូលចិត្តរបស់កូន។
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាសិក្សាសង្គម អំពីល្បែងសេរី
- គ្រូឱ្យកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមនិងទាំងអងស់គ្នា
- គ្រូបង្ហាញសម្ភារល្បែងដែលមាននៅតាមជ្រុងឱ្យកុមារដឹងពីទីកន្លែងដែលកុមារត្រូវនាំគ្នាយកមកលេង
- គ្រូណែនាំកុមារមុនពេលលេង
    - គ្រូឱ្យកុមារទាំងអស់គ្នាយកសម្ភារដែលមាននៅក្នុងថ្នាក់រៀនលេងទៅតាមចំណង់ចំណូលចិត្តរបស់កូនម្នាក់ៗ ឬកូនអាចទៅលេងល្បែងនៅក្រៅថ្នាក់ក៏បាន
    - ពេលកូនយកសម្ភារទាំងនោះមកលេង កូនត្រូវចេះថែរក្សាសម្ភារទាំងនោះ ហើយពេលឈប់លេងកូនត្រូវមើលសម្ភារនោះឱ្យបានគ្រប់ចំនួនមិនឱ្យបាត់បង់ ទើបយកទៅទុកឱ្យមានសណ្តាប់ធ្នាប់នៅកន្លែងដើមវិញ
    - ពេលលេងកូនអាចលេងម្នាក់ឯងក៏បាន កូនអាចលេងជាមួយមិត្តភក្តិក៏បាន អាស្រ័យទៅតាមចិត្តរបស់កូន។ បើកូនលេងជាមួយមិត្តភក្តិ កូនត្រូវចេះចែកគ្នាលេងកុំដណ្តើមគ្នា កុំស្រែកឡូឡា ទើបជាកូនល្អ
    - ចំពោះទីកន្លែងដែលពួកកូនត្រូវលេងនោះអាចលេងនៅក្នុងថ្នាក់ក៏បាន លេងនៅក្រៅថ្នាក់ក៏បាន ស្រេចតែ ចិត្តពួកកូន។ បើកូនណាចង់លេងស្គរ ឬគោះកំប៉ុង កូនត្រូវលេងឱ្យឆ្ងាយពីមិត្តភក្តិ កុំឱ្យរំខានមិត្តភក្តិ
    - បើមានកូនណាមិនសូវចេះលេង ឬមិនចូលលេងនឹងគេនោះ កូនៗត្រូវជួយប្រាប់មិត្តភក្តិនិងនាំមិត្តភក្តិលេងផង
    - ពេលកូនឈប់ចង់លេង កូនត្រូវនាំគ្នាយកសម្ភារទៅទុកកន្លែងដើមវិញ រួចនាំគ្នាមកអង្គុយនៅក្រុមដំរិញ
    - គ្រូឱ្យកុមារស្ម័គ្រចិត្តមួយនាក់ និយាយពីអ្វីដែលគ្រូបានប្រាប់។ គ្រូត្រូវបំពេញបន្ថែមនូវអ្វីដែលកុមារនិយាយមិនបានពេញលេញ
- គ្រូឱ្យកុមារលើកកៅអីទុកទៅខាង ម្តងមួយក្រុមៗរួចនាំគ្នាទៅយកសម្ភារមកលេង
- គ្រូឱ្យកុមារលេងតាមចំណង់ចំណូលចិត្តរបស់ពួកគេ
- គ្រូដើរសម្របសម្រួល កុមារលេងដើម្បីកែតម្រូវកុមារលេងខុង និងជួយកុមារណាដែលមិនទាន់ចេះលេង
- ពេលកុមារលេងចប់គ្រូឱ្យកុមារយកសម្ភារទៅទុកដាក់ឱ្យមានសណ្តាប់ធ្នាប់នៅតាមកន្លែងដើមវិញ រួចឱ្យពួកគេ យកកៅអីមករៀបអង្គុយវិញ
- ពេលកុមារអង្គុយជុំគ្នាហើយ គ្រូឱ្យកុមារនិយាយប្រាប់ពីអ្វីដែលគេបានលេង និងគេស្គាល់អ្វីខ្លះ? ឱ្យកុមារនិយាយ ទៅតាមការយល់ដឹងរបស់គេ។ ចំពោះចំនួនកុមារដែលត្រូវនិយាយអាស្រ័យទៅតាមពេលវេលា។

✱ **រំលឹកមេរៀនប្រចាំថ្ងៃៈ** គ្រូសួរកុមារពីមេរៀនដែលបានរៀនក្នុងមួយព្រឹក ក្នុងករណីកុមារមិនអាចប្រាប់បានគ្រប់ គ្រូត្រូវប្រាប់បន្ថែម រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា។

✱ **អនាម័យរៀបចំខ្លួនទៅផ្ទះៈ** គ្រូឱ្យកុមារលាងដៃ លុបមុខ សិតសក់ឱ្យស្អាតរួចរៀបចំកៅអីទុក និងតម្រង់ជួរទៅតាមក្រុម គ្រូណែនាំសណ្តាប់ធ្នាប់ពេលដើរតាមផ្លូវ ការគួរសមជាមួយមនុស្សពេលទៅដល់ផ្ទះ ការទុកដាក់សម្ភារ សកម្មភាពមុន និងក្រោយពេលញ៉ាំបាយ ...

## ថ្ងៃទី២

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ហាត់ប្រាណតាមរឿងនិទាន៖ យើងនាំគ្នាទៅលេងបុណ្យចូលឆ្នាំខ្មែរ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបដើរជាក្រុម លោតទៅឆ្វេងស្តាំ លោតទៅមុខទៅក្រោយ លោតបង្វិលខ្លួន និងរត់លឿនទៅមុខតាមខ្លឹមសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារដើរជាក្រុម លោតទៅឆ្វេងស្តាំ លោតទៅមុខទៅក្រោយ លោតបង្វិលខ្លួន និងរត់លឿនទៅមុខតាមខ្លឹមសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឈរជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- កូនៗធ្លាប់ដែលឃើញគេដើរបង្ហាញម៉ូតទេ ?ឃើញនៅឯណា ? បើអញ្ចឹងកូនៗនាំគ្នាដើរបង្ហាញម៉ូតជាមួយអ្នកគ្រូទាំងអស់គ្នា (នាំកុមារដើរដល់ទីកំណត់រួចត្រឡប់មកកន្លែងដើមវិញ)
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើង៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន "យើងនាំគ្នាទៅលេងបុណ្យចូលឆ្នាំ" រួចឱ្យកុមារថាតាមជាក្រុម ឬជាបុគ្គល២ទៅ៣ដង
- គ្រូនាំកុមារពិភាក្សាអំពីការធ្វើចលនាទៅតាមខ្លឹមសាររឿងនិទាន ដោយប្រាប់កុមារពេលគ្រូនិទានដល់ពាក្យដើរកាន់ដៃគ្នាប្រាំនាក់ ពីរនាក់ កូនដើរកាន់ដៃគ្នាតាមចំនួនគ្រូនិទាន ពេលនិទានដល់ពាក្យលោតទៅឆ្វេង ទៅស្តាំ ទៅមុខទៅក្រោយ និងលោតបង្វិល កូនធ្វើចលនាតាមពាក្យនោះ។
- គ្រូចាប់ផ្តើមនិទានរឿងបណ្តើរនាំកុមារធ្វើសកម្មភាពបណ្តើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយមិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ (ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្តងទៀត)
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗហាត់ទេ ?បើហាត់តើកូនចង់ធ្វើត្រាប់តាមសម្លេងសត្វអ្វី ?តើសត្វឆ្មាយំដូចម្តេច ?កូនៗទាំងអស់គ្នាយកម្រាមដៃសងខាងមកដាក់ជិតមាត់ធ្វើជាពុកមាត់ឆ្មារួចស្រែក ថា ម៉េវ ម៉េវ ម៉េវ!!

## អត្ថបទរឿងនិទាន "យើងនាំគ្នាទៅលេងបុណ្យចូលឆ្នាំ"

ថ្ងៃនេះមានកុមារតូចៗមួយក្រុមបាននាំគ្នាដើរទៅលេងល្បែងប្រជាប្រិយនៅឯវត្ត ព្រោះជាថ្ងៃបុណ្យចូលឆ្នាំ។ ពេលដើរតាមផ្លូវពួកគេកាន់ដៃគ្នាដើរជាក្រុមប្រាំៗនាក់។ ពួកគេសប្បាយចិត្តណាស់ គេនាំគ្នាលោតទៅឆ្វេង លោតទៅស្តាំ ម្តងទៅមុខ ម្តងទៅក្រោយ បន្ទាប់មកគេលោតបង្វិលខ្លួនម្នាក់ម្តងៗ រួចក៏នាំគ្នារត់យ៉ាងលឿនទៅមុខក៏បានដល់ផ្លូវធំមួយ គេក៏ឈប់ងាកឆ្វេង ងាកស្តាំ ហើយក៏ដើរយ៉ាងស្វាហាប់ដើម្បីឆ្លងថ្នល់នោះ។ ពួកគេកាន់ដៃគ្នាពីរៗនាក់ រត់តិចៗ បន្តទៅមុខទៀតក៏បានជួបស្ពានតូចមួយ ពួកគេក៏បាននាំគ្នាឆ្លងស្ពាននោះម្នាក់ម្តងៗ បន្តបន្ទាប់ជាជួររួចក៏នាំគ្នារត់ចូលវត្ត ហើយក៏ចូលលេងល្បែងទៅតាមចំណូលចិត្តរៀងៗខ្លួន។ លុះដល់ពេលព្រលប់បន្តិចទើបពួកគេត្រឡប់មកផ្ទះវិញ ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ត្រូវចេះគោរពចាស់ទុំ( ពេលដើរជិតចាស់ៗត្រូវឱននិងដោះមួក) (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី២ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ

### ល្បែងៈ ធ្វើចំណាត់ថ្នាក់ក្រុមអាហារ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបធ្វើចំណាត់ថ្នាក់ក្រុមអាហារ បានត្រឹមត្រូវ
- កុមារធ្វើចំណាត់ក្រុមអាហារ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀនៈ** បន្ទះបណ្ណអាហារបន្លែ ត្រី សាច់ (មួយមុខមានចំនួន៤បណ្ណ)ចំនួន៤ឈុត

**៣. ការរៀបចំកុមារៈ** អង្គុយជារាងពាក់កណ្តាលរង្វង់ "ប" អង្គុយតាមក្រុមតូចៗ (៣ក្រុម)

**៤. ដំណើរការបង្រៀន(អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូបង្ហាញបន្ទះបណ្ណអាហារបន្លែ ត្រី សាច់ ដោយដាក់នៅលើតុពីមុខកុមារ រួចឱ្យកុមារម្នាក់ជាអ្នកលើកបង្ហាញ ហើយកុមារដទៃទៀតជាអ្នកប្រាប់ឈ្មោះ (ឱ្យកុមារប្រាប់ឈ្មោះអាហារទាំងនោះ)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវមានបណ្ណអាហារបន្លែ ត្រី សាច់ ដែលកូនបានបង្ហាញមួយកញ្ចប់មុននេះ
  - ពេលក្រុមកូននីមួយៗបានសម្ភារទាំងនេះហើយ កូនត្រូវយកសម្ភារចេញពីថង់ដាក់នៅកណ្តាលវង់ ។ បន្ទាប់មកពួកកូនក្នុងក្រុមនីមួយៗ នាំគ្នាសង្កេតមើលក្រុមអាហារទាំងនោះ ដើម្បីចំណាំ ប៉ុន្តែកូននាំគ្នាមើលឱ្យស្ងៀមស្ងាត់ មិនដណ្តើមគ្នាមើលទេ
  - នៅពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនៗគ្រប់ក្រុមត្រូវនាំគ្នារើសប្រភេទអាហារដាក់ម៉ុំៗ ក្រុមបន្លែដាក់១ដុំ ក្រុមសាច់ដាក់១ដុំ ក្រុមត្រីដាក់១ដុំ ។ បើក្រុមណារៀបបានរួចរាល់មុនគេ កូនត្រូវទះដៃជាសញ្ញាបន្ទាប់មកអ្នកដែលបានរៀបរួចបន្តបន្ទាប់ ក៏ទះដៃបន្តបន្ទាប់ដែរ ។ ពេលកូនរៀបអាហារដាក់ម៉ុំៗ កូនត្រូវធ្វើម្នាក់ម្តងៗរង់ចាំវេន មិនដណ្តើមគ្នារញ៉េរញ៉ៃទេ ទើបជាកូនល្អ
  - ពេលក្រុមកូនរៀបចំគ្រប់ក្រុមហើយនោះ កូនទុកមិត្តភក្តិយើងម្នាក់នៅកន្លែងរៀបសម្ភារ ឯកូនដទៃទៀត ទៅអង្គុយនៅក្រុមជុំវិញ ហើយនាំគ្នាផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗជាមួយគ្រូ ។
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់

ម្តងទៀត)

- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត និងឱ្យក្រុមនីមួយៗចាប់ផ្តើមអនុវត្តតាមសញ្ញាបញ្ជារបស់គ្រូ
- គ្រូឱ្យក្រុមកុមារនីមួយៗដែលធ្វើរួចហើយទៅអង្គុយនៅក្រុមធំវិញ ក្នុងមួយក្រុមទុកតែកុមារម្នាក់ដើម្បីបង្ហាញលទ្ធផល
- គ្រូនាំកុមារផ្ទៀងផ្ទាត់ម្តងមួយក្រុមៗ ដោយឱ្យម្ចាស់ក្រុមនីមួយៗជាអ្នកបង្ហាញពីអ្វីដែលពួកគេបានធ្វើ ។ បន្ទាប់ មកឱ្យកុមារដែលនៅអង្គុយក្នុងក្រុមធំជាអ្នកវាយតម្លៃ បើមានខុសជួយកែតម្រូវ ។ គ្រូត្រូវនាំផ្ទៀងផ្ទាត់គ្រប់ក្រុមទាំង អស់ ។ ពេលផ្ទៀងផ្ទាត់ចប់ គ្រូត្រូវឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ ។
- **គ្រូសួរកុមារ៖** អំបាញ់មិញកូនស្គាល់អ្វីខ្លះ? ដូចនេះកូនជួយប្រាប់គ្រូបានទេ តើយើងរៀនមុខវិជ្ជាអ្វី? អំពីអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង មេរៀន "ចំណាត់ថ្នាក់ក្រុមអាហារ" រួចសួរកុមារ អំបាញ់មិញមានកូនណាទាយត្រូវឬទេ ដូចនេះកូនៗដែលទាយត្រូវគឺជាកូនពូកែ កូនឆ្លាត។ រីឯកូនដែលទាយមិន ត្រូវក៏ល្អដែរ ដែលក្លាហានក្នុងការនិយាយជាមួយគ្រូ។
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

### ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### គំនូរ៖ ព្រះអាទិត្យ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបគូររូបព្រះអាទិត្យបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃគូររូបព្រះអាទិត្យ ដោយទប់លំនឹងបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

+ **សម្ភារសម្រាប់គ្រូ៖**

- ផ្ទាំងក្រដាសដែលមានគូររូបព្រះអាទិត្យ ចំនួន១សន្លឹក
- ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)
- ខ្មៅដៃចំនួន១ដើម ស្កុតចំនួន១ដុំ។

+ **សម្ភារសម្រាប់កុមារ៖**

- ក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃគ្រប់ចំនួនកុមារ

**៣. ការរៀបចំកុមារ៖** អង្គុយរាងអក្សរ "U" ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារថា៖ តើពេលព្រឹកកូនក្រោកពីគេងកូនសំឡឹងទៅទិសខាងកើតមើលទៅលើមេឃឃើញអ្វីខ្លះ?(ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសដែលមានគូររូបព្រះអាទិត្យរួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្ដាខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹកទៀត ដែលគ្រូមិនទាន់គូររូបព្រះអាទិត្យឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសសនេះគ្រូទុកសម្រាប់គូរ ឱ្យកូនមើលពីរបៀបគូរ។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្ដើមគូរពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាសនោះទៅបិទនៅលើក្ដាខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបគូរ
- គ្រូណែនាំពីរបៀបគូរនៅលើផ្ទាំងក្រដាសសដែលបានបិទលើក្ដាខៀន ដោយគូរបណ្ដើរ និយាយប្រាប់កុមារបណ្ដើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការគូរ។
- គ្រូប្រាប់កុមារ៖
  - កូនយកខ្មៅដៃគូររូបព្រះអាទិត្យដោយចាប់គូរចំណុចដៅកណ្ដាលខាងលើ ដោយទាញពីលើខាងឆ្វេង រួចទាញមកស្ដាំឡើងទៅលើភ្ជាប់ចំណុចដៅកណ្ដាល (តាមរូបគំនូរគំរូរបស់គ្រូជាក់ស្ដែង)
  - បន្ទាប់មកកូនយកខ្មៅដៃកូនគូររូបព្រះអាទិត្យឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ៖ កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូរ (តាមស្ថានភាពជាក់ស្ដែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃគូរ និងមិនទាន់យល់ពីរបៀបគូរ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារ៖ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូរហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្ដងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្ដិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់៖ តើមិត្តភក្ដិយើងគូរបានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្ដិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្ដីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្ដិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## សម្គាល់៖ ចំនួន និងលេខពី ១ ដល់ ១៣

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំនួននិងលេខពី ១ ដល់១៣ បានត្រឹមត្រូវ
- កុមាររាប់ចំនួននិងលេខពី ១ ដល់១៣ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារឈ្លាសវៃ រហ័សរហួន ក្នុងការគិតបានហ្មត់ចត់ សហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

- បណ្ណចំនួនរូបភាពពី១ ដល់១៣ ចំនួន ១៣ បន្ទះ
- បណ្ណចំនួនចំណុចពី១ ដល់១៣ ចំនួន១៣ បន្ទះ
- បណ្ណលេខ១ ដល់លេខ១៣ ចំនួន ១៣ បន្ទះ
- ស្កុតក្រដាស់ ១ដុំ

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "U" និងក្រុមតូច

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា បុរេគណិត មេរៀន សម្គាល់ចំនួន និងលេខពី១ ដល់ ១៣
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុមនិងទាំងអស់គ្នា
- ថ្ងៃនេះគ្រូមានសម្ភារជាច្រើន កូនចង់លេងទេ?
- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១ ដល់១៣ ឱ្យកុមារប្រាប់ចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយកទៅបិទនៅលើក្ដាខៀន រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១ ដល់១៣ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយកទៅបិទនៅលើក្ដាខៀនពីក្រោមចំនួនរូបភាព រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណលេខពី១ ដល់១៣ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកទៅបិទនៅលើក្ដាខៀនពីក្រោមចំនួនចំណុចពី ១ដល់១៣ រួចនាំកុមាររាប់
- គ្រូនាំកុមាររាប់ចំនួនរូបភាព ចំនួនចំណុចនិងលេខពី១ ដល់១៣ សារឡើងវិញម្ដងមួយៗ គ្រូណែនាំកុមារជាមុនសិន រួចឱ្យក្រុមនីមួយៗទៅជ្រុងសិក្សា ដើម្បីរើសវត្ថុដែលមាននៅក្នុងជ្រុងនោះ (តាមវត្ថុជាក់ស្ដែងដែលមានដូចជាបំពង់បឺត ចង្កឹះ ដុំឈើ...)
- គ្រូឱ្យកុមាររើសវត្ថុតាមក្រុមនីមួយៗ៖
  - ក្រុមទី១ រើសចំនួន១១
  - ក្រុមទី២ រើសវត្ថុចំនួន១២
  - ក្រុមទី៣ រើសវត្ថុចំនួន១៣
- គ្រូឱ្យកុមារបង្ហាញតាមក្រុមនីមួយៗ និងសម្របសម្រួលផ្ទៀងផ្ទាត់។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ៖** (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី៣

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

**ចលនាមូលដ្ឋាន៖ បោះ (បោះបាល់ចូលកន្ត្រក បោះកងចូលដប និងបោះបាល់ឱ្យគ្នាទៅ វិញទៅមក)**

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបបោះបាល់ចូលកន្ត្រក បោះកងចូលដប និងបោះបាល់ឱ្យគ្នាទៅវិញទៅមក តាមលំដាប់ លំដោយបានត្រឹមត្រូវ
- កុមារ បោះបាល់ចូលកន្ត្រក បោះកងចូលដប និងបោះបាល់ឱ្យគ្នាទៅវិញទៅមក តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន អំណត់ ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បាល់ចំនួន ៥ កន្ត្រកចំនួន៥ កងចំនួន៥ ដបចំនួន៥

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុមក្នុង១ក្រុមចំនួន៥នាក់ ឱ្យកុមារឈរតាមខ្សែបន្ទាត់ដែលបានកំណត់ (ករណីកុមារច្រើនអាចចែកជា៥ក្រុមរឺច្រើនជាងនេះ លុះត្រាអស់កុមារ)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពបោះបាល់ ដោយឱ្យកុមារធ្វើចលនាលើកដៃបោះទៅលើ
- គ្រូរៀបចំបាល់ដោយការកែច្នៃក្រដាស រឺបាល់ជ័រចំនួន៥ កន្ត្រកចំនួន៥ កងចំនួន៥ ដបចំនួន៥ និងគូសខ្សែបន្ទាត់២ ស្របគ្នាចំងាយគ្នា ២,៥០ម៉ែត្រទៅ៣ម៉ែត្រ សម្រាប់កុមារឈរ ដាក់កន្ត្រក និងដប
- គ្រូណែនាំកុមារធ្វើសកម្មភាពទាំង៣បន្តបន្ទាប់គ្នា ពីចលនាបោះបាល់ចូលកន្ត្រក បោះកងចូលដប និងបោះបាល់ឱ្យគ្នាទៅវិញទៅមក
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗ៖
  - ក្រុមទី១៖ បោះបាល់ចូលកន្ត្រកឱ្យដល់ទិសដៅដែលបានកំណត់
  - ក្រុមទី២៖ បោះបាល់បោះកងចូលដបឱ្យដល់ទិសដៅដែលបានកំណត់
  - ក្រុមទី៣៖ បោះបាល់ឱ្យគ្នាទៅវិញទៅមកឱ្យដល់ទិសដៅដែលបានកំណត់
- បន្ទាប់ពីកុមារបានបោះបាល់ និងកង តាមរបៀបខាងលើរួច គ្រូឱ្យក្រុមនីមួយៗប្តូរសកម្មភាពដើរតាមសញ្ញា របស់គ្រូ
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានចូលរួមបោះបាល់ និងកងបាន គ្រប់សកម្មភាពទាំង៣បន្តបន្ទាប់គ្នារួចសួរកុមារថា៖
  - តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ ចលនាមូលដ្ឋាន បោះ (បោះបាល់ចូលកន្ត្រក បោះកងចូលដប និងបោះបាល់ឱ្យគ្នាទៅវិញទៅមក)
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណា

ឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បាន ត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត)

- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុមនិងទាំងអស់គ្នា ហើយសួរថាដើម្បីឱ្យមានកម្លាំង កូនធ្វើដូចម្ដេច? (កុមារឆ្លើយហិតផ្កា) ហើយផ្កាអីក្រអូបជាងគេ? គេដាំនៅឯណា? ដើមវាទាប ឬខ្ពស់ ? អញ្ចឹងយើងនាំ គ្នាហិតផ្កាម្លិះ និងផ្កាំទៀនទាំងអស់គ្នា គ្រូនាំកូនទៅបេះផ្កាហិតដោយដកដង្ហើមវែងៗ (កូនៗយកដៃធ្វើសកម្មភាព បេះផ្កា យកមកដាក់ជិតច្រមុះរួចហិត ហើយដកដង្ហើមចូល ចេញឱ្យវែងៗ?)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

✱ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)

✱ ទម្លាប់ល្អ៖ ត្រូវចេះគោរពចាស់ទុំ (ពេលដើរជិតចាស់ៗត្រូវឱននិងដោះមួក) (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)

✱ គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៣ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

### ល្បែង៖ ផ្គូរផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុច ទៅនឹងលេខពី១ ដល់១៣

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីចំនួនរូបភាព ចំនួនចំណុច និងលេខពី១ ដល់១៣ បានត្រឹមត្រូវ
- កុមារផ្គូផ្គងចំនួនរូបភាព ទៅនឹងចំនួនចំណុច និងទៅនឹងលេខពី១ ដល់១៣ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖**

- បណ្ណចំនួនរូបភាពពី១ ដល់១៣ មានចំនួន១៥បណ្ណ
- បណ្ណចំនួនចំណុចពី១ ដល់១៣ មានចំនួន១៥បណ្ណ
- បណ្ណចំនួនលេខពី១ ដល់១៣ មានចំនួន១៥បណ្ណ

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរ U, អង្គុយតាមក្រុមតូចៗ (៣ក្រុម)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀន រួចនាំកុមារអានតាមជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១ ដល់១៣ ឱ្យកុមារប្រាប់ពីចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយកបិទលើក្ដារ ខៀន និងនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១ ដល់១៣ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយក បិទលើក្ដារខៀន ពីក្រោមរូបភាព និងនាំកុមាររាប់

- គ្រូបង្ហាញបណ្ណលេខពី១ ដល់១៣ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកមកបិទលើក្តារខៀន ពីក្រោមចំនួនចំណុច និងលេខ រួចនាំកុមារអាន
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវបានសម្ភារទាំងអស់នេះមួយកំប្លេរ
  - ពេលក្រុមកូនបានសម្ភារទាំងនេះហើយ កូនត្រូវសង្កេតមើលចំនួន និងលេខទៅតាមបណ្ណនីមួយៗ រួចហើយកូននាំគ្នារៀបបណ្ណចំនួនរូបភាពពី១ ដល់១៣ តាមលំដាប់។ បន្ទាប់មកកូនត្រូវយកបណ្ណចំនួនចំណុចពី១ ដល់១៣ រៀបពីក្រោមបណ្ណរូបភាពពី១ ដល់១៣ តាមលំដាប់ដែរ និងយកបណ្ណនេះមករៀបពីក្រោម បណ្ណ ចំនួនចំណុចពី១ ដល់១៣ ទៀត
  - ពេលកូននាំគ្នារៀប កូនត្រូវចេះចែកគ្នារៀបម្តងម្នាក់ៗទៅតាមវេន កុំដណ្តើមគ្នា ។ ពេលកូនរៀបហើយ កូនត្រូវនាំគ្នាពិនិត្យឡើងវិញ ក្រែងមានខុស ហើយកូនទៅអង្គុយនៅកន្លែងសិន រង់ចាំក្រុមមិត្តភក្តិយើងរៀបហើយទាំងអស់គ្នា
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តទៅតាមក្រុមនីមួយៗ ហើយគ្រូដើរសម្របសម្រួលកែតម្រូវ
- ពេលកុមារធ្វើហើយគ្រប់ក្រុម គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារតាមក្រុមជាអ្នកផ្ទៀងផ្ទាត់ការងាររបស់ក្រុមនីមួយៗ ។ មុនផ្ទៀងផ្ទាត់ឱ្យម្ចាស់ក្រុមប្រាប់ពីអ្វីដែលពួកគេបានរៀប រួចរាប់ឱ្យមិត្តភក្តិស្តាប់ ។ គ្រូនាំកុមារផ្ទៀងផ្ទាត់រហូតគ្រប់ក្រុមទាំងអស់ ។ បើករណីមានខុស ឱ្យមិត្តភក្តិជួយកែតម្រូវ ។
- ពេលផ្ទៀងផ្ទាត់គ្រប់ក្រុមហើយ ត្រូវឱ្យតំណាងក្រុមនីមួយៗប្រមូលសម្ភារទៅទុកឱ្យគ្រូវិញ ហើយនាំគ្នាទៅអង្គុយជារួមក្រុមធំវិញ ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពកសាង៖ រៀបវត្ថុតូចៗបិទលើរូបផ័ត្រ

### ១. វត្ថុបំណង៖

- កុមារប្រាប់ពីរបៀបរៀបវត្ថុតូចៗបិទលើរូបផ័ត្របានត្រឹមត្រូវ
- កុមាររៀបវត្ថុតូចៗបិទលើរូបផ័ត្របានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្ត ។

### ២. សម្ភារបង្រៀន៖

- គ្រូ៖ ផ្ទាំងរូបភាពផ័ត្រដែលបានរៀបគ្រាប់សណ្តែកបិទពីលើចំនួនមួយផ្ទាំង ,ផ្ទាំងរូបភាពផ្ទាំងដែលមិនមានរៀបគ្រាប់សណ្តែកបាយបិទលើរូបភាពចំនួនមួយផ្ទាំង ,គ្រាប់សណ្តែកបាយចំនួន១កញ្ចប់ ស្កុតមួយដុំ កាវមួយ១ដប កន្សែងចំនួន១ និងប្រាសដុសធ្មេញចំនួនមួយ។
- កុមារ៖ ផ្ទាំងរូបភាពផ័ត្រគ្រប់ចំនួនកុមារដែលមានដាក់ថ្ងៃខែឆ្នាំអនុវត្ត មុខវិជ្ជាចំណងជើងមេរៀននៅលើ

សន្លឹកកិច្ចការ ,គ្រាប់សណ្តែកបាយគ្រប់ចំនួនក្រុមកុមារ( ១ក្រុម១កញ្ចប់ )

- ការគ្រប់ចំនួនក្រុមកុមារ( ១ក្រុម១ដប )។ច្រាសដុសធ្មេញគ្រប់ចំនួនក្រុមកុមារ( ១ក្រុម១ដើម ),កន្សែងគ្រប់ចំនួនក្រុមកុមារ( ១ក្រុមកន្សែងចំនួន ១ )

៣. **ការរៀបចំកុមារ ៖** កុមារអង្គុយជារាងអក្សរ "ប"

**៤.ដំណើរការបង្រៀន ៖**

- គ្រូបង្ហាញរូបផ័ត្រដែលបានរៀបគ្រាប់សណ្តែកបាយបិទពីលើឱ្យកុមារប្រាប់ឈ្មោះ និងយករូបនោះបិទលើក្តារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូណែនាំពីរបៀបរៀបគ្រាប់សណ្តែកបាយបិទលើរូបផ័ត្រយឺតៗដើម្បីឱ្យកុមារងាយចាប់បាន
    - គ្រូឱ្យកូនលេងជាក្រុមតូចៗហើយក្រុមនីមួយៗ ត្រូវបានផ្ទាំងរូបភាពផ័ត្រមួយសន្លឹក គ្រាប់សណ្តែកចំនួនមួយកញ្ចប់ ការចំនួនមួយដប កន្សែងចំនួនមួយ និងច្រាស់ដុសធ្មេញចំនួនមួយ
    - ដំបូងកូននាំគ្នាយកផ្ទាំងរូបភាពផ័ត្រមួយផ្ទាំងដាក់នៅចំកណ្តាល ហើយគ្រាប់សណ្តែក ការ កន្សែង និងច្រាស់ដុសធ្មេញ ក៏ដាក់ចំកណ្តាលរង្វង់ក្បែរគ្នាដែរ
    - បន្ទាប់មកកូនណាម្នាក់ក្នុងក្រុមយកច្រាស់ដុះធ្មេញមកជ្រលក់ក្នុងការហើយយកទៅលាបលើរូបផ័ត្រដោយពាសឱ្យសព្វពេញរូបផ័ត្រប៉ុន្តែមិនឱ្យហៀរចេញក្រៅរូបផ័ត្រទេ បើមានការប្រឡាក់ដៃកូនត្រូវយកកន្សែងមកជូត។បន្ទាប់មកយកគ្រាប់សណ្តែកបាយរៀបលើការក្នុងរូបផ័ត្រឱ្យជិតៗគ្នា ឱ្យពេញរូបផ័ត្រគ្រូប្រាប់កុមារបណ្តើរធ្វើបង្ហាញបណ្តើរ ប៉ុន្តែការរៀបគ្រាប់សណ្តែកបាយក្នុងរូបផ័ត្រមិនចាំបាច់រៀបពេញរូបផ័ត្រនោះទេ រៀបតែបន្តិចជាគំរូបានហើយ
    - ពេលកូននាំគ្នារៀបគ្រាប់សណ្តែកបាយបិទលើរូបផ័ត្រ តាមក្រុមនីមួយៗត្រូវចេះរង់ចាំវេនធ្វើម្នាក់ម្តងៗកុំដណ្តើមគ្នា ហើយដាក់ដបការ ឱ្យបានត្រឹមត្រូវប្រយ័ត្នកំពប់ប្រឡាក់រូបហើយច្រាសដុសធ្មេញពេលលាបរួចហើយត្រូវយកក្រដាសដាក់ពីក្រោម
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលកុមារបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារៈដែលគ្រូត្រៀមទុកអនុវត្ត
- គ្រូឱ្យកុមារក្នុងក្រុមនីមួយៗចាប់ផ្តើមអនុវត្តទាំងអស់គ្នាទៅតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមហើយជួយកែតម្រូវក្រុមណាដែលធ្វើមិនទាន់បាន
- គ្រូប្រាប់កុមារ៖ បើក្រុមកូនណាធ្វើរួចហើយកូនយកទៅបិទលើការខៀនតាមកន្លែងដែលគ្រូកំណត់ឱ្យទៅតាមក្រុមនីមួយៗហើយពួកកូនត្រូវយកសម្ភារ ទៅទុកជូនគ្រូវិញនិងនាំគ្នាទៅអង្គុយនៅតាមក្រុមជំវិញ
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យតំណាងក្រុមទៅឈរនៅជិតរូបដែលបានបិទនៅលើក្តារខៀនបន្ទាប់មកឱ្យកុមារក្រុមធំសង្កេតមើលរូបនោះ ហើយវាយតម្លៃ ( តើត្រឹមត្រូវឬទេ ? រៀបពេញរូបផ័ត្រទេ ? មានរៀប ចេញក្រៅរូបផ័ត្រទេ ? )
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់នៅពេលផ្ទៀងផ្ទាត់មានក្រុមណាធ្វើមិនបានល្អគ្រូមិនត្រូវស្តីបន្ទោសឡើយ ត្រូវចេះលើកទឹកចិត្តកុមារឱ្យខិតខំប្រឹងប្រែងបន្តទៀត
- គ្រូឱ្យតំណាងក្រុមនីមួយៗដករូបចេញពីក្តារខៀនជូនគ្រូរួចគ្រូដាក់ឈ្មោះក្រុមសម្រាប់ទុកដាក់តាំងស្នាដៃកុមារ
- គ្រូសួរកុមារ៖ ថ្ងៃនេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី ?អំពីអ្វី ?
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះយើងនាំគ្នារៀនមកវិជ្ជាសិក្សាសង្គម អំពីសកម្មភាពកសាង "រៀបវត្ថុតូចៗបិទលើរូបផ័ត្រ"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ បើមានកុមារទាយត្រូវលើកសរសើរដោយប្រើពាក្យសម្តី
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមរួចទាំងអស់គ្នា។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## ល្បែង៖ ទះដៃតាមចំនួនព្យាង្គពី ២ ទៅ៤ ព្យាង្គ

**១. វត្ថុបំណង៖**

-កុមារប្រាប់បានពីរបៀបទះដៃតាមចំនួនព្យាង្គដែលមាន ២ ទៅ៤ព្យាង្គបានត្រឹមត្រូវ

-កុមារកំណត់ពីចំនួនព្យាង្គនៃពាក្យដែលមាន ២ទៅ ៤ព្យាង្គ បានត្រឹមត្រូវ

-កុមារមានភាពឈ្លាសវៃ រហ័សរហួន បម្រុងប្រយ័ត្ន និងសប្បាយរីករាយ ។

**២. សម្ភារៈបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងពាក់កណ្តាលរង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារទះដៃតាមចំនួនកំណត់ (ទះដៃមួយដង ទះដៃពីរដង ទះដៃបីដង ទះដៃបួនដង)
- គ្រូប្រាប់កុមារថា នៅថ្ងៃនេះ គ្រូនឹងនាំកូនលេង ទះដៃតាមចំនួនព្យាង្គ នៅក្នុងពាក្យដែលគ្រូហៅឱ្យកូនស្តាប់
- គ្រូចាប់ផ្តើមណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងដល់កុមារ ដោយនិយាយថា៖ ដើម្បីលេងល្បែងនេះ កូនត្រូវស្តាប់ឱ្យបានច្បាស់នៅពាក្យដែលគ្រូអានឱ្យកូនស្តាប់ ហើយកូនត្រូវទះដៃទៅតាមចំនួនព្យាង្គនៃពាក្យនោះ។ ឧទាហរណ៍៖ គ្រូហៅពាក្យថា "កៅអី" ពាក្យនេះមានចំនួន២ព្យាង្គគឺ "កៅ" និង "អី" ដូចនេះ កូនត្រូវទះដៃចំនួន២ដងដែរ ដោយព្យាង្គ "កៅ" ទះដៃ១ដង និង "អី" ទះដៃ១ដងទៀត ហើយប្រសិនបើ គ្រូហៅពាក្យដែលមានព្យាង្គចំនួន ៣ ឬ ៤ កូនៗត្រូវទះដៃតាមចំនួនព្យាង្គនៃពាក្យដែលគ្រូបានហៅប្រាប់ នោះដែរ។
- គ្រូឱ្យកុមារនិយាយឡើងវិញពីរបៀបលេង បើកុមារនិយាយមិនបានល្អគ្រូត្រូវប្រាប់ម្តងទៀត
- គ្រូនាំកុមារលេងសាកល្បងជាមួយនឹងពាក្យ ១ ទៅ ២ពាក្យ ទៅតាមរបៀបដែលបានណែនាំខាងលើ ហើយសួរកុមារឡើងវិញពីរបៀបលេង
- គ្រូនាំកុមារលេងដោយហៅម្តងមួយពាក្យៗឱ្យកុមារស្តាប់ និងទះដៃតាមព្យាង្គនៃពាក្យទាំងនោះដោយការ យកចិត្តទុកដាក់ ក្រោមការជួយសម្របសម្រួល និងពិនិត្យលើការអនុវត្តរបៀបលេងផងដែរ
- គ្រូត្រូវនាំកុមារផ្ទៀងផ្ទាត់ ដោយទះដៃតាមចំនួនព្យាង្គរបស់ឈ្មោះកុមារឡើងវិញ នៅពេលដែលធ្វើ សកម្មភាពតាមពាក្យនីមួយៗរួច។
- គ្រូលើកសរសើរ និងលើកទឹកចិត្តកុមារដែលបានចូលរួមក្នុងសកម្មភាពលេង
- គ្រូសួរបំផុសកុមារថា៖
  - កូនៗទាំងអស់គ្នាសប្បាយទេ?
  - តើមុននេះ កូនលេងល្បែងអ្វីជាមួយគ្រូ?
  - តើចំនួនព្យាង្គដែលកូនទះដៃក្នុងពេលលេង មានចំនួនប៉ុន្មានខ្លះ?
  - ដូចនេះ តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (ឱ្យកុមារឆ្លើយតាមការចងចាំរបស់ពួកគេ)
- គ្រូបញ្ជាក់កុមារបន្ថែមថា ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង "ទះដៃតាមចំនួនព្យាង្គ២ទៅ៥ ព្យាង្គពី២ទៅ៤ព្យាង្គ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**កំណត់សម្គាល់៖** ពាក្យដែលត្រូវប្រើក្នុងល្បែងនេះរួមមាន "កៅអី បូណា សុថារី បូណាកាន់កែវ តាពាំវង់..."

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

# ថ្ងៃទី៤

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

**ចលនាចរន្ត៖ ដើរ រត់ លោត បោះ (ដើរបត់បែនតាមខ្សែ រត់ទៅរកទី លោតជើង២ទៅមុខ បោះបាល់ចូលកន្ត្រក)**

**១. វត្ថុបំណង៖**

- កុមាររៀបរាប់ពីរបៀបធ្វើចលនានីមួយៗ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារធ្វើចលនានីមួយៗ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន សហការគ្នា និងសប្បាយរីករាយ ។

**២. សម្ភារៈបង្រៀន៖ ខ្សែ បាល់ និងកន្ត្រក**

**៣. ការរៀបចំកុមារ៖**

- ចែកកុមារជាបីក្រុម ដោយឱ្យកុមារឈរជាជួរ

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូចែកកុមារជាបីក្រុម ដោយឈរជាបីជួរ
- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារដើរបង់បោយវែងៗទៅមុខ រួចដើរត្រឡប់មកក្រោយវិញ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាចរន្តនីមួយៗ (ដើរបត់បែនតាមខ្សែ រត់ទៅរកទីកំណត់ លោតជើងពីរទៅមុខ បោះបាល់ចូលកន្ត្រក)
    - ដើរបត់បែនតាមខ្សែ៖ ដើរបត់បែនទៅតាមខ្សែដែលគ្រូបានរៀបចំរួច
    - រត់ទៅរកទីកំណត់៖ បន្ទាប់មកកូនត្រូវរត់ទៅរកទីដែលគ្រូបានគូសកំណត់
    - លោតជើងពីរទៅមុខ៖ ពេលកូនរត់ដល់ទីកំណត់រួច កូនត្រូវលោតជើងពីរទៅមុខ
    - បោះបាល់ចូលកន្ត្រក ៖ បន្ទាប់ពីលោតរួចកូនត្រូវ យកបាល់បោះចូលកន្ត្រក
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានអនុវត្តគ្រប់សកម្មភាព
- គ្រូសួរកុមារ៖
    - តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
    - ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ ចលនាចរន្ត ដើរ រត់ លោត បោះ " ដើរបត់បែនតាមខ្សែ រត់ទៅរកទីកំណត់ លោតជើងពីរទៅមុខ បោះបាល់ចូលកន្ត្រក "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្ត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូនាំកុមារផ្លុំទឹកក្តៅដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃ ធ្វើកាយវិការដូចកាន់កែវទឹកក្តៅ រួចយកមកដាក់ជិតមាត់ ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ រហូតដល់ទឹកត្រជាក់ រួចកូនញ៉ាំ គ្រូសួរកុមារថា តើកូនៗឆ្អែតហើយឬនៅ? កុមារឆ្លើយថាឆ្អែតហើយ) គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្តែង ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចេះគោរពចាស់ទុំ( ពេលដើរជិតចាស់ៗត្រូវឱននិងដោះមួក) (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៤ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### ល្បែង៖ គូសភ្ជាប់តួអក្សរទៅនឹងពាក្យរៀនរួច ( ទ ធ ន ប )

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបគូសភ្ជាប់តួអក្សរទៅ ទ ធ ន ប នឹងពាក្យទូក ធុង នំ បាល់បានត្រឹមត្រូវ
- កុមារគូសភ្ជាប់តួអក្សរទ ធ ន បទៅនឹងពាក្យទូក ធុង នំ បូ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** តួអក្សរ និងពាក្យ ចំនួន៥ផ្ទាំង ខ្មៅដៃ

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ ∪ និងអង្គុយជាក្រុមតូចៗជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរសំណួរបំផុសកុមារថា៖ តើពាក្យ ទូក មានសូរដើម និងផ្ដើមដោយអក្សរអ្វីកូន? តើព្យញ្ជនៈ "ទ" មានពាក្យអ្វីផ្សេងទៀតកូន?
- គ្រូលើកយកផ្ទាំងក្រដាស ដែលមានតួអក្សរ និងពាក្យ មកបង្ហាញកុមារ ហើយឱ្យកុមារសង្កេត រួចសួរកុមារថា តើឃើញតួអក្សរអ្វីខ្លះ? ពាក្យអ្វីខ្លះ?
- គ្រូនាំកុមារអានតួអក្សរ និងពាក្យនៅលើផ្ទាំងក្រដាស១ ទៅ២ដង
- គ្រូសួរកុមារថា៖ ចូរកូនទស្សន៍ទាយទៅមើលថា តើគ្រូនឹងនាំកូនលេងល្បែងអ្វីជាមួយនឹងផ្ទាំងក្រដាសនេះ?
- គ្រូទទួលចម្លើយរបស់កុមារ និងសម្របសម្រួលចម្លើយទស្សន៍ទាយ រួចប្រាប់កុមារថា ថ្ងៃនេះគ្រូមានល្បែងមួយចង់នាំកូនលេងជាមួយ គឺល្បែងគូសភ្ជាប់តួអក្សរទៅនឹងពាក្យ តើកូនអាចចូលរួមលេងបានដែរឬទេ?
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងដល់កុមារ៖ គ្រូនឹងចែកកូនជា៥ក្រុម អង្គុយជុំគ្នាជារង្វង់ ដោយមានផ្ទាំងក្រដាសព្យញ្ជនៈ និងពាក្យ ១ផ្ទាំង (និយាយបណ្ដើរលើកបង្ហាញបណ្ដើរ)។ គ្រូនឹងទុកពេលឱ្យក្រុមកូនៗទាំងអស់ ពិភាក្សាគ្នា គូសភ្ជាប់តួអក្សរទៅពាក្យដែលមានសូរ និងផ្ដើមដោយតួអក្សរនោះ។ ឧទាហរណ៍៖ "ទ" គូសភ្ជាប់ទៅនឹងពាក្យ "ទូក"។ ក្រុមកូនៗណាដែលគូសភ្ជាប់រួចរាល់ត្រូវទះដៃមួយដង ដើម្បីប្រាប់ថាក្រុមរបស់កូនៗបានធ្វើរួចហើយ។
- គ្រូឱ្យកុមារចូលទៅតាមក្រុម ហើយចែកផ្ទាំងក្រដាសតួអក្សរ និងពាក្យ

- គ្រូចាប់ផ្ដើមឱ្យកុមារតាមក្រុម ពិភាក្សាគ្នាគូសភ្ជាប់តួអក្សរ ទៅនឹងពាក្យលើផ្ទាំងក្រដាសដែលបានចែក ហើយដើរសម្របសម្រួលតាមក្រុម
- គ្រូឱ្យក្រុមនីមួយៗយកលទ្ធផលតាមក្រុមមកបិតលើក្ដារខៀន រួចនាំកុមារផ្ទៀងផ្ទាត់ និងវាយតម្លៃលទ្ធផលតាមក្រុម
- គ្រូលើកសរសើរ ចំពោះក្រុមកុមារដែលធ្វើបានត្រឹមត្រូវ ហើយចំពោះក្រុមដែលធ្វើមិនទាន់បានត្រឹមត្រូវ ត្រូវលើកទឹកចិត្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់ឡើយ
- គ្រូសួរកុមារបំផុសកុមារថា៖
  - តើល្បែងដែលកូនលេងអំបាញ់មិញមានឈ្មោះអ្វី?
  - តើមេរៀនដែលកូនរៀន ថ្ងៃនេះស្ថិតក្នុងមុខវិជ្ជាអ្វី? មេរៀនអ្វី?(កុមារឆ្លើយតាមគំនិតម្នាក់ៗ)
- គ្រូប្រាប់បញ្ជាក់កុមារបន្ថែមថា ថ្ងៃនេះយើងរៀន មុខវិជ្ជាភាសាខ្មែរ មេរៀនល្បែង គូសភ្ជាប់តួអក្សរ ទៅនឹងពាក្យ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ល្បែង៖ ទាយលំដាប់អក្សរ

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីរបៀបលេងល្បែងទាយលំដាប់អក្សរ បានត្រឹមត្រូវ
- កុមារលេងល្បែងទាយលំដាប់អក្សរ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន និងមានភាពសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណអក្សរចល័តចំនួន១២ ( មួយអក្សរ២បណ្ណ)

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរ "U"

៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបណ្ណអក្សរចល័ត រួចសួរកុមារថា នេះជាអ្វី? កុមារឆ្លើយតាមការយល់ឃើញរបស់គេម្នាក់ៗ រួចគ្រូសម្របសម្រួលចម្លើយរបស់កុមារ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងទាំងអស់គ្នា ដោយគ្រូមានបណ្ណអក្សរចល័តចំនួន៦តួ បន្ទាប់ពីកូនឃើញអក្សរទាំងនោះហើយ កូនត្រូវអានវាទាំងអស់គ្នា រួចមកគ្រូយកបណ្ណអក្សរចល័តទាំងនេះទៅបិទនៅលើក្ដារខៀន កូនៗទាំងអស់គ្នាត្រូវសង្កេត និងចំណាំលេខរៀងតួអក្សរទាំងនោះឱ្យច្បាស់
  - ពេលបិទបណ្ណអក្សរលើក្ដារខៀនរួច គ្រូយកក្រដាស់ផ្ទាំងធំទៅបិទឱ្យជិតកុំឱ្យឃើញតួអក្សរទាំងនោះ
  - ពេលគ្រូលើកបណ្ណអក្សរចល័តបង្ហាញកូនម្ដងមួយៗ កូនត្រូវប្រាប់គ្រូថា តើតួអក្សរនេះមាននៅលើក្ដារខៀនឬទេ បើមានតើស្ថិតនៅលេខរៀងទីប៉ុន្មាន? ពេលកូនទាយរួច គ្រូបើកក្រដាស់ដើម្បីផ្ទៀងផ្ទាត់ចម្លើយជាមួយកូន។ គ្រូធ្វើរបៀបនេះ រហូតដល់អស់បណ្ណអក្សរចល័ត ។
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេគ្រូត្រូវនិយាយប្រាប់ម្ដងទៀត)
- គ្រូរៀបចំកុមារលេងទាំងអស់គ្នា នៅកន្លែងដែលបានកំណត់ និងតាមការណែនាំ

- គ្រូសួរកុមារថា៖ កូនៗទាំងអស់គ្នាសប្បាយទេ? តើមុននេះកូនៗបានលេងល្បែងអ្វី? (កុមារឆ្លើយទៅតាមការចងចាំរបស់គេម្នាក់ៗ ) ដូចនេះកូនរៀនពីមុខវិជ្ជាអ្វី? មេរៀនអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម អំពីល្បែង "**ទាយលំដាប់អក្សរ**"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអំបាញ់មិញមានកូនណាទាយត្រូវឬទេ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើយសំណួរគ្រូទៀតណា!
- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)

ម៉ោងទី៥ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## សន្ទនា៖ វត្ថុធាតុដើមនៃចំណីអាហារ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីវត្ថុធាតុដើមនៃចំណីអាហារ បានត្រឹមត្រូវ។
- កុមាររៀបរាប់បានពីវត្ថុធាតុដើមនៃចំណីអាហារ បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យយកចិត្តទុកដាក់ មានអំណត់ និងចូលរួមសហការយ៉ាងសកម្មជាមួយគ្រូ និងកុមារដទៃ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជាអក្សរ(U) កុមារអង្គុយជាក្រុម៦នាក់

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

-គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀនឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា

-គ្រូណែនាំពីរបៀបសន្ទនា៖

- កូនៗត្រូវឈរ១ក្រុមមានគ្នា៦នាក់ ហើយឈរនៅដាច់ៗពីគ្នា
- ក្នុងក្រុមនីមួយៗកូនត្រូវនាំគ្នាប៉ាវរកអ្នកដែលត្រូវចាប់ផ្តើមនិយាយមុនគេ
- កូនដែលត្រូវនិយាយមុនគេពេលចាប់ផ្តើមដំបូង ត្រូវជម្រាបសួរមិត្តភក្តិសិន បន្ទាប់មកទើបនិយាយប្រាប់មិត្តភក្តិពីវត្ថុធាតុដើមនៃចំណីអាហារដែលគ្រូបានរៀបចំ
    - ក្រុមទី១ ម្ហូបឆា(កូនត្រូវរៀបរាប់គ្រឿងផ្សំរបស់ម្ហូបឆាមានអ្វីខ្លះ?)
    - ក្រុមទី២ សម្លរម្ជូរ(កូនត្រូវរៀបរាប់គ្រឿងផ្សំរបស់សម្លរម្ជូរមានអ្វីខ្លះ?)
    - ក្រុមទី៣ ស្ងោរជ្រក់(កូនត្រូវរៀបរាប់គ្រឿងផ្សំរបស់ស្ងោរជ្រក់មានអ្វីខ្លះ?) បន្ទាប់មកសួរទៅមិត្តភក្តិនៅស្តាំដៃបន្ត ដោយប្រើសំណួរចុះអ្នកវិញ?
- កូនដែលមិត្តភក្តិសួរត្រូវនិយាយដូចមិត្តភក្តិចាប់ផ្តើមដំបូងដែរ រួចក៏សួរទៅមិត្តភក្តិនៅចុងក្រោយបន្តទៀតដោយប្រើសំណួរដូចកូនមុនដែរ

- គ្រូហៅកុមារ២នាក់ឱ្យមកឈរជាមួយគ្រូនៅមុខមិត្តភក្តិទាំងអស់គ្នាដើម្បីអនុវត្តជាគំរូឱ្យកុមារមើលសិនតាមរបៀបដែលបានណែនាំដោយគ្រូជាអ្នកចាប់ផ្តើមនិយាយមុនគេ

- គ្រូរៀបចំកុមារឱ្យឈរជាក្រុម នៅដាច់ៗពីគ្នា
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តគ្រប់ក្រុមក្នុងពេលតែមួយ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយធ្វើយ៉ាងណាត្រូវស្តាប់កុមារនិយាយឱ្យបានគ្រប់ក្រុមដើម្បីជួយកែសម្រួលនៅពាក្យណាដែលពួកគេនិយាយមិនបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ
- គ្រូឱ្យកុមារចាប់ក្រុម៦នាក់ៗសារថ្មីទៀតហើយអនុវត្តការសន្ទនាដូចក្រុមមុនដែរ( បើក្នុងករណីនៅសល់ម៉ោង )

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

# ថ្ងៃទី៥

## ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែងចលនា៖ លាក់កន្សែង

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបរត់លាក់កន្សែង បានត្រឹមត្រូវ
- កុមារលេងល្បែង លាក់កន្សែង បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្ន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** កន្សែង ឬក្រម៉ា វេញជារមូ

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរតម្រង់ជួរជា៣ជួរ រួចនាំកុមារធ្វើចលនារត់នៅមួយកន្លែង
- គ្រូបង្ហាញកន្សែងឱ្យកុមារសង្កេត ហើយសួរកុមារថា កូនទាយទៅមើលថា តើគ្រូនឹងនាំកូនលេងអ្វីជាមួយនឹងកន្សែងនេះ?(គ្រូទទួលចម្លើយទស្សន៍ទាយរបស់កុមារ)
- គ្រូចាប់ផ្ដើមណែនាំពីរបៀបលេងដល់កុមារ៖ ល្បែងនេះតម្រូវឱ្យមានកូនម្នាក់ស្ម័គ្រចិត្តធ្វើជាអ្នកលាក់កន្សែង ហើយកូនៗផ្សេងទៀតត្រូវអង្គុយឃ្លាតគ្នាបន្តិចជារង្វង់ ហើយមិនឱ្យងាកមើលមកក្រោយឡើយ។ កូនដែលអង្គុយត្រូវនៅនឹងមួយកន្លែងហើយច្រៀងដដែលៗនូវឃ្លា "លាក់កន្សែង ឆ្មាខាំកែងអូសលោងៗ" ហើយកូនដែលកាន់កន្សែងដើរជុំវិញ ច្រៀងបណ្ដើរ សង្កេតមើលមិត្តណាភ្លេចខ្លួន ត្រូវទម្លាក់កន្សែងក្រោយខ្នងមិត្តនោះ។ កូនដែលត្រូវបានគេលាក់កន្លែងក្រោយខ្នង ត្រូវក្រោកឡើងចាប់យកកន្សែងរត់ដេញវាយអ្នកនៅខាងស្ដាំដៃ បើកូនដេញវាយបាន កូនត្រូវមកអង្គុយនៅកន្លែងដើមវិញ ហើយយើងចាប់ផ្ដើមលេងសាឡើងវិញដោយអ្នកដដែលជាអ្នកលាក់កន្សែង តែបើកូននោះដេញវាយមិនបាន ត្រូវធ្វើជាអ្នកលាក់កន្សែងវិញម្ដង។ តែប្រសិនបើកូនដែលគេលាក់កន្សែងខាងក្រោយខ្នង មិនដឹងថាមានអ្វីនៅខាងក្រោយខ្នងសោះ កូនអ្នកលាក់កន្សែងនោះត្រូវដើរមួយជុំមកកន្លែងដែលលាក់កន្សែងហើយចាប់យកកន្លែងនោះមកវិញ ហើយយកមកវាយកុមារនោះដោយដេញតាមមួយជុំ រហូតដល់កន្លែងដើមវិញ។
- បន្ទាប់មកគ្រូឱ្យកុមារ១ទៅ២នាក់ ប្រាប់ឡើងវិញពីរបៀបលេង និងលក្ខខណ្ឌ
- គ្រូនាំកុមាររៀបចំឱ្យអង្គុយជារង្វង់ ដោយឃ្លាតពីគ្នាបន្តិច ហើយនាំកុមារលេងសាកល្បងតាមរបៀបដែលបានណែនាំ
- គ្រូនាំកុមារលេង និងសម្របសម្រួលដំណើរការលេង ដោយផ្ទៀងផ្ទាត់ទៅនឹងលក្ខខណ្ឌដែលបានប្រាប់
- គ្រូលើកសរសើរ លើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប ឬបន្ទះបង្អាប់កុមារឡើយ
- គ្រូនាំកុមារធ្វើចលនាផ្លុំទឹកក្ដៅ ដោយដកដង្ហើមចូល ចេញវែងៗ៣ ទៅ៤ដង (កូនៗស្រូយកខ្យល់ដង្ហើមចូល ហើយផ្លុំខ្យល់ដង្ហើមចេញមកក្រៅវែងៗដូចជាផ្លុំទឹកក្ដៅឱ្យត្រជាក់) រួចគ្រូសួរកុមារថា តើទឹកក្ដៅរបស់កូនត្រជាក់ល្មមញ៉ាំហើយឬនៅ? អញ្ចឹងកូននាំគ្នាផឹកទាំងអស់គ្នា!
- គ្រូសួរកុមារ៖
  - តើមុននេះ កូនៗបានលេងល្បែងអ្វី?

- តើកូនបានធ្វើចលនាអ្វីខ្លះក្នុងល្បែងនេះ?
- តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់បញ្ជាក់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា "លាក់កន្សែង"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា
-

### ម៉ោងទី ២ (រយៈពេល ៣០នាទី)

## សកម្មភាពប្រចាំថ្ងៃ

✱ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)

✱ ទម្លាប់ល្អ៖ ត្រូវចេះគោរពចាស់ទុំ( ពេលដើរជិតចាស់ៗត្រូវឱននិងដោះមួក) (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)

✱ គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៥ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

### ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

ល្បែង៖ គូសភ្ជាប់លេខដូចគ្នាពី១ ដល់១៣

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីលេខដូចគ្នាពី១ដល់១៣ តាមការណែនាំ បានត្រឹមត្រូវ
- កុមារគូសភ្ជាប់លេខដែលដូចគ្នាពី១ដល់១៣ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងលេខអ៊ុតរួច ៥ផ្ទាំង ហ្វឺតសរសេរក្តារខៀន តាមជាក់ស្តែង

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជាពាងពាក់កណ្តាលរង្វង់ (អក្សរ U) និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញផ្ទាំងលេខ ដែលគ្រូបានរៀបចំទុកនៅតាមទីកន្លែងរួចជាស្រេច (ផ្ទាំងមានលេខពី១ដល់១៣ ដាក់ឆ្លាស់លាយគ្នាជាមួយលេខផ្សេងៗទៀតនៅលើក្រដាសតែ១ និងហ្វឺត) ហើយសួរកុមារថា តើសម្ភារទាំងអស់នេះមានអ្វីខ្លះ?
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនៗលេងជាក្រុម ដោយក្នុងមួយក្រុមមានផ្ទាំងលេខមួយសន្លឹក និងហ្វឺត១ដើម
  - ពេលក្រុមកូនបានផ្ទាំងលេខនេះហើយ កូននាំគ្នាសង្កេតលេខដែលដូចគ្នា កូនត្រូវយកប៊ិកហ្វឺតមកគូសភ្ជាប់លេខ ទៅនឹងលេខដែលដូចគ្នា ពេលកូនសង្កេតត្រូវចែកគ្នាសង្កេតកុំដណ្តើមគ្នាណា ។
  - ពេលក្រុមកូនណាធ្វើរួចហើយកូនត្រូវយកមកបិទលើក្តារខៀនតាមកន្លែងដែលគ្រូបានរៀបចំឱ្យ ហើយយកប៊ិកហ្វឺតទៅទុកនៅតុគ្រូវិញ
  - ក្រុមណាដែលហើយមុនគេ ត្រូវទះដៃចំនួន៣ដង
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបដែលក្រុមត្រូវធ្វើតាមការណែនាំ (បើកុមារនិយាយមិន

បានគ្រូត្រូវប្រាប់ម្តងទៀត)

- គ្រូឱ្យកុមារទៅអង្គុយនៅតាមក្រុម តាមកន្លែងដែលគ្រូបានរៀបចំ ដោយគ្រូរៀបចំកុមារជា៣ក្រុម
- គ្រូឱ្យតំណាងក្រុមឡើងមកយកសម្ភារទៅអនុវត្តតាមក្រុមនីមួយៗ ហើយគ្រូជាអ្នកដើរសម្របសម្រួល ពេលកុមារអនុវត្តចប់គ្រប់ក្រុមហើយ ឱ្យពួកគេទៅអង្គុយជារួមវិញ ហើយឱ្យតំណាងក្រុមយកលទ្ធផលក្រុមនិមួយៗទៅបិតនៅលើក្តារខៀន
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដែលបានបិទលើក្តារខៀន ដោយឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញពីអ្វីដែលក្រុមបានធ្វើ ( ធ្វើម្តងមួយក្រុម)
- គ្រូលើកសរសើរចំពោះក្រុមដែលធ្វើរួចមុនគេ ចំពោះក្រុមធ្វើហើយក្រោយគេ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? តើមុននេះ កូនៗបានលេងល្បែងអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិត មេរៀនល្បែង "គូសភ្ជាប់លេខដែលដូចគ្នា ពី១ដល់១៣"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត) គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ មើមឆៃថាវដ៏ធំ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ យកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាបណ្តុំ ជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំនួរ៖ តើប៉ាម៉ាក់កូនធ្លាប់ដាំដំណាំមើមអ្វីខ្លះ ? តើកូនចូលចិត្តញ៉ាំបន្លែមើមទាំងនេះទេ? តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអំពីអ្វី? គ្រូសរុបចម្លើយរបស់កុមារ
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា សិក្សាសង្គម ចំណងជើងរឿងនិទាន «មើមឆៃថាវដ៏ធំ »
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដោយសួរកុមារថា៖ មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ? ដូចច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលបានទាយត្រូវទាំងអស់គ្នា

- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- ប្រាប់ឈ្មោះអ្នកនិពន្ធ៖ រឿងនិទាននេះនិពន្ធដោយអ៊ុំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម
- គ្រូនិទានរឿងផ្ទាល់មាត់ឱ្យកុមារស្តាប់ ដោយលើកដាក់សម្លេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា៖
  - សព្វ៖ ទាំងពួង ទាំងស្រុង
  - តស់៖ ឧទានសព្ទសម្រាប់ប្រាប់ឬបបួល ឧ.តោះយើងចេញដំណើរ
- គ្រូសួរកុមារ៖ក្រោយពីស្តាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើនរណាជាអ្នកដកមើមផៃថាវមុនគេ?តើគាត់ដកបានដែរទេ?ហេតុអ្វី? តើនរណាខ្លះបានមកជួយដកមើមផៃថាវលោកតា?ពួកគេដកបានដែរឬទេ? គាត់យកផៃថាវនោះយកទៅធ្វើអ្វី? តើការញ៉ាំបន្លែមានប្រយោជន៍(កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញម្តងទៀត
- បន្ទាប់មកគ្រូឱ្យកុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្តិស្តាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំ)
- ប្រាប់ឈ្មោះអ្នកនិពន្ធ ៖ រឿងនេះ អ៊ំៗនៅក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកនិពន្ធ ។

**អត្ថបទរឿង "មើមផៃថាវដ៏ធំ"**

ល្ងាចថ្ងៃនេះ មេឃស្រទំ លោកតាជីកដីដាំគ្រាប់ផៃថាវ។ លោកតា និងគីគី ស្រោចទឹក បោចស្មៅ ដាក់ដីជារៀងរាល់ថ្ងៃ។ ព្រឹកនេះលោកតាបានទៅមើលថែទាំសួនបន្លែដូចសព្វដង ស្រាប់តែគាត់លាន់មាត់ថា ៖ យី! ផៃថាវយើងចេញមើមធំណាស់។ គាត់ក៏ប្រឹងដកផៃថាវ អឹសៗៗ ១ ២ ៣ ៗៗ ។ ដកច្រើនដងហើយនៅតែមិនបាន លោកតាក៏បាន ស្រែកហៅយាយមកជួយដកមើមផៃថាវ។ពេលនោះយាយមកដល់ យាយឱបចង្កេះតា តាទាញបន្លែ "១ ២ ៣ ៗៗ" ដកច្រើនដងហើយ នៅតែមិនបាន យាយស្រែកហៅចៅស្រី ចៅស្រីឱបចង្កេះយាយ យាយឱបចង្កេះតា តាទាញបន្លែ "១ ២ ៣ ៗៗ" ដកច្រើនដង ហើយនៅតែមិនបាន។ ចៅស្រីរត់ហៅ គីគី វ៉ូស វ៉ូស! គីគី ខាំទាញសំពត់ចៅស្រី ចៅស្រីឱបចង្កេះយាយ យាយឱបចង្កេះតា តាទាញបន្លែ "១ ២ ៣ ៗៗ" ដកច្រើនដងហើយនៅតែមិនបាន។គីគី រត់ទៅហៅឆ្មា។ ម៉េវ ម៉េវ ឆ្មារត់មកតោងកន្ទុយគីគី គីគីខាំទាញសំពត់ចៅស្រី ចៅស្រីឱបចង្កេះយាយ យាយឱបចង្កេះតា តាទាញបន្លែ "១ ២ ៣ ៗៗ" ដកច្រើនដងហើយនៅតែមិនបាន។ ឆ្មារត់ទៅហៅកណ្តុរ ចិច ចិច! កណ្តុររត់ទៅតោងកន្ទុយឆ្មា ឆ្មាតោងកន្ទុយគីគី គីគីខាំទាញសំពត់ចៅស្រី ចៅស្រីឱបចង្កេះយាយ យាយឱបចង្កេះតា តាទាញបន្លែ "១ ២ ៣ ៗៗ" អូ! ដកបានហើយ មើមផៃថាវធំណាស់ តស់ពួកយើងយកមើមផៃថាវនេះទៅស្ល »។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## កំណាព្យ៖ អាហារបីក្រុម

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីពាក្យឃ្លា និងអត្ថន័យនៃកំណាព្យ "អាហារបីក្រុម" បានត្រឹមត្រូវ
- កុមារសូត្រកំណាព្យតាមវាក្យស័ព្ទ និងលំនាំបទ បានត្រឹមត្រូវ
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀន៖**

- គ្រូប្រាប់កុមារ ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូនាំកុមារអានអត្ថបទ រកពាក្យពិបាក និងពន្យល់អត្ថន័យ
  - អាហារបីក្រុម បានន័យថាអាហារដែលមានក្រុមសាច់ ក្រុមផ្លែឈើ និងក្រុមបន្លែ
  - កំណាព្យ នេះនិយាយពីអាហារទាំង៣ក្រុម ដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ ដើម្បីឱ្យកូនធំលូតលាស់ មានបញ្ញាវៀងវៃ រាងកាយមាំមួនល្អ
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២ ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ
- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអំបាញ់កូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជា៖ ភាសាខ្មែរ មេរៀន៖កំណាព្យ«**អាហារបីក្រុម**»អ្នកនិពន្ធដោយលោកអ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

អត្ថបទកំណាំព្យ "អាហារបីក្រុម"(បទ ពំនោល)

| | | |
|---|---|---|
| អាហារយើងញាំរាល់ថ្ងៃ | មានប្រយោជន៍ក្រៃ | ឱ្យយើងរស់រានមានជីវិត |
| ញាំហើយត្រូវតែរិះគិត | អាហារល្អពិត | នោះគឺអាហារបីក្រុម ។ |
| ក្រុមមួយជួយយើងធាប់ធំ | ក្រុមមួយជួយផ្តុំ | ការពាររោគាចង្រៃ |
| ក្រុមមួយជួយឱ្យឆ្លាតវៃ | សុខភាពប្រពៃ | រស់នៅប្រសើរថ្លៃថ្លា |

## ម៉ោងទី៦ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែង៖ ចាក់ទឹកដូង

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពី របៀបធ្វើចលនាម្រាមដៃ ចាក់ទឹកដូង បានត្រឹមត្រូវ
- កុមារធ្វើចលនាម្រាមដៃ ចាក់ទឹកដូង បានត្រឹមត្រូវ
- កុមារមានបំរុងប្រយ័ត្ន សហការរីករាយ និងមានភាពជឿជាក់រហ័សរហួន

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារង្វង់ និងចាប់ដៃគូរ២នាក់ៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀន រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា
- គ្រូឱ្យកុមារទាំងអស់ ឈរជារង្វង់ ហើយចាប់ដៃគូរ ២នាក់ៗ ដោយឈរទល់មុខគ្នា
- គ្រូណែនាំពីរបៀបលេង៖
  - កូនៗទាំងអស់គ្នាចាប់គូរ ឈរទល់មុខគ្នា រួចស្តាប់ និងធ្វើតាមការណែនាំរបស់គ្រូ
  - កូនម្នាក់ដែលឈរខាងស្តាំដៃលើកដៃស្តាំ ហើយផ្ងារបាតដៃឡើងលើ រីឯកូនម្នាក់ទៀតដាក់ចង្អុលដៃស្តាំនៅចំកណ្តាលបាតដៃគូររបស់កូនហើយញាក់ឡើងចុះតិចៗតាមចង្វាក់ចម្រៀង
  - បន្ទាប់មកកូនៗត្រូវច្រៀងទាំងអស់គ្នា តាមគ្រូ «ចាក់ទឹកដូងមីឡូងមីឡា កន្ទុយត្រីប្រាមហានាងអុកអកកំបោរប្រចាំថង់ បំពង់ឫស្សីប្រចាំវែក ក្បាលទំពែកក្អែកជុះដាក់ប៉ក់»
  - ពេលកូនឮពាក្យ «ប៉ក់» ចប់ភ្លាម កូនដែលផ្ងារបាតដៃត្រូវចាប់ក្តោបបាតដៃឱ្យរហ័ស ចំណែកឯកូនដៃគូរម្ខាងទៀតដែលដាក់ចង្អុលដៃនៅកណ្តាលបាតដៃកូនម្នាក់ទៀត ត្រូវដកចង្អុលដៃកូនចេញឱ្យបានលឿនដែរ
  - កូនត្រូវអនុវត្ត២ដង បើកូនណាត្រូវដៃគូរចាប់ចង្អុលដៃបាន កូននោះជាអ្នកចាញ់ បើចាប់ចង្អុលដៃមិនបាន កូននោះជាអ្នកឈ្នះ
  - បន្ទាប់មកកូនត្រូវប្តូរដៃគូរ កូនម្ខាងជាអ្នកដាក់បាតដៃផ្ងារហើយកូនម្ខាងទៀតប្តូរជាអ្នកដាក់ចង្អុលដៃលើបាតដៃ វិញម្តង រួចធ្វើការច្រៀងទាំងអស់គ្នា និងអនុវត្តដូចមុនចំនួន២ដង
- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តនិយាយ របៀបលេងឡើងវិញពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនទាន់ច្បាស់លាស់ទេ គ្រូត្រូវប្រាប់សារឡើងវិញ
- គ្រូរៀបចំកុមារជាក្រុម ហើយចាប់គូរៗ ទៅតាមកន្លែងដែលគ្រូបានរៀបចំទុក
- គ្រូចាប់ផ្តើមដឹកនាំការអនុវត្តការលេងសាកល្បងម្តង រួចឱ្យកុមារអនុវត្តយកមែនទែនដោយកំណត់នាទីក្នុងការលេង
- គ្រូដើរសម្របសម្រួលដៃគូរកុមារ និងជួយកែតម្រូវដៃគូរកុមារណាដែលលេងខុស
- គ្រូឱ្យកុមារលេង រហូតដល់នាទីដែលបានកំណត់
- គ្រូលើកសរសើរកុមារទាំងអស់គ្នា ដែលលេងសហការគ្នាបានល្អ និងរហ័សរហួន ហើយលើកទឹកចិត្តកុមារដែលលេងមិនទាន់បានរហ័សល្អ

✱ **ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

## ថ្ងៃទី៦

ម៉ោងទី១ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ ចិត្តចលភាព

### រំលឹក ហាត់ប្រាណតាមបទចម្រៀង៖ ឆ្វេង-ស្តាំ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)

* **ទម្លាប់ល្អ៖** ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)

- **គ្រូសួរកុមារ៖**
  - នៅផ្ទះឪពុកម្តាយកូនមានដាំដំណាំឬទេ? ដាំអ្វីខ្លះ? មានចិញ្ចឹមសត្វដែរឬទេ? ចិញ្ចឹមសត្វអ្វីខ្លះច្រើនឬតិច?
  - តើកូនដែលបានជួយធ្វើអ្វីខ្លះ ពេលឪពុកម្តាយកូនដាំដំណាំ?
  - កូនខ្លះបើឪពុកម្តាយមានចិញ្ចឹមសត្វ តើកូនបានជួយធ្វើអ្វីខ្លះ?
  - កូនសង្កេតមើលនៅក្នុងភូមិ តើលោកយាយ លោកតា អ៊ំមីងមារគាត់ធ្វើអ្វីខ្លះ? តើកូនធ្លាប់ទៅជួយធ្វើអ្វីខ្លះជាមួយពួកគាត់?
  - នៅសាលារៀន តើមានកិច្ចការអ្វីខ្លះដែលកូនធ្លាប់ធ្វើជាមួយគ្រូ?
- **គ្រូណែនាំកុមារបន្ថែម៖** ពេលកូនឃើញឪពុកម្តាយ គ្រូ លោកតា លោកយាយ ពូមីង កំពុងតែធ្វើកិច្ចការអ្វីមួយ កូនត្រូវជួយធ្វើពួកគាត់ ទៅតាមអ្វីដែលពួកកូនអាចជួយធ្វើបានទៅតាមកម្លាំងរបស់កូនម្នាក់ៗមិនចាំបាច់ពួកគាត់ប្រើនោះទេ។

* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៦ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ ភាសាខ្មែរ

### សម្គាល់តួអក្សរ៖ "ថ"

**១. វត្ថុបំណង**

- កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ "ថ" បានត្រឹមត្រូវ
- កុមារកំណត់បានពីរូបរាងឈ្មោះអក្សរ"ថ" និងរកពាក្យថ្មីផ្តើមចេញពីអក្សរ"ថ" បានត្រឹមត្រូវ
- កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្តើមពីអក្សរ"ថ"។

**២. សម្ភារបង្រៀន៖**

- ផ្ទាំងរូបភាព ថូ ថាស ថតតុ
- ប័ណ្ណពាក្យ ថូ ថាស ថតតុ និងឈ្មោះ ថី ថូ ទិញពូថៅ- ប៊ិក ហ្វឹត ស្កុត (កាត់រៀបចំឱ្យហើយ)

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "ថូ" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញប័ណ្ណពាក្យ "ថូ" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"ថាស" ដោយលោស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញប័ណ្ណពាក្យ "ថាស" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "ថតតុ" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "ថតតុ" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្តិបានឮពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "ថតតុ" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន ហើយបង្ហាញបណ្ណពាក្យ"ថតតុ" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "ថី ថូ ទិញពូថៅ" អានឱ្យកុមារស្តាប់រួចយកបិទពីក្រោមពាក្យ ហើយនាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង

**+ ស្តាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្តាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអំបាញ់មិញឮសូរដូចម្តេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

**+ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នា (ពេលកុមារឡើងមកគូសវង់ជុំវិញអក្សរមានរាងដូចគ្នា បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមារ

រាប់ចំនួនអក្សរដែលកុមារបានគូសវង់ដើម្បីផ្ទៀងផ្ទាត់ ។

**+ ប្រាប់ឈ្មោះតួអក្សរ៖**

- គ្រូសួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "ថ" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"ថ" យ៉ាងធំនៅជ្រុងក្តារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"ថ" នាំកុមារអានអក្សរ"ថ" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្តារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

**+ ប្រៀបធៀបអក្សរស្រដៀង៖**

- គ្រូសរសេរអក្សរ "ថ ជ ផ " នៅលើក្តារខៀន
- គ្រូអានអក្សរ "ថ ជ ផ " ឱ្យកុមារស្តាប់ និងសង្កេត
- គ្រូសួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?
- (កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង)

**+ រកពាក្យថ្មីផ្តើមពីអក្សរ"ថ" ៖**

- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្តាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្តើមពីអក្សរ"ថ"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្តារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- គ្រូនាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្តងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"ថ" ឬទេ? បើមានតួអក្សរក្នុងពាក្យដូចតួអក្សរ "ថ" នេះ កុមារត្រូវធ្វើសញ្ញាបាទ/ចាស (ដោយក្តាប់ដៃស្តាំលើកឡើងត្រឹមភ្នែក រួចធ្វើសញ្ញាបាទ/ចាស ដូចងក់ក្បាល) រួចគ្រូគូសវង់ជុំវិញពាក្យនោះ។ តែបើក្នុងពាក្យនោះមិនមានតួអក្សរ "ថ" ទេកុមារត្រូវធ្វើសញ្ញាទេ (ដោយលាដៃស្តាំលើកឡើងត្រឹមភ្នែក រួចគ្រវី) ដោយគ្រូមិនត្រូវធ្វើអ្វីទាំងអស់ចំពោះពាក្យនោះ។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ ដើរ ឬដេក(ពេលទី២)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីអត្ថន័យ និងរបៀបធ្វើកាយវិការបទចម្រៀងដើរ ឬដេកបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងដើរ ឬដេកបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងបទចម្រៀង សហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។

**២. សម្ភារៈបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀន៖**

- គ្រូបំផុសសំណួរ៖ កូនគិតបន្តិចទៅមើលថា តើថ្ងៃមុនកូនបានរៀនច្រៀងចម្រៀងអ្វី?តើចម្រៀងនោះមានន័យដូចម្តេច?(បើកុមារឆ្លើយមិនត្រូវគ្រូប្រាប់កុមារតែម្តង)
- គ្រូសួរកុមារបន្តថា ដូច្នេះកូនទាយទៅមើលថា ថ្ងៃនេះ គ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី?កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះ គ្រូនឹងបង្រៀនកូននូវមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "ដើរ ឬដេក" នេះម្តងទៀត
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់ និងសរសេរមុខវិជ្ជា និងចំណងជើងដាក់លើក្តារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូឱ្យកុមារច្រៀង និងធ្វើកាយវិការដែលបានធ្វើនៅពេលទី១ឡើងវិញជាក្រុម និងទាំងអស់គ្នា ឱ្យបាន២ចប់
- គ្រូប្រាប់កុមារថា ឥឡូវគ្រូនឹងច្រៀងចម្រៀងនេះម្តង តែគ្រូដូចជាភ្លេចពាក្យខ្លះៗ តើកូនអាចជួយថាពាក្យនោះប្រាប់លោកគ្រូបានទេ បើគ្រូភ្លេចពាក្យទាំងនោះ។ បន្ទាប់មកគ្រូចាប់ផ្តើមច្រៀងដោយធ្វើជាបំបាត់ពាក្យខ្លះក្នុងខ្លឹមសារអត្ថបទចម្រៀង ឱ្យកុមារជួយបំពេញ។ គ្រូអនុវត្តបែបនេះឱ្យបាន២ចប់។
- គ្រូប្រាប់កុមារថា៖ ឥឡូវនេះគ្រូចង់នាំកូនលេងល្បែងមួយគឺគ្រូនឹងធ្វើកាយវិការតាមបទចម្រៀងនេះ ហើយកូនជាអ្នកច្រៀងឱ្យគ្រូធ្វើកាយវិការ តើកូនអាចច្រៀងចម្រៀងឱ្យគ្រូធ្វើកាយវិការបានដែរឬទេ? ។បន្ទាប់មកគ្រូចាប់ផ្តើមធ្វើកាយវិការ ហើយកុមារទាំងអស់ច្រៀងចម្រៀង។គ្រូនាំអនុវត្តបែបនេះឱ្យបាន ២ចប់។
- គ្រូប្រាប់កុមារថា៖ អម្បាញ់កូនបានច្រៀងឱ្យគ្រូធ្វើកាយវិការ។ ឥឡូវកូនជាអ្នកធ្វើកាយវិការម្តង ហើយគ្រូនឹងច្រៀងឱ្យកូនធ្វើកាយវិការវិញម្តង តើកូនយល់ព្រមដែរឬទេ? ។បន្ទាប់មកគ្រូចាប់ផ្តើមច្រៀង ហើយកុមារជាអ្នកធ្វើកាយវិការទាំងអស់គ្នា។ គ្រូនាំអនុវត្តបែបនេះឱ្យបាន២ចប់។
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសារឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

**ខ្លឹមសារ និងរបៀបធ្វើកាយវិការ**

**+ អត្ថបទចម្រៀង៖ ដើរ ឬដេក យើងក្មេងៗ ដើរ ឬដេកដងខ្លួនឱ្យត្រង់ ត្រូវតម្រង់ទាន់ខ្លួននៅក្មេង**

ទោះអង្គុយឬមួយឈរលេង យើងក្មេងៗឈរឱ្យត្រង់ខ្លួន ។
មុខញញឹមសង្ឃឹមជានិច្ច កុំបែរគេចលបមើលក្រោយខ្នង
ងើបមុខឡើងនិយាយឆ្លើយឆ្លង ទើបអ្នកផងគេហៅក្លាហាន។

**+ របៀបធ្វើកាយវិការ៖**

- "ដើរឬដេកដងខ្លួនឱ្យត្រង់" ធ្វើកាយវិការដើរនៅមួយកន្លែងដូចពួកកងទ័ព ហើយយកម្រាមផ្ទុំផ្តេកក្រោមថ្គាមខាងស្តាំ រួចយកដៃទម្លាក់ចុះមកវិញឱ្យស្របនឹងដងខ្លួនដោយផ្ទុំជើងឈរនៅស្មៀមឱ្យត្រង់ដូចតម្រង់ជួរ
- "ត្រូវតម្រង់ទាន់ខ្លួននៅក្មេង" ធ្វើកាយវិការដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលើកយកម្រាមចង្អុលមករលាស់ចង្អុលចុះទៅឆ្វេងទៅស្តាំ

- "ទោះអង្គុយឬមួយឈរលេង យើងក្មេងៗឈរឱ្យត្រង់ខ្លួន" ធ្វើកាយវិការ ដុចជង្គង់បន្តិចដូចជាការអង្គុយ រួចងើបមកវិញដោយឈរឱ្យត្រង់ខ្លួន។
- "មុខញញឹមសង្ឃឹមជានិច្ច" ធ្វើកាយវិការ ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលើកម្រាមចង្អុល មកចង្អុលមាត់ ហើយញញឹមបណ្តើរ
- "កុំបែរគេចលបមើលក្រោយខ្នង" ធ្វើកាយវិការ ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលើករាចុះចំឡើង ក្បាលធ្វើងាកទៅក្រោយម្តងទៅងាកទៅឆ្វេង ម្តងងាកទៅស្តាំ
- "ងើបមុខឡើងនិយាយសាសង ទើបអ្នកផងគេហៅក្លាហាន" ធ្វើកាយវិការ ទម្លាក់ដៃទាំងសងខាងឱ្យស្របនឹងដងខ្លួន មុខបែរឱ្យត្រង់ហើយងើយឡើងបន្តិច រួចទាញមេដៃឆ្វេងចង្អុលមកលើទ្រូងរួចបោះទៅមុខត្រង់ឱ្យលះ។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ

## សង្កេតៈ បុណ្យចូលឆ្នាំខ្មែរ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីពិធីបុណ្យចូលឆ្នាំ បានត្រឹមត្រូវ
- កុមារបង្ហាញពីដំណាក់កាលនៃការធ្វើពិធីបុណ្យចូលឆ្នាំ បានត្រឹមត្រូវ
- បណ្តុះគំនិតកុមារឱ្យស្គាល់ពីទនៀមទម្លាប់ប្រពៃណីខ្មែរ

**២. សម្ភារបង្រៀនៈ**

- ផ្ទាំងរូបភាពបុណ្យចូលឆ្នាំមាន៤សន្លឹក
- គ្រូៈ មានផ្ទាំងរូបភាពបុណ្យចូលឆ្នាំ១សន្លឹក
- កុមារៈ មានផ្ទាំងរូបភាពក្នុងក្រុមមាន១សន្លឹក( ទាំងអស់កុមារមាន៣ក្រុម )

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងរង្វង់ កុមារអង្គុយតាមក្រុម( ៣ក្រុម )

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងដំហ៊ានទី៣)

- គ្រូសួរកុមារៈកូនៗធ្លាប់ទៅធ្វើពីធីបុណ្យអ្វីខ្លះ? ហើយពីធីបុណ្យនោះគេធ្វើនៅឯណាកូន? ដូច្នេះកូនអាចប្រាប់គ្រូបានទេថា តើកូនៗចង់រៀនមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមការគិតរបស់ពួកគេម្នាក់ៗ
- គ្រូប្រាប់កុមារពេលនេះគ្រូចង់បង្រៀនកូនពីមុខវិជ្ជា វិទ្យាសាស្ត្រ អំពីពិធីបុណ្យចូលឆ្នាំ តើកូនៗចង់រៀនជាមួយគ្រូឬទេ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនិងការនិយាយប្រាប់របស់គ្រូរួចសួរកុមារថា តើអម្បាញ់មិញមានកូនណាចង់រៀនដូចគ្រូទេ? កូនដែលមានគំនិតដូចគ្រូ ជាកូនដែលឆ្លាតនិងពូកែឈ្លាសវៃមែន។
- គ្រូឱ្យកុមារនិយាយពីពិធីបុណ្យចូលឆ្នាំដែលពួកគេបានទៅជាមួយឪពុកម្តាយ
- គ្រូបង្ហាញផ្ទាំងរូបភាពពិធីបុណ្យចូលឆ្នាំដោយបិទលើក្តារខៀនឱ្យកុមារសង្កេត
- គ្រូបំផុសគំនិតឱ្យកុមារសង្កេតនិងរៀបរាប់ពីអ្វីដែលគេបានឃើញ និងអ្វីដែលគេស្គាល់
- គ្រូបែងចែកកុមារជា៣ក្រុមតូចៗ ហើយក្នុងមួយក្រុមកុមារនីមួយៗនាំគ្នាសង្កេតផ្ទាំងរូបភាពពិធីបុណ្យចូលឆ្នាំ
- គ្រូឱ្យតំណាងក្រុមឡើងរៀបរាប់ពីអ្វីដែលពួកគេបានឃើញនិងស្គាល់ឱ្យមិត្តភក្តិទាំងអស់គ្នាស្តាប់

- គ្រូបំពេញបន្ថែមនៅអ្វីដែលកុមារមិនទាន់ស្គាល់
- គ្រូនាំកុមារអានពាក្យពិបាកទាក់ទងនឹងពិធីបុណ្យចូលឆ្នាំ ឧទាហរណ៍ៈចោលឈូង បោះអង្គុញ ទាញព្រ័ត្រ លាក់កន្សែង ចាប់កូនខ្លែង...(អានជាក្រុម និងទាំងអស់គ្នា)
- គ្រូសួរកុមារ តើអម្បាញ់មិញកូនបានស្គាល់ពិធីបុណ្យអ្វីខ្លះ? អញ្ចឹងថ្ងៃនេះកូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី? (កុមារឆ្លើយតបគំនិតរបស់កុមារម្នាក់) អរគុណកូនៗដែលបានឆ្លើយ
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពីមេរៀនសង្កេត«ពិធីបុណ្យចូលឆ្នាំ» តើមានកូនណាឆ្លើយត្រូវតាមចម្លើយរបស់គ្រូទេ?
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម និងទាំងអស់គ្នា។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី៧

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

### រំលឹក ហាត់ប្រាណតាមរឿងនិទានៈ យើងនាំគ្នាទៅលេងបុណ្យចូលឆ្នាំខ្មែរ

( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២ ម៉ោងទី១ )

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២ )
* ទម្លាប់ល្អៈ ចេះជួយធ្វើការងារមនុស្សធំ ( នៅផ្ទះ នៅសាលារៀន និងនៅភូមិ ) ( ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២ )
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៧ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ

### សន្ទនាៈ សារៈសំខាន់នៃការញ៉ាំចំណីអាហារ

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីសារសំខាន់នៃការញ៉ាំចំណីអាហារ បានត្រឹមត្រូវ។
- កុមាររៀបរាប់ពីសារសំខាន់នៃការញ៉ាំចំណីអាហារ បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យយកចិត្តទុកដាក់ មានអំណត់ និងចូលរួមសហការយ៉ាងសកម្មជាមួយគ្រូ និងកុមារដទៃ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជាអក្សរអ៊ុយ "ᑌ" កុមារអង្គុយជាក្រុម៥នាក់

**៤. ដំណើរការបង្រៀនៈ** ( អនុវត្តនៅក្នុងជំហានទី៣ )

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។

-គ្រូណែនាំពីរបៀបសន្ទនា

- គ្រូឱ្យកូនបង្កើតក្រុម៥នាក់ៗហើយឈរនៅដាច់ៗពីគ្នា
- ក្នុងក្រុមនីមួយៗកូនត្រូវនាំគ្នាប៉ាវរកអ្នកដែលត្រូវចាប់ផ្តើមនិយាយមុនគេ
- កូនដែលត្រូវនិយាយមុនគេពេលចាប់ផ្តើមដំបូងត្រូវជម្រាបសួរមិត្តភក្តិសិន។បន្ទាប់មកទើបនិយាយប្រាប់មិត្តភក្តិពីសារសំខាន់នៃការញ៉ាំចំណីអាហារ( តើកូនញ៉ាំចំណីអាហារបែបណា ?ចុះបើកូនញ៉ាំចំណីអាហារទាំងអស់នោះតើកូនមានសុខភាពដូចម្តេច ?ប្រសិនបើកូនញ៉ាំចំណីអាហារមិនមានអនាម័យ តើកូនមានសុខភាពដូចម្តេច ? )បន្ទាប់មកសួរទៅមិត្តភក្តិនៅស្តាំដៃបន្ត ដោយប្រើសំណួរចុះអ្នកវិញ ?

- កូនដែលមិត្តភក្តិសួរត្រូវនិយាយដូចមិត្តភក្តិចាប់ផ្តើមដំបូងដែរ។រួចក៏សួរទៅមិត្តភក្តិនៅចុងក្រោយបន្តទៀតដោយប្រើសំណួរដូចកូនមុនដែរ

- គ្រូហៅកុមារ២នាក់ឱ្យមកឈរជាមួយគ្រូនៅមុខមិត្តភក្តិទាំងអស់គ្នាដើម្បីអនុវត្តជាគំរូឱ្យកុមារមើលសិនតាមរបៀបដែលបានណែនាំដោយគ្រូជាអ្នកចាប់ផ្តើមនិយាយមុនគេ
- គ្រូរៀបចំកុមារឱ្យឈរជាក្រុម ៥ នាក់នៅដាច់ៗពីគ្នា
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តគ្រប់ក្រុមក្នុងពេលតែមួយ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយធ្វើយ៉ាងណាត្រូវស្តាប់កុមារនិយាយឱ្យបានគ្រប់ក្រុមដើម្បីជួយកែសម្រួលនៅពាក្យណាដែលពួកគេនិយាយមិនបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ
- គ្រូឱ្យកុមារចាប់ក្រុម៥នាក់ៗសារថ្មីទៀតហើយអនុវត្តការសន្ទនាដូចក្រុមមុនដែរ បើក្នុងករណីនៅសល់ម៉ោង

### ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## គំនូរ៖ ផាត់ពណ៌ព្រះអាទិត្យ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបផាត់ពណ៌ព្រះអាទិត្យ បានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃពណ៌ ផាត់ពណ៌ព្រះអាទិត្យដោយទប់លំនឹងបង្វិលតាមរូប បានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

\+ **សម្ភារសម្រាប់គ្រូ៖**

- ផ្ទាំងក្រដាសដែលមានរូបព្រះអាទិត្យផាត់ពណ៌រួចចំនួន១សន្លឹក
- ផ្ទាំងក្រដាសរូបព្រះអាទិត្យដែលមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)
- ខ្មៅដៃពណ៌ចំនួន២ដើម(២ពណ៌) ស្កុតចំនួន១ដុំ

\+ **សម្ភារសម្រាប់កុមារ៖** ផ្ទាំងក្រដាសរូបព្រះអាទិត្យមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃពណ៌សម្រាប់កុមារ

**៣. ការរៀបចំកុមារ៖** អង្គុយរាងអក្សរអ៊ុយ "U" បែកកុមារជាក្រុម (អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងដំហានទី៣)

- គ្រូសួរ៖ តើពេលព្រឹកកូនក្រោកពីគេងកូនសំឡឹងទៅទិសខាងកើតមើលទៅលើមេឃឃើញអ្វីខ្លះ? មានពណ៌អ្វីកូនៗ?(ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសរូបដែលមានរូបព្រះអាទិត្យផាត់ពណ៌រួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្តាខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសរូបព្រះអាទិត្យ ១សន្លឹកទៀត ដែលគ្រូមិនទាន់ផាត់ពណ៌ឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសរូបនេះគ្រូទុកសម្រាប់ផាត់ពណ៌ឱ្យកូនមើលពីរបៀបផាត់ពណ៌។ ដូច្នេះកូន

នាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្តើមផាត់ពណ៌ពីណាទៅណា ?

- គ្រូយកផ្ទាំងក្រដាសរូបនោះទៅបិទនៅលើក្តាខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបផាត់ពណ៌
- គ្រូណែនាំពីរបៀបផាត់ពណ៌នៅលើផ្ទាំងក្រដាសរូបព្រះអាទិត្យដែលបានបិទលើក្តាខៀន ដោយផាត់ពណ៌បណ្តើរ និយាយប្រាប់កុមារបណ្តើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការផាត់ពណ៌
- គ្រូណែនាំកុមារៈ
    - កូនយកខ្មៅដៃពណ៌មកផាត់រូបព្រះអាទិត្យដោយចាប់ដោយកូនចាប់ផ្តើមទាញពីលើចុះក្រោមដោយមិនឱ្យផាត់ចេញក្រៅរូបភាពព្រះអាទិត្យទេ។ កូនៗត្រូវផាត់បន្ទើរៗរបៀបនេះឱ្យពេញរូបព្រះអាទិត្យ។បន្ទាប់មកកូនគូសបន្ទាត់បញ្ឈរនិងត្រង់ផ្តេកខ្លីៗល្មមជុំវិញរូបព្រះអាទិត្យនោះ( តាមរូបគំនូរផាត់ពណ៌របស់គ្រូដាក់ស្តែង )
    - បន្ទាប់មកកូនយកខ្មៅដៃពណ៌កូនផាត់ពណ៌រូបព្រះអាទិត្យឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃពណ៌ សម្រាប់កូនផាត់ពណ៌ទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយផាត់ពណ៌ (តាមស្ថានភាពជាក់ស្តែង)
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- គ្រូនាំកុមារម្នាក់ៗអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃពណ៌ផាត់ និងមិនទាន់យល់ពីរបៀបផាត់ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារៈ ពេលកូនផាត់រួចហើយកូនយកខ្មៅដៃពណ៌ទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន ពេលកូនផាត់ហើយគ្រប់គ្នា កូនទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់ៈ តើមិត្តភក្តិយើងផាត់បានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

**ម៉ោងទី៩ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ បុរេគណិត

## ល្បែងៈ ភ្លើងឆេះលើភ្នំលេខពី ៥ដល់១៣

### ១. វត្ថុបំណង

- កុមារប្រាប់បានពីចំនួនលេខ និងយល់ន័យ ពី ៥ដល់១៣ តាមលំដាប់លំដោយ បានត្រឹមត្រូវ
- កុមាររាប់ចំនួនលេខ និងយល់ន័យ ពី៥ដល់១៣ តាមលំដាប់លំដោយ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** កូនកាសលេខពី៥ ដល់១៣ (ក្នុងមួយលេខមានចំនួន៣សន្លឹក)

**៣. ការរៀបចំកុមារៈ** ឱ្យកុមារឈរជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងដំហានទី៣)

- គ្រូបង្ហាញកូនកាសលេខពី ៥ដល់១៣ ដែលគ្រូបានរៀបចំទុក រួចឱ្យកុមារប្រាប់ឈ្មោះលេខទាំងនោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងទាំងអស់គ្នា ហើយឈរជារង្វង់។ កូនត្រូវបានកូនកាសលេខម្នាក់មួយសន្លឹក ហើយពេលចាប់ផ្តើមលេង កូនត្រូវចាំស្តាប់គ្រូនិយាយ
  - ពេលឮគ្រូនិយាយថា៖ « ភ្លើងឆេះលើភ្នំហើយ » កូនទាំងអស់គ្នាត្រូវរត់តិចៗ
  - ពេលឮគ្រូនិយាយថា «ភ្លើងឆេះលើភ្នំកាន់តែខ្លាំងហើយ» កូនទាំងអស់គ្នាត្រូវរត់លឿនជារង្វង់
  - ពេលឮគ្រូនិយាយថា៖ «ភ្លើងរលត់ហើយ» កូនទាំងអស់គ្នាត្រូវរត់បង្កើតក្រុម ដែលមានកូនកាសលេខដូចគ្នា
  - ពេលកូនចូលក្រុមរួចហើយ នៅពេលគ្រូនាំកូនផ្ទៀងផ្ទាត់ កូនក្រុមនីមួយៗ ត្រូវប្រាប់មិត្តភក្តិក្រុមផ្សេងដោយបង្ហាញពីកូនកាសលេខ និងប្រាប់លេខ ។ បើករណីក្រុមណាធ្វើមិនទាន់បានត្រឹមត្រូវទេនោះ ឱ្យក្រុមដទៃជាអ្នកកែតម្រូវ ។
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារលេងទាំងអស់គ្នា (បើសល់ពេលអាចលេង២ឬ៣ដង)
- គ្រូ និងកុមារផ្ទៀងផ្ទាត់លទ្ធផលឱ្យបានគ្រប់ក្រុម ពេលលេងលើកទី១ ដោយឱ្យម្ចាស់ក្រុមបង្ហាញបណ្ណលេខ និងប្រាប់លេខ ហើយកុមារក្រុមដទៃជាអ្នកកែតម្រូវ រួចនាំកុមារអានលេខទាំងអស់គ្នា
- គ្រូលើកសរសើរចំពោះកុមារដែលធ្វើបានល្អ ចំពោះកុមារដែលធ្វើមិនទាន់បានល្អគ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? តើមុននេះ កូនៗបានលេងល្បែងអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិត អំពីមេរៀនល្បែង " ភ្លើងឆេះលើភ្នំ លេខពី៥ដល់១៣ "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត) គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុមនិងទាំងអស់គ្នា។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី៨

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

**ចលនាមូលដ្ឋាន៖ បោះ (បោះបាល់ចូលរាងការេ បោះបាល់ឬវត្ថុបន្តគ្នា និងបោះបាល់ឬវត្ថុឱ្យចំទិសដៅ)**

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបបោះបាល់ចូលរាងការេ, បោះបាល់បន្តគ្នា និងបោះបាល់ឱ្យចំទិសដៅ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារអនុវត្តសកម្មភាពចូលរាងការេ, បោះបាល់បន្តគ្នា និងបោះបាល់ឱ្យចំទិសដៅ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រឹងមាំ រហ័សរហួន បម្រុងប្រយ័ត្ន អំណត់ ព្យាយាម និងរីករាយ ។

**២. សម្ភារបង្រៀន៖** បាល់ធ្វើពីក្រដាស រឺបាល់ជ័រ

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុមរឺ៥ក្រុម ដោយក្នុង១ក្រុមមាន៥នាក់ រហូតអស់កុមារ

៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពបោះប៉េងប៉ោង ទៅលើចំនួន៥ដង
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាមូលដ្ឋាននីមួយៗ ដោយបោះបាល់ចូលរាងការេ, បោះបាល់បន្តគ្នា និងបោះ បាល់ឱ្យចំទិសដៅ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗ៖
    - ក្រុមទី១៖ បោះបាល់ទៅមុខ ឱ្យចូលរាងការេឱ្យដល់ទិសដៅដែលបានកំណត់
    - ក្រុមទី២៖ បោះបាល់បន្តគ្នាឱ្យដល់ទិសដៅដែលបានកំណត់
    - ក្រុមទី៣៖ បោះបាល់ឱ្យចំទិសដៅឱ្យដល់ទិសដៅដែលបានកំណត់
- បន្ទាប់ពីកុមារបានដើរតាមរបៀបខាងលើរួច គ្រូឱ្យក្រុមនីមួយៗប្តូរសកម្មភាពដើរតាមសញ្ញារបស់គ្រូ
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានដើរគ្រប់សកម្មភាព
- គ្រូសួរកុមារថា៖
    - តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
    - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ បោះបាល់ចូលរាងការេ, បោះបាល់បន្តគ្នា និងបោះបាល់ឱ្យចំទិសដៅ
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូ លើកទឹកចិត្តឱ្យចូល រួម បន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- កូនៗហត់ទេ? ដើម្បីឱ្យមានកម្លាំងឡើងវិញកូនធ្វើដូចម្តេច? (កុមារឆ្លើយថា "ត្រូវផ្លុំទឹកក្តៅ") ដូច្នេះ យើងនាំ គ្នាធ្វើកាយវិការផ្លុំទឹកក្តៅទាំងអស់គ្នា តោះ យកទឹកក្តៅមួយពែងមកកាន់ដៃពីរ ផ្លុំទឹកក្តៅវែងៗចំនួន៥ដង

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ) (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៨ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## សម្គាល់ៈ ខ្ពស់និងទាប

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីកម្ពស់ខ្ពស់ និងទាប បានត្រឹមត្រូវ។
- កុមារបង្ហាញពីកម្ពស់ខ្ពស់ និងទាប បានត្រឹមត្រូវ។
- កុមារឈ្លាសវៃ រហ័សរហួន ក្នុងការគិតបានហ្មត់ចត់ សហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** អង្គុយជាអក្សរ អ៊ុយ "ប" ចាប់ដៃគូ២នាក់

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

-គ្រូបំផុសសំណួរៈ

- កូនៗសង្កេតមើលរូបភាពនៅពីមុខកូនក្នុងថ្នាក់រៀនរបស់យើងយ៉ាងមិចដែរ?
- តើកូនដឹងទេថាថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វី?

-គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងៈថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាៈបុរេគណិត ចំណងជើងៈសម្គាល់ "ខ្ពស់ និងទាប"

- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់(តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូឬទេ? បើកូនណាឆ្លើយត្រូវគ្រូលើកសរសើរ បើកូនឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើក ទឹក ចិត្តឱ្យចូលរួមបន្តទៀត
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុមនិងទាំងអស់គ្នា
- គ្រូឱ្យកុមារ ២នាក់ឡើងមកឈរនៅមុខក្តារខៀនរួច គ្រូសួរទៅកុមារទាំងអស់ថា កូនសង្កេតមើលពួក ម៉ាក ដែលឈរ នៅពីមុខកូននេះយ៉ាងមិចដែរ?
- គ្រូឱ្យកុមារចាប់ដៃគូ២នាក់ៗទៅតាមការកំណត់របស់គ្រូ ហើយវាស់កម្ពស់ដោយខ្លួនឯងរួចប្រាប់ចម្លើយ មកគ្រូកូនណាម្នាក់ខ្ពស់កូនណាម្នាក់ទាបដោយពិនិត្យផ្ទៀងផ្ទាត់ទៅតាមដៃគូធ្វើរបៀបនេះរហូតដល់អស់ ដៃគូក្នុងក្រុម
- គ្រូឱ្យតំណាងក្រុមម្នាក់ៗផ្ទៀងផ្ទាត់លទ្ធផលដែលគេអនុវត្ត
- កូនពិនិត្យមើលតើនៅក្នុងថ្នាក់រៀនយើងមានវត្ថុអ្វីខ្ពស់ នឹងវត្ថុអ្វីទាប ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពកសាង៖ ដេរតាមទម្រង់រូបមួក

### ១. វត្ថុបំណង៖

- កុមារប្រាប់ពីរបៀបដេរតាមទម្រង់រូបមួក បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការដេរតាមទម្រង់រូបមួក បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ។

### ២. សម្ភារបង្រៀន៖

- គ្រូ៖ ផ្ទាំងរូបភាពមួកដែលបានដេររួចចំនួនមួយផ្ទាំង ,ផ្ទាំងរូបភាពមួកដែលមិនទាន់ដេរចំនួនមួយផ្ទាំង , អំបោះមួយដុំ ១
- កុមារ៖ ផ្ទាំងរូបភាពមួកគ្រប់ចំនួនកុមារដែលមានដាក់ថ្ងៃខែឆ្នាំអនុវត្ត មុខវិជ្ជាចំណងជើង មេរៀននៅលើសន្លឹកកិច្ចការ ,អំបោះមួយដុំៗ គ្រប់ចំនួនក្រុមកុមារ(១ក្រុម១ដុំ)

**៣.ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "U" រង្វង់ជា៣ក្រុម

### ៤.ដំណើរការបង្រៀន៖

- គ្រូបង្ហាញរូបមួកដែលបានដេររួចឱ្យកុមារប្រាប់ឈ្មោះនិងយករូបនោះបិទលើក្តារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូណែនាំពីរបៀបដេរតាមទម្រង់រូបមួកយឺតៗដើម្បីឱ្យកុមារងាយចាប់បាន
  - គ្រូឱ្យកូនលេងជាក្រុមតូចៗហើយក្រុមនីមួយៗ ត្រូវបាន«ផ្ទាំងរូបភាពមួកមួយសន្លឹកអំបោះមួយដុំ»
  - ដំបូងកូននាំគ្នាយកផ្ទាំងរូបភាពមួកមួយផ្ទាំងដាក់នៅចំកណ្តាល និងអំបោះមួយដុំក៏ដាក់ចំកណ្តាលរង្វង់ក្បែរគ្នាដែរ
  - បន្ទាប់មកកូនណាម្នាក់ក្នុងក្រុមយកអំបោះមួយដុំនិងផ្ទាំងរូបមួកហើយយកទៅដេរតាមទម្រង់រូបមួក ប៉ុន្តែមិនឱ្យដេរខុសថ្នេររូបមួកទេ គ្រូប្រាប់កុមារបណ្តើរធ្វើបង្ហាញបណ្តើរ ប៉ុន្តែការដេរតាមទម្រង់រូបមួក មិនចាំបាច់ដេរពេញសាច់របស់វាទេគ្រាន់តែដេរតាមទម្រង់រូបមួកទៅបានហើយ
  - ពេលកូននាំគ្នាដេរលើទម្រង់រូបមួក តាមក្រុមនីមួយៗត្រូវចេះរង់ចាំវេនធ្វើម្នាក់ម្តងៗកុំដណ្តើមគ្នាប្រយ័ត្នដេរខុស
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលបានរៀបចំ។
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារៈដែលគ្រូត្រៀមទុកអនុវត្ត
- គ្រូឱ្យកុមារក្នុងក្រុមនីមួយៗចាប់ផ្តើមអនុវត្តទាំងអស់គ្នាទៅតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមហើយជួយកែតម្រូវក្រុមណាដែលធ្វើមិនទាន់បាន
- គ្រូប្រាប់កុមារ៖បើក្រុមកូនណាធ្វើរួចហើយកូនយកទៅបិទលើការខៀនតាមកន្លែងដែលគ្រូកំណត់ឱ្យទៅតាមក្រុមនីមួយៗហើយពួកកូនត្រូវយកសម្ភារៈទៅទុកជូនគ្រូវិញនិងនាំគ្នាទៅអង្គុយនៅតាមក្រុមធំវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យតំណាងក្រុមទៅឈរនៅជិតរូបដែលបានបិទនៅលើការខៀន បន្ទាប់មកឱ្យកុមារក្រុមធំសង្កេតមើលរូបនោះដើម្បីឱ្យដឹងថា តើដេរតាមទម្រង់រូបមួកបានត្រឹមត្រូវទេ ?
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់នៅពេលផ្ទៀងផ្ទាត់មានក្រុមណាធ្វើមិនបានល្អគ្រូ

មិនត្រូវស្ដីបន្ទោសឡើយ ត្រូវចេះលើកទឹកចិត្តកុមារឱ្យខិតខំប្រឹងប្រែងបន្តទៀត
- គ្រូឱ្យតំណាងក្រុមនីមួយៗដកក្រូបចេញពីក្តារខៀនជូនគ្រូរួចគ្រូដាក់ឈ្មោះក្រុមសម្រាប់ទុកដាក់តាំងស្នាដៃកុមារ
- គ្រូសួរកុមារ៖ ថ្ងៃនេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី?អំពីអ្វី?
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះយើងនាំគ្នារៀនមកវិជ្ជាសិក្សាសង្គម អំពីសកម្មភាពកសាង«**ដេរតាមទម្រង់រូបម្ជុក**»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ បើមានកុមារទាយត្រូវលើកសរសើរដោយប្រើពាក្យសម្ដី
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមរួចទាំងអស់គ្នា។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## ល្បែង៖ សង្កេតរួចគូសវង់រូបដែលដូចគ្នា

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីឈ្មោះរូបភាពដែលដូចគ្នា បានត្រឹមត្រូវ
- កុមារ គូសវង់រូបដែលដូចគ្នាតាមរយៈការសង្កេត បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖**
- ផ្ទាំងរូបភាពសម្ភារផ្ទះបាយ ចំនួន៨ផ្ទាំង (៤ផ្ទាំងមានរូបភាពសម្ភារដូចជា ឆ្នាំង ចាន ស្លាបព្រា កាំបិត សម ចានដែក ជ្រុញ ខ្ទះ ។ រីឯ ៤ផ្ទាំងទៀតមានរូបភាពសម្ភារដូចជា៖ ឆ្នាំង ចាន ស្លាបព្រា កាបិត កំសៀវទឹក បំពង់ទឹកក្តៅ ជ្រុញ ខ្ទះ )

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ អក្សរ "ប" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូបង្ហាញផ្ទាំងរូបភាពម្តងមួយផ្ទាំងឱ្យកុមារសង្កេត ហើយសួរបំផុសកុមារថា៖ តើឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ? តើសម្ភារៈទាំងនេះ មាននៅកន្លែងណា? តើនៅផ្ទះរបស់កូនមានសម្ភារៈទាំងនេះនឹងដែរឬទេ?
- គ្រូផ្តាប់រូបភាពនោះនៅលើតុ ហើយឱ្យកុមារ២ ទៅ៣នាក់រៀបរាប់ពីអ្វីដែលបានឃើញអំបាញ់មិញ
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងដល់កុមារ ដោយនិយាយថា ថ្ងៃនេះគ្រូនាំកូនលេង គូសវង់រូបដែលដូចគ្នា នៅលើផ្ទាំងរូបភាពដែលកូនសង្កេតអំបាញ់មិញ។ តែដើម្បីលេងល្បែងនេះបាន គ្រូនឹងបែងចែកកូនជា៣ក្រុម ហើយផ្តល់ផ្ទាំងរូបភាពចំនួន២ផ្ទាំង និងខ្មៅដៃសម្រាប់គូសវង់(លើកបង្ហាញកុមារ)។ បន្ទាប់មកគ្រូនឹងទុកពេលឱ្យកូនពិភាក្សាគ្នា សង្កេតមើលរូបសម្ភារៈដែលដូចគ្នា ក្នុងរូបភាពទាំងពីរផ្ទាំង ដោយយកខ្មៅដៃគូសវង់ដើម្បីបញ្ជាក់ថាវាដូចគ្នា(ណែនាំបណ្តើរបង្ហាញពីរបៀបគូសបណ្តើរ)។ ក្រុមកូនៗណាដែលគូសរួចមុនគេ ត្រូវទះដៃចំនួន៣ដង ដើម្បីបញ្ជាក់ថាក្រុមរបស់ខ្លួនរួចរាល់ ។
- គ្រូចែកកុមារជាបួនក្រុមអង្គុយជុំវិញតុ ឬលើកន្ទេលជារាងរង្វង់ ហើយចែកផ្ទាំងរូបភាពក្នុង១ក្រុមចំនួន២ផ្ទាំង និងខ្មៅដៃសម្រាប់គូស
- គ្រូចាប់ផ្តើមឱ្យកុមារតាមក្រុមលេង និងដើរសម្របសម្រួល ពិនិត្យមើលការអនុវត្តរបៀបលេងតាមក្រុមនីមួយៗ

- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលម្តងមួយក្រុមៗ បន្ទាប់ពីកុមារតាមក្រុមពិភាក្សាគ្នាចប់
- គ្រូលើកសរសើរចំពោះ(ក្រុម)ដែលគូសបានត្រឹមត្រូវ ចំពោះក្រុមដែលគូសមិនទាន់បានត្រឹមត្រូវ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ
- គ្រូសួរបំផុសកុមារះ
  - •កូនៗទាំងអស់គ្នាសប្បាយទេ? តើមុននេះ កូនៗបានលេងល្បែងអ្វី?
  - •តើរូបសម្ភារណាខ្លះដែលដូចគ្នា?
  - •តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូបញ្ជាក់ប្រាប់កុមារបន្ថែមថាះ ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង "សង្កេត រួចគូសវង់រូបដែលដូចគ្នា"
- គ្រូនាំកុមារអានមុខវិជ្ជា ចំណងជើងមេរៀន ឡើងវិញ ២ ទៅ៣ដង។
-

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី៩

ម៉ោងទី១ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ ចិត្តចលភាព

**រំលឹក ចលនាចរន្ត៖ ដើរ រត់ លោត បោះ (ដើរបត់បែនតាមខ្សែ រត់ទៅរកទី លោតជើង២ទៅមុខ បោះបាល់ចូលកន្ត្រក )**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៤ ម៉ោងទី១)**

ម៉ោងទី ២ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ) (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៩ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ ភាសាខ្មែរ

**ល្បែង៖ ប្រព័ន្ធគ្រួសារម្ហូបអាហារ**

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីឈ្មោះម្ហូបអាហារដែលចូលចិត្ត បានត្រឹមត្រូវ
- កុមារកំណត់បានពីម្ហូបអាហារដែលគាត់ និងមិត្តភក្តិចូលចិត្ត បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឱ្យកុមារឈរជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូសួរបំផុសកុមារថា៖ តើកូនចូលចិត្តញ៉ាំម្ហូបអាហារអ្វីខ្លះ? តើម្ហូបអាហារនោះមានរសជាតិដូចម្តេច? ហេតុអ្វីបានកូនចូលចិត្តម្ហូបអាហារទាំងនោះ?
- គ្រូប្រាប់កុមារថា ថ្ងៃនេះ គ្រូនឹងនាំកូនលេងល្បែងមួយឈ្មោះថា ល្បែង គ្រួសារម្ហូបអាហារ។
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងដល់កុមារ ដោយនិយាយថា ដើម្បីលេងល្បែងនេះបាន កូនៗត្រូវឈរជារង្វង់ បន្ទាប់មកកូនត្រូវប្រាប់ឈ្មោះម្ហូបអាហារដែលកូនស្គាល់ ក្នុងម្នាក់មួយមុខ ឱ្យបានគ្រប់គ្នា។ ក្នុងកំឡុងពេលប្រាប់ឈ្មោះម្ហូបអាហារនោះ ប្រសិនបើមានកូនណា ប្រាប់ឈ្មោះម្ហូបអាហារដូចគ្នាទៅនឹងមិត្តរបស់កូនដែលប្រាប់រួចហើយ ឬប្រាប់ឈ្មោះខុស គឺត្រូវរំលងទៅឱ្យកូនបន្ទាប់ ប្រាប់បន្ត។

ក្រោយពីបញ្ចប់ការលេង គ្រូនឹងនាំកូនច្រៀង និងរាំលេងកម្សាន្ត។

- គ្រូឱ្យកុមារនិយាយឡើងវិញពីរបៀបលេង ហើយឱ្យកុមារឈរជារង្វង់
- គ្រូចាប់ផ្ដើមឱ្យកុមារតាមក្រុមលេង ដោយជួយសម្របសម្រួល ពិនិត្យមើលការអនុវត្តរបៀបលេង និងលក្ខខណ្ឌរបស់កុមារ
- គ្រូនាំកុមារច្រៀង រាំតាមចង្វាក់ភ្លេងជារង្វង់ បន្ទាប់ពីបញ្ចប់ការលេង
- គ្រូលើកសរសើរចំពោះកុមារដែលអនុវត្តរបៀបលេងបានត្រឹមត្រូវ ចំពោះកូនដែលអនុវត្តមិនទាន់បានត្រឹមត្រូវ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- គ្រូសួរបំផុសកុមារ៖
  - កូនៗទាំងអស់គ្នាសប្បាយទេ? តើមុននេះ កូនៗបានលេងល្បែងអ្វី?
  - តើម្ហូបអាហារអ្វីខ្លះដែលកូនបានឮនៅពេលលេងល្បែងអំបាញ់មិញ?
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូបញ្ជាក់ប្រាប់កុមារបន្ថែមថា៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង " គ្រួសារម្ហូបអាហារ"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### រំលឹក ល្បែង៖ ទាយលំដាប់អក្សរ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៤ ម៉ោងទី៤)

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ល្បែង៖ សួ សម្លកកូរ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីឈ្មោះបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរ បានត្រឹមត្រូវ
- កុមារកំណត់ឈ្មោះបន្លែ ត្រី សាច់និងសារៈសំខាន់នៃការញ៉ាំអាហារ បានត្រឹមត្រូវ
- កុមារស្រឡាញ់សុខភាព និងចូលចិត្តញ៉ាំអាហារមានគុណភាព។

**២. សម្ភារបង្រៀន៖** បណ្ណរូបភាពបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរ

**៣. ការរៀបចំកុមារ៖** គ្រូចែកកុមារជា២ក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបណ្ណរូបភាពបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរ ដោយបិទលើក្ដារខៀនជាជួរម្ដងមួយសន្លឹកទាល់តែ អស់បណ្ណទាំងនោះ
- គ្រូចង្អុលបណ្ណរូបភាពលើក្ដារខៀនម្ដងមួយៗឱ្យកុមារប្រាប់ឈ្មោះ ករណីកុមារមិនស្គាល់គ្រូត្រូវប្រាប់កុមាររួចនាំពួក គាត់ថាតាម និងដកបណ្ណរូបភាពទាំងនោះពីក្ដារខៀនវិញ
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង

- គ្រូឱ្យកូនឱ្យលេងជា២ក្រុម ដោយមួយក្រុមធ្វើជាបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរ និងមួយក្រុមទៀតធ្វើជាផ្ទាំង
- ក្រុមកូនធ្វើជាផ្ទាំងត្រូវកាន់ដៃគ្នាឱ្យអស់ពីដៃដោយឈរជារង្វង់
- ក្រុមកូនធ្វើជាបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរត្រូវឈរផ្តុំគ្នាជិតគ្រូហើយត្រូវបានបណ្ណរូបភាពបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរម្នាក់មួយសន្លឹក។ពេលកូនបានបណ្ណរូបភាពនោះហើយកូនត្រូវប្រាប់ពីឈ្មោះរូបភាពនៅក្នុងបណ្ណម្នាក់ម្តងៗ( ឧទាហរណ៍: ខ្ញុំឈ្មោះផ្លែត្រប់វែង ខ្ញុំឈ្មោះផ្លែល្ពៅ....)
- ពេលឮគ្រូនិយាយថា៖ "សម្លកកូរ" កូនត្រូវចាប់ផ្តើមលេងគឺក្រុមធ្វើជាផ្ទាំងត្រូវទំឡាក់ដៃចុះ។ឯក្រុមធ្វើជាបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរត្រូវរត់ជុំវិញផ្ទាំងចុះឡើងៗឱ្យឆ្ងាយពីផ្ទាំងកន្លះម៉ែត្រ
- ពេលឮគ្រូនិយាយថា៖ "សម្លជិតឆ្អិនហើយ" ក្រុមកូនធ្វើជាំផ្ទាំងត្រូវចាប់ដៃមិត្តភក្តិ
- បើក្រុមបន្លែត្រី សាច់ និងគ្រឿងផ្សំសម្លកកូរមានកូនណារត់ចូលមិនទាន់ទេនោះ ក្រុមនោះគឺជាអ្នកចាញ់ត្រូវប្តូរទៅធ្វើជាំផ្ទាំងវិញម្តង។ឯក្រុមបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរមកធ្វើជាផ្ទាំងវិញម្តង

- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រប់ ទេនោះត្រូវឱ្យមិត្តភក្តិដទៃជួយប្រាប់បន្ថែម បើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវប្រាប់សារឡើងវិញម្តងទៀត)
- គ្រូរៀបចំកុមារលេងដោយចែកកុមារជា២ក្រុម។មួយក្រុមកាន់ដៃគ្នាឈរជារង្វង់ទៅតាមទីដែលគ្រូកំណត់ និង១ ក្រុមទៀតឈរជាមួយគ្រូ
- គ្រូឱ្យកុមារ១នាក់ក្នុងក្រុមបន្លែ ត្រី សាច់ និងគ្រឿងផ្សំសម្លកកូរទៅយកសម្ភារមកចែកគ្នាម្នាក់ៗក្នុងក្រុម។ ពេលបាន សម្ភារគ្រប់គ្នាហើយគ្រូឱ្យកុមារម្នាក់ៗប្រាប់ពីឈ្មោះរូបភាពនៅក្នុងបណ្ណ
- គ្រូនាំកុមារលេងទាំងអស់គ្នា ពេលលេងនិងនាំកុមារផ្ទៀងផ្ទាត់លទ្ធផល។ លេងមួយជងផ្ទៀងផ្ទាត់មួយជងដោយ ផ្អែកទៅលើរបៀប និងលក្ខខណ្ឌនៃការលេង
- គ្រូនាំកុមារលេងរបៀបនេះរហូតដល់ម៉ោង។លេងចប់ឱ្យកុមារប្រមូលសម្ភារទុកវិញ
- គ្រូសួរកុមារ៖ អំបាញ់មិញកូននាំគ្នាស្លសម្លអ្វី?តើឆ្ងាញ់ឬទេ?ហេតុអ្វីមិនឆ្ងាញ់?ហេតុអ្វីបានឆ្ងាញ់? ដូច្នេះកូនៗ ជួយប្រាប់គ្រូបានទេអំបាញ់មិញយើងនាំគ្នារៀនពីមុខវិជ្ជាអ្វី?អំពីអ្វី?ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ
- គ្រូនិយាយថា៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពី សម្លកកូរ
- គ្រូសួរកុមារ៖ តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀតណា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

# ថ្ងៃទី១០

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលនាព

## ល្បែងចលនាៈ បោះអង្គញ់

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបបោះអង្គញ់ទៅមុខឱ្យចំកូនកោយ បានត្រឹមត្រូវ
- កុមារលេងល្បែង បោះអង្គញ់ចំកូនកោយ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្នក្នុងការទប់លំនឹងខ្លួន ម្ចាស់ការ និងសប្បាយរីករាយ ។

**២. សម្ភារៈបង្រៀនៈ** អង្គញ់(៥០គ្រាប់)

**៣. ការរៀបចំកុមារៈ** ចែកកុមារជាពីរក្រុមធំៗ(ក្នុងមួយក្រុមមានកុមារចំនួន៦នាក់)

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរ ចំនួន២ក្រុម
- គ្រូយកគ្រាប់អង្គញ់មកបង្ហាញកុមារ ហើយសួរថាៈ តើកូនស្គាល់ដែរឬទេ ថានេះជាគ្រាប់អ្វី? តើកូនធ្លាប់ឃើញគ្រាប់នេះនៅឯណា? តើគេយកវាសម្រាប់ធ្វើអ្វី?ចូរកូនទាយទៅមើលថា តើថ្ងៃនេះ គ្រូនឹងនាំកូនលេងល្បែងអ្វី ជាមួយនឹងគ្រាប់នេះ?
- គ្រូទទួលចម្លើយរបស់កុមារដោយការលើកទឹកចិត្ត
- គ្រូសម្របសម្រួលចម្លើយរបស់កុមារ និងប្រាប់កុមារថាៈបន្តិចទៀតនេះ គ្រូនឹងនាំកូនលេងល្បែងមួយឈ្មោះថាល្បែងបោះអង្គញ់
- គ្រូនាំកុមារធ្វើចលនាគ្រាប់តាមពូកងទ័ព (ឱ្យកុមារទម្លាក់ដៃឱ្យស្របនឹងដងខ្លួន ជើងស្តាំលើកឱ្យកែងនឹងដងខ្លួនរួចទម្លាក់ចុះ រួចលើកជើងឆ្វេងឱ្យកែងនឹងដងខ្លួន ធ្វើចុះឡើងម្តងស្តាំ ម្តងឆ្វេង ដៃបោះតាមការលើកជើង ម្តងស្តាំ ម្តងឆ្វេង ដោយឈរនៅមួយកន្លែង)
- គ្រូបង្ហាញទីតាំងដល់ក្រុមនីមួយៗ ដែលមានចម្ងាយ៣ ម៉ែត្រពីកន្លែងចាប់ផ្តើម ដល់កន្លែងទីកំណត់ដោយទីម្ខាងមានគំនូសចាប់ផ្តើម និងទីម្ខាងទៀតមានគំនូសបញ្ចាក់ មុននឹងណែនាំពីរបៀបលេង
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង រួមមានៈ ដើម្បីលេងល្បែងនេះបាន កូនៗត្រូវចែកគ្នាជា២ក្រុមដែលមានសមាជិកស្មើៗគ្នា ហើយឈរចម្ងាយឃ្លាតពីគ្នាចំនួន៣ម៉ែត្រ។ គ្រាប់អង្គញ់ដែលលេងគឺមានចំនួន ៥០គ្រាប់ ដោយក្រុមនីមួយៗនឹងទទួលបានចំនួន១០គ្រាប់ ដើម្បីយកដាំធ្វើជាកូនកោយជាជួរ ហើយគ្រាប់អង្គញ់ដែលនៅសល់ត្រូវប្រើសម្រាប់បោះ។ មុននឹងចាប់ផ្តើមលេង តំណាងក្រុមនីមួយៗត្រូវប៉ាវរកអ្នកឈ្នះដើម្បីបានបោះមុនគេ។ ក្រុមកូនៗដែលឈ្នះចាប់ផ្តើមបោះអង្គញ់ម្នាក់ម្តងៗ បន្តបន្ទាប់ដើម្បីផ្តួលកូនកោយនៅក្រុមម្ខាងទៀត។ ប្រសិនបើបោះអស់គ្រាប់អង្គញ់កូនៗក្រុមបោះ ត្រូវរាប់កូនកោយដែលដួល ។ បន្ទាប់មកឱ្យក្រុមដែលប៉ាវចាញ់បោះទៅវិញម្តង ហើយរាប់កូនកោយដែលដួល។ គ្រូនឹងពិនិត្យបើក្រុមណាសល់កូនកោយមិនរលំច្រើនជាងគេ គឺជាអ្នកឈ្នះ។
- គ្រូឱ្យកុមារ១ ឬ ២នាក់ និយាយឡើងវិញពីរបៀបនៃការលេងតាមដំណាក់កាល (បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូបែងចែកកុមារជាពីរក្រុមដែលមានសមាជិកស្មើៗគ្នា រួចនាំកុមារលេង និងជួយសម្របសម្រួលរបៀប

លេង និងពិនិត្យលើក្រុមណាធ្វើខុសលក្ខខណ្ឌ
- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ
- គ្រូនាំកុមារផ្តុំប៉េងប៉ោងដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃទាំងពីរធ្វើជាប៉េងប៉ោង ហើយផ្តុំដោយដកដង្ហើមចូល ចេញឱ្យវែងៗ ដល់ប៉េងប៉ោងធំហួតដល់បែកឮសូរផ្ទុង) គ្រូសួរកុមារថា តើកូនៗផ្តុំប៉េងប៉ោងសប្បាយទេ? កុមារឆ្លើយ គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្តែង ។
- គ្រូសួរកុមារថា៖ កូនៗទាំងអស់គ្នាសប្បាយទេ ? តើមុននេះ កូនៗបានលេងល្បែងអ្វី? តើកូនបានធ្វើចលនាអ្វីខ្លះ ក្នុងពេលលេងល្បែងនេះ? តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូបញ្ជាក់ប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា "បោះអង្គញ់"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ដែលបានទាយទៅនឹងអ្វីដែលគ្រូបានប្រាប់
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម
## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ) (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១០ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

### រំលឹក ល្បែង៖ បន្ថែមនិងបន្ថយចំនួនពី១ដល់១០
### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៤ ម៉ោងទី៤)

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម
### រឿងនិទាន៖ ចូលឆ្នាំខ្មែរ (និទាន)

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីខ្លឹមសា និងសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿង និងវិភាគតួអង្គនៅក្នុងរឿង បានត្រឹមត្រូវ

- កុមារយកចិត្តទុកដាក់ យកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារៈបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាបណ្តុំ ជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំនួរ៖ តើប៉ាម៉ាក់ធ្លាប់កូនទៅលេងពិធីបុណ្យអ្វីខ្លះ ?តើពិធីបុណ្យនោះគេធ្វើនៅឯណា ? តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអំពីអ្វី? គ្រូសរុបចម្លើយរបស់កុមារ
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា សិក្សាសង្គម ចំណងជើងរឿងនិទាន «ចូលឆ្នាំខ្មែរ »
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដោយសួរកុមារថា៖មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ? ដូចច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូប្រាប់ឈ្មោះអ្នកនិពន្ធ៖ រឿងនិទាននេះនិពន្ធដោយអ៊ុំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម
- គ្រូនិទានរឿងផ្ទាល់មាត់ឱ្យកុមារស្តាប់ ដោយលើកដាក់សម្លេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា៖
  - ចង្ហាន់៖ អាហារសម្រាប់សង្ឃ
  - ស្កប់ស្កល់៖ ឆ្អែតឆ្អន់ ឆ្អែតពេញចំណង់
  - ស្រង់ព្រះ៖ ពិធីស្រោចទឹកដោយអប់ផ្កាភ្លី
- គ្រូសួរកុមារ៖ក្រោយពីស្តាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើវណ្ណីនិងបងស្រីបាននាំគ្នាលេងល្បែងអ្វីខ្លះ?តើពួកគេសមុទ្រនៅពេលណា?ហេតុអ្វី?(កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញម្តងទៀត
- គ្រូឱ្យកុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្តិស្តាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំ)

**អត្ថបទរឿង«ចូលឆ្នាំខ្មែរ »**

ព្រឹកថ្ងៃអាទិត្យនេះ វណ្ណីគេងលក់យ៉ាងស្កប់ស្កល់។ យី! អ្វីមកចាំងភ្នែកខ្ញុំម្ល៉េះ! អូ! ពន្លឺព្រះអាទិត្យចាំងចូលតាម បង្អួច ខ្ញុំសុំងំបន្តិចទៀតសិន។ គួរឱ្យរំខានមែន! ទ្រនិចនាឡិកាពេទ៍ណឹងណុងងៗ ១ ណឹងណុងៗ ២ ណឹងណុងៗ ៣ ណឹងណុងៗ ៤ ណឹងណុងៗ ៥ ណឹងណុងៗ ៦ ណឹងណុងៗ ៧ ទ្រាំមិនបានទេម៉ោង៧ហើយ ខ្ញុំត្រូវតែភ្ញាក់។ វណ្ណី ភ្ញាក់ពីដំណេកទាញបន្ទឹងកម្រាលពូក រៀបចំខ្នើយ បត់ភួយ ឃើញមានខោអាវថ្មី ២សម្រាប់ នៅលើកៅអី។ វណ្ណីញញឹមដើរចេញទៅក្រៅបន្ទប់ឃើញទីធ្លាផ្ទះស្អាតខុសពីថ្ងៃធម្មតា។ នៅរានហាលខាងមុខផ្ទះ មានតុមួយរៀបចំយ៉ាងស្អាត ក្រាលកម្រាលពណ៌ស ដែលមានទៀនធូប បាយសី ផ្លែឈើ២ថាស ផ្តិលទឹកអប់ផ្កាម្លិះ និងថូផ្កា១គូ មានក្លិនក្រអូបឈ្ងុយ ឈ្ងប់។ វណ្ណីរត់ទៅផ្ទះបាយឃើញម្តាយ និងបងស្រីកំពុងរៀបចំម្ហូបដាក់ស្រាក់ ម្តាយនិយាយថា៖ វណ្ណី ឆាប់ទៅមុជទឹក ស្លៀកពាក់ ទទួលទេវតាឆ្នាំថ្មី ដល់ម៉ោងឥឡូវហើយកូន។ វណ្ណីឆ្លើយ ចាស ហើយរត់ទៅមុជទឹក ស្លៀកពាក់ខោអាវថ្មីតុបតែងខ្លួនយ៉ាងស្អាត រួចចេញទៅអុចធូបជាមួយក្រុមគ្រួសារទទួលទេវតាឆ្នាំថ្មី។ បន្ទាប់មកវណ្ណីកាន់ស្លាដក បងស្រី កាន់ស្រាក់ ម្តាយទូលកញ្ជើដាក់អន្សម និងផ្លែឈើដើរទៅវត្តនៅចុងភូមិ។ ល្ងាចថ្ងៃទី១នេះ បងស្រីកាន់ដៃវណ្ណីបណ្តើរគ្នាទៅលេងល្បែងប្រជាប្រិយនៅឯវត្ត។ វណ្ណីនិយាយទៅកាន់បងស្រីថា៖ បងមើលហ្ន៎! ពួកគេលេងល្បែងចោល

ឈូងក៏ សប្បាយ បោះអង្គញ់ក៏សប្បាយ ចាប់កូនខ្លែងក៏សប្បាយ តើយើងលេងល្បែងមួយណា? ប្អូនមើលទៅខាងនោះវិញមានក្មេងៗ ស្រករនឹងប្អូនកំពុងលេងល្បែងលាក់កន្សែង។ បងស្រីតបគ្រាន់តែក្រឡេកឃើញភ្លាម វណ្ណីព្រលែងដៃបងស្រី ហើយរត់ទៅសុំមិត្តភក្តិលេងជាមួយរហូតដល់ហត់នឿយត្រឡប់មកផ្ទះវិញ។ នៅពេលយប់កំពុងញ៉ាំអាហារជុំគ្នា ប៉ា បាននិយាយថា ៖ ថ្ងៃស្អែកជាថ្ងៃទី២ កូនៗ ត្រូវភ្ញាក់ពីព្រលឹមជួយរៀបចំម្ហូបអាហារម៉ាក់ និងយកវណ្ណាប់រួមទាំងលុយ កាក់ ទៅជូនលោកតាលោកយាយរបស់កូននៅឯដើមភូមិណា! ខានស្អែកជាថ្ងៃទី៣ កូនៗត្រូវទៅវត្តជាមួយប៉ាម៉ាក់យក ចង្ហាន់ប្រគេនព្រះសង្ឃ ពូនភ្នំខ្សាច់ ស្រង់ទឹកព្រះពុទ្ធរូបរួចទៅផ្ទះឯដើមភូមិស្រង់ទឹកជូនលោកតាលោកយាយ។ បងស្រី និយាយថា៖ តើកូនទាំង២ អាចស្រង់ទឹកជូនប៉ាម៉ាក់ ព្រមពេលលោកយាយ លោកតាបានឬទេ? ប្រាកដជាបានណា កូន! ប៉ាម៉ាក់ ឆ្លើយព្រមគ្នា។ ប៉ាម៉ាក់! បន្ទាប់ពីស្រង់ទឹកអ្នកមានគុណហើយ តើប៉ាម៉ាក់អាចជូនកូនទៅលេងសមុទ្របាន ឬទេ? គ្រាន់តែវណ្ណីសួរចប់ភ្លាម។ ក្រុមគ្រួសារនាំគ្នាទះដៃសើចយល់ព្រមតាមសំណើរបស់វណ្ណី។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

## ល្បែង៖ បំពេញតួអក្សរតាមចន្លោះពី ច ដល់ ណ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីតួអក្សរដែលបាត់នៅចន្លោះ ពី ច ដល់ ណ បានត្រឹមត្រូវ
- កុមារបំពេញតួអក្សរដែលបាត់ តាមចន្លោះពីច ដល់ណ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖**

- ផ្ទាំងក្រដាសតួអក្សរពី ច ដល់ ណ មួយផ្ទាំង
- ផ្ទាំងក្រដាសតួអក្សរពីច ដល់ ណ តែបាត់តួអក្សរខ្លះ នៅចន្លោះតួអក្សរទាំង២) ចំនួន៤ផ្ទាំង
- ស្កុត...

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរអ៊ុយ "ပ"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូលើកផ្ទាំងក្រដាសតួអក្សរពី ច ដល់ ណ មកបង្ហាញកុមារ ហើយបិតលើក្តារខៀន រួចនាំកុមារអាន
- គ្រូលើកផ្ទាំងក្រដាសតួអក្សរពី ច ដល់ ណ ដែលមានបាត់តួអក្សរខ្លះ នៅចន្លោះតួអក្សរទាំង២ បិតលើក្តារខៀន រួចនាំកុមារអាន ហើយសួរកុមារថា តើតួអក្សរនៅក្នុងផ្ទាំងក្រដាសនេះ ពេញលេញដែរឬទេកូនៗ? ដើម្បីឱ្យមានតួអក្សរពេញលេញ កូនត្រូវធ្វើដូចម្តេច? បន្តិចទៀត គ្រូនឹងឱ្យកូនបំពេញនូវតួអក្សរដែលបាត់ទាំងនោះ។
- គ្រូចាប់ផ្តើមណែនាំពីរបៀបលេងដល់កុមារថា ដើម្បីបំពេញតួអក្សរក្នុងចន្លោះក្នុងផ្ទាំងក្រដាសនេះ គ្រូនឹងចែកកូនជា៤ក្រុម ហើយក្រុមនីមួយៗទទួលបានផ្ទាំងក្រដាសតួអក្សរពី ច ដល់ ណា ដែលមានបាត់តួអក្សរខ្លះ(លើកបង្ហាញបណ្តើរ) មួយផ្ទាំង។ កូនៗក្រុមនីមួយៗត្រូវពិភាក្សាគ្នាបំពេញតួអក្សរដែលបាត់ឱ្យបានត្រឹមត្រូវ។ កូនៗក្រុមណាដែលបំពេញរួចត្រូវត្រូវទះដៃទាំងអស់គ្នាដើម្បីបញ្ជាក់ថាក្រុមរបស់ខ្លួនរួចរាល់។

- គ្រូរៀបចំកុមារជា៤ក្រុម អង្គុយជារង្វង់ជុំតុ ឬកន្ទេល រួចចែកផ្ទាំងក្រដាសតួអក្សរពី ជ ដល់ ណ តែបាត់តួអក្សរខ្លះ នៅចន្លោះតួអក្សរទាំង២ ដល់ក្រុមនីមួយៗ។
- គ្រូចាប់ផ្តើមឱ្យកុមារតាមក្រុមលេងទៅតាមការណែនាំ និងដើរសម្របសម្រួលការលេងតាមក្រុមនីមួយៗ
- គ្រូឱ្យក្រុមនីមួយៗយកលទ្ធផលតាមក្រុមមកបិតលើក្តារខៀន រួចនាំកុមារពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមក្រុម
- គ្រូលើកសរសើរ ចំពោះក្រុមកុមារដែលធ្វើបានត្រឹមត្រូវ ហើយចំពោះក្រុមដែលធ្វើមិនទាន់បានត្រឹមត្រូវ ត្រូវលើកទឹកចិត្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់ឡើយ។
- គ្រូសួរបំផុសកុមារថា៖
  - តើល្បែងដែលកូនលេងអំបាញ់មិញមានឈ្មោះអ្វី?
  - តើមេរៀនដែលកូនរៀនថ្ងៃនេះស្ថិតក្នុងមុខវិជ្ជាអ្វី? មេរៀនអ្វី?(កុមារឆ្លើយតាមគំនិតម្នាក់ៗ)
- គ្រូប្រាប់បញ្ជាក់កុមារបន្ថែមថា ថ្ងៃនេះយើងរៀន មុខវិជ្ជាភាសាខ្មែរ មេរៀនល្បែង បំពេញតួអក្សរនៅចន្លោះពី ច ដល់ ណ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

### រំលឹក ល្បែង៖ ចាក់ទឹកដូង

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៥ ម៉ោងទី៦)

**✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី១១

ម៉ោងទី១ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ ចិត្តចលភាព

ហាត់ប្រាណតាមបទចម្រៀង៖ សារិកាកែវពត់ប្រាណ

**( ដំណើរការបង្រៀនអនុវត្តដូចខែទី២ ថ្ងៃទី១៩ ម៉ោងទី១ )**

ម៉ោងទី ២ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២ )

* ទម្លាប់ល្អ៖ ត្រូវចូលគេងឱ្យបានទៀងទាត់ពេលវេលា

- **គ្រូសួរកុមារ៖**
  - ដើម្បីឱ្យកូនមានសុខភាពល្អ កូនត្រូវធ្វើដូចម្ដេចខ្លះ?
  - ក្រៅពីញ៉ាំផ្លែឈើ បន្លែ សាច់ តើកូនត្រូវធ្វើអ្វីទៀត?
  - ក្រៅពីកូនហាត់ប្រាណតើកូនត្រូវធ្វើអ្វីទៀត?

- ក្នុងមួយថ្ងៃកូនគេងប៉ុន្មានដង? គេងនៅពេលណាខ្លះ?
- **គ្រូប្រាប់កុមារបន្ថែម ៖** ពេលកូនគេងគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា គឺជួយមួយផ្នែកឱ្យកូនមានសុខភាពល្អ កូនត្រូវគេងមួយថ្ងៃពីរដង គឺនៅពេលកូនញ៉ាំបាយថ្ងៃត្រង់ហើយ កូនត្រូវនាំគ្នាគេងមួយដង នៅពេលយប់ គេងមួយដងទៀត។ ពេលញ៉ាំបាយថ្ងៃត្រង់ហើយកូនត្រូវនាំគ្នាគេង រួចទើបងើបឡើងងូតទឹកអោយស្អាតទើបកូនលេង ពេលយប់កូនត្រូវគេងពីម៉ោង 9:00 ទៅបើគេងយប់ជ្រៅពេកក៏មិនល្អដែរ។

* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១១ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ ភាសាខ្មែរ

**គំនូរ៖ គូសចម្លងតាមគំរូតួអក្សរ ញ ដ ណ**

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបគូសចម្លងតាមគំរូតួអក្សរ ញ ដ ណ បានត្រឹមត្រូវ
- កុមារ គូសចម្លងតាមគំរូតួអក្សរ ញ ដ ណ បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀន៖**

- បណ្ណតួអក្សរ ញ ដ ណ គំរូមួយសន្លឹក
- សន្លឹកក្រដាសមានសរសេរតួអក្សរ ញ ដ ណ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម

ហើយមាន ថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ

- ខ្មៅដៃសម្រាប់គូសម្នាក់១
- ស្កុតកាត់រួចជាស្រេច

៣. **ការរៀបចំកុមារ៖** អង្គុយជាបុគ្គល

៤. **ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណតួអក្សរ ញ ដ ណ ឱ្យកុមារប្រាប់ ដោយសួរកុមារថា៖ តើបណ្ណនេះមានតួអក្សរអ្វីខ្លះ? រួចគ្រូបិទបណ្ណតួអក្សរនោះលើក្ដារខៀន
- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរតួអក្សរ ញ ដ ណ ដែលមានស្នាមចុច ហើយបិទលើក្ដារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបសរសេរម្ដងមួយតួអក្សរៗ យឺតៗលើផ្ទាំងក្រដាសតួអក្សរដែលមានស្នាមចុចនោះ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្ដើរចាប់ពីកន្លែងចាប់ផ្ដើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថា បន្តិចទៀតគ្រូនឹងចែកក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្ដើរ) ។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូសតួអក្សរ ញ ដ ណ តាមស្នាមចុច ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវ ដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរតួអក្សរ ញ ដ ណ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារចាប់ផ្ដើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកបណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្ដារខៀន បន្ទាប់ពីគូសរួច
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្ដងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរនៅមុខមិត្តភក្ដិ ម្ដងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្ដិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់មិត្តភក្ដិដែលលើកបង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវនាំណែនាំមិត្តភក្ដិឱ្យចេះលើកសសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងជាក្រុម និងទាំងអស់គ្នា
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## ចម្រៀងៈ មេរៀនសង្កេត(ពេលទី១)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីអត្ថន័យ និងរបៀបធ្វើកាយវិការបទចម្រៀងមេរៀនសង្កេតបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងមេរៀនសង្កេតបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងបទចម្រៀង សហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ**

- ផ្ទាំងក្រដាសធំ សរសេរខ្លឹមសារបទចម្រៀងដើរ ឬដេកសម្រាប់បិទលើក្តារខៀន
- ស្កុត ហែកត្រៀមទុកជាស្រេច

**៣. ការរៀបចំកុមារៈ** អង្គុយជាអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀនៈ**

- គ្រូបំផុសសំណួរ ៖ នៅពេលដែលគ្រូលើករូបភាព តើគ្រូតែងតែឱ្យធ្វើអ្វីមុនគេ? ដូច្នេះកូនទាយទៅមើល ថាថ្ងៃនេះ គ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណង ជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារៈ ថ្ងៃនេះ គ្រូនឹងបង្រៀនកូននូវមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "មេរៀនសង្កេត"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថាៈ អម្បាញ់មិញ មានកូនៗ បានទាយត្រូវ ពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែល ទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់ និងសរសេរមុខវិជ្ជា និងចំណងជើងដាក់លើក្តារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូយកផ្ទាំងក្រដាសខ្លឹមសារចម្រៀងបិទលើក្តារខៀន រួចច្រៀង និងធ្វើកាយវិការឱ្យកុមារស្តាប់ និងមើល មួយចប់
- គ្រូនាំកុមារអានពាក្យពិបាកនៅក្នុងអត្ថបទចម្រៀងដែលគ្រូគូសសម្គាល់លើខ្លឹមសារផ្ទាំងអត្ថបទចម្រៀង (ចិញ្ចឹម បរិភោគ )ជាក្រុម និងទាំងអស់គ្នា រួចប្រាប់ពីអត្ថន័យរបស់ពាក្យទៅកាន់កុមារ និងនាំកុមារអាន តាមទាំងអស់គ្នាផងដែរ(-ចិញ្ចឹម មានន័យថា ថែទាំ ឱ្យចំណី - បរិភោគ មានន័យថាហូប ញ៉ាំ)។
- គ្រូសួរកុមារៈ កូនដឹងទេថា តើចម្រៀង"មេរៀនសង្កេត"នេះ ចង់និយាយពីអ្វី? បើកុមារមិនអាចឆ្លើយ បាន គ្រូត្រូវប្រាប់កុមារពីអត្ថន័យបទចម្រៀង ដោយប្រាប់កុមារថាៈ ចម្រៀងនេះមានន័យថា ពេលដែល កូនរៀនមេរៀនសង្កេត កូនត្រូវយកចិត្តទុកដាក់សង្កេតឱ្យបានល្អ មិនថាសង្កេតមាន់ ទា ឬជ្រូកឡើយ។
- គ្រូអានអត្ថបទចម្រៀងជាពាក្យរាយឱ្យកុមារស្តាប់ម្តងមួយឃ្លាៗ រួចឱ្យកុមារអានតាមម្តងមួយក្រុម រួច ទាំងអស់គ្នា
- គ្រូធ្វើសំឡេង ឡា ឡា ឡា ឡាៗៗៗ ទៅតាមចង្វាក់នៃបទចម្រៀងឱ្យកុមារស្តាប់ មួយចប់នៃបទចម្រៀង។
- គ្រូនាំកុមារធ្វើសំឡេង ឡា ឡា ឡា ឡាៗៗៗ ទៅតាមចង្វាក់នៃបទចម្រៀងដែលគ្រូបានធ្វើជាគំរូឱ្យស្តាប់ (ម្តងមួយក្រុមៗរួចទាំងអស់គ្នា) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀង ម្តងមួយឃ្លាៗ រហូតដល់ចប់បទចម្រៀង(ម្តងមួយ

ក្រុមរួចទាំងអស់គ្នាឱ្យបាន១ ឬ២ចប់)

- គ្រូច្រៀងតិចៗ ម្តងមួយឃ្លាៗ កុមារច្រៀងឮៗ ម្តងមួយឃ្លាៗតាមគ្រូ រហូតចប់បទចម្រៀង(ម្តងមួយក្រុម ឬទាំងអស់គ្នា) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសារឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

**ខ្លឹមសារ និងរបៀបធ្វើកាយវិការ**

+ អត្ថបទចម្រៀង៖ មេរៀនសង្កេត គ្រប់ប្រភេទមុខវិជ្ជា

សង្កេតមេរៀនកូនទា ចប់កាលណាចូលដល់កូនមាន់ ។

មាន់ទាមានពងដូចគ្នា តុកតតមាន់ទាមានពងដូចគ្នា កាបកាប

ចិញ្ចឹមជ្រូកផងយកសាច់បរិភោគ។

**+ របៀបធ្វើកាយវិការ៖**

- "មេរៀនសង្កេត គ្រប់ប្រភេទមុខវិជ្ជា" ធ្វើកាយវិការ លើកដៃស្តាំនឹងឆ្វេងឡើង ហើយយកម្រាមមេដៃ និងចង្អុលដៃប្រទាក់គ្នាដូចជារង្វង់គ្រប់ភ្នែក( ទាំងស្តាំ និងឆ្វេងដូចគ្នា) លើកដាក់ទៅលើភ្នែក ហើយ បន្ទាប់មកយកដៃឆ្វេងច្រត់ចង្កេះ រីឯដៃស្តាំបោះចង្អុលដៃទៅមុខហើយរលាស់ចុះឡើងម្តងទៅឆ្វេង ម្តងទៅស្តាំ ធ្វើជាកំពុងរៀបរាប់ពីអ្វីមួយ
- "សង្កេតមេរៀនកូនទា ចប់កាលណាចូលដល់កូនមាន់" ធ្វើកាយវិការលើកដៃស្តាំនឹងឆ្វេងឡើង ហើយ យកម្រាមមេដៃ និងចង្អុលដៃប្រទាក់គ្នាដូចជារង្វង់គ្រប់ភ្នែក( ទាំងស្តាំ និងឆ្វេងដូចគ្នា)ដោយងក់ ក្បាលបណ្តើរម្តងទៅឆ្វេងម្តងទៅស្តាំតាមចង្វាក់ចម្រៀង
- "មាន់ទាមានពងដូចគ្នា តុកតត"យកដៃឆ្វេងច្រត់ចង្កេះ រីឯដៃស្តាំបោះចង្អុលដៃទៅមុខហើយរលាស់ ចុះឡើង បន្ទាប់មកទាញដៃឆ្វេង និងស្តាំលាបាតដៃឱ្យត្រង់មកដាក់នៅសងខាងនៃមាត់ រួចច្រៀងថា តុកតត
- "មាន់ទាមានពងដូចគ្នា កាកាប"យកដៃឆ្វេងច្រត់ចង្កេះ រីឯដៃស្តាំបោះចង្អុលដៃទៅមុខហើយរលាស់ ចុះឡើង បន្ទាប់មកទាញដៃឆ្វេង និងស្តាំលាបាតដៃឱ្យត្រង់មកផ្តុំគ្នាផ្តេកហើយលើកទៅដាក់នៅខាង មុខមាត់រួចធ្វើចលនាដៃម្តងបិតម្តងបើកដូចជាចំពុះទា រួចច្រៀងថា កាបកា
- "ចិញ្ចឹមជ្រូកផងយកសាច់បរិភោគ" ធ្វើកាយវិការ យកដៃឆ្វេង និងស្តាំក្តាប់ ហើយលើកមកដាក់ជិត ច្រមុះ រួចទាញដៃឆ្វេងមកលាឱ្យត្រង់ យកម្រាមដៃស្តាំផ្តុំគ្នាដូចជាកញ្ចុំ ហើយចលនាធ្វើដូចចាប់ អាហារមកដាក់ក្នុងមាត់ ដោយយកកញ្ចុំដៃស្តាំ ដាក់លើបាតដៃឆ្វេង ហើយលើកមកដាក់មាត់។

ម៉ោងទី៩ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### សង្កេត៖ រដូវប្រាំង

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីអាកាសធាតុរដូវប្រាំង បានត្រឹមត្រូវ
- កុមារសង្កេតនិងរៀបរាប់បានពីអាកាសធាតុរដូវប្រាំង បានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ មានបម្រុងប្រយ័ត្ន ក្នុងការសង្កេតដោយភាពសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរអ៊ុយ "U" កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារ៖ កូនៗសង្កេតមើលតើរាល់ថ្ងៃនេះកូនដែលឃើញមានភ្លៀងធ្លាក់ដែរឬទេ? គ្រូបន្តសួរទៀត ឥឡូវកូនៗក្រោកឈរទាំងអស់គ្នាហើយមើលតាមបង្អួចទៅខាងក្រៅថ្នាក់រៀន តើស្លឹកឈើ ស្មៅ ដើមផ្កា មានសភាពដូចម្តេច? កូនៗនិយាយតាមគំនិតរបស់កូនៗម្នាក់ៗ
- គ្រូដាក់ផ្ទាំងរូបភាពរដូវប្រាំងនៅលើតុពីមុខកុមារ បន្ទាប់មកឱ្យកូនណាម្នាក់ឡើងមកយករូបភាពទៅបង្ហាញមិត្តភក្តិ ហើយឱ្យកូននាំគ្នាសង្កេតមើលថា អាកាសធាតុក្នុងថ្ងៃនេះយ៉ាងមិចដែរ? កូនសង្កេតទាំងអស់គ្នាដោយយកចិត្តទុកដាក់ ហើយពេលបន្តិចទៀតកូនចាំឆ្លើយប្រាប់គ្រូនិងមិត្តភក្តិ
- គ្រូសួរកុមារ៖ កូនដឹងទេថា គ្រូយកបណ្ណរូបភាពនេះមកឱ្យមកូនៗទាំងអស់គ្នាធ្វើអ្វី?
- គ្រូណែនាំជារួមដើម្បីឱ្យកុមារសង្កេតការងារតាមក្រុមតូចៗ ហើយតាមក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពនេះមួយផ្ទាំង
  - ពេលក្រុមកូននីមួយៗបានផ្ទាំងរូបភាពនេះហើយ កូនត្រូវដាក់កណ្តាលរង្វង់ ហើយនាំគ្នាសង្កេតមើលរូបទាំងនោះ ហើយពិភាក្សាគ្នាលើរូបនីមួយៗមានសភាពដូចម្តេច? ពេលកូននាំគ្នាសង្កេតកុំដណ្តើមគ្នា កុំដកផ្ទាំងរូបភាពនេះចុះឡើង បើកូនអង្គុយបញ្ច្រាសរូបត្រូវបង្វិលផ្ទាំងរូបភាពឱ្យត្រូវមិត្តភក្តិអាចមើលឃើញច្បាស់។ ហើយបើកូនណាស្គាល់ជួយប្រាប់មិត្តភក្តិដែលមិនស្គាល់ផង។ ហើយត្រូវយកមិត្តភក្តិណាម្នាក់ឡើងនិយាយប្រាប់ពីអ្វីដែលពួកកូនបានស្គាល់ ពេលកូនពិភាក្សាគ្នាចប់គ្រប់ក្រុមហើយ ត្រូវនាំគ្នាទៅអង្គុយនៅក្រុមធំវិញ ដោយយកសម្ភារទៅរៀងៗខ្លួន
- គ្រូឱ្យកុមារម្នាក់ឡើងនិយាយពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានទេឱ្យមិត្តភក្តិជួយបំពេញបន្ថែម ប៉ុន្តែបើនិយាយមិនបានពេញលេញទេនោះ គ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារៈទៅនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមទាំងអស់ដើម្បីជួយក្រុមណាដែលមិនទាន់យល់ច្បាស់
- គ្រូឱ្យកុមារទៅអង្គុយនៅក្រុមធំវិញដោយយកផ្ទាំងរូបភាពទៅវិញ ពេលក្រុមនីមួយៗអនុវត្តចប់ ហើយឱ្យតំណាងក្រុមឡើងរាយការណ៍
- គ្រូឱ្យតំណាងក្រុមនីមួយៗទៅនិយាយប្រាប់មិត្តភក្តិនឹងគ្រូពីលទ្ធផលដែលពួកគេបានពិភាក្សាគ្នា(ម្តង១ក្រុមៗ)ដោយលើកផ្ទាំងរូបភាពចង្អុលបង្ហាញរូបក្នុងរូបភាពរដូវប្រាំងម្តងមួយៗ
- គ្រូត្រូវកែតម្រូវពាក្យដែលពួកគេនិយាយមិនទាន់បានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ រួចនាំកុមារអាននៅពាក្យជាក្រុមនិងទាំងអស់គ្នា
- គ្រូសរុបពីលទ្ធផលរបស់កុមារគ្រប់ក្រុមបន្ទាប់ពីបានស្តាប់ពួកគេនិយាយចប់។
- គ្រូត្រូវផ្តល់ចំណេះដឹងថ្មីបន្ថែមតាមរយៈ៖ បង្ហាញផ្ទាំងរូបភាពឱ្យសង្កេតជារួម ឱ្យកុមារបានមើលឃើញទាំងអស់គ្នាបន្ទាប់មកគ្រូចង្អុលនិងប្រាប់ឈ្មោះរូប ឧទាហរណ៍ ៖ រដូវប្រាំង អាកាសធាតុក្តៅខ្លាំង ដើមឈើស្វិតស្រពោន...(កុមារអានជាក្រុម និង អានទាំងអស់គ្នា)
- គ្រូបំផុសសំណួរ៖ តើផ្ទាំងរូបភាពនេះគេប្រើសម្រាប់សម្គាល់អ្វី?បើកុមារមិនអាចឆ្លើយបានគ្រូត្រូវប្រាប់ ហើយនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា
- គ្រូយកផ្ទាំងរូបភាពនោះបិទលើក្តាខៀនរួចនាំកុមារអានឈ្មោះរដូវប្រាំង អាកាសធាតុក្តៅខ្លាំង ដើមឈើស្វិតស្រពោន ដោយគ្រូចង្អុលផង ប្រាប់ឈ្មោះផង

- គ្រូសួរកុមារៈ អម្បាញ់មិញកូនស្គាល់អ្វីខ្លះ ? ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជា វិទ្យាសាស្ត្រអំពី សង្កេត រជូរប្រាំង
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន( ជាក្រុមនិងទាំងអស់គ្នា២ឬ៣ដង )។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

# ថ្ងៃទី១២

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមរឿងនិទានៈ តាយាយនាំគ្នាទៅមើលស្រែ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបដើរ លោត រត់បោះ តាមខ្លឹមសារនៃរឿងនិទាន បានត្រឹមត្រូវ
- កុមារដើរ លោត រត់ បោះ តាមខ្លឹមសារនៃរឿងនិទាន បានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** ឈរជាជួរ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- គ្រូបំផុសសំនួរៈតើកូនធ្លាប់ទៅលេងសួនសត្វដែរឬទេ?តើសត្វខ្លាឃ្មុំមានរូបរាងដូចម្តេច?វាដើរយ៉ាងដូចម្តេច?
- គ្រូនាំកុមារទាំងអស់ធ្វើដំណើរត្រាប់តាមសត្វខ្លាឃ្មុំ ដោយក្តាប់ដៃទាំងពីរដាក់ត្រឹមដើមទ្រូង បន្ទន់ជង្គង់បន្តិច រួចដើរ ទៅមុខតិចៗ មួយៗអ៊ឹកអៀកៗ ដំណើរជើងបោះជំហានធ្ងន់ៗ (ដើរដល់ទីកំណត់រួចត្រឡប់មកកន្លែងដើមវិញ)
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន "តាយាយនាំគ្នាទៅមើលស្រែ"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូនាំកុមារធ្វើសកម្មភាពខ្លះៗទាក់ទងទៅនឹងខ្លឹមសាររឿងនិទាន ដោយនាំកុមារដើរទៅមុខ កាប់បោះ រត់ លោតលបៗ
- គ្រូចាប់ផ្តើមនិទានរឿងបណ្តើរនាំកុមារធ្វើសកម្មភាពបណ្តើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយមិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ (ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្តងទៀត)
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗហត់ទេ?បើហត់កូនទាំងអស់គ្នាផ្លុំប៉េងប៉ោងដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃទាំងពីរធ្វើជាប៉េងប៉ោង ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ ដល់ប៉េងប៉ោងធំហួតដល់បែកឮសូរផ្ទុង គ្រូសួរកុមារថាតើកូនៗផ្លុំប៉េងប៉ោងសប្បាយទេ? កុមារឆ្លើយ គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្តែង។

### អត្ថបទរឿងៈ តាយាយនាំគ្នាទៅមើលស្រែ

ពីព្រេងនាយមានតានិងយាយពីរនាក់ប្តីប្រពន្ធចិញ្ចឹមសត្វចំនួន ២ ទីណូកូនឆ្កែ និងម៉ាវៗកូនឆ្មា។ ថ្ងៃមួយតាយាយបានដើរមកមើលស្រែ ហើយទុកឱ្យ ទីណូ និងម៉ាវៗចាំផ្ទះ។ ពេលគាត់ដើរមកដល់ស្រែ បានឃើញស្រែគាត់មួយមានទឹកពេញ និងស្រែមួយទៀតមិនមានទឹកសោះ ពេលនោះតាក៏បានកាប់ដីទម្លាយភ្លឺស្រែដើម្បីបង្ហូរទឹក ដោយគាត់បានកាប់បោះៗជាច្រើនដងទើបធ្លាយទឹកចូលស្រែមួយទៀត ។ ចំណែកម៉ាវៗពេលតាយាយមិននៅ វាក៏បានលោត លបៗ ទៅយកត្រីអាំងស៊ី ពេលនោះទីណូឃើញក៏រត់យ៉ាងលឿនដេញចាប់ម៉ាវៗ។ ម៉ាវៗភ័យខ្លាំងក៏បានរត់ផង លោតផងទៅមុខយ៉ាងលឿន តែទីណូនៅតែតាមទាន់ទៀត ហើយក៏បានណែនាំអោយម៉ាវៗឈប់ធ្វើរបៀបនេះទៀត។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម
## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ត្រូវចូលគេងឱ្យបានទៀងទាត់ពេលវេលា (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១២ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ
## ពិសោធន៍៖ វត្ថុលោយក្នុងទឹក យឺត លឿន

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីឈ្មោះវត្ថុលោយក្នុងទឹកយឺត លឿន បានត្រឹមត្រូវ
- កុមាររៀបរាប់វត្ថុលោយក្នុងទឹកយឺត លឿន បានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់តាមដាននិងចូលរួមដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

- កែវថ្លាចំនួន ១៥ កែវ
- អំបិលគ្រួស ស្ករស ប៊ីចេង ដីឥដ្ឋ ទឹក

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "ប" និងក្រុមតូច

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូដាក់សម្ភារនៅលើតុមុខកុមារ(អំបិលគ្រួស ស្ករស ប៊ីចេង ដីឥដ្ឋ...)
- គ្រូអោយកុមារមួយនាក់ដែលស្ម័គ្រចិត្តមករើសសម្ភារៈនៅលើតុម្តងមួយៗដើម្បីបង្ហាញរួចឱ្យមិត្តភក្តិជាអ្នកប្រាប់ ឈ្មោះ បើកុមារមិនស្គាល់សម្ភារៈណាមួយទេគ្រូត្រូវប្រាប់កុមាររួចឱ្យកុមារថាតាម។
- គ្រូសួរកុមារ
  - តើសម្ភារទាំងអស់នេះគ្រូយកមកឱ្យកូនដើម្បីធ្វើអ្វីដែរ?
  - ពេលកូនយកសម្ភារទាំងអស់នេះទៅលេងជាមួយទឹក តើកូនសង្កេតឃើញវាយ៉ាងដូចម្តេចដែរ?
- គ្រូត្រូវសរសេរចម្លើយរបស់កុមារនៅគៀនក្តារខៀន ពេលកុមារឆ្លើយប៉ាន់ស្មានដើម្បីទុកទៀងផ្ទាត់។
- គ្រូណែនាំកុមារពីរបៀបអនុវត្តទៅតាមក្រុម
  - គ្រូអោយកូនលេងជាក្រុមតូចៗ ហើយក្នុងមួយក្រុមកូនត្រូវបានសម្ភារៈទាំងអស់នេះមួយឈុត
  - គ្រូប្រាប់កុមារ៖ កូនត្រូវយកសម្ភារៈទាំងអស់នេះទៅដាក់លើកណ្តាលរង់ បន្ទាប់មកកូនណាម្នាក់យកទឹកទៅចាក់ដាក់ក្នុងកែវ រួចហើយកូននាំគ្នាទម្លាក់សម្ភារៈទាំងនេះទៅក្នុងទឹកម្តងមួយៗ ដោយមិនដណ្តើមគ្នា ត្រូវចេះរង់ចាំវេន ធ្វើម្តងម្នាក់ៗ
  - កូនត្រូវនាំគ្នាសង្កេតសម្ភារៈទាំងអស់នោះនៅក្នុងកែវ តើសម្ភារៈនោះយ៉ាងដូចម្តេចដែរ?

- ពេលកូននាំគ្នាអនុវត្តធ្វើយ៉ាងណាកុំឱ្យកំពប់ទឹកពេញថ្នាក់ត្រូវនាំគ្នាប្រយ័ត្នទាំងអស់គ្នា។

- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តឡើងមកនិយាយប្រាប់ពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានត្រឹមត្រូវទេ ឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារៈទៅអនុវត្តការពិសោធន៍តាមក្រុម
- គ្រូឱ្យអនុវត្តការពិសោធន៍គ្រប់ក្រុមទាំងអស់នៅពេលតែមួយ
- គ្រូដើរសម្របសម្រួលទៅតាមក្រុមនីមួយៗនិងជួយបំផុសគំនិតបន្ថែមដើម្បីឱ្យធ្វើបានត្រឹមត្រូវ
- គ្រូឱ្យកុមារទៅអង្គុយនៅក្រុមធំវិញហើយនាំគ្នាយកសម្ភារៈទៅទុកឱ្យគ្រូវិញពេលគេធ្វើរួចគ្រប់ក្រុម
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ពីលទ្ធផលនៃការពិសោធន៍
- គ្រូសរុបលទ្ធផលរបស់កុមារគ្រប់ក្រុមតាមលទ្ធផលដែលពួកគេបានរាយការណ៍( ស្ពរស ប៊ិចេង រលាយក្នុងទឹកលឿន ចំណែកជីឥដ្ឋ អំបិលក្រួសរលាយក្នុងទឹកយឺត )
- គ្រូប្រាប់កុមារៈ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមកូនៗដែលបានរាយការណ៍ដូចនេះគ្រូយកសំភារៈទាំងនេះមកអនុវត្តជាមួយកូនម្តងទៀត
- គ្រូយកសម្ភារៈទាំងនោះមកដាក់នៅលើតុមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តមួយនាក់យកសម្ភារៈដាក់ក្នុងទឹកម្តងមួយៗរហូតដល់តែអស់សម្ភារៈ
- គ្រូនាំកុមារសង្កេតទាំងអស់គ្នា ពេលទម្លាក់សម្ភារៈមួយនាំកុមារសង្កេតម្តង ហើយផ្ទៀងផ្ទាត់ទៅនឹងចម្លើយពេលពិសោធន៍ដូចនឹងចម្លើយដែលបានពេលប៉ាន់ស្មានទុកមុន ដែលគ្រូបានសរសេរទុកលើក្តារខៀន
- គ្រូធ្វើរបៀបនេះទាល់តែអស់សម្ភារៈ
- គ្រូបូកសរុប និងសន្និដ្ឋានៈ
  - គ្រូប្រាប់កុមារៈ ស្ករស ប៊ីចេង រលាយក្នុងទឹកលឿន ចំណែកជីឥដ្ឋ អំបិលក្រួសរលាយក្នុងទឹកយឺត (នាំកុមារអានជាក្រុមទាំងអស់គ្នា)
  - គ្រូបញ្ជាក់ប្រាប់កុមារៈ ស្ករស ប៊ីចេង ជាវត្ថុរលាយក្នុងទឹកលឿនព្រោះគ្រាប់វាល្អិតតូច ចំណែកអំបិលក្រួស រលាយក្នុងទឹកយឺតព្រោះគ្រាប់វាធំ និងជីឥដ្ឋរលាយក្នុងទឹកយឺតព្រោះមានលក្ខណៈស្អិត (រួចនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា)
  - នាំកុមារអានពាក្យថ្មី និងពន្យល់អត្ថន័យនៃពាក្យលឿនមានន័យថាឆាប់រហ័ស ( រួចនាំកុមារអានជាក្រុមនិងទាំងអស់គ្នា)
  - ណែនាំកុមារពេលទៅផ្ទះវិញកូនកុំយកវត្ថុផ្សេងៗទៅទម្លាក់ក្នុងពាងទឹកដែលឪពុកម្តាយទុកប្រើប្រាស់ ហើយកុំទៅលេងទឹកបឹងស្ទឹងផ្តេសផ្តាសខ្លាចគ្រោះថ្នាក់ ម្យ៉ាងទៀតកូនត្រូវនាំគ្នាញ៉ាំទឹកឆ្អិន។
- គ្រូសួរកុមារៈ អម្បាញ់មិញកូននាំគ្នាធ្វើអ្វីខ្លះ? ដូច្នេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី?អំពីអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីពិសោធន៍ «វត្ថុរលាយទឹកយឺត លឿន»
- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារទៅនឹងការប្រាប់របស់គ្រូ។
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនិងទាំងអស់គ្នា)។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

## គំនូរ៖ គូររូបឆ័ត្រ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបគូររូបឆ័ត្រ បានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃគូររូបឆត្រដោយទប់លំនឹង បានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

+ **សម្ភារសម្រាប់គ្រូ៖**
- ផ្ទាំងក្រដាសដែលមានគូររូបឆត្រចំនួន១សន្លឹក
- ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)
- ខ្មៅដៃចំនួន១ដើម,ស្កុតចំនួន១ដុំ។

+ **សម្ភារសម្រាប់កុមារ៖** ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃគ្រប់ចំនួនកុមារ

**៣. ការរៀបចំកុមារ៖** អង្គុយរាងអក្សរអ៊ុយ "U"

-ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារ៖ តើនៅពេលកូនដើរកាត់ភ្លៀងកុំឱ្យទទឹកកូនត្រូវប្រើអ្វីខ្លះ?(ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសដែលមានគូររូបឆត្ររួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្តាខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹកទៀត ដែលគ្រូមិនទាន់គូររូបឆត្រឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសសនេះគ្រូទុកសម្រាប់គូរ ឱ្យកូនមើលពីរបៀបគូរ។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្តើមគូរពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាសនោះទៅបិទនៅលើក្តាខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបគូរ
- គ្រូណែនាំពីរបៀបគូរនៅលើផ្ទាំងក្រដាសសដែលបានបិទលើក្តាខៀន ដោយគូរបណ្តើរ និយាយប្រាប់កុមារបណ្តើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការគូរ។
- គ្រូណែនាំកុមារ៖
  - កូនយកខ្មៅដៃគូររូបឆត្រដោយចាប់គូរបន្ទាត់កោងពីក្រោមឡើងទៅលើ ពីឆ្វេងទៅស្តាំកោងពីលើចុះក្រោមប្រហែលពាក់កណ្តាលរង្វង់ រួចកូនគូររឹមជរដោយបន្ទាត់កោងចុះឡើងពីឆ្វេងមកស្តាំនៅផ្នែកខាងក្រោមឆត្រ បន្ទាប់មកកូនគូរឆ្អឹងឆត្រដោយទាញបន្ទាត់កោងពីកំពូលរឹមឆត្រឱ្យបានចំនួន៣ឬ៤បន្ទាត់ ហើយកូនគូរបន្ទាត់បញ្ឈរបន្តិចនៅចំកំពូល ចុងបញ្ចប់កូនគូរដងឆត្រដោយគូសបន្ទាត់ត្រង់ពីលើចុះក្រោមហើយកោងបន្តិចនៅផ្នែកខាងក្រោម(ដងឆត្រ) (តាមរូបគំនូរគំរូរបស់គ្រូជាក់ស្តែង)
  - បន្ទាប់មកកូនយកខ្មៅដៃកូនគូររូបឆ័ត្រឱ្យពេញលេញ

- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូរ ( តាមស្ថានភាពជាក់ស្តែង )
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- គ្រូទុកពេលឱ្យកុមារម្នាក់ៗអនុវត្ត ដោយដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃគូរ និងមិនទាន់យល់ពីរបៀបគូរ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារៈ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ( អ៊ុយ )វិញ ពេលកុមារគូរហើយគ្រប់គ្នា
- គ្រូ និងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់ៈ តើមិត្តភក្តិយើងគូរបានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

**ម៉ោងទី៨ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ បុរេគណិត

### គំនូរៈ គូរចម្លងតាមគំរូលេខ ៩ និងលេខ១០

**១. វត្ថុបំណងៈ**
- កុមារប្រាប់បានពីរបៀបគូរចម្លងតាមគំរូលេខ ៩និងលេខ១០ បានត្រឹមត្រូវ
- កុមារ គូរចម្លងតាមគំរូលេខ ៩និងលេខ១០ បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀនៈ**
- បណ្ណលេខ ៩ និង ១០ មួយសន្លឹកជាគំរូ
- សន្លឹកក្រដាសមានសរសេរលេខ ៩ និង១០ ដែលមានទុកចន្លោះសរសេរខាងក្រោម ហើយមានថ្ងៃខែឆ្នាំមុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- ខ្មៅដៃសម្រាប់គូសម្នាក់១
- ស្កុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារៈ** អង្គុយគូសជាបុគ្គល

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណលេខ ៩ និង១០ ឱ្យកុមារប្រាប់ ដោយសួរកុមារថាៈ តើបណ្ណនេះមានលេខអ្វីខ្លះ? រួចគ្រូបិទបណ្ណលេខនោះលើក្តារខៀន

- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរលេខ ៩ និង១០ ដែលមានទុកចន្លោះសរសេរខាងក្រោម ហើយបិទលើក្តារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបសរសេរម្តងមួយតួអក្សរៗ យឺតៗលើផ្ទាំងក្រដាសតួអក្សរដែលមានស្នាមចុចនោះ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្តើរចាប់ពីកន្លែងចាប់ផ្តើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថា បន្តិចទៀតគ្រូនឹងក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្តើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូរចម្លងតាមគំរូលេខ ៩ និង១០ នៅចន្លោះខាងក្រោម ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរលេខ ៩ និង១០ ដែលមានស្នាមចុច ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារចាប់ផ្តើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកបណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្តារខៀន
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្តងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរនៅមុខមិត្តភក្តិ ម្តងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្តិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់មិត្តភក្តិដែលលើកបង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវនាំណែនាំមិត្តភក្តិឱ្យចេះលើកសសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងជាក្រុម និងទាំងអស់គ្នាឡើងវិញ
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# កម្មវិធីសិក្សាខែទី៦

## កម្មវិធីសិក្សាប្រចាំខែទី៦ (១៩ថ្ងៃ)

| ម៉ោង | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ថ្ងៃទី៥ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ចលនាមូលដ្ឋាន៖ "បោះ"<br>- បោះបាល់ឬវត្ថុផ្តួលដបឬកំប៉ុង<br>- បោះបាល់ឬវត្ថុចូលកន្ត្រកចងព្យួរ<br>- បោះបាល់ឬវត្ថុចូលក្នុងកងឬរង្វង់ | ចលនាចរន្ត៖ "ដើរ-រត់-លោត-បោះ"<br>- ដើរលើជុំឥដ្ឋ<br>- រត់យកបាល់ទៅដល់ទី<br>- លោតចូលកង ឬរង្វង់<br>- បោះបាល់ចូលកន្ត្រក | ល្បែងចលនា៖ "បោះផ្តួលកូនកោយ" | ហាត់ប្រាណតាមបទចម្រៀង៖ "យើងអុំទូកលេង" | ហាត់ប្រាណតាមរឿងនិទាន៖ "បូណា និងនារីនាំគ្នាទៅលេងចម្ការស្វាយ" |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ចេះជួយធ្វើការការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ) | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ទ" | បុរេគណិត<br>សម្គាល់៖ ចំនួននឹងលេខពី ១ ដល់១៥ | ភាសាខ្មែរ<br>ល្បែង៖ ទាយឈ្មោះសកម្មភាពតាមកាយវិការ (រំលឹក) | វិទ្យាសាស្ត្រ<br>សង្កេត៖ សត្វទា | បុរេគណិត<br>ល្បែង៖ ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១០ ដល់១៥ |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ល្បែង៖ ទុំទាវ | សិក្សាសង្គម<br>រឿងនិទាន៖ "សត្វឈ្លូសសម្លាប់ខ្លា"(និទាន) | សិក្សាសង្គម<br>ចម្រៀង៖ "មេរៀនសង្កេត" (ពេលទី២) | សិក្សាសង្គម<br>គំនូរ៖ គូរសេរី | សិក្សាសង្គម<br>សកម្មភាពកសាង៖"ចាក់ស្លឹកដូងឬស្លឹកត្នោតធ្វើនាឡិកាដៃ" |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>ទស្សនាសង្កេត៖ "កន្លែងចិញ្ចឹមសត្វ" | ភាសាខ្មែរ<br>ល្បែង៖ "ទាយឈ្មោះសកម្មភាពតាមកាយវិការ" | វិទ្យាសាស្ត្រ<br>សង្កេត៖ "សត្វមាន់" | បុរេគណិត<br>សម្គាល់៖ "វែង ខ្លី" | ភាសាខ្មែរ<br>កំណាព្យ៖ "សួនសាធារណៈ" |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖"លោតមឹកម្រាមដៃ" | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី៦ | ថ្ងៃទី៧ | ថ្ងៃទី៨ | ថ្ងៃទី៩ | ថ្ងៃទី១០ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ចលនាមូលដ្ឋាន៖ "បោះ"<br>-បោះបាល់ឬវត្ថុផ្តួលដបឬកំប៉ុង<br>-បោះបាល់ឬវត្ថុចូលកន្ត្រ ចង្ក្រ<br>-បោះបាល់ឬវត្ថុចូលកងឬរង្វង់ (រំលឹក) | ចលនាចន្លេះ "ដើរ រត់ លោត បោះ"<br>-ដើរលើជុំគដ្ឋ<br>-រត់យកបាល់ទៅដាក់ទីកំណត់<br>-លោតចូលកងឬរង្វង់<br>-បោះបាល់ចូលកន្ត្រក (រំលឹក) | ល្បែងចលនា៖ "បោះផ្តួលកូនកោយ" (រំលឹក) | ហាត់ប្រាណតាមបទចម្រៀង៖ "យើងអុំទូកលេង" (រំលឹក) | ហាត់ប្រាណតាមរឿងនិទាន៖ "បូណា និងនារីនាំគ្នាទៅលេងចម្ការស្វាយ" (រំលឹក) |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀងបទ "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ត្រូវចេះជួយគ្នាពេលមានគ្រោះថ្នាក់ (នៅសាលារៀន នៅផ្ទះនិងនៅតាមភូមិ) | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖"ជ" | បុរេគណិត<br>ប្រៀបធៀប៖ "ខ្លីជាង វែងជាង" | | | |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ល្បែង៖"ភ្លៀងធ្លាក់" | សិក្សាសង្គម<br>រឿងនិទាន៖"មេអំបៅមួយគូ" (និទាន) | | | |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>ប្រៀបធៀប៖ "សត្វមាន់ និងសត្វទា" | ភាសាខ្មែរ<br>ល្បែង៖ "ប្រព័ន្ធគ្រួសារឈ្មោះម្ហូបអាហារ" | | | |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ "លោតមឹកម្រាមដៃ" (រំលឹក) | | | |

អនុវត្តតេស្តកុមារលើកទី២

| ម៉ោង | ថ្ងៃទី១១ | ថ្ងៃទី១២ | ថ្ងៃទី១៣ | ថ្ងៃទី១៤ | ថ្ងៃទី១៥ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ចលនាមូលដ្ឋាន៖ "គប់"<br>- គប់បាល់ឬវត្ថុផ្តួលកំប៉ុង<br>- គប់បាល់ឬវត្ថុឱ្យចំចំណុច<br>- គប់បាល់ឬវត្ថុយកចម្ងាយ | ចលនាចរន្ត៖ "ដើរ-រត់-លោត-គប់"<br>- ដើរកែងជើងទៅមុខ<br>- រត់ចុងជើងទៅមុខ<br>- លោតជើង២ទៅមុខ<br>- គប់វត្ថុយកចម្ងាយ | ល្បែងចលនា៖ "អោបចង្កេះ" | ហាត់ប្រាណតាមបទចម្រៀង៖ "លេងឈូង" | ហាត់ប្រាណតាមរឿងនិទាន៖ "ទីណូ ស្រួចនាំគ្នាទៅបេះផ្លែត្រសក់នៅចម្ការ" |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀងបទ "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ពេលឃើញអ្នកដទៃជ្រុះសម្ភារ ត្រូវរើសជូនពួកគាត់វិញ | | | | |
| ៨៖១០-៨៖៤០ | បុរេគណិត<br>ល្បែង៖"បង្កើតសំណុំចំនួនតូចៗពី ៥ ដល់១៥" | ភាសាខ្មែរ<br>ល្បែង៖ "គូសភ្ជាប់ពាក្យទៅនឹងអក្សរដែលរៀនរួច" (ន ប ផ ព) | វិទ្យាសាស្ត្រ<br>ល្បែង៖ "គូសភ្ជាប់សត្វទៅនឹងជម្រក" | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ន" | បុរេគណិត<br>ល្បែង៖ "បង្កើតសំណុំចំនួនតូចៗពី៥ដល់១៥" (រំលឹក) |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ចម្រៀង៖ "ជីតាខ្ញុំ"(ពេលទី១) | សិក្សាសង្គម<br>គំនូរ៖ "សត្វទា" | សិក្សាសង្គម<br>សកម្មភាពកសាង៖ "រៀបវត្ថុតូចៗលើរូបសត្វគោ" | សិក្សាសង្គម<br>ល្បែង៖ "ដាក់សញ្ញាតាង" | សិក្សាសង្គម<br>រឿងនិទាន៖ "ប្រាជ្ញាទីណូ" (អំណាន) |
| ៩៖២០-៩៖៥០ | ភាសាខ្មែរ<br>ល្បែង៖ "សង្កេតរករូបភាពដែលដូចគ្នា" | វិទ្យាសាស្ត្រ<br>ល្បែង៖ "គូសភ្ជាប់សត្វ ទៅនឹងចំណីអាហារ" | បុរេគណិត<br>ល្បែង៖ "ផ្គុំចំនួនរូបភាពទៅនឹងលេខពី១០ ដល់១៥" | វិទ្យាសាស្ត្រ<br>ល្បែង៖ "ធ្វើចំណាត់ថ្នាក់សត្វរស់នៅក្នុងទឹក លើគោក និងលើអាកាស" | ភាសាខ្មែរ<br>កំណាព្យ៖ "ត្រូវចេះញ៉ាំ" |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | ចិត្តចលភាព<br>ល្បែង៖ "លាក់ម្រាមដៃ" | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ "លាក់ម្រាមដៃ" (រំលឹក) |

| ម៉ោង | ថ្ងៃទី១៦ | ថ្ងៃទី១៧ | ថ្ងៃទី១៨ | ថ្ងៃទី១៩ |
|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | |
| ៧៖១០-៧៖៤០ | ចលនាមូលដ្ឋាន៖ "គប់"<br>- គប់បាល់ឬវត្ថុផ្តួលកំប៉ុង<br>- គប់បាល់ឬវត្ថុឱ្យចំចំណុច<br>- គប់បាល់ឬវត្ថុយកចម្ងាយ (រំលឹក) | ចលនាចន្លុះ៖ "ដើរ-រត់-លោត-គប់"<br>- ដើរកែងជើងទៅមុខ<br>- រត់ចុងជើងទៅមុខ<br>- លោតជើងពីរទៅមុខ<br>- គប់វត្ថុយកចម្ងាយ(រំលឹក) | ល្បែងចលនា៖ "បោះបាល់ប្រណាំងគ្នាឱ្យអស់ពីកន្ត្រក" | ហាត់ប្រាណតាមបទចម្រៀង៖ "លេងឈូក"(រំលឹក) |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀងបទ "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ត្រូវចេះជួយគ្នាពេលមានគ្រោះថ្នាក់ (នៅសាលារៀន នៅផ្ទះ និងនៅតាមភូមិ) | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>ល្បែង៖ "ឡុកឡាក់តាមតួអក្សរពី ក ដល់ ន " | វិទ្យាសាស្ត្រ<br>ល្បែង៖ "ធ្វើចំណាត់ថ្នាក់សត្វជើងបួន និងសត្វជើងពីរ" | បុរេគណិត<br>គំនូរ៖ "គូរចម្លងតាមគំរូលេង ១១" | ភាសាខ្មែរ<br>កំណាព្យ៖ "អ្នកគ្រូយើងអើយ" |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ចម្រៀង៖ "ជីតាខ្ញុំ"(ពេលទី២) | សិក្សាសង្គម<br>គំនូរ៖ "ផាត់ពណ៌រូបសត្វទា" | សិក្សាសង្គម<br>សកម្មភាពកសាង៖ "បត់រូបត្រី" | សិក្សាសង្គម<br>ល្បែង៖ "ដាក់សញ្ញាតាង" (រំលឹក) |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>ពិសោធន៍៖ "វត្ថុជ្រាបទឹក និងមិនជ្រាបទឹក" | បុរេគណិត<br>ល្បែង៖ "បំពេញលេខតាមចន្លោះពី ៥ ដល់ ១៥" | ភាសាខ្មែរ<br>គំនូរ៖ "គូរចម្លងតាមគំរូតួអក្សរ ណ ត ថ" | វិទ្យាសាស្ត្រ<br>សន្ទនា៖ "សត្វចិញ្ចឹមកូនដោយទឹកដោះ និងសត្វដែលចិញ្ចឹមកូនដោយចំណីអាហារ" |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

# ដំណើរការបង្រៀនតាមកម្មវិធី

# សកម្មភាពបង្រៀនប្រចាំខែទី៦
## ថ្ងៃទី១
ម៉ោងទី១ (រយៈពេល ៣០នាទី)
## មុខវិជ្ជាៈ ចិត្តចលភាព
**ចលនាមូលដ្ឋាន ៖ "បោះ" (បោះបាល់ឬវត្ថុផ្តួលដបឬកំប៉ុង បោះបាល់ឬវត្ថុចូលកន្ត្រកចងព្យួរ បោះបាល់ឬវត្ថុចូលក្នុងកងឬវង្វង់)**

**១. វត្ថុបំណង៖**
- កុមារប្រាប់ពីរបៀបបោះបាល់តាមការណែនាំ បានត្រឹមត្រូវ
- កុមារបោះបាល់មានលំនឹងតាមការណែនាំ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន អំណត់ ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បាល់ ដប/កំប៉ុង កន្ត្រក កង/វង្វង់ ខ្សែសម្រាប់ចងកន្ត្រក

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុម ឱ្យកុមារឈរជាជួរ ករណីកុមារច្រើនអាចចែកជា៦ក្រុម ដោយ២ក្រុមធ្វើ១សកម្មភាព

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូឱ្យកុមារឈរជាជួរ ទៅតាមទីកន្លែងដែលគ្រូបានកំណត់
- **គ្រូឱ្យកុមារធ្វើចលនាខ្យល់បក់** (ខ្យល់បក់តិចៗ ខ្យល់បក់ខ្លាំងៗ ទៅមុខ ទៅក្រោយ) ឥឡូវនេះកូនៗចាំធ្វើចលនាខ្យល់បក់តាមគ្រូទាំងអស់គ្នា កូនលើកដៃឡើងទៅលើ ពេលឮគ្រូប្រាប់ថាខ្យល់បក់តិចៗ កូនៗត្រូវរវេដៃទៅឆ្វេងរួចទៅស្តាំតិចៗ ពេលឮគ្រូប្រាប់ថាខ្យល់បក់ខ្លាំងៗ កូនៗត្រូវរវេដៃទៅឆ្វេងរួចទៅស្តាំខ្លាំងៗ ពេលឮគ្រូប្រាប់ថាខ្យល់បក់ទៅមុខ កូនត្រូវបោះដៃឱនទៅមុខមួយៗ ពេលគ្រូប្រាប់ថាខ្យល់បក់ទៅក្រោយ កូនត្រូវបោះដៃទៅក្រោយមួយៗ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាមូលដ្ឋាននីមួយៗ ដោយគ្រូបោះបាល់បង្ហាញតាមសកម្មភាពនីមួយៗ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗ៖
  - ក្រុមទី១៖ បោះបាល់ ឬវត្ថុផ្តួលដប ឬកំប៉ុង
  - ក្រុមទី២៖ បោះបាល់ ឬវត្ថុចូលកន្ត្រកចងព្យួរ
  - ក្រុមទី៣៖ បោះបាល់ចូលកង ឬវង្វង់
- បន្ទាប់ពីកុមារបានបោះបាល់តាមរបៀបខាងលើរួច គ្រូឱ្យក្រុមនីមួយៗប្តូរសកម្មភាពបោះបាល់តាមសញ្ញារបស់គ្រូ
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានធ្វើគ្រប់សកម្មភាព
- គ្រូសួរកុមារ៖
  - តើមុននេះ កូនៗបានធ្វើសកម្មភាពអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព អំពីៈ ចលនាមូលដ្ឋាន បោះ "បោះបាល់ឬវត្ថុ

ផ្តលដបឬកំប៉ុង បោះបាល់ឬវត្ថុចូលកន្ត្រកចងព្យួរ បោះបាល់ចូលកងឬរង្វង់ ”
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត )
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុមទាំងអស់គ្នា
- កូនៗហត់ទេ? ដើម្បីឱ្យមានកម្លាំងកូនធ្វើដូចម្តេច? (កុមារឆ្លើយហិតផ្កា) ហើយផ្កាអីក្រអូបជាងគេ? គេដាំនៅឯណា? ដើមវាទាប ឬខ្ពស់ ? ដូចនេះគ្រូនាំកូនទៅបេះផ្កាហិតដោយដកដង្ហើមវែងៗ (កូនៗយកដៃធ្វើសកម្មភាពបេះផ្កា យកមកដាក់ជិតច្រមុះរួចហិត ហើយដកដង្ហើមចូល ចេញឱ្យវែងៗ? កុមារឆ្លើយថាក្រអូប ) គ្រូឱ្យកុមារហិតផ្កាឱ្យបានពីរ ឬបីដងដោយដកដង្ហើមវែងៗ ។

### ម៉ោងទី២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និង ចម្រៀង "ជម្រាបសួរ"
* ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីរបៀបគួរសមជាមួយគ្រូពេលចូលថ្នាក់រៀន ឈ្មោះថ្ងៃ ខែ ឆ្នាំដែលកំពុងរៀន វត្តមាន និងអវត្តមានកុមារប្រចាំថ្ងៃ ពេលវេលាដែលត្រូវលាងដៃ និងសកម្មភាពដែលត្រូវរៀនក្នុងមួយព្រឹកបានត្រឹមត្រូវ
- កុមារកំណត់បានពីឈ្មោះថ្ងៃ ខែ ឆ្នាំដែលកំពុងរៀនចំនួនវត្តមាន និងអវត្តមានកុមារប្រចាំថ្ងៃ ពេលវេលាដែលត្រូវលាងដៃ និងសកម្មភាពដែលត្រូវរៀនក្នុងមួយព្រឹកបានត្រឹមត្រូវ
- កុមារសប្បាយរីករាយ យកចិត្តទុកដាក់ក្នុងការសង្កេតឈ្មោះ និងសហការជួយគ្នាទៅវិញទៅមក។

**២. សម្ភារបង្រៀន៖**
- បញ្ជីហៅឈ្មោះកុមារ.តារាងឈ្មោះថ្ងៃក្នុងសប្តាហ៍
- តារាងប្រតិទិនប្រចាំខែ.បញ្ជីឈ្មោះកុមារម្នាក់ៗ
- តារាងឈ្មោះខែទាំង១២ ( មករា...ធ្នូ )
- តារាងឈ្មោះឆ្នាំខ្មែរទាំង១២ ( ជូត...កុរ )
- តារាងខ្មៅដៃ ( បើមាន )

**៣. ការរៀបចំកុមារ៖** រៀបចំកុមារអង្គុយជាអក្សរអ៊ុយ "U"

**៤. ដំណើរការបង្រៀន៖ដំណាក់កាលទី ២**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូឱ្យកុមារក្រោកឈរទាំងអស់គ្នាលើកដៃសំពះជម្រាបសួរគ្រូពេលគ្រូដើរចូលក្នុងថ្នាក់
- គ្រូឱ្យកុមារឈរទល់មុខគ្នាពីរៗនាក់នៅតាមជួរ រួចច្រៀងបទ " ជម្រាបសួរ " ដើម្បីស្វាគមន៍មិត្តភក្តិ រួចឱ្យកុមារអង្គុយចុះវិញ
- គ្រូសួរកុមារថ្ងៃនេះថ្ងៃអ្វី ? ទីប៉ុន្មាន? ខែអ្វី? ឆ្នាំប៉ុន្មាន ? ឱ្យកុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ

- គ្រូឱ្យកុមារមួយនាក់មកអូសតារាងឈ្មោះថ្ងៃ ប្រចាំសប្តាហ៍ឱ្យចំថ្ងៃកំពុងរៀននិងប្រាប់ឈ្មោះថ្ងៃនោះ
- គ្រូឱ្យកុមារមួយនាក់មកចង្អុលឈ្មោះថ្ងៃម្សិលមិញ និងថ្ងៃស្អែក ក្នុងតារាងឈ្មោះថ្ងៃប្រចាំសប្តាហ៍ រួចប្រាប់ឈ្មោះថ្ងៃនោះ
- គ្រូឱ្យកុមារមួយនាក់ឡើងមកគូសវង់លេខថ្ងៃកំពុងរៀន នៅក្នុងតារាងប្រតិទិន និងប្រាប់ឈ្មោះលេខនោះ និងគូសខ្វែងថ្ងៃម្សិលមិញ រួចប្រាប់ឈ្មោះថ្ងៃនោះ
- គ្រូសួរកុមារ ថ្ងៃនេះថ្ងៃអ្វី ? ទីប៉ុន្មាន ?ខែអ្វី ? ឆ្នាំប៉ុន្មាន? បើកុមារឆ្លើយមិនត្រូវគ្រូប្រាប់ រួចនាំកុមារថាតាម ( ក្រុម ទាំងអស់គ្នា )
- គ្រូសរសេរឈ្មោះ ថ្ងៃ ខែ ឆ្នាំ លើក្តារខៀន រួចនាំកុមារអាន ដោយគ្រូជាអ្នកចង្អុលឱ្យចំតួអក្សរ( ជាក្រុម និងទាំងអស់គ្នា )
- គ្រូហៅនិងចែកបណ្ណឈ្មោះឱ្យកុមារម្នាក់ៗរួចប្រាប់កុមារ ( កូនយកបណ្ណឈ្មោះកូនម្នាក់ៗទៅពិនិត្យមើលដើម្បីចំណាំអក្សរ )
- គ្រូឱ្យកុមារម្នាក់ៗយកបណ្ណឈ្មោះរបស់ខ្លួនទៅដាក់ក្នុងតារាងឈ្មោះឱ្យកុមារតាមក្រុមនិងប្រាប់កុមារ ( កូនសង្កេតមើលពណ៌បណ្ណឈ្មោះដែលកាន់នៅដៃទៅផ្ទៀងពណ៌បណ្ណឈ្មោះនៅក្នុងតារាងឈ្មោះកុមារតាមក្រុម បន្ទាប់មកកូនផ្ទៀងឈ្មោះក្នុងបណ្ណដែលកាន់នៅដៃ ទៅនឹងឈ្មោះដែលមាននៅក្នុងតារាងឈ្មោះកុមារតាមក្រុម បើរាងដូចគ្នាកូនត្រូវស៊កចូលទៅក្នុងតារាងនោះដោយដាក់ស្របគ្នា
- ពេលកុមារយកឈ្មោះទៅដាក់ក្នុងតារាងឈ្មោះកុមារតាមក្រុមគ្រប់គ្នាហើយ គ្រូនាំកុមារផ្ទៀងផ្ទាត់ឈ្មោះកុមារម្តងមួយក្រុមៗ បើមានកុមារណាដាក់ខុស ត្រូវនាំគ្នាជួយកែតម្រូវ
- នាំកុមារផ្ទៀផ្ទាត់វត្តមាន និង អវត្តមានតាមក្រុមនីមួយៗដោយបញ្ជាក់ពីចំនួនវត្តមាន និង អវត្តមាន។ បើមានកុមារអវត្តមានត្រូវផ្ទៀងផ្ទាត់បណ្ណឈ្មោះកុមារដែលនៅសល់ទៅនឹងបណ្ណឈ្មោះនៅក្នុងតារាងឈ្មោះកុមារតាមក្រុម
- គ្រូបង្ហាញពីឈ្មោះកុមារអវត្តមាន ដោយប្រាប់ឈ្មោះ និងប្រាប់ពីមូលហេតុ។ បើករណីកុមារឈប់គ្មានច្បាប់ទេ គ្រូត្រូវអប់រំណែនាំដោយបញ្ជាក់ប្រាប់កុមារ ( បើសិនជាកូនឈប់ត្រូវសុំអនុញ្ញាតច្បាប់ពីគ្រូ មិនត្រូវឈប់ឥតដំណឹងទេ )គ្រូនាំកុមាររាប់ចំនួនកុមារវត្តមាន និង អវត្តមាន តាមក្រុម និងមួយថ្នាក់
- គ្រូចុះអវត្តមានកុមារនៅខាងលើជ្រុងក្តារខៀន និងចុះក្នុងសៀវភៅបញ្ជីហៅឈ្មោះទម្លាប់ល្អ
- គ្រូឱ្យកុមារម្នាក់ឡើងមកយកកូនកាសអាកាសធាតុ និងកូនកាសសម្គាល់ថ្ងៃឈប់ និងថ្ងៃរៀនដាក់ក្នុងតារាងខ្មៅដៃ ។ នាំកុមារផ្ទៀងផ្ទាត់ រគ្រូឱ្យកុមារម្នាក់ឡើងមកយកកូនកាសអាកាសធាតុ និងកូនកាសសម្គាល់ថ្ងៃឈប់ និងថ្ងៃរៀនដាក់ក្នុងតារាងខ្មៅដៃ រួច នាំកុមារផ្ទៀងផ្ទាត់ ទៅនឹងអាកាសធាតុជាក់ស្តែង និងរូបសម្គាល់ថ្ងៃរៀន និងថ្ងៃឈប់ បើកុមារដាក់ខុសត្រូវជួយកែតម្រូវ ( បើសិនគ្រូមានតារាងខ្មៅដៃទើបអនុវត្ត )
- គ្រូនាំកុមាររាប់ឈ្មោះខែទាំង១២ ( មករា...)និងឈ្មោះឆ្នាំខ្មែរទាំង១២ ( ជូត...កុរ ) ដោយគ្រូជាអ្នកចង្អុល។

**∗ ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)**

- គ្រូសួរកុមារ៖
  - នៅផ្ទះឪពុកម្តាយកូនមានដាំដំណាំឬទេ? ដាំអ្វីខ្លះ? មានចិញ្ចឹមសត្វដែរឬទេ? ចិញ្ចឹមសត្វអ្វីខ្លះ

ច្រើនឬតិច?

- តើកូនដែលបានជួយធ្វើអ្វីខ្លះ ពេលឪពុកម្ដាយកូនដាំដំណាំ?
- កូនខ្លះបើឪពុកម្ដាយមានចិញ្ចឹមសត្វ តើកូនបានជួយធ្វើអ្វីខ្លះ
- កូនសង្កេតមើលនៅក្នុងភូមិ តើលោកយាយ លោកតា អ៊ំមីងមារគាត់ធ្វើអ្វីខ្លះ? តើកូនធ្លាប់ទៅជួយធ្វើអ្វីខ្លះជាមួយពួកគាត់?
- នៅសាលារៀន តើមានកិច្ចការអ្វីខ្លះដែលកូនធ្លាប់ធ្វើជាមួយគ្រូ?

- គ្រូណែនាំកុមារបន្ថែម៖ ពេលកូនឃើញឪពុកម្ដាយ គ្រូ លោកតា លោកយាយ ពូមីង កំពុងតែធ្វើកិច្ចការអ្វីមួយ កូនត្រូវជួយធ្វើពួកគាត់ ទៅតាមអ្វីដែលពួកកូនអាចជួយធ្វើបានទៅតាមកម្លាំងរបស់កូនម្នាក់ៗមិនចាំបាច់ពួកគាត់ប្រើនោះទេ។

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## *សម្គាល់តួអក្សរ ៖ " ទ "*

**១វត្ថុបំណង៖**

កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ -"**ទ**" បានត្រឹមត្រូវ

កុមារកំណត់បានពីរូបរាងឈ្មោះអក្សរ - "**ទ**" និងរកពាក្យថ្មីផ្ដើមចេញពីអក្សរ "**ទ**" បានត្រឹមត្រូវ

កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្ដើមពីអក្សរ - "**ទ**" ។

**២សម្ភារបង្រៀន៖ .**

ផ្ទាំងរូបភាព -ទូ ទូក ទា

ប័ណ្ណពាក្យ -ទូ ទូក ទា និងល្បះ ទទាមុជទឹកទទះស្លាប

ប៊ិក ហ្វឺត -ស្កុត កាត់រៀបចំ)ឱ្យហើយ

**៣ការរៀបចំកុមារ៖ .** អង្គុយជាអក្សរ អ៊ុយ "U"

**៤ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "**ទូ**" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្ដាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន រួចបង្ហាញបណ្ណពាក្យ "**ទូ**" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**ទូក**" ដោយរលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយបើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន រួចបង្ហាញបណ្ណពាក្យ "**ទូក**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារម្នាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ទា**" រួចហើយឱ្យចូលថ្នាក់វិញ ហើយ

ខ្សឹបពាក្យ "**ទា**" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្តិៗ ពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ទា**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន ហើយបង្ហាញបណ្ណពាក្យ"**ទា**" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង

- គ្រូបង្ហាញឃ្លា "**ទទាមុជទឹកទទះស្លាប**" អានឱ្យកុមារស្តាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្តាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្តាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអំបាញ់មិញឮសូរដូចម្តេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

**+ ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នា (ពេលកុមារឡើងមកគូសវង់ជុំវិញអក្សរមានរាងដូចគ្នា បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារបានគូសវង់ដើម្បីផ្ទៀងផ្ទាត់ ។

**+ ប្រាប់ឈ្មោះតួអក្សរ៖**

- សួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួច ទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "**ទ**" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"**ទ**" យ៉ាងធំនៅជ្រុងក្តារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"**ទ**" នាំកុមារអានអក្សរ"**ទ**" (ក្រុមរួច ទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្តារខៀន រួចនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

**+ ប្រៀបធៀបអក្សរស្រដៀង៖**

- គ្រូសរសេរអក្សរ "ទ ឡ " នៅលើក្តារខៀន
- គ្រូអានអក្សរ "ទ ឡ " ឱ្យកុមារស្តាប់ និងសង្កេត

- សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ ? ហើយខុសគ្នាត្រង់ណាខ្លះ ?
- កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

**+ រកពាក្យថ្មីផ្ដើមពីអក្សរ"ទ"៖**

- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្ដាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្ដើមពីអក្សរ"ទ"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្ដារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- គ្រូនាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្ដងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"**ទ**" ឬទេ ? បើមានតួអក្សរក្នុងពាក្យដូចតួអក្សរ "**ទ**" នេះ កុមារត្រូវធ្វើសញ្ញា**បាទ/ចាស** (ដោយក្ដាប់ដៃស្ដាំលើកឡើងត្រឹមភ្នែក រួចធ្វើសញ្ញាបាទ/ចាស ដូចងក់ក្បាល) រួចគ្រូគូសវង់ជុំវិញពាក្យនោះ។ តែបើក្នុងពាក្យនោះមិនមានតួអក្សរ "**ទ**" ទេ កុមារត្រូវធ្វើសញ្ញា**ទេ** (ដោយលាដៃស្ដាំលើកឡើងត្រឹមភ្នែក រួចគ្រវី) ដោយគ្រូមិនត្រូវធ្វើអ្វីទាំងអស់ចំពោះពាក្យនោះ។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។
-

## ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ល្បែង៖ " ទុំទាវ "

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពី របៀបលេងល្បែងទុំទាវ បានត្រឹមត្រូវ
- កុមារអនុវត្តការលេងល្បែងទុំទាវ បានត្រឹមត្រូវ
- កុមារមានបំរុងប្រយ័ត្ន សហការរីករាយ និងមានភាពជឿជាក់រហ័សរហួន

**២. សម្ភារបង្រៀន៖** ក្រមាចងមុខ តូចវែងចំនួន ១

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារង្វង់ និងចាប់ដៃគូរ២នាក់ៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូរៀបចំកុមារឱ្យឈរជារង្វង់ ហើយជ្រើសរើសកុមារ២នាក់ ស្រី១ ប្រុស១ មកឈរនៅកណ្ដាលរង្វង់
- **គ្រូណែនាំពីរបៀបលេង៖**
  - គ្រូចងក្រមាមុខកុមារាហើយឱ្យឈ្មោះ ថា "ទុំ" ឯកុមារីគ្រូមិនចងក្រមាមុខទេ ហើយឱ្យឈ្មោះថា "ទាវ"
  - ពេលគ្រូឱ្យសញ្ញាកុមារាដែលចងក្រមាមុខស្រែកថា "ទាវ ទាវ" ហើយកុមារីស្រែកថា "ទុំ ទុំ" ស្របគ្នារួចកុមារាដេញចាប់កុមារីតាមទិសសំឡេងដែលបានឮ ឯកុមារីត្រូវព្យាយាមលោតគេចចេញតែមិនអោយរត់ទេ។
  - ពេល "ទុំ" ចាប់បាន "ទាវ" កូន២នាក់ទៀត ត្រូវមកលេងបន្ត
  - កូន "ទាវ" ដែលត្រូវ "ទុំ" ចាប់បាន ត្រូវចំណាំទុកដើម្បីទទួលការកំណត់ឱ្យធ្វើសកម្មភាពតាមក្រុមធំ (ដូចជាចម្រៀង ឬធ្វើត្រាប់តាមដំណើរសត្វ)
- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តនិយាយ របៀបលេងឡើងវិញពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនទាន់ច្បាស់ លាស់ទេ គ្រូត្រូវប្រាប់សារឡើងវិញៈ តើកូនណាអាចនិយាយរបៀបលេង ដូចគ្រូណែនាំ អម្បាញ់មិញប្រាប់មិត្តភ័ក្តយើងបានឬទេ ?

- គ្រូចាប់ផ្តើមដឹកនាំអនុវត្តការលេងសាកល្បងម្តង រួចឱ្យកុមារអនុវត្តយកមែនទែន
- គ្រូដើរសម្របសម្រួលដៃគូកុមារ និងជួយកែតម្រូវដៃគូកុមារណាដែលលេងខុស
- គ្រូឱ្យកុមារលេង រហូតដល់ម៉ោងដែលបានកំណត់
- គ្រូលើកសរសើរកុមារទាំងអស់គ្នា ដែលលេងសហការគ្នាបានល្អ និងរហ័សរហួន ហើយលើកទឹកចិត្តកុមារដែលលេងមិនទាន់បានល្អ
- គ្រូបំផុសរកចំណងជើង មេរៀន៖
  - ដូច្នេះថ្ងៃនេះ តើយើងរៀនពីមុខវិជ្ជាអ្វី មេរៀនអ្វី?

-គ្រូបញ្ជាក់ប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀន ដោយសរសេរលើក្តារខៀនបណ្តើរ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ទស្សនាសង្កេត៖ " កន្លែងចិញ្ចឹមសត្វ "

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីឈ្មោះសត្វគ្រប់ប្រភេទ បានត្រឹមត្រូវ។
- កុមារបង្ហាញពី ឈ្មោះ រូបរាងនិងផលប្រយោជន៍សត្វ បានត្រឹមត្រូវ។
- កុមារឈ្លាសវៃ រហ័សរហួន ច្នៃប្រឌិត សហការនិងថែរក្សាបរិស្ថាន។

**២. សម្ភារបង្រៀន៖** កន្លែងចិញ្ចឹមសត្វទៅតាមមូលដ្ឋាន

**៣. ការរៀបចំកុមារ៖** ជាបណ្តុំ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ៖
  - ថ្ងៃនេះមេឃស្រឡះល្អ តើកូនទាំងអស់គ្នាចង់ដើរលេងឬទេ?តើកូនចង់ទៅលេងនៅឯណា?
  - តើនៅផ្ទះកូនមានចិញ្ចឹមសត្វអ្វីខ្លះ?ហើយកូនស្គាល់សត្វអ្វីខ្លះ?
  - តើសត្វទាំងនោះចិញ្ចឹមនៅឯណា?
  - តើកូនចង់ទៅមើលវាជាមួយគ្រូឬទេ?បើកូនចង់ទៅមើលវា កូនត្រូវនាំគ្នាស្តាប់គ្រូ
- គ្រូណែនាំកុមារមុនពេលចេញដំណើរ៖
  - ពេលដើរនៅតាមផ្លូវកូនៗទាំងអស់គ្នាដើរខាងស្តាំដៃ ដើរជិតៗគ្រូកុំដើរលឿនទៅចោលគ្រូ កុំប្រឡែងគ្នា លេងនៅតាមផ្លូវ។ ហើយកូនមើលនៅតាមផ្លូវបើមានអ្វីៗកូនជួយប្រាប់គ្រូនិងប្រាប់មិត្តភក្តិយើងទៅវិញទៅមក។ បើកូនឃើញហើយមិនស្គាល់ទេនោះកូនត្រូវសួរគ្រូ
  - ពេលដើរទៅដល់កន្លែងចិញ្ចឹមសត្វកូនៗនាំគ្នាជម្រាបសួរម្ចាស់កសិដ្ឋាន ហើយកូនមិនត្រូវរញ៉េរញ៉ៃពេញកន្លែងចិញ្ចឹមសត្វទេ កូនត្រូវនាំគ្នាដើរមើលឱ្យមានសណ្តាប់ធ្នាប់ទើបជាកូនល្អ ។
- គ្រូឱ្យកុមារមកជុំគ្នារួចហើយក៏ធ្វើដំណើរចេញទៅកន្លែងចិញ្ចឹមសត្វ
- ពេលដើរតាមផ្លូវគ្រូត្រូវស្តាប់កុមារជជែកគ្នា ហើយបើគេនិយាយខុសគ្រូវកែលម្អភ្លាមប៉ុន្តែបើកុមារស្ងាត់ស្ងៀមមិននិយាយអ្វីសោះគ្រូត្រូវបំផុសសំណួរ(តើនៅតាមដងផ្លូវកូនឃើញអ្វីខ្លះ?)

- ពេលជិតទៅដល់កន្លែងចិញ្ចឹមសត្វគ្រូឱ្យកុមារឈប់ទាំងអស់គ្នាបន្តិចរួចប្រាប់កុមារឱ្យមើលទៅខាងមុខ តើឃើញ អ្វីខ្លះ? ឱ្យកុមារប៉ាន់ស្មានទាយ តាមគំនិតរបស់កុមារម្នាក់ៗ ដោយមិនគិតពីចម្លើយត្រូវឬខុសឡើយ
- គ្រូឱ្យកុមារធ្វើដំណើរបន្តទៀតដើម្បីឱ្យឆាប់ទៅដល់កន្លែងចិញ្ចឹមសត្វ
- ពេលទៅដល់កន្លែងចិញ្ចឹមសត្វ គ្រូនាំកុមារទាំងអស់ជម្រាបសួរ ម្ចាស់កសិដ្ឋាន រួចឱ្យកុមារប្រាប់ម្ចាស់កសិដ្ឋាន ថា៖ (ពួកខ្ញុំមកពីសាលាមត្តេយ្យសិក្សាសហគមន៍ភូមិ........)និងសួរម្ចាស់កសិដ្ឋាន ថា៖ (តើអ៊ំឈ្មោះអ្វីដែរ?ពួកខ្ញុំអាចសុំមើលសត្វផ្សេងៗដែលមាននៅក្នុងកសិដ្ឋានអ៊ំ បានដែរឬទេ?)ឱ្យកុមារអរគុណអ៊ំម្ចាស់កសិដ្ឋាន
- គ្រូនាំកុមារដើរចូលទៅក្នុង កសិដ្ឋាន និងប្រាប់កុមារឱ្យនាំគ្នាដើរមើលជុំវិញកសិដ្ឋាន តើកូនឃើញមានអ្វីខ្លះ?
- គ្រូប្រាប់កុមារពេលកូនដើរមើលនៅក្នុងកសិដ្ឋានកូនមិនត្រូវដេញចាប់ឬគប់សត្វទាំងនោះនៅក្នុងកសិដ្ឋានទេ ពេលកុមារមើលជុំវិញកសិដ្ឋានរួចហើយក៏ឱ្យកុមារមកជុំគ្នាហើយជួបជាមួយម្ចាស់កសិដ្ឋាន ដើម្បីឱ្យកុមារសួរគាត់ពីសត្វផ្សេងៗដែលមាននៅក្នុងកសិដ្ឋានទាំងអស់នោះ។
- ពេលកុមារមិនសូវចេះសួរគ្រូត្រូវបំផុសគំនិតឱ្យកុមារសួរទៅអ៊ំម្ចាស់កសិដ្ឋាន
- (ឧទាហរណ៍៖តើសត្វទាំងអស់នេះឈ្មោះអ្វីខ្លះ?តើអ៊ំចិញ្ចឹមវារបៀបដូចម្ដេច?ហើយរយៈពេលប៉ុន្មានខែប៉ុន្មានឆ្នាំទើបអ៊ំបានផល? តើអ៊ំថែទាំសត្វទាំងអស់ហ្នឹងដូចម្ដេច?ទើសត្វទាំងអស់នេះល្អនិងមិនងាប់? តើអ៊ំយកវាទៅលក់នៅឯណា? លក់ក្នុងមួយខែបានប៉ុន្មាន?ហេតុអ្វីបានជាអ៊ំចាំបាច់ត្រូវធ្វើទ្រុងដាក់វា?
- ពេលកុមារសួរអ៊ំ រួចហើយគ្រូឱ្យកុមារចូលរួមធ្វើការងារផ្ទាល់ជាមួយអ៊ំ ដូចជាដាក់ចំណីដាក់ទឹកឱ្យសត្វ
- បន្ទាប់មកគ្រូនាំកុមារលាងដៃ
- គ្រូនាំកុមារជម្រាបលាអ៊ំ ដើម្បីធ្វើដំណើរមកសាលារៀនវិញ។
- ពេលមកដល់សាលាវិញគ្រូឱ្យកុមារអង្គុយសម្រាកឱ្យបាត់ហត់បន្តិចសិន
- គ្រូបំផុសសំណួរ៖តើអំបាញ់មិញកូននាំគ្នាទៅណា?កូនឃើញអ្វីខ្លះ?ដូច្នេះកូនជួយប្រាប់គ្រូថាតើអំបាញ់មិញកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី?
- គ្រូប្រាប់កុមារ៖ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពីទស្សនាសង្កេត "កន្លែងចិញ្ចឹមសត្វ " ។តើមានកូនណាទាយត្រូវឬទេ?បើអញ្ចឹងកូននាំគ្នាទះដៃទាំងអស់គ្នាដើម្បីសរសើរមិត្តភក្តិយើងដែលបានទាយត្រូវ។
- ចំពោះកូនដែលទាយមិនត្រូវកុំអន់ចិត្តអី ព្រោះកូនក្លាហានហ៊ានឆ្លើយសំណួរគ្រូបាន
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន(ជាក្រុមនិងទាំងអស់គ្នា)។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

## ល្បែងសេរី

**✱ ល្បែងសេរី**

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបលេងល្បែងទៅតាមចំណង់ចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារជ្រើសរើសល្បែងលេងទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារ សប្បាយរីករាយ សហការគ្នាក្នុងការលេងមានចិត្តអំណត់។

**២. ការរៀបចំសម្ភារៈ** សម្ភារមាននៅតាមជ្រុងថ្នាក់រៀននិងក្រៅថ្នាក់

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជាអក្សរអ៊ុយ "ប" និងក្រុមតូច កុមារអង្គុយទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេម្នាក់ៗក្នុងថ្នាក់និងក្រៅថ្នាក់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារៈ កូនទាំងអស់គ្នាចង់លេងល្បែងឬទេ? បើកូនចង់លេង តើកូននាំគ្នាលេងល្បែងអ្វីខ្លះ? ដូច្នេះគ្រូនឹង ឱ្យកូនទាំងអស់គ្នាលេងទៅតាមចំណង់ចំណូលចិត្តរបស់កូន។
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាសិក្សាសង្គម អំពីល្បែងសេរី
- គ្រូឱ្យកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមនិងទាំងអងស់គ្នា
- គ្រូបង្ហាញសម្ភារល្បែងដែលមាននៅតាមជ្រុងឱ្យកុមារដឹងពីទីកន្លែងដែលកុមារត្រូវនាំគ្នាយកមកលេង
- គ្រូណែនាំកុមារមុនពេលលេង៖
  - គ្រូឱ្យកុមារទាំងអស់គ្នាយកសម្ភារដែលមាននៅក្នុងថ្នាក់រៀនលេងទៅតាមចំណង់ចំណូលចិត្តរបស់កូនម្នាក់ៗ ឬកូនអាចទៅលេងល្បែងនៅក្រៅថ្នាក់ក៏បាន
  - ពេលកូនយកសម្ភារទាំងនោះមកលេង កូនត្រូវចេះថែរក្សាសម្ភារទាំងនោះ ហើយពេលឈប់លេង កូនត្រូវមើលសម្ភារនោះឱ្យបានគ្រប់ចំនួនមិនឱ្យបាត់បង់ ទើបយកទៅទុកឱ្យមានសណ្តាប់ធ្នាប់នៅកន្លែងដើមវិញ
  - ពេលលេងកូនអាចលេងម្នាក់ឯងក៏បាន កូនអាចលេងជាមួយមិត្តភក្តិក៏បាន អាស្រ័យទៅតាមចិត្តរបស់កូន។ បើកូនលេងជាមួយមិត្តភក្តិ កូនត្រូវចេះចែកគ្នាលេងកុំដណ្តើមគ្នា កុំស្រែកឡូឡា ទើបជាកូនល្អ
  - ចំពោះទីកន្លែងដែលពួកកូនត្រូវលេងនោះអាចលេងនៅក្នុងថ្នាក់ក៏បាន លេងនៅក្រៅថ្នាក់ក៏បាន ស្រេចតែ ចិត្តពួកកូន។ បើកូនណាចង់លេងស្តរ ឬគោះកំប៉ុង កូនត្រូវលេងឱ្យឆ្ងាយពីមិត្តភក្តិ កុំឱ្យរំខានមិត្តភក្តិ
  - បើមានកូនណាមិនសូវចេះលេង ឬមិនចូលលេងនឹងគេនោះ កូនៗត្រូវជួយប្រាប់មិត្តភក្តិនិងនាំមិត្តភក្តិលេងផង
  - ពេលកូនឈប់ចង់លេង កូនត្រូវនាំគ្នាយកសម្ភារទៅទុកកន្លែងដើមវិញ រួចនាំគ្នាមកអង្គុយនៅក្រុមធំវិញ
  - គ្រូឱ្យកុមារស្ម័គ្រចិត្តមួយនាក់ និយាយពីអ្វីដែលគ្រូបានប្រាប់។ គ្រូគ្រូបំពេញបន្ថែមនូវអ្វីដែលកុមារ

និយាយមិនបានពេញលេញ

- គ្រូឱ្យកុមារលើកកៅអីទុកទៅខាង ម្តងមួយក្រុមៗរួចនាំគ្នាទៅយកសម្ភារមកលេង
- គ្រូឱ្យកុមារលេងតាមចំណង់ចំណូលចិត្តរបស់ពួកគេ
- គ្រូដើរសម្របសម្រួលកុមារលេងដើម្បីកែតម្រូវកុមារលេងខុសនិងជួយកុមារណាដែលមិនទាន់ចេញលេង
- ពេលកុមារលេងចប់គ្រូឱ្យកុមារយកសម្ភារទៅទុកដាក់ឱ្យមានសណ្តាប់ធ្នាប់នៅតាមកន្លែងដើមវិញ រួចឱ្យពួកគេ យកកៅអីមករៀបអង្គុយវិញ
- ពេលកុមារអង្គុយជុំគ្នាហើយ គ្រូឱ្យកុមារនិយាយប្រាប់ពីអ្វីដែលគេបានលេង និងគេស្គាល់អ្វីខ្លះ? ឱ្យកុមារនិយាយ ទៅតាមការយល់ដឹងរបស់គេ។ ចំពោះចំនួនកុមារដែលត្រូវនិយាយអាស្រ័យទៅតាមពេលវេលា។

* **រំលឹកមេរៀនប្រចាំថ្ងៃ៖** គ្រូសួរកុមារពីមេរៀនដែលបានរៀនក្នុងមួយព្រឹក ក្នុងករណីកុមារមិនអាចប្រាប់បានគ្រប់ គ្រូត្រូវប្រាប់បន្ថែម រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា។
* អនាម័យរៀបចំខ្លួនទៅផ្ទះ៖ គ្រូឱ្យកុមារលាងដៃ លុបមុខ សិតសក់ឱ្យស្អាតរួចរៀបចំកៅអីទុក និងតម្រង់ជួរទៅតាមក្រុម គ្រូណែនាំសណ្តាប់ធ្នាប់ពេលដើរតាមផ្លូវ ការគួរសមជាមួយមនុស្សពេលទៅដល់ផ្ទះ ការទុកដាក់សម្ភារ សកម្មភាពមុន និងក្រោយពេលញ៉ាំបាយ ...

## ថ្ងៃទី២

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ចលនាចរន្ត ៖ " ដើរ រត់ លោត បោះ" (ដើរលើដុំឥដ្ឋ រត់យកបាល់ទៅដល់ទី លោតចូលកងឬរង្វង់ បោះបាល់ចូលកន្ត្រក)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបធ្វើចលនា**ដើរ រត់ លោត បោះ** តាមលំដាប់លំដោយ បានត្រឹមត្រូវ
- កុមារធ្វើចលនា**ដើរ រត់ លោត បោះ** តាមលំដាប់លំដោយ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន សហការ អំណត់ ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ដុំឥដ្ឋ បាល់ កងឬរង្វង់ កន្ត្រក

**៣. ការរៀបចំកុមារ៖** ចែកកុមារជា៣ក្រុម ឱ្យកុមារឈរជាជួរតាមក្រុម (ធ្វើសកម្មភាពម្តង១ក្រុម ដោយធ្វើគ្រប់សកម្មភាពទាំងអស់)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរ ទៅតាមទីកន្លែងដែលគ្រូបានកំណត់
- គ្រូលើកសម្ភារបង្ហាញកុមារ រួចសួរថា តើនេះជាអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់គេ បើកុមារឆ្លើយខុស គ្រូសម្របសម្រួលចម្លើយដែលត្រឹមត្រូវ
- តើមានកូនៗណាខ្លះធ្លាប់ហែលទឹកឬទេ? ដូចនេះកូនទាំងអស់គ្នាធ្វើចលនាហែលទឹកជាមួយគ្រូ ដោយលើកដៃស្តាំបោះទៅមុខ ដៃឆ្វេងបោះទៅក្រោយ ដោយផ្លាស់ប្តូរគ្នាទៅមកដូចអ្នកហែលទឹកឱ្យបានច្រើនដង
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាទាំងអស់តាមលំដាប់លំដោយ ដោយគ្រូធ្វើសកម្មភាពបង្ហាញកុមារមុន
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- **គ្រូចែកកុមារជា៣ក្រុម ដោយក្រុមនីមួយៗត្រូវអនុវត្តគ្រប់សកម្មភាពទាំងអស់៖**
  - ក្រុមទី១៖ ដើរលើដុំឥដ្ឋ រួចរត់យកបាល់ទៅដល់ទីកំណត់ បន្ទាប់មកលោតចូលកងឬរង្វង់ និងចុងក្រោយយកបាល់បោះចូលកន្ត្រក តាមលំដាប់លំដោយបន្តបន្ទាប់គ្នារហូតអស់គ្រប់សកម្មភាព
  - ក្រុមទី២៖ ពេលក្រុមទី១ធ្វើចប់គ្រប់សកម្មភាពហើយ ក្រុមទី២ត្រូវបន្តធ្វើដូចក្រុមទី១ដែរ
  - ក្រុមទី៣៖ ពេលក្រុមទី២ធ្វើចប់គ្រប់សកម្មភាពហើយ ក្រុមទី៣ត្រូវបន្តធ្វើដូចក្រុមទី១ដែរ
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានធ្វើគ្រប់សកម្មភាព
- **គ្រូសួរកុមារ៖**
  - តើមុននេះ កូនៗបានធ្វើសកម្មភាពអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? អំពីអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព អំពី៖ ចលនាចរន្ត ដើរ រត់ លោត បោះ " ដើរលើដុំឥដ្ឋ រត់យកបាល់ទៅដល់ទីកំណត់ លោតចូលកងឬរង្វង់ បោះបាល់ចូលកន្ត្រក "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណា

ឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត )

- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- គ្រូនាំកុមារផ្លុំប៉េងប៉ោងដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃទាំងពីរធ្វើជាប៉េងប៉ោង ហើយផ្លុំដោយដកដង្ហើមចូល ចេញឱ្យវែងៗ ដល់ប៉េងប៉ោងធំរហូតដល់បែកឮសូរផ្ទុង) គ្រូសួរកុមារថាតើកូនៗផ្លុំប៉េងប៉ោងសប្បាយទេ? កុមារឆ្លើយ គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្តែង ។

ម៉ោងទី២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

### ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

### សម្គាល់ ៖ " ចំនួន និងលេខពី១ ដល់១៥ "

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំនួននិងលេខពី ១ ដល់១៥ បានត្រឹមត្រូវ
- កុមាររាប់ចំនួននិងលេខពី ១ ដល់១៥ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារឈ្លាសវៃ រហ័សរហួន ក្នុងការគិតបានហ្មត់ចត់ សហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

- បណ្ណចំនួនរូបភាពពី១ ដល់១៥ ចំនួន១៥ បន្ទះ
- បណ្ណចំនួនចំណុចពី១ ដល់១៥ ចំនួន១៥ បន្ទះ
- បណ្ណលេខ១ ដល់លេខ១៥ ចំនួន១៥ បន្ទះ
- ស្កុតក្រដាស់ ១ដុំ

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "ប" និងក្រុមតូច

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំនួរ៖ កូនៗណាអាចរាប់ចំនួនពី១ ដល់១៥?គ្រូឱ្យកុមាររាប់ចំនួនសម្ភារដែលមាននៅក្នុងថ្នាក់រៀន (រំយោលលេខឬវត្ថុផ្សេងៗ.. )
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀន៖ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជា បុរេគណិត មេរៀន "សម្គាល់ចំនួន និងលេខពី ១ ដល់ ១៥"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុមនិងទាំងអស់គ្នា
- ថ្ងៃនេះគ្រូមានសម្ភារជាច្រើន កូនចង់លេងទេ?

- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១ ដល់១៥ ឱ្យកុមារប្រាប់ចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយកទៅបិទនៅលើក្ដាខៀន រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១ ដល់១៥ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយកទៅបិទនៅលើក្ដាខៀនពីក្រោមចំនួនរូបភាព រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណលេខពី១ ដល់១៥ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកទៅបិទនៅលើក្ដាខៀនពីក្រោមចំនួនចំណុចពី ១ដល់១៥ រួចនាំកុមាររាប់
- គ្រូនាំកុមាររាប់ចំនួនរូបភាព ចំនួនចំណុចនិងលេខពី១ ដល់១៥ សារឡើងវិញម្ដងមួយៗ គ្រូណែនាំកុមារជាមុនសិនបានឱ្យក្រុមនីមួយៗអង្គុយជាក្រុមតូចៗ ដើម្បីរើសវត្ថុដែលមាននៅតាមជ្រុងសិក្សានីមួយៗ (តាមវត្ថុជាក់ស្ដែងដែលមានក្នុងបរិវេណថ្នាក់រៀន)
- គ្រូឱ្យកុមារក្រុមទី១ រើសវត្ថុចំនួន១ដល់៥
- គ្រូឱ្យកុមារក្រុមទី២ រើសវត្ថុចំនួន១ដល់១០
- គ្រូឱ្យកុមារក្រុមទី៣ រើសវត្ថុចំនួន១ដល់១៥

\+ ពេលកុមាររាប់រួច គ្រូឱ្យកុមារបង្ហាញតាមក្រុមនីមួយៗ និងសម្របសម្រួលផ្ទៀងផ្ទាត់។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## រឿងនិទានៈ សត្វឈ្លូសសម្លាប់ខ្លា (និទាន)

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីសកម្មភាពតួអង្គតាមដំណើររឿងបានត្រឹមត្រូវ
- កុមារនិទានរឿង និងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ស្ដាប់រឿង យកគំរូតាមតួអង្គល្អ សហការជួយគ្នា និងនិទានរឿងឱ្យមិត្តភក្ដិស្ដាប់

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** អង្គុយជាបណ្ដុំ ជាជួរ

**៤. ដំណើរការបង្រៀនៈ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូបំផុសសំនួរៈ គ្រូបង្ហាញក្របសៀវភៅរួចសួរកុមារថា កូនៗសង្កេតមើលមានរូបភាពអ្វីខ្លះ? តើរឿងនិទាននេះមានចំណងជើងដូចម្ដេច?(កុមារទាយតាមគំនិតពួកគេម្នាក់ៗ)គ្រូសរុបចំណងជើងដែលកុមារបានទាយហើយសួរថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី?
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា សិក្សាសង្គម ចំណងជើងរឿងនិទាន " សត្វឈ្លូស សម្លាប់ខ្លា " រួចសួរថា មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ?ដូចច្នេះកូនទះដៃសរសើរមិត្តភក្ដិយើងដែលដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- ប្រាប់ឈ្មោះអ្នកនិពន្ធៈ រឿងនិទាននេះនិពន្ធដោយអ៊ុំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម
- គ្រូនិទានរឿងដោយផ្ទាល់មាត់ឱ្យកុមារស្ដាប់ ដោយលើកដាក់សម្លេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា (ភ័យ,ប្រក់,មាំ..)៖

- ភ័យ ៖ ព្រួយ ខ្លាច បារម្ភ
- ប្រក់ ៖ បិទបាំងពីខាងលើ
- មាំ ៖ ដែលរឹងប៉ឹង ជាប់ស៊ប់

- គ្រូបំផុសសំនួរ ៖ តើរឿងនិទាននេះចង់និយាយអំពីអ្វី?
- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ម្តងទៀត
- គ្រូសួរកុមារថា ក្រោយពីកូនស្តាប់រឿងនេះចប់ តើនៅក្នុងរឿងនេះមានតួអង្គអ្វីខ្លះ? តើឈ្លូសទាំងបីឈ្លូសណាមានផ្ទះមាំជាងគេ? ហេតុអ្វី? តើក្នុងរឿងនេះតួអង្គណាដែលកូនស្រឡាញ់ជាងគេ?ហេតុអ្វី?
- គ្រូឱ្យកុមារនិទានឡើងវិញ។

**អត្ថបទរឿង " សត្វឈ្លូស សម្លាប់ខ្លា "**

ឈ្លូសមេមួយមានកូនបី។ កូនទីមួយឈ្មោះ ឈ្លូសបង។ កូនទីពីរឈ្មោះ ឈ្លូសប្អូន។ កូនទីបីឈ្មោះ ឈ្លូស ពៅ។ ឈ្លូសទាំងបួនរស់នៅក្នុងព្រៃយ៉ាងសុខសាន្ត។ ឈ្លូសមេនិយាយថា: ម៉ែចាស់ហើយ "ម៉ែចង់រកកន្លែងស្ងាត់ដើម្បីសម្រាក។ ចូរកូនរកស៊ីដោយខ្លួនឯងចុះ"។

ឈ្លូសបងខ្ជិលណាស់។ នៅពេលម្តាយវាឱ្យចំណី វាមិនដែលនិយាយថាអរគុណឡើយ។ ថ្ងៃមួយវានិយាយទៅកាន់ប្អូនៗថា: "ឥឡូវបងចង់សង់ផ្ទះមួយ។ ចូរឈ្លូសប្អូនទៅរកឈើ.វល្លិ៍មក។ ឯឈ្លូសពៅទៅរកកាប់ស្លឹកត្នោតនិងឬស្សីមក"។ នៅពេលធ្វើការឈ្លូសបងឥតជួយធ្វើអ្វីទាំងអស់។ ឈ្លូសពៅខំជីករណ្តៅ។ ឯឈ្លូសប្អូនដាំបង្គោល។ឈ្លូសទាំងពីរខំធ្វើការពុំហ៊ានសម្រាកឡើយ។ ឈ្លូសពៅយកស្លឹកប្រក់ដំបូលផ្ទះ។ ឯឈ្លូសបងអង្គុយធ្វើព្រងើយ។ មិនយូរប៉ុន្មានផ្ទះមួយបានសង់ហើយស្រេច។ ឈ្លូសបងចូលក្នុងផ្ទះដេកធ្វើបែបហី។ វាគ្មាននិយាយអរគុណទៅរកប្អូនឡើយ។ ចំណែកឈ្លូសប្អូនក៏បានសង់ផ្ទះមួយដែរ។ វាហៅឈ្លូសពៅឱ្យជួយធ្វើការ។

លុះផ្ទះសង់រួចហើយ ឈ្លូសប្អូនបណ្តេញឈ្លូសពៅឱ្យចេញក្រៅ។ វាទាញទ្វារបិទហើយចូលដេកធ្វើព្រងើយ។ឈ្លូសពៅបើកភ្នែកធំៗហាក់ដូចស្រឡាំងកាំង។

ឥឡូវនេះឈ្លូសពៅចាប់សង់ផ្ទះវាម្តង។ គ្មាននរណាជួយធ្វើការឱ្យឈ្លូសពៅឡើយ។ ឈ្លូសពៅប្រឹងធ្វើការណាស់។ ផ្ទះវាសង់អំពីឈើយ៉ាងមាំ ហើយល្អផង។

ឈ្លូសពៅស្លូតណាស់ហើយសុភាពផង។ នៅពេលម្តាយឱ្យចំណី ឈ្លូសពៅនិយាយ "អរគុណ "ជានិច្ច។

ថ្ងៃមួយខ្លានិយាយថា: "កូនឈ្លូសទាំងបីធំអស់ហើយ។ អញត្រូវទៅចាប់ឈ្លូសទាំងនោះយកមកធ្វើអាហារ "។

ខ្លាកាន់ដំបងធំមួយ ដើរសំដៅផ្ទះឈ្លូសបងមុនគេ។ ខ្លាដើរមកកាន់តែចិត្តឈ្លូសបងភ័យញ័រញ័រស្រែកហៅម្តាយឱ្យជួយ។ ប៉ុន្តែគ្មាននរណាមកជួយវាបានឡើយ។ ខ្លានិយាយថា "ឱ្យអញចូលផ្ទះនេះលេងផង"។ ឈ្លូសបងនិយាយថា: "ទេ! មិនបានទេ "។ ខ្ញុំឥតត្រូវការបងខ្លាឯងទេ។ ម្តាយខ្ញុំប្រាប់ថាបងខ្លាឯងស៊ីខ្ញុំ។ ខ្លានិយាយថា: "បើឯងមិនបើកទ្វារនេះទេ អញកម្ទេចផ្ទះឯងឥឡូវហ្នឹង!"។

និយាយមិនទាន់ផុតផង ខ្លាលោតទាំងកំពោលកម្ទេចផ្ទះឈ្លូសបង រលំក្រាំង។ ខ្លាចាប់ឈ្លូសបងញាត់ចូលក្នុងស្បោង។ ខ្លាដើរទៅរកផ្ទះឈ្លូសប្អូនទៀត។ ឈ្លូសប្អូនឃើញដូច្នោះភ័យញើរញ័រ។ ខ្លាស្រែកពីចម្ងាយឱ្យឈ្លូសប្អូនបើកទ្វារ។ ប៉ុន្តែឈ្លូសប្អូនពុំបើកទ្វារឡើយ។ វាពួនសំងំឈឹង។ ខ្លាខឹងណាស់ ក៏លោតសង្រ្គប់

បំផ្លាញផ្ទះឈ្លូសប្អូនបាក់ខ្ទេចខ្ទីអស់។ ខ្លាក៏ចាប់ឈ្លូសប្អូនដាក់ស្បោងហើយដើរទៅរកផ្ទះឈ្លូសពៅទៀត។

ខ្លាដើរមកដល់មុខផ្ទះឈ្លូសពៅ។ ឈ្លូសពៅស្ទុះទៅបិទទ្វារនិងបិទបង្អួចជិត។ ខ្លាហៅឈ្លូសពៅអោយបើកទ្វារ។ ប៉ុន្តែឈ្លូសពៅពុំបើកទ្វារឡើយ។ ខ្លាក៏លោតទន្រ្ទាំផ្ទះឈ្លូសពៅពេញទំហឹង។ ផ្ទះឈ្លូសពៅមិនរលំឡើយ។ ទន្រ្ទាំហើយ ទន្រ្ទាំទៀតផ្ទះឈ្លូសពៅមិនរលំឡើយ។ ខ្លាក្រឡេកមើលលើឃើញបំពង់បង្ហុយផ្សែងមួយ វាក៏ចូលតាមបំពង់ផ្សែងនោះដើម្បីចាប់ឈ្លូសពៅ។ ឈ្លូសពៅឃើញដូច្នោះក៏ស្ទុះទៅដុតភ្លើងពីក្រោម។ ភ្លើងឆាបឆេះរោលពេញខ្លួនខ្លា។មួយរំពេចនោះខ្លាក៏ប្រកាច់ងាប់ភ្លាមទៅ។

លុះខ្លានោះងាប់ហើយឈ្លូសពៅហៅឈ្លូសបងនិងឈ្លូសប្អូនឱ្យចេញពីស្បោង។ ឈ្លូសពៅប្រាប់ថាៈ ″ផ្ទះខ្ញុំមាំ ណាស់៉។ ខ្លាពុំអាចកម្ទេចផ្ទះខ្ញុំបានឡើយ។ ″ឥឡូវខ្ញុំសម្លាប់ខ្លាបានហើយ៉ ។ឈ្លូសបងនិងឈ្លូសប្អូនឮដូច្នោះត្រេកអរយ៉ាងខ្លាំង។ គេក៏ស្ទុះចេញពីស្បោងយ៉ាងប្រញាប់។ ចាប់តាំងពីពេលនោះមកឈ្លូសទាំងពីរខំប្រឹងធ្វើការណាស់។ គេលែងខ្ជិលទៀតហើយ។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

### ល្បែង៖ ៉ទាយឈ្មោះសកម្មភាពតាមកាយវិការ″

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះសកម្មភាពនិងរបៀបធ្វើកាយវិការ បានត្រឹមត្រូវ
- កុមារកំណត់ឈ្មោះសកម្មភាពនិងធ្វើកាយវិការ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ ៉ʋ″

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរសំណួរបំផុស តើព្រឹកឡើងកូនធ្វើអ្វីខ្លះ? កូនណាឡើងមកធ្វើសកម្មភាពនោះបាន?
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
  - គ្រូធ្វើកាយវិការ ហើយឱ្យកុមារទាយ
  - គ្រូសម្តែងធ្វើកាយវិការដោយឱ្យកុមារចាំមើលដូចជាកាយវិការដំណើរសត្វដំរី កាយវិការដំណើរសត្វទា កាយវិការដុសធ្មេញ កាយវិការសិតសក់...
  - ពេលគ្រូធ្វើកាយវិការ១សកម្មភាពចប់ផ្ទៀងផ្ទាត់ម្តង
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយ ពីរបៀបលេងឡើងវិញ(បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារអនុវត្តបន្តបន្ទាប់គ្នារហូតដល់អស់សកម្មភាពគ្រប់គ្នា គ្រូជាអ្នកសម្របសម្រួល
- គ្រូលើកសរសើរចំពោះអ្នកដែលអនុវត្តបានត្រឹមត្រូវតាមកាណែនាំ មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ

**-គ្រូសួរកុមារ៖**

- កូនៗទាំងអស់គ្នាសប្បាយទេ?តើមុននេះកូនៗបានលេងល្បែងអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- តើថ្ងៃនេះកូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែងមេរៀន "ទាយឈ្មោះសកម្មភាពតាមកាយវិការ"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។
-

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ល្បែង ៖ លោតមឹកម្រាមដៃ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបប្រើចលនាម្រាមដៃលោតមឹកបានត្រឹមត្រូវ
- កុមារស្គាល់រាងធរណីមាត្របានត្រឹមត្រូវ
- កុមារព្យាយាម អំណត់ ស្វាហាប់ ប្រុងប្រយ័ត្ន រហ័សរហួន ទន់ភ្លន់ និងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖** ដុំឈើសំប៉ែតតូច

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ អ៊ុយ "ប" កុមារអង្គុយនៅពីមុខគំនូស

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូគូរក្រឡាមឹកជារាងការេ និងចតុកោណកែង នៅលើទីដែលបានកំណត់
- គ្រូឱ្យកូន២នាក់អង្គុយនៅចំពីមុខគំនូសមឹក
- គ្រូសួរកុមារតើកូនដឹងទេថា ថ្ងៃនេះគ្រូនាំកូនលេងល្បែងអ្វី?កុមារឆ្លើយតាមគំនិតគេម្នាក់ៗ
- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា
- **គ្រូណែនាំពីរបៀបលេង**
  - ដំបូងគ្រូដាក់ដុំឈើសំប៉ែតតូចមួយនៅចំក្រឡាទី១ហើយកូនមិនត្រូវលោតចូលក្រឡាណាដែលដាក់មេនោះទេ
  - កូនត្រូវប្រើចង្អុលដៃនិងម្រាមកណ្តាលលោតជំនួសជើង
  - គ្រូឱ្យកូនប៉ាវរកអ្នកឈ្នះដើម្បីចាប់ផ្តើមមុនគេ ដោយដាក់ម្រាមកណ្តាលនៅលើទី
  - គ្រូឱ្យកូនលោតរំលងក្រឡាទី១ ដោយយកម្រាមកណ្តាលចូលក្នុងក្រឡាទី២តែម្តងព្រោះក្រឡាទី១ជាកន្លែងដែលយើងបោះមេ
  - គ្រូឱ្យកូនលោតពីក្រឡាទី២ចូលទៅក្រឡាទី៣ដោយប្រើម្រាមពីរគឺយកចង្អុលដៃដាក់នៅខាងឆ្វេងនិងចង្អុលកណ្តាលដាក់នៅខាងស្តាំ
  - គ្រូឱ្យកូនលោតពីក្រឡាទី៣ចូលទៅក្រឡាទី៤ដោយយកតែចង្អុលកណ្តាលមួយប៉ុណ្ណោះ
  - គ្រូឱ្យកូនលោតពីក្រឡាទី៤ចូលទៅក្រឡាទី៥ដោយយកចង្អុលដៃដាក់នៅខាងឆ្វេងនិងចង្អុលកណ្តាលដាក់នៅខាងស្តាំ
  - គ្រូឱ្យកូនលោតត្រឡប់មកទីវិញក្នុងដំណើរដូចមុន តែពេលលោតមកដល់ក្រឡាទី២កូនត្រូវ

យកចង្កុលដៃនិងមេដៃកៀបយកមេបោះហើយលោតផ្លោះក្រឡាទី១

- ពេលលោតមកដល់ទីហើយកូនត្រូវបោះមេចូលក្រឡាទី២ម្តង លោតចូលក្រឡាទី១ហើយផ្លោះចូលក្រឡាទី៣រួចបន្តដំណើរនិងវិលត្រឡប់ដូចលើកមុន ពេលកូនបោះមេទៅដល់ក្រឡាស្លាប(ឆ្វេង ស្តាំ)កូនត្រូវលោតដោយប្រើម្រាមតែមួយទេនៅលើក្រឡាស្លាបម្ខាងទៀតដែលពុំមានដាក់មេធ្វើរបៀបនេះរហូតគ្រប់ក្រឡា
- ពេលលេងបើកូនចាប់យកមេហើយធ្វើឱ្យជ្រុះកូននោះត្រូវផ្អាកសិន រួចឱ្យកូនជាដៃគូរធ្វើម្តងកូនណាធ្វើចប់មុនគេ ចាត់ទុកថាជាអ្នកឈ្នះ

- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តនិយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់បើនិយាយមិនទាន់ច្បាស់លាស់ទេត្រូវឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែមិនទាន់ពេញលេញនោះទេ គ្រូត្រូវនិយាយសារឡើងវិញម្តងទៀត
- គ្រូចាប់ផ្តើមឱ្យសញ្ញាដើម្បីក្រុមនីមួយៗប៉ាវរកអ្នកឈ្នះ
- ពេលក្រុមនីមួយៗរកបានអ្នកចាប់ផ្តើមហើយគ្រូឱ្យកុមារនាំគ្នាអនុវត្ត
- គ្រូដើរសម្របសម្រួលគ្រប់ក្រុមនិងជួយកែតម្រូវក្រុមណាដែលលេងខុស
- នៅពេលក្រុមនីមួយៗលេងដល់អ្នកចុងក្រោយគ្រូនឹងកុមារនាំគ្នាផ្ទៀងផ្ទាត់លទ្ធផលដើម្បីរកអ្នកឈ្នះនិងអ្នកចាញ់
- នាំកុមារលេងនិងផ្ទៀងផ្ទាត់របៀបនេះរហូតដល់ម៉ោង គ្រាន់តែលេងចប់មួយដងផ្ទៀងផ្ទាត់មួយដងនិងត្រូវប៉ាវរកអ្នកចាប់ផ្តើមសារជាថ្មីពេលលេងបន្ត។

# ថ្ងៃទី៣

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ល្បែងចលនា ៖ បោះផ្តួលកូនកោយ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបបោះផ្តួលកូនកោយ បានត្រឹមត្រូវ
- កុមារបោះផ្តួលកូនកោយ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្ន និងសប្បាយរីករាយ និងចេះអធ្យាស្រ័យគ្នា ។

**២. សម្ភារបង្រៀន៖** កូនបាល់សម្រាប់បោះ(ម្នាក់បាល់២) កូនកោយដែលមានពណ៌ខុសគ្នា(ពណ៌ក្រហម៥ និងបៃតង៥) សម្រាប់កោយ

**៣. ការរៀបចំកុមារ៖** ឱ្យកុមារលេងជាក្រុម

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជា២ជួរបណ្តោយនិងឱ្យកុមារឈរគម្លាតពីគ្នាសមល្មម និងងាយស្រួលក្នុងការសកម្មភាព
- គ្រូនាំកុមារធ្វើចលនាដើរបោះជើងឱ្យអស់ទៅមុខ រួចទៅក្រោយចុះឡើង ទាំងអស់គ្នា
- គ្រូបង្ហាញសម្ភារ ឱ្យកុមារសង្កេត ហើយសួរកុមារថា តើកូនឃើញមានសម្ភារអ្វីខ្លះ ?ចូរកូនទាយទៅមើល ថា តើគ្រូនឹងនាំកូនលេង ល្បែងអ្វី ជាមួយនឹងសម្ភារទាំងនេះ ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗ បានទាយត្រូវ ឈ្មោះល្បែងដែលត្រូវលេងក្នុងពេលនេះ។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែ កូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀត ណា!
- គ្រូប្រាប់កុមារថា៖ ល្បែងដែលយើងត្រូវលេង គឺ ល្បែងចលនា បោះផ្តួលកូនកោយ។ រួចនាំកុមារអាន ទាំងអស់គ្នា២ ទៅ៣ដង
- គ្រូបន្តណែនាំពីរបៀបលេង និងលក្ខខណ្ឌទៅក្រុមនីមួយៗថា គ្រូនឹងនាំកូនលេងល្បែងនេះជាក្រុម ដោយគ្រូនឹងចែកកូនជាពីរក្រុម ដែលក្នុងមួយក្រុមមានគ្នា៥នាក់ ហើយក្នុងម្នាក់ៗមានបាល់ចំនួន២។ កូនក្រុមទាំងពីរត្រូវឈរទល់មុខគ្នាជាជួរទទឹង ដែលមានចម្ងាយឃ្លាតពីគ្នាចំនួន ៦ម៉ែត្រ ហើយនៅចំ កណ្តាល មានដាំកូនកោយចំនួន១០ ដែលមានពណ៌ខុសគ្នា(៥ពណ៌ក្រហម ៥ពណ៌បៃតង)ដោយដាំ ឆ្លាស់ពណ៌គ្នា(កូនកោយពណ៌ក្រហម រួចពណ៌បៃតង រហូតអស់ទាំង១០គ្រាប់)។ កូនៗមួយក្រុមត្រូវ មានកូនកោយ ពណ៌ក្រហម ហើយកូនៗក្រុមមួយទៀតមានកូនកោយពណ៌បៃតង ។នៅពេលដែលគ្រូ ឱ្យសញ្ញាចាប់ផ្តើមទះដៃពីរដង កូនម្នាក់ៗនៅក្នុងក្រុមនីមួយៗ ត្រូវយកបាល់មកបោះផ្តួលកូនកោយ របស់ក្រុមខ្លួនឱ្យដួល។ បើក្រុមណាបោះដួលកូនកោយរបស់ក្រុមគេ ដូច្នេះក្រុមគេជាអ្នកចំណេញកូនកោ យ។ ហើយនៅពេលកូនម្នាក់ៗក្នុងក្រុមនីមួយៗ បោះអស់បាល់គ្រប់គ្នា ហើយត្រូវពិនិត្យមើលថា ក្រុម កូនណា ផ្តួលកូនកោយអស់ច្រើនជាងគេ គឺជាអ្នកឈ្នះ។ បន្ទាប់មកត្រូវប្តូរឱ្យក្រុមកូនៗដទៃទៀតបាន លេងម្តង។
- គ្រូឱ្យកុមារ ១ ទៅ២នាក់ និយាយឡើងវិញពីរបៀបលេង និងលក្ខខណ្ឌដែលគ្រូបានប្រាប់

- គ្រូចាប់ផ្ដើមនាំកុមារលេងទៅតាមរបៀបលេងដែលបានណែនាំរួច និងជួយសម្របសម្រួលពិនិត្យផ្ទៀងផ្ទាត់ការលេង
- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ
- គ្រូសួរកុមារថា៖ តើកូនហត់ដែរឬទេ? តើកូនស្រេកទឹកដែរឬទេ? គ្រូមានភេសជ្ជៈកូកាកូឡាត្រជាក់ដូច្នេះកូនចង់ផឹកដែរឬទេ? បន្ទាប់នាំកុមារធ្វើចលនាផ្ដុំទឹកតែក្ដៅ( យកម្រាមដៃឆ្វេង ធ្វើដូចជាកំប៉ុងទឹកកូកាកូឡា ម្រាមដៃស្ដាំធ្វើដូចជាគាស់ក្រវិលកំប៉ុងចេញ បន្ទាប់មកចលនាលើកដៃដែលធ្វើជាកាន់កំប៉ុងកូនកូកាកូឡា មកផឹកចូលក្នុងមាត់ចំនន៣ ក្អឹក ហើយហាមាត់ធ្វើដូចកឺរខ្យល់ចេញមកក្រៅឱ្យឮ)រួចគ្រូសួរកុមារថា តើកូកាកូឡាឆ្ងាញ់ដែរឬទេកូនៗ? បើឆ្ងាញ់ តោះយើងផឹកឱ្យអស់ទាំងអស់គ្នា។ គ្រូត្រូវប្រាប់កុមារបន្ថែមថា ទឹកកូកាកូឡា វាឆ្ងាញ់ តែវាមិនល្អសម្រាប់កូនៗទេបើកូនផឹកវាច្រើន។ ដូច្នេះកូនត្រូវផឹកវាម្ដងម្កាលបានហើយ។
- បន្ទាប់គ្រូសួរម្ដងមួយសំណួរឱ្យកុមារឆ្លើយ៖  តើមុននេះ កូនៗបានលេងល្បែងអ្វី? តើកូនធ្វើចលនាអ្វីខ្លះក្នុងល្បែងដែលកូនអំបាញ់មិញនេះ? តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- បន្ទាប់មកទៀត គ្រូប្រាប់បញ្ជាក់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា " បោះផ្ដួលកូនកោយ "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា

ម៉ោងទី២ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

**សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**

**ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**

ម៉ោងទី៣ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ ភាសាខ្មែរ**

**ល្បែង ៖ ទាយឈ្មោះសកម្មភាពតាមកាយវិការ រំលឹក**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២ ខែ៦ ម៉ោងទី៥)**

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## ចម្រៀងៈ មេរៀនសង្កេត (ពេលទី២)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីអត្ថន័យ និងរបៀបធ្វើកាយវិការបទចម្រៀងមេរៀនសង្កេតបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងមេរៀនសង្កេតបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងបទចម្រៀង សហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរៈ កូនគិតបន្តិចទៅមើលថា តើថ្ងៃមុនកូនបានរៀនច្រៀងចម្រៀងអ្វី?តើចម្រៀងនោះមានន័យដូចម្តេច?(បើកុមារឆ្លើយមិនត្រូវគ្រូប្រាប់កុមារតែម្តង)
- គ្រូសួរកុមារបន្តថា ដូច្នេះកូនទាយទៅមើលថា ថ្ងៃនេះ គ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារៈ ថ្ងៃនេះ គ្រូនឹងបង្រៀនកូននូវមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "មេរៀនសង្កេត" នេះម្តងទៀត
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថាៈ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់ និងសរសេរមុខវិជ្ជា និងចំណងជើងដាក់លើក្តារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូឱ្យកុមារច្រៀង និងធ្វើកាយវិការដែលបានធ្វើនៅពេលទី១ឡើងវិញជាក្រុម និងទាំងអស់គ្នា ឱ្យបាន២ចប់
- គ្រូប្រាប់កុមារថា ឥឡូវគ្រូនឹងច្រៀងចម្រៀងនេះម្តង តែគ្រូដូចជាភ្លេចពាក្យខ្លះៗ តើកូនអាចជួយថាពាក្យនោះប្រាប់លោកគ្រូបានទេ បើគ្រូភ្លេចពាក្យទាំងនោះ។ បន្ទាប់មកគ្រូចាប់ផ្តើមច្រៀងដោយធ្វើជាបំបាត់ពាក្យខ្លះក្នុងខ្លឹមសារអត្ថបទចម្រៀង ឱ្យកុមារជួយបំពេញ។ គ្រូអនុវត្តបែបនេះឱ្យបាន២ចប់។
- គ្រូប្រាប់កុមារថាៈ ឥឡូវនេះគ្រូចង់នាំកូនលេងល្បែងមួយគឺគ្រូនឹងធ្វើកាយវិការតាមបទចម្រៀងនេះ ហើយកូនជាអ្នកច្រៀងឱ្យគ្រូធ្វើកាយវិការ តើកូនអាចច្រៀងចម្រៀងឱ្យគ្រូធ្វើកាយវិការបានដែរឬទេ? បន្ទាប់មកគ្រូចាប់ផ្តើមធ្វើកាយវិការ ហើយកុមារទាំងអស់ច្រៀងចម្រៀង។គ្រូនាំអនុវត្តបែបនេះឱ្យបាន២ចប់។
- គ្រូប្រាប់កុមារថាៈ អម្បាញ់កូនបានច្រៀងឱ្យគ្រូធ្វើកាយវិការ។ ឥឡូវកូនជាអ្នកធ្វើកាយវិការម្តង ហើយគ្រូនឹងច្រៀងឱ្យកូនធ្វើកាយវិការវិញម្តង តើកូនយល់ព្រមដែរឬទេ? ។បន្ទាប់មកគ្រូចាប់ផ្តើមច្រៀង ហើយកុមារជាអ្នកធ្វើកាយវិការទាំងអស់គ្នា។ គ្រូនាំអនុវត្តបែបនេះឱ្យបាន២ចប់។
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសារឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

ខ្លឹមសារ និងរបៀបធ្វើកាយវិការ

**+ អត្ថបទចម្រៀង៖** ដើរ ឬដេកយើងក្មេងៗ មេរៀនសង្កេត គ្រប់ប្រភេទមុខវិជ្ជា
សង្កេតមេរៀនកូនទា ចប់កាលណាចូលដល់កូនមាន់ ។
មាន់ទាមានពងដូចគ្នា តុកតត មាន់ទាមានពងដូចគ្នា កាបកាប
ចិញ្ចឹមជ្រូកផងយកសាច់បរិភោគ។

**+ របៀបធ្វើកាយវិការ៖**

- "មេរៀនសង្កេត គ្រប់ប្រភេទមុខវិជ្ជា" ធ្វើកាយវិការ លើកដៃស្តាំនិងឆ្វេងឡើង ហើយយកម្រាមមេដៃ និងចង្អុលដៃប្រទាក់គ្នាដូចជារង្វង់គ្រប់ភ្នែក( ទាំងស្តាំ និងឆ្វេងដូចគ្នា ) លើកដាក់ទៅលើភ្នែក ហើយបន្ទាប់មកយកដៃឆ្វេងច្រត់ចង្កេះ រីឯដៃស្តាំបោះចង្អុលដៃទៅមុខហើយរលាស់ចុះឡើងម្តងទៅឆ្វេង ម្តងទៅស្តាំធ្វើជាកំពុងរៀបរាប់ពីអ្វីមួយ
- "សង្កេតមេរៀនកូនទា ចប់កាលណាចូលដល់កូនមាន់" ធ្វើកាយវិការលើកដៃស្តាំនឹងឆ្វេងឡើង ហើយយកម្រាមមេដៃ និងចង្អុលដៃប្រទាក់គ្នាដូចជារង្វង់គ្រប់ភ្នែក( ទាំងស្តាំ និងឆ្វេងដូចគ្នា )ដោយងក់ក្បាលបណ្តើរម្តងទៅឆ្វេងម្តងទៅស្តាំតាមចង្វាក់ចម្រៀង
- "មាន់ទាមានពងដូចគ្នា តុកតត"យកដៃឆ្វេងច្រត់ចង្កេះ រីឯដៃស្តាំបោះចង្អុលដៃទៅមុខហើយរលាស់ចុះឡើង បន្ទាប់មកទាញដៃឆ្វេង និងស្តាំលាបាតដៃឱ្យត្រង់មកដាក់នៅសងខាងនៃមាត់ រួចច្រៀងថា តុកតត
- "មាន់ទាមានពងដូចគ្នា កាកាប"យកដៃឆ្វេងច្រត់ចង្កេះ រីឯដៃស្តាំបោះចង្អុលដៃទៅមុខហើយរលាស់ចុះឡើង បន្ទាប់មកទាញដៃឆ្វេង និងស្តាំលាបាតដៃឱ្យត្រង់មកផ្គុំគ្នាផ្តេកហើយលើកទៅដាក់នៅខាងមុខមាត់រួចធ្វើចលនាដៃម្តងបិតម្តងបើកដូចជាចំពុះទា រួចច្រៀងថា កាបកាប
- "ចិញ្ចឹមជ្រូកផងយកសាច់បរិភោគ" ធ្វើកាយវិការ យកដៃឆ្វេង និងស្តាំក្តាប់ ហើយលើកមកដាក់ជិតច្រមុះរួចទាញដៃឆ្វេងមកលាឱ្យត្រង់ យកម្រាមដៃស្តាំផ្តុំគ្នាដូចជាកញ្ចុំ ហើយចលនាធ្វើដូចចាប់អាហារមកដាក់ក្នុងមាត់ ដោយយកកញ្ចុំដៃស្តាំ ដាក់លើបាតដៃឆ្វេង ហើយលើកមកដាក់មាត់។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## សង្កេត៖ សត្វមាន់

### ១. វត្ថុបំណង

- កុមារប្រាប់បានពីឈ្មោះនិងផ្នែកនីមួយៗនៃសត្វមាន់បានត្រឹមត្រូវ
- កុមាររៀបរាប់បានពីឈ្មោះ រូបរាង សម្បុរ និងផ្នែកនីមួយៗនៃសត្វមាន់បានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម សហការ ចូលរួមបានយ៉ាងសកម្ម និងសប្បាយរីករាយ។

**២ .សម្ភារបង្រៀន៖** បណ្ណរូបសត្វមាន់ចំនួន៤ផ្ទាំង

**៣. រៀបចំកុមារ៖** រៀបចំកុមារជារាងអក្សរ អ៊ុយ " U" អង្គុយជាក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនិទានរឿង៖ ថ្ងៃនេះគ្រូបានធ្វើដំណើរមកសាលារៀនបានឃើញកសិដ្ឋានមួយមានចិញ្ចឹមមាន់យ៉ាងច្រើននៅតាមផ្លូវមកសាលារៀន ពេលនោះអ៊ុំម្ចាស់កសិដ្ឋានបានហៅគ្រូឱ្យឈប់ហើយគាត់បានធ្វើថង់មួយមកឱ្យគ្រូ ដើម្បីយកមកធ្វើកូនៗទាំងអស់គ្នាព្រោះគាត់ថាកូនៗទាំងអស់គ្នាជាកូនល្អ។ ប៉ុន្តែគ្រូមិន

ដឹងថាខាងក្នុងនោះមានអ្វីទេ?ដូច្នេះកូនៗទាំងអស់គ្នាចង់ដឹងទេថាតើខាងក្នុងថង់មានអ្វីខ្លះ ? អញ្ចឹងកូនចង់ចិញ្ចឹមសត្វអ្វីខ្លះ?កុមារឆ្លើយតមតាមគំនិតគេម្នាក់ៗ។

- គ្រូបង្ហាញថង់នោះហើយប្រាប់កុមារថាគ្រូនឹងឱ្យកូនៗទាំងអស់គ្នាបានស្ទាបគ្រប់ៗគ្នាពេលកូនស្ទាបកូនត្រូវគិតវាតើក្នុងថង់នេះមានអ្វី?ហើយប្រាប់គ្រូមានអ្វីនៅក្នុងថង់នេះ?
- គ្រូឱ្យកុមារម្នាក់ឡើងមកយកសម្ភារចេញពីក្នុងថង់ហើយបង្ហាញមិត្តភក្តិ រួចសួរកុមារដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ (មានមិត្តភក្តិណាទាយត្រូវទេកូនតើអម្បាញ់មិញ?)ពេលមានកុមារទាយត្រូវឱ្យកុមារទាំងអស់ទះដៃសរសើរ
- គ្រូបញ្ជាក់ថានេះជារូបសត្វមាន់ រួចសួរកុមារតើសត្វមាន់នេះជាមាន់ញីឬមាន់ឈ្មោល ?កហើយគ្រូយ ឱ្យកូនធ្វើអ្វី?
- គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ
  - គ្រូឱ្យកូនធ្វើជាក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវទទួលបានបណ្ណរូបសត្វមាន់១សន្លឹកក្នុងមួយក្រុម
  - ពេលក្រុមកូននីមួយៗបានបណ្ណរូបសត្វមាន់នេះហើយកូនៗត្រូវនាំគ្នាពិនិត្យមើលនៅលើផ្នែកនីមួយៗនៃដងខ្លួនមានអ្វីខ្លះ?ពេលកូនសង្កេតហើយប្រាប់គ្រូនិងមិត្តភក្តិ បន្ទាប់មកកូនពិភាក្សាគ្នាត្រូវចេះចែកគ្នាមើលនិងនិយាយ ហើយកូនត្រូវរកមិត្តភក្តិណាម្នាក់ក្នុងក្រុមដើម្បីឡើងនិយាយប្រាប់មិត្តភក្តិ និងគ្រូពីអ្វីដែលកូនបានសង្កេត។
  - ពេលកូនសង្កេតចប់គ្រប់ក្រុមហើយកូនៗនាំគ្នាទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុកវិញ
- គ្រូឱ្យកុមារម្នាក់ឡើងនិយាយពីអ្វីដែលគ្រូបានប្រាប់បើសិននិយាយមិនបានគ្រប់ទេត្រូវឱ្យមិត្តភក្តិជួយបំពេញបន្ថែមប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យកុមារម្នាក់ក្នុងក្រុមនីមួយៗមកយកសម្ភារទៅនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយជួយបំផុសគំនិតបន្ថែមចំពោះក្រុមខ្លះមិនទាន់យល់
- ពេលក្រុមនីមួយៗសង្កេតចប់សព្វគ្រប់ហើយគ្រូឱ្យពួកគេទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុកវិញ
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់ពីលទ្ធផលដែលពួកគេបានជជែកគ្នា(ម្តងមួយក្រុមៗ) ពេលកុមារនិយាយពាក្យមិនត្រឹមត្រូវតាមអក្ខរាវិរុទ្ធ គ្រូត្រូវកែតម្រូវហើយនាំកុមារអានទាំងអស់គ្នា (ឧទាហរណ៍= កុមារគ្រប់ក្រុមបានប្រាប់ផ្នែកនីមួយៗនៃសត្វមាន់មាន ឈ្មោះ រូបរាង សម្បុរ...)
- គ្រូសរុបពីលទ្ធផលរបស់កុមារទាំងអស់ដែលបានឡើងបង្ហាញ។ ពេលគ្រូសរុបត្រូវគិតមើលតើក្រុមទាំងអស់នៅមិនទាន់ស្គាល់អ្វីខ្លះ?ដូច្នេះត្រូវផ្តល់ចំណេះដឹងថ្មីឱ្យកុមារទៀត។ (ឧទាហរណ៍ ៖ កុមារមិនទាន់ប្រាប់ពីឈ្មោះ រូបរាង សម្បុរ និងអត្ថប្រយោជន៍នៃមាន់)
- គ្រូត្រូវបំផុសសំណួរដើម្បីផ្តល់ចំណេះដឹងបន្ថែម
  - នៅផ្ទះម្តាយកូនមានចិញ្ចឹមមាន់ដែរឬទេ?
  - កូនសង្កេតឃើញថាគាត់ថែទាំដូចម្តេចដើម្បីឱ្យមានការធំធាត់បានល្អ?
  - ពេលឪពុកម្តាយកូនចិញ្ចឹមមាន់តើកូនអាចជួយអ្វីបានខ្លះ?

- តើមាន់មានប្រយោជន៍អ្វីខ្លះ ?
- គ្រូត្រូវប្រាប់កុមារពេលឆ្លើយមិនបាននៅសំណួរណាមួយនោះ ?
- គ្រូនាំកុមារអានពាក្យខ្លះៗដែលពិបាក
- គ្រូសួរកុមារះអម្បាញ់មិញកូនស្គាល់ពីអ្វី ?ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេតសត្វមាន់
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន( ជាក្រុមនិងអានទាំងអស់គ្នា )។

ម៉ោងទី៦ (រយ:ពេល ៣០នាទី)

**មុខវិជ្ជាៈ សិក្សាសង្គម**

**ល្បែងសេរី ( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦ )**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

## ថ្ងៃទី៤

ម៉ោងទី១ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមបទចម្រៀង ៖ យើងអុំទូកលេង

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបធ្វើចលនាក្ដាប់ដៃទាំងពីរដាក់ចំហៀងខ្លួនលើកចុះលើកឡើងបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើចលនាក្ដាប់ដៃទាំងពីរដាក់ចំហៀងខ្លួនលើកចុះលើកឡើងបានត្រឹមត្រូវ
- កុមារស្វាហាប់ រហ័សរហួន ស្រឡាញ់និងចូលចិត្តច្រៀងដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារឈរជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរ ៣ជួរតាមក្រុមនៅទីធ្លាមុខថ្នាក់រៀន ហើយគ្រូឈរពីខាងមុខកុមារ
- គ្រូនាំកុមារធ្វើចលនាគ្រាប់តាមសត្វកង្កែប ហើយបញ្ចេញសំឡេងឱក ឱក ឱក(កុមារយកដៃច្រត់ចង្កេះ លោតទៅមុខលោតទៅឆ្វេង លោតទៅស្តាំ ហើយធ្វើសំឡេងជាសត្វកង្កែបអូក អូក អូកៗៗៗ ១ដង ឬ ២ដង
- គ្រូច្រៀងឱ្យកុមារស្ដាប់ និងធ្វើចលនាឱ្យកុមារមើលតាមបទចម្រៀងរហូត១ចប់
- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងទាំងអស់គ្នាអាស្រ័យតាមពេលវេលា(២ឬ៣ចប់)
- គ្រូសួរ៖ តើកូនៗធ្លាប់បានទៅលេងពិធីបុណ្យអុំទូកដែរឬទេ? ហើយទូកគេច្រើនអុំនៅឯណា?(កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ)
- ថ្ងៃនេះកូនរៀនមុខវិជ្ជាចិត្តចលភាពអំពី ហាត់ប្រាណតាមបទចម្រៀង ចំណងជើង "យើងអុំទូកលេង" គ្រូឱ្យកុមារថាតាម១នាក់ ២នាក់តាមក្រុម
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗធ្វើចលនាតាមបទចម្រៀងសប្បាយទេ?ឥឡូវគ្រូនាំកូនផ្លុំប៉េងប៉ោងទាំងអស់គ្នាដៃទាំងពីរកាន់មាត់ប៉េងប៉ោងផ្លុំតិចៗ បន្ទាប់មកផ្លុំឱ្យប៉ោងខ្លាំង បញ្ចេញសំឡេងបែកផោងៗៗ

**+ របៀបធ្វើចលនា៖**

- ច្រៀងមួយចប់បទចម្រៀងលើកទី១៖ គ្រូឱ្យកុមារក្ដាប់ដៃទាំងពីរដាក់ចំហៀងខ្លួនលើកចុះលើកឡើង ធ្វើចលនាអុំទូកម្ដងទៅខាងឆ្វេង(៣ដង) ធ្វើចលនាអុំទូកម្ដងទៅខាងស្ដាំ(៣ដង) នៅមួយកន្លែង ១ចប់បទចម្រៀង (កុមារឈរ)
- ច្រៀងមួយចប់បទចម្រៀងលើកទី២៖ គ្រូឱ្យកុមារក្ដាប់ដៃទាំងពីរដាក់ចំហៀងខ្លួនលើកចុះលើកឡើង ធ្វើចលនាអុំទូកម្ដងទៅខាងឆ្វេង(៣ដង) ធ្វើចលនាអុំទូកម្ដងទៅខាងស្ដាំ(៣ដង) នៅមួយកន្លែង ១ចប់បទចម្រៀង (កុមារអង្គុយ)
- ច្រៀងមួយចប់បទចម្រៀងលើកទី៣៖ គ្រូឱ្យកុមារក្ដាប់ដៃទាំងពីរដាក់ចំហៀងខ្លួនលើកចុះលើកឡើង ធ្វើចលនាអុំទូកម្ដងទៅខាងឆ្វេង(៣ដង) ធ្វើចលនាអុំទូកម្ដងទៅខាងស្ដាំ(៣ដង) នៅមួយកន្លែង ១ចប់បទចម្រៀង (កុមារដើរទៅមុខ)

## អត្ថបទចម្រៀង "យើងអុំទូកលេង"

| | | |
|---|---|---|
| យើងអុំទូកទៅ | ឱណាមិត្តណា | ទៅសាលារៀន |
| ទៅរៀនហាត់ធ្វើចលនា | ឱណាមិត្តណា | ចលនាជាចរន្ត។ |
| ចលនានានា | ឱណាមិត្តណា | មានដើររត់លោត |
| លូនឡើងចុះទាញរុញរ៉ា | ឱណាមិត្តណា | បង្វិលគប់បោះ។ |
| យើងអុំទូកទៅ | ឱណាមិត្តណា | ហាត់តាមបទចម្រៀង |
| ចលនាហាត់តាមការនិទាន | ឱណាមិត្តណា | មានកម្លាំងមាំមួន។ |

ម៉ោងទី២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**

**ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

**សង្កេត ៖ សត្វទា**

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះនិងផ្នែកនីមួយៗនៃសត្វទាបានត្រឹមត្រូវ
- កុមាររៀបរាប់បានពីឈ្មោះ រូបរាង សម្បុរ និងផ្នែកនីមួយៗនៃសត្វទាបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម សហការ ចូលរួមបានយ៉ាងសកម្ម និងសប្បាយរីករាយ។

**២ .សម្ភារបង្រៀន៖** បណ្ណរូបសត្វទាចំនួន៤ផ្ទាំង

**៣. រៀបចំកុមារ៖** រៀបចំកុមារជារាងអក្សរ អ៊ុយ "U" អង្គុយជាក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនិទានរឿង៖ ថ្ងៃនេះគ្រូបានធ្វើដំណើរមកសាលារៀនបានឃើញកសិដ្ឋានមួយមានចិញ្ចឹមទាយ៉ាងច្រើននៅតាមផ្លូវមកសាលារៀន ពេលនោះអ៊ុំម្ចាស់កសិដ្ឋានបានហៅគ្រូឱ្យឈប់ហើយគាត់បានផ្ញើថង់មួយមកឱ្យគ្រូ ដើម្បីយកមកផ្ញើកូនៗទាំងអស់គ្នាព្រោះគាត់ថាកូនៗទាំងអស់គ្នាជាកូនល្អ។ ប៉ុន្តែគ្រូមិនដឹងថាខាងក្នុងនោះមានអ្វីទេ?ដូច្នេះកូនៗទាំងអស់គ្នាចង់ដឹងទេថាតើខាងក្នុងថង់មានអ្វីខ្លះ ? អញ្ចឹងកូនចង់ចិញ្ចឹមសត្វអ្វីខ្លះ?កុមារឆ្លើយតមតាមគំនិតគេម្នាក់ៗ។
- គ្រូបង្ហាញថង់នោះហើយប្រាប់កុមារថាគ្រូនឹងឱ្យកូនៗទាំងអស់គ្នាបានស្ទាបគ្រប់ៗគ្នាពេលកូនស្ទាបកូនត្រូវគិតវាតើក្នុងថង់នេះមានអ្វី?ហើយប្រាប់គ្រូមានអ្វីនៅក្នុងថង់នេះ?
- គ្រូឱ្យកុមារម្នាក់ឡើងមកយកសម្ភារចេញពីក្នុងថង់ហើយបង្ហាញមិត្តភក្តិ រួចសួរកុមារដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ (តើអម្បាញ់មិញមានមិត្តភក្តិណាទាយត្រូវទេកូន?)ពេលមានកុមារទាយត្រូវឱ្យ

កុមារទាំងអស់ទះដៃសរសើរ

- គ្រូបញ្ជាក់ថានេះជារូបសត្វទា រួចសួរកុមារ តើសត្វទានេះជាទាញីឬ ទាឈ្មោលហើយគ្រូយកមក ឱ្យកូនធ្វើអ្វី ?
- គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ
  - គ្រូឱ្យកូនធ្វើជាក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវទទួលបានប័ណ្ណរូបសត្វទា១សន្លឹកក្នុងមួយក្រុម
  - ពេលក្រុមកូននីមួយៗបានប័ណ្ណរូបសត្វទានេះហើយកូនៗត្រូវនាំគ្នាពិនិត្យមើលនៅលើផ្នែកនីមួយៗនៃដងខ្លួនមានអ្វីខ្លះ ?ពេលកូនសង្កេតហើយប្រាប់គ្រូនិងមិត្តភក្តិ បន្ទាប់មកកូនពិភាក្សាគ្នាត្រូវចេះចែកគ្នាមើលនិងនិយាយ ហើយកូនត្រូវរកមិត្តភក្តិណាម្នាក់ក្នុងក្រុមដើម្បីឡើងនិយាយប្រាប់មិត្តភក្តិនិងគ្រូពីអ្វីដែលកូនបានសង្កេត។
  - ពេលកូនសង្កេតចប់គ្រប់ក្រុមហើយកូនៗនាំគ្នាទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុកវិញ
- គ្រូឱ្យកុមារម្នាក់ឡើងនិយាយពីអ្វីដែលគ្រូបានប្រាប់បើសិននិយាយមិនបានគ្រប់ទេត្រូវឱ្យមិត្តភក្តិជួយបំពេញបន្ថែមប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យកុមារម្នាក់ក្នុងក្រុមនីមួយៗមកយកសម្ភារទៅនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយជួយបំផុសគំនិតបន្ថែមចំពោះក្រុមខ្លះមិនទាន់យល់
- ពេលក្រុមនីមួយៗសង្កេតចប់សព្វគ្រប់ហើយគ្រូឱ្យពួកគេទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុកវិញ
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់ពីលទ្ធផលដែលពួកគេបានជជែកគ្នា( ម្តងមួយក្រុមៗ ) ពេលកុមារនិយាយពាក្យមិនត្រឹមត្រូវតាមអក្ខរាវិរុទ្ធ គ្រូត្រូវកែតម្រូវហើយនាំកុមារអានទាំងអស់គ្នា ( ឧទាហរណ៍= កុមារគ្រប់ក្រុមបានប្រាប់ផ្នែកនីមួយៗនៃសត្វទាមាន ឈ្មោះ រូបរាង សម្បុរ... )
- គ្រូសរុបពីលទ្ធផលរបស់កុមារទាំងអស់ដែលបានឡើងបង្ហាញ។ ពេលគ្រូសរុបត្រូវគិតមើលតើក្រុមទាំងអស់នៅមិនទាន់ស្គាល់អ្វីខ្លះ ?ដូច្នេះត្រូវផ្តល់ចំណេះដឹងថ្មីឱ្យកុមារទៀត។ ( ឧទាហរណ៍ ៖ កុមារមិនទាន់ប្រាប់ពីឈ្មោះ រូបរាង សម្បុរ និងអត្ថប្រយោជន៍នៃទា )
- គ្រូត្រូវបំផុសសំណួរដើម្បីផ្តល់ចំណេះដឹងបន្ថែម
  - នៅផ្ទះម្តាយកូនមានចិញ្ចឹមទាដែរឬទេ ?
  - កូនសង្កេតឃើញថាគាត់ថែទាំដូចម្តេចដើម្បីឱ្យមានការធំធាត់បានល្អ?
  - ពេលឪពុកម្តាយកូនចិញ្ចឹមទាតើកូនអាចជួយអ្វីបានខ្លះ ?
  - តើទាមានប្រយោជន៍អ្វីខ្លះ ?
  - គ្រូត្រូវប្រាប់កុមារពេលឆ្លើយមិនបាននៅសំណួរណាមួយនោះ ?
  - គ្រូនាំកុមារអានពាក្យខ្លះៗដែលពិបាក
  - គ្រូសួរកុមារះ អម្បាញ់មិញកូនស្គាល់ពីអ្វី ?ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេតសត្វទា
  - គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន( ជាក្រុម និងអានទាំងអស់គ្នា )។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

## គំនូរ៖ " គូរសេរី"

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបគូររូបផ្សេងៗដោយសេរីតាមការស្រមើស្រមៃបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃគូររូបផ្សេងៗដោយសេរីតាមការស្រមើស្រមៃបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖**

- **សម្ភារសម្រាប់គ្រូ៖** គ្មាន
- **សម្ភារសម្រាប់កុមារ៖** ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃគ្រប់ចំនួនកុមារ

**៣ .ការរៀបចំកុមារ៖**អង្គុយរាងអក្សរអ៊ុយ" ں "ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរ៖ តើកូនៗធ្លាប់ទៅដើរលេងជាមួយឪពុកម្តាយនៅកន្លែងណាខ្លះ? ហើយនៅពេលកូនទៅដើរលេង កូនបានសង្កេតឃើញអ្វីខ្លះនៅទីនោះ? តើកូនៗពេញចិត្តនិងស្រឡាញ់អ្វីជាងគេ? (ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹក ដែលគ្រូមិនទាន់គូរឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសសនេះគ្រូទុកសម្រាប់ឱ្យកូនគូរគំនូរដោយសេរីតាមចំណង់ចំណូលចិត្តកូនដែលកូនបានឃើញ។ គ្រូឱ្យកូននាំគ្នាគូរដោយសេរី
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរដោយសេរីទៅតាមអ្វីដែលកូនចង់គូរម្នាក់ៗ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូរ (តាមស្ថានភាពជាក់ស្តែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម សួរកុមារដាក់ចំណងជើងមេរៀនទៅតាមរូបភាពគំនូរជាក់ស្តែងរបស់កុមារម្នាក់ៗ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងលើសន្លឹកកិច្ចការរបស់កូនម្នាក់ៗ
- គ្រូប្រាប់កុមារ៖ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូរហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមៗនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការ ដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់: តើមិត្តភក្តិយើងមួយណាគូរបានស្អាតជាងគេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## សម្គាល់ ៖ " វែង ខ្លី "

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីបញ្ញត្តិវែង និងខ្លីបានត្រឹមត្រូវ។
- កុមារបង្ហាញពីបញ្ញត្តិប្រវែង និងខ្លីបានត្រឹមត្រូវ។
- កុមារឈ្លាសវៃ រហ័សរហួន ក្នុងការគិតបានហ្មត់ចត់ សហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** ស្លាបព្រា ខ្មៅដៃ ប៊ិច បន្ទាត់ ដំរលុប ខ្សែ....

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "ᑌ" ជាដៃគូ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

**-គ្រូបំផុសសំណួរ៖**

- កូនៗសង្កេតមើលស្លាបព្រាចំនួនពីរដែលនៅលើតុពីមុខកូនយ៉ាងមិចដែរ? តើស្លាបព្រាទាំងពីរនេះមានអ្វីដែលខុសប្លែកគ្នា?
- តើកូនដឹងទេថាថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វី?

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើង៖ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជា៖បុរេគណិត ចំណងជើង៖សម្គាល់ "វែង និងខ្លី"
- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់(តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់ គ្រូឬទេ? បើកូនណាឆ្លើយត្រូវគ្រូលើកសរសើរ បើកូនឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុមនិងទាំងអស់គ្នា
- គ្រូឱ្យកុមារ ២នាក់ឡើងមកឈរនៅមុខក្តារខៀនរួចម្នាក់កាន់ខ្មៅដៃ ម្នាក់ទៀតកាន់បន្ទាត់វែង គ្រូសួរទៅកុមារទាំងអស់ថា កូនសង្កេតមើលវត្ថុទាំងពីរនេះយ៉ាងមិចដែរ? តើកូនធ្វើដូចម្តេចទើបដឹងថាវត្ថុមួយណាវែង និងមួយណាខ្លី?
- គ្រូឱ្យកុមារចាប់ដៃគូ២នាក់ៗទៅតាមការកំណត់របស់គ្រូ ហើយវាស់ប្រវែងដោយខ្លួនឯង(ដាក់វត្ថុផ្តេកចុះ ឬបញ្ឈរ តាមការយល់ឃើញរបស់កុមារ) រួចប្រាប់ចម្លើយមកគ្រូ ហើយពិនិត្យផ្ទៀងផ្ទាត់ដោយប្រើខ្នាតជាបន្ទះក្រដាសតូចវែង ឬខ្សែ ដើម្បីកំណត់បញ្ញត្តិ វែង.ខ្លី (អនុវត្តទៅតាមដៃគូ ធ្វើរបៀបនេះរហូតដល់អស់ដៃគូក្នុងក្រុម)
- គ្រូឱ្យតំណាងក្រុមម្នាក់ៗផ្ទៀងផ្ទាត់លទ្ធផលដែលគេអនុវត្ត
- កូនពិនិត្យមើលតើនៅក្នុងថ្នាក់រៀនយើងមានវត្ថុអ្វីខ្លះដែលជាវត្ថុវែង និងវត្ថុខ្លី ?

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**ល្បែងសេរី**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦)**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

# ថ្ងៃទី៥

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមរឿងនិទាន ៖ បូណា និងនារីនាំគ្នាទៅលេងចម្ការស្វាយ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបដើរទៅមុខ ដើរថយក្រោយ លោតផ្លោះ គប់ រត់លឿន តាមខ្លឹមសារនៃរឿងនិទាន បានត្រឹមត្រូវ
- កុមារដើរទៅមុខ ដើរថយក្រោយ លោតផ្លោះ គប់ រត់លឿន តាមខ្លឹមសារនៃរឿងនិទាន បានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** ឈរជាជួរ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- គ្រូបំផុសសំនួរៈ តើកូនធ្លាប់មើលតុក្កតារឿងមនុស្សយន្តដែរឬទេ? តើមនុស្សយន្តដើរដូចម្ដេច?
- គ្រូនាំកុមារទាំងអស់ធ្វើដំណើរមនុស្សយន្តដោយដើរទៅមុខមួយៗ យឺតៗ  ស្ទុបៗដោយចលនាដៃ និងដងខ្លួនត្រូវស្របគ្នាជាមួយចលនាជើង
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន "បូណានិងនារីនាំគ្នាទៅលេងចំការស្វាយ"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូនាំកុមារធ្វើសកម្មភាពខ្លះៗទាក់ទងទៅនឹងខ្លឹមសាររឿងនិទាន ដោយនាំកុមារដើរទៅមុខ ដើរថយក្រោយ លោតផ្លោះ គប់ រត់លឿន
- គ្រូចាប់ផ្ដើមនិទានរឿងបណ្ដើរនាំកុមារធ្វើសកម្មភាពបណ្ដើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយមិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ (ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្ដងទៀត)
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗហាត់ទេ?បើហាត់កូនទាំងអស់គ្នាផ្លុំប៉េងប៉ោងដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃទាំងពីរធ្វើជាប៉េងប៉ោង  ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ ដល់ប៉េងប៉ោងធំហួតដល់បែកឮសូរផ្ទុង គ្រូសួរកុមារថាតើកូនៗផ្លុំប៉េងប៉ោងសប្បាយទេ? កុមារឆ្លើយ គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្ដែង។

**អត្ថបទរឿង "បូណានិងនារីនាំគ្នាទៅលេងចំការស្វាយ"**

ថ្ងៃមួយបូណា និងនារីកាន់ដៃគ្នាដើរមួយៗ ជជែកគ្នាពីនេះពីនោះនឹងមានកាន់កញ្ច្រែងនៅដៃផង។ ពេលនោះស្រាប់តែគេឈប់ង៉ក់ដោយឃើញមានទឹកថ្លុកមួយ។ បន្ទាប់មកគេក៏កាន់ដៃគ្នាថយក្រោយ ២-៣ជំហានវែងៗ ហើយគេក៏រត់លោតផ្លោះថ្លុកនោះ។ពួកគេសប្បាយចិត្តណាស់ក៏នាំគ្នាទះដៃ រួចហើយកាន់ដៃគ្នារត់តិចៗបន្តដំណើរទៅមុខទៀតលុះទៅជិតដល់ចំការមានផ្លូវតូចមួយដែលមានបន្លាជាច្រើន។ ផុតពីផ្លូវតូចនោះ ពួកគេក៏បានបន្តដំណើរទៅដល់ចំការស្វាយដែលមានផ្លែជាច្រើន។ ពួកគេក៏នាំគ្នាលោតផ្លោះរបង ហើយក៏នាំគ្នាលោតបេះផ្លែស្វាយរួចក៏នាំគ្នាគប់ផ្លែស្វាយទៀត ។ ពេលនោះផ្លែស្វាយធ្លាក់យ៉ាងច្រើន គេក៏នាំគ្នារើសបោះ

ចូលកញ្ច្រែង ហើយក៏មកអង្គុយទល់ខ្នងគ្នា។ លុះយូរបន្តិចស្រាប់តែមានភ្លៀងលើមស្រិចៗ ពួកគេក៏ក្រោក ឈរកាន់កញ្ច្រែងផ្លែស្វាយរត់យ៉ាងលឿនត្រឡប់មកផ្ទះវិញ ។

ម៉ោងទី២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**

**ទម្លាប់ល្អ៖ ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

**ល្បែង ៖ ផ្គូផ្គងចំនួនរូបភាពនិងចំនួនចំណុចទៅនឹងលេខពី១០ដល់១៥**

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបផ្គូផ្គងចំនួន និងលេខពី១០ ដល់១៥ បានត្រឹមត្រូវ
- កុមារកំណត់បានចំនួនចំណុច ពី ១០ ដល់១៥ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖**

- បណ្ណចំនួនរូបភាពពី១០ ដល់១៥ មានចំនួន១៥បណ្ណ
- បណ្ណចំនួនចំណុចពី១០ ដល់១៥ មានចំនួន១៥បណ្ណ
- បណ្ណចំនួនលេខពី១០ ដល់១៥ មានចំនួន១៥បណ្ណ

**៣. ការរៀបចំកុមារ៖** អង្គុយជារាងពាក់កណ្ដាលរង្វង់(ប) អង្គុយតាមក្រុមតូចៗ (៣ក្រុម)

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១០ ដល់១៥ ឱ្យកុមារប្រាប់ពីចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយក បិទលើក្ដារ ខៀន និងនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១០ ដល់១៥ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយក បិទលើក្ដារ ខៀន ពីក្រោមរូបភាព និងនាំកុមាររាប់
- គ្រូបង្ហាញបណ្ណលេខពី១០ ដល់១៥ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកមកបិទលើក្ដារខៀន ពីក្រោម ចំនួនចំណុច និងលេខ រួចនាំកុមារអាន
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវបានសម្ភារទាំងអស់នេះមួយកំប្លេ
  - ពេលក្រុមកូនបានសម្ភារទាំងនេះហើយ កូនត្រូវសង្កេតមើលចំនួន និងលេខទៅតាមបណ្ណនីមួយៗ រួចហើយកូននាំគ្នារៀបបណ្ណចំនួនរូបភាពពី១០ ដល់១៥តាមលំដាប់។ បន្ទាប់មកកូនត្រូវយកបណ្ណ

ចំនួនចំណុចពី១០ ដល់១៥ រៀបពីក្រោមបណ្ណរូបភាពពី១០ ដល់១៥ តាមលំដាប់ដែរ និងយកប
ណ្ណនេះមករៀបពីក្រោម  បណ្ណចំនួនចំណុចពី១០ ដល់១៥ ទៀត

- ពេលកូននាំគ្នារៀប កូនត្រូវចេះចែកគ្នារៀបម្តងម្នាក់ៗទៅតាមវេន កុំដណ្តើមគ្នា ។ ពេលកូនរៀបហើយ កូនត្រូវនាំគ្នាពិនិត្យឡើងវិញ ក្រែងមានខុស ហើយកូនទៅអង្គុយនៅនឹងកន្លែងសិន រង់ចាំក្រុមមិត្តភក្តិយើងរៀបហើយទាំងអស់គ្នា

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តទៅតាមក្រុមនីមួយៗ ហើយគ្រូដើរសម្របសម្រួលកែតម្រូវ
- ពេលកុមារធ្វើហើយគ្រប់ក្រុម គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារតាមក្រុមជាអ្នកផ្ទៀងផ្ទាត់ការងាររបស់ក្រុមនីមួយៗ ។ មុនផ្ទៀងផ្ទាត់ឱ្យម្ចាស់ក្រុមប្រាប់ពីអ្វីដែលពួកគេបានរៀប រួចរាប់ឱ្យមិត្តភក្តិស្តាប់ ។ គ្រូនាំកុមារផ្ទៀងផ្ទាត់រហូតគ្រប់ក្រុមទាំងអស់ ។ បើករណីមានខុស ឱ្យមិត្តភក្តិជួយកែតម្រូវ ។
- ពេលផ្ទៀងផ្ទាត់គ្រប់ក្រុមហើយ ត្រូវឱ្យតំណាងក្រុមនីមួយៗប្រមូលសម្ភារទៅទុកឱ្យគ្រូវិញ ហើយនាំគ្នាទៅអង្គុយជារួមក្រុមធំវិញ
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ? តើមុននេះកូនៗបានលេងល្បែងអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ) ?មេរៀនអ្វីដែរ ?កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ(
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិត អំពីមេរៀនល្បែង "ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១០ ដល់១៥ "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ  ទៅនឹងអ្វីដែលគ្រូបានប្រាប់  (តើមុននេះមានកូនៗណាឆ្លើយដូច  ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)

គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា  ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពកសាង៖ ចាក់ស្លឹកដូងឬស្លឹកត្នោតធ្វើនាឡិកាដៃ

**១វត្ថុបំណង៖ .**

-កុមារប្រាប់បានពី របៀបបត់នាឡិកាដៃដោយប្រើស្លឹកត្នោត និងស្លឹកដូង បានត្រឹមត្រូវ

-រកុមាបត់ស្លឹកត្នោត និងស្លឹកដូងធ្វើជានាឡិកាដៃ បានត្រឹមត្រូវ

-កុមារព្យាយាមអំណត់ មានបម្រុងប្រយ័ត្ន ច្នៃប្រឌិត និងចេះស្រឡាញ់និងឱ្យតម្លៃទៅលើរបស់ដែលខ្លួនខិតខំធ្វើ

**២  សម្ភារបង្រៀន៖ .**

- ស្លឹកត្នោត ស្លឹកដូង ហែកជំរៀក មានវែង(បណ្តោយ២០cm*ទទឹង២cm) និងខ្លី(បណ្តោយ10cm*ទទឹង២cm) គ្រប់កុមារ
- នាឡិកាដៃ ធ្វើពីស្លឹកដូង ១

**៣ការរៀបចំកុមារៈ** . កុមារអង្គុយជាអក្សរ ប

**៤. ដំណើរការបង្រៀនៈ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញនាឡិកាដៃដែលបត់ពីស្លឹកដូងដែលបានបត់រួច ឱ្យកុមារប្រាប់ និងយកទៅបិទលើក្តារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូបង្ហាញសម្ភារដែលត្រូវអនុវត្តដាក់លើតុខាងមុខកុមារ ឱ្យកុមារសង្កេត ហើយសួរកុមារថា តើកូនឃើញអ្វីខ្លះនៅលើតុនេះ? ចូរកូនទាយទៅមើលថា តើគ្រូនឹងនាំកូនធ្វើអ្វីជាមួយសម្ភារទាំងនេះ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយទស្សន៍ទាយរបស់កុមារ ដោយលើកសសើរចំពោះកុមារដែលទាយត្រូវ ហើយលើកទឹកចិត្តកុមារដែលឆ្លើយមិនទាន់បានត្រឹមត្រូវឱ្យប្រឹងប្រែងបន្ថែមទៀត រួចគ្រូប្រាប់កុមារថា ដូច្នេះថ្ងៃនេះយើងនឹងលេងល្បែងបត់រូបត្រី។ ហើយនាំកុមារអានទាំងអស់គ្នា២ចប់។
- គ្រូរៀបចំឱ្យកុមារទាញកៅអីមកអង្គុយជាក្រុមព័ទ្ធជុំវិញតុដែលបានរៀបចំរួច និងឱ្យកុមារពីរនាក់មកយកសម្ភារពីគ្រូទៅចែកមិត្តភក្តិគេតាមក្រុមអនុវត្តម្នាក់ៗ
- គ្រូណែនាំពីរបៀបបត់ស្លឹកដូងធ្វើនាឡិកាដៃ ដើម្បីឱ្យកុមារសង្កេតឱ្យបានច្បាស់ ហើយគ្រូត្រូវឈរធ្វើយ៉ាងណាឱ្យកុមារមើលឃើញគ្រប់ៗគ្នា ហើយឱ្យកុមារអនុវត្តតាមបណ្តើរ ដោយនិយាយថា
  - យកសន្លឹកដែលខ្លីដាក់ពីក្រោមស្លឹកវែង ផ្នែកខាងចុង
  - បត់រុំ លើចុងស្លឹកដែលមានប្រវែង វែង បន្ទាប់មកកូនចាប់ចុងស្លឹកវែងហើយបត់ចូលទៅក្នុងចន្លោះដែលស្លឹកខ្លីបត់ជាប់ផ្នែកខាងលើ រួចទាញព័ទ្ធ១ជុំ
  - បន្ទាប់មកបត់ព័ទ្ធ១ជុំទៀតទុកចន្លោះប្រវែងកដៃរបស់កូនសម្រាប់ពាក់ចូលដៃ
- គ្រូដើរសម្របសម្រួលទៅតាមជួរនីមួយៗដោយជួយកុមារណាដែលមិនទាន់ចេះធ្វើ
- គ្រូនាំកុមារទៀងផ្ទាត់លទ្ធផលរបស់កុមារម្នាក់ៗរួចឱ្យកុមារចេញម្តងមួយក្រុមៗតាមឈរពីមុខមិត្តភក្តិគេដោយរកនាឡិកាដៃដែលបានបត់មកពាក់នឹងកដៃរៀងៗខ្លួន ហើយលើកបង្ហាញ
- គ្រូសួរកុមារៈ តើមិត្តភក្តិបត់នាឡិកាដៃបានត្រឹមត្រូវទេ?បត់បានស្អាតទេ?
- គ្រូនិយាយប្រាប់កុមារៈ ពេលក្រុមកូនបង្ហាញរួចហើយកូន ទៅអង្គុយកន្លែងដើមវិញ។
- ពេលនាំកុមារផ្ទៀងផ្ទាត់លទ្ធផល គ្រូមិនត្រូវបង្អាប់កុមារដែលធ្វើមិនទាន់បានល្អនោះទេ។គ្រូត្រូវចេះសរសើរ លើកទឹកចិត្តកុមារឱ្យបានគ្រប់ៗគ្នាដើម្បីឱ្យពួកគេប្រឹងប្រែងបន្តទៀត។
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតទាល់តែគ្រប់កុមារទាំងអស់។
- គ្រូប្រាប់ឱ្យ កុមារម្នាក់ៗយកនាឡិកាដែលខ្លួនបត់បាន ពាក់យកទៅបង្ហាញឪពុកម្តាយនៅផ្ទះ ។

**ម៉ោងទី៥** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## កំណាព្យ ៖ សួនសាធារណៈ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំណងជើង និងអត្ថន័យនៃកំណាព្យ "សួនសាធារណៈ" បានត្រឹមត្រូវ។
- កុមារមានសមត្ថភាពសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងលំនាំបទ  បានត្រឹមត្រូវ។
- បណ្ដុះទម្លាប់កុមារឱ្យមានភាពក្លាហាន រហ័សរហួន  មានចិត្តស្រឡាញ់  និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "ប "

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣ )

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្ដាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទ និងរកពាក្យពិបាក គ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់និយាយពីអ្វី?
  - គ្រូប្រាប់និងពន្យល់ពាក្យពិបាក(ប្រសិនបើមាន)
  - អត្ថបទកំណាព្យនេះគឺចង់ឱ្យកុមារចេះរកពាក្យបណ្ដៅ
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ
- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអំបាញ់កូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជា៖ភាសាខ្មែរ មេរៀន៖កំណាព្យ "**សួនសាធារណៈ**" អ្នកនិពន្ធដោយលោកអ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាំព្យ "សួនសាធារណៈ "(បទកាកគតិ)**

មើលនំ ! សួនច្បារ     មានស្មៅមានផ្កា     សិរមាន់ស្បែរឿង
ចេកទេសទំហូ     ពណ៌ក្រហមលឿង     ចេកផ្ចិតដុះឡើង
ចំកណ្ដាលសួន ។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ល្បែងសេរី

## រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ

## (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦)

# ថ្ងៃទី៦

**ម៉ោងទី១** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

ចលនាមូលដ្ឋាន៖ "បោះ"បោះបាល់ឬវត្ថុផ្តួលដបឬកំប៉ុង បោះបាល់ឬវត្ថុចូលកន្ត្រកចង់ព្យួរ
បោះបាល់ឬវត្ថុចូលកងឬរង្វង់ (រំលឹក)
(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី១)

ម៉ោងទី២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ**
**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**
**ទម្លាប់ល្អ៖ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)**

- គ្រូប្រើតុក្កតាដើម្បីសម្តែង៖ សួស្តី! មិត្តភក្តិទាំងអស់គ្នា សុខសប្បាយឬទេ? ថ្ងៃនេះខ្ញុំមានរឿងមួយមកនិទានឱ្យមិត្តភក្តិទាំងអស់គ្នាស្តាប់។ តើចង់ស្តាប់ទេបើចង់ស្តាប់ជួយប្រាប់ខ្ញុំមើលតើរឿងអ្វី? អូ! មិត្តភក្តិទាំងអស់គ្នាឆ្លាតមែន ។
- តុក្កតាចាប់ផ្តើមនិទានរឿង៖ កុមារសុខនិងសៅជាមិត្តសម្លាញ់នឹងគ្នា ថ្ងៃមួយបន្ទាប់ពីបានជួយធ្វើការឪពុកម្តាយរួច គេក៏នាំគ្នាដើរលេង។ ពេលគេនាំគ្នាដើរទៅដល់សាលារៀនមួយ ស្រាប់តែឃើញកុមារម្នាក់រត់ដួលរលាត់ជង្គង់ឈាមហូររហាម គេឃើញដូច្នេះក៏បាននាំគ្នាទៅមុខទៀត ដើរជិតដល់ភូមិមួយស្រាប់តែឃើញកុមារម្នាក់ទៀតដួលកង់នៅតាមផ្លូវបែកក្បាលកំពុងអង្គុយយំ។ គេទាំងពីរនាក់ក៏ឈរមើលមួយសន្ទុះ ហើយក៏បានដើរទៅមុខបន្តទៀត បន្ទាប់មកក៏បានឃើញកូនពូសំធ្លាក់ពីលើកាំជណ្តើរដួលសន្លប់បាត់មាត់ឈឹង ពួកគេឃើញដូច្នេះក៏នាំគ្នាដើរត្រឡប់ទៅផ្ទះវិញ មិនបានជួយកូនពូសំ និងប្រាប់ពូសំទេ។
- តុក្កតានិទានរឿងចប់ ក៏សួរទៅមិត្តភក្តិទាំងអស់គ្នា៖ រឿងដែលខ្ញុំនិទានអម្បាញ់មិញ តើកុមារសុខនិងសៅធ្វើដូច្នេះត្រឹមត្រូវដែរទេ? បើមិត្តភក្តិទាំងអស់គ្នាជួបរឿងដូចសុខនិងសៅ តើត្រូវធ្វើដូចម្តេច? ចំណែកខ្ញុំវិញក៏មិនធ្វើដូចសុខនិងសៅដែរ ខ្ញុំត្រូវជួយអ្នកទាំងអស់នោះ បើអញ្ចឹងខ្ញុំលាមិត្តទាំងអស់គ្នាសិនហើយណា។
- គ្រូប្រាប់ទៅកុមារបន្ថែម៖ កូនៗទាំងអស់គ្នាបើជួបមិត្តភក្តិ ឬអ្នកណាម្នាក់មានគ្រោះថ្នាក់ត្រូវចេះជួយគ្នាបើកូនមិនអាចជួយបានត្រូវរត់ទៅរកអ្នកជិតៗឱ្យជួយ។

## ម៉ោងទី៣ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ ភាសាខ្មែរ

## សម្គាល់តួអក្សរ ៖ " ធ "

**១វត្ថុបំណង៖ .**

-កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ "**ធ**" បានត្រឹមត្រូវ

-កុមារកំណត់បានពីរូបរាងឈ្មោះអក្សរ "**ធ**" និងរកពាក្យថ្មីផ្ដើមចេញពីអក្សរ "**ធ**" បានត្រឹមត្រូវ

-កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្ដើមពីអក្សរ "**ធ**" ។

**២សម្ភារបង្រៀន៖ .**

-ផ្ទាំងរូបភាព ធាង ធុង ធូប

- ប័ណ្ណពាក្យធាង ធុង ធូប និងល្បះ ចៅធាធំហើយធាត់

-ប៊ិក ហ្វឺត ស្កុត កាត់រៀបចំ )ឱ្យហើយ(

**៣ការរៀបចំកុមារ៖ .** អង្គុយជាអក្សរ អ៊ុយ "ប"

**៤ដំណើរការបង្រៀន៖ .**

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "**ធាង**" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្ដាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន រួចបង្ហាញប័ណ្ណពាក្យ "**ធាង**" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**ធុង**" ដោយលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូប ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារ ខៀន រួចបង្ហាញប័ណ្ណពាក្យ "**ធុង**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ធូប**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ធូប**" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្តិៗ ពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ធូប**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន ហើយបង្ហាញប័ណ្ណពាក្យ"**ធូប**" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "**ចៅធាធំហើយធាត់**" អានឱ្យកុមារស្ដាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្ដាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្ដាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអំបាញ់មិញឮសូរដូចម្ដេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

+ **ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសរង្វង់ជុំវិញតួអក្សរដែលមានរាងដូចគ្នា (ពេលកុមារឡើងមកគូសរង្វង់ជុំវិញអក្សរមានរាងដូចគ្នា បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសរង្វង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារបានគូសរង្វង់ដើម្បីផ្ទៀងផ្ទាត់ ។

+ **ប្រាប់ឈ្មោះតួអក្សរ៖**

- សួរកុមារ តើតួអក្សរដែលកូនគូសរង្វង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "**ធ**" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសរង្វង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"**ធ**" យ៉ាងធំនៅជ្រុងក្ដារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសរង្វង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"**ធ**" នាំកុមារអានអក្សរ"**ធ**" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- **គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)**

+ **ប្រៀបធៀបអក្សរស្រដៀង៖**

- គ្រូសរសេរអក្សរ "ធ ផ ជ " នៅលើក្ដារខៀន
- គ្រូអានអក្សរ "ធ ផ ជ " ឱ្យកុមារស្ដាប់ និងសង្កេត
- សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?
- កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

+ **រកពាក្យថ្មីផ្ដើមពីអក្សរ"ធ" ៖**

- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្ដាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្ដើមពីអក្សរ"**ធ**"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្ដារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- គ្រូនាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្ដងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"**ធ**" ឬទេ? បើមានតួអក្សរក្នុងពាក្យដូចតួអក្សរ "**ធ**" នេះ កុមារត្រូវធ្វើសញ្ញា**បាទ/ចាស** (ដោយក្ដាប់ដៃស្ដាំលើកឡើងត្រឹមភ្នែក រួចធ្វើសញ្ញាបាទ/ចាស ដូចងក់ក្បាល) រួចគ្រូគូសរង្វង់ជុំវិញពាក្យនោះ។ តែបើក្នុងពាក្យនោះមិនមានតួអក្សរ "**ធ**" ទេ កុមារត្រូវធ្វើសញ្ញា**ទេ** (ដោយលាដៃស្ដាំលើកឡើងត្រឹមភ្នែក រួចគ្រវីចុះឡើង) ដោយគ្រូមិនត្រូវធ្វើអ្វីទាំងអស់ចំពោះពាក្យនោះ។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

## ល្បែង៖ " ភ្លៀងធ្លាក់ "

### ១. វត្ថុបំណង៖

- កុមារប្រាប់ពីលក្ខណៈអាកាសធាតុ មុនពេល ក្នុងពេល និងក្រោយពេលភ្លៀងបានត្រឹមត្រូវ
- កុមារបង្ហាញពីលក្ខណៈអាកាសធាតុ មុនពេល ក្នុងពេល និងក្រោយពេលភ្លៀងបានត្រឹមត្រូវ
- កុមារមានការប្រុងប្រយ័ត្ន និងការពារខ្លួនពេលមានភ្លៀងធ្លាក់បានត្រឹមត្រូវ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "U" កុមារទាំងអស់គ្នាឈរជារង្វង់

### ៤. ដំណើរការបង្រៀន៖

- គ្រូសួកុមារ កូនសង្កេតមើលតើអាកសាធាតុ មុនពេល ក្នុងពេល និងក្រោយពេលភ្លៀងយ៉ាងដូចម្ដេចដែរ?
- គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភក្តិដែលបានរៀបរាប់ពីមុនពេល ក្នុងពេល និងក្រោយពេលភ្លៀង។
- តើកូនដឹងទេថាថ្ងៃនេះ គ្រូនាំកូនលេងល្បែងអ្វី?កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- **គ្រូណែនាំពីរបៀបលេង៖** គ្រូឱ្យកូនទាំងអស់ឈរជារង្វង់ ហើយគ្រូដកកូនម្នាក់ឱ្យឈរនៅកណ្ដាលវង់ធ្វើជាអ្នកដឹកនាំចំណែកកូនៗដ៏ទៃទៀត ត្រូវចាំស្ដាប់បញ្ជារបស់អ្នកដឹកនាំនៅពេលកូនឮអ្នកដឹកនាំបញ្ជាថា៖
  - ផ្គរ ៖ កូនទាំងអស់គ្នាត្រូវធ្វើកាយវិការយកដៃខ្ទប់ត្រចៀកទាំងសងខាង
  - ខ្យល់ ៖ កូនទាំងអស់គ្នាត្រូវធ្វើកាយវិការដោយយោលដៃយោលដងខ្លួនទៅឆ្វេងទៅស្ដាំ
  - ភ្លៀង ៖ កូនទាំងអស់គ្នាត្រូវធ្វើកាយវិការដោយយកដៃទាំងពីរទទូលក្បាល
  - ផ្លេកបន្ទោរ៖ កូនទាំងអស់គ្នាត្រូវធ្វើកាយវិការដោយយកដៃទាំងសងខាងខ្ទប់ត្រចៀកហើយឱនក្បាលអង្គុយចុះ
  - ផ្គរ ខ្យល់ ភ្លៀង ផ្លេកបន្ទោរ ៖កូនទាំងអស់គ្នាត្រូវធ្វើកាយវិការទាំង៤ខាងលើ ជាបន្តបន្ទាប់ឡើងវិញ។
  - ប្រសិនបើកូនណាធ្វើមិនទាន់ត្រឹមត្រូវគ្រូឱ្យកូនចេញក្រៅវង់ទៅឈរមួយកន្លែង
- គ្រូនាំកុមារលេងរបៀបនេះ ដោយលើកដំបូងគ្រូឱ្យអ្នកដឹកនាំហៅយឺតៗជាបន្តបន្ទាប់រួចហៅកាន់តែញាប់។
- គ្រូឱ្យកុមារលេងនិងផ្ទៀងផ្ទាត់រហូតដល់ចប់ម៉ោង។
- ពេលកូនលេងចប់គ្រូឱ្យអ្នកចាញ់ទាំងអស់ ធ្វើសកម្មភាពតាមអ្នកឈ្នះឱ្យធ្វើ ។

## ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## ប្រៀបធៀប ៖ " សត្វមាន់ សត្វទា "

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីភាពខុសគ្នារវាងសត្វមាន់ និងសត្វទា បានត្រឹមត្រូវ
- កុមារប្រៀបធៀបរវាងសត្វមាន់ និងសត្វទា បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការគ្នាក្នុងក្រុម បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាព សត្វមាន់ សត្វទា

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជាពាក់កណ្ដាលរង្វង់ និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

- **គ្រូសួរកុមារ៖**
  - ថ្ងៃមុនកូនសង្កេតពីសត្វអ្វីខ្លះ?(បើករណីកុមារឆ្លើយមិនបានគ្រូអាចធ្វើជាសម្លេងសត្វមាន់និងសត្វទាដើម្បីឱ្យកុមារនឹកឃើញ រួចឆ្លើយម្ដងទៀត
  - តើផ្នែកផ្សេងៗនៃសត្វមាន់មានអ្វីខ្លះ?(បើកុមារឆ្លើយមិនបានគ្រប់គ្រូបំផុសសំណួរបន្ថែម)
  - តើផ្នែកផ្សេងៗនៃសត្វទាមានអ្វីខ្លះ?(បើកុមារឆ្លើយមិនបានគ្រប់គ្រូបំផុសសំណួរបន្ថែម)
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះគ្រូមានផ្ទាំងរូបភាពមួយផ្ទាំងមកឱ្យកូនមើល តើកូនចង់ឃើញឬទេ?
- គ្រូឱ្យកុមារបិទភ្នែកទាំងអស់គ្នារួចគ្រូយកផ្ទាំងរូបភាពសត្វមាន់និងសត្វទាកាន់ដាក់ពីមុខបង្ហាញ
- គ្រូឱ្យកុមារបើកភ្នែកវិញ រួចសង្កេតរូបនៅពីមុខគ្រូ
- គ្រូសួរកុមារ តើនេះជារូបអ្វី? គ្រូយកមកធ្វើអ្វី?
- **គ្រូប្រាប់កុមារ៖**
  - ផ្ទាំងរូបភាពនេះគ្រូយកមកឱ្យកូនសង្កេតទៅយតាមក្រុមប្រៀបធៀបសត្វមាន់និងសត្វទា
  - ពេលក្រុមកូននីមួយៗបានផ្ទាំងរូបភាពនេះហើយ កូននាំគ្នាសង្កេតម្ដងម្នាក់ៗ(កុំដណ្ដើមគ្នា)
  - កូននាំគ្នាសង្កេតរួច នាំគ្នាជជែករកលក្ខណៈខុសគ្នានិងដូចគ្នារវាងសត្វមាន់និងសត្វទា
  - ពេលជជែកគ្នាចប់កូនត្រូវរកកូនម្នាក់ជាតំណាងក្រុមសម្រាប់ឡើងរាយការណ៍។
- គ្រូឱ្យកុមារម្នាក់ស្ម័គ្រចិត្តនិយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានពេញលេញគ្រូត្រូវប្រាប់សាឡើងវិញម្ដងទៀត
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- ឱ្យកុមារម្នាក់ក្នុងមួយក្រុមមកយកសម្ភារទៅអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលតាមក្រុមនីមួយៗ ដោយជួយបំផុសគំនិតបន្ថែម
- ពេលក្រុមនីមួយៗសង្កេតចប់គ្រូឱ្យពួកគេទៅអង្គុយនៅក្រុមធំវិញ ដោយយកផ្ទាំងរូបភាពទៅជាមួយទុកបង្ហាញពេលឡើងរាយការណ៍
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់ពីលទ្ធផលនៃពួកគេបានជជែកគ្នា (ម្ដងមួយក្រុម) ពេលកុមារនិយាយពាក្យមិនត្រឹមត្រូវតាមអក្ខរាវិរុទ្ធគ្រូត្រូវកែតម្រូវ ហើយនាំកុមារអានទាំងអស់គ្នា( ឧទាហរណ៍៖ កុមារគ្រប់ក្រុមប្រាប់មាន់និងទាមានលក្ខណៈដូចគ្នា ដូចជា រោម ក្បាល ភ្នែក ជើងពីរ ស្លាប... ឯ

លក្ខណៈខុសគ្នាជំពុះមាន់តូចស្រួច ជំពុះទាធំសំប៉ែត ម្រាមជើងមាន់មូល ម្រាមជើងទាសំប៉ែត...)

- គ្រូសរុបពីលទ្ធផលរបស់ក្រុមទាំងអស់ដែលបានបង្ហាញ(ពេលគ្រូសរុបត្រូវស្តាប់ តើក្រុមទាំងអស់នៅមិនទាន់ស្គាល់អ្វីខ្លះ? ដូច្នេះគ្រូត្រូវផ្តល់ចំណេះដឹងថ្មីអ្វីខ្លះបន្ថែមទៀតដល់កុមារ) (ឧទាហរណ៍៖ កុមារមិនបានប្រាប់លក្ខណៈខុសគ្នាពីម្រាមជើង ហែលទឹក ហើរ ក្រាប ភ្ញាស់កូន ផលប្រយោជន៍...)
- **គ្រូត្រូវបំផុសសំណួរដើម្បីផ្តល់ចំណេះដឹងថ្មីបន្ថែម៖**
  - តើម្រាមជើងសត្វមាន់និងសត្វទាយ៉ាងដូចម្តេចដែរ?
  - តើសត្វមាន់និងសត្វទាហែលទឹកដូចគ្នាដែរឬទេ?
  - តើសត្វមាន់និងសត្វទានេះចេះហើរដូចគ្នាឬទេ?
  - តើសត្វមាន់និងសត្វទាមានប្រយោជន៍អ្វីខ្លះ?
  - តើសត្វទាចេះក្រាបភ្ញាស់កូនដូចសត្វមាន់ឬទេ?
  - បើឪពុកម្តាយកូនចិញ្ចឹមសត្វមាន់និងសត្វទា តើកូនត្រូវធ្វើដូចម្តេច?
- គ្រូត្រូវប្រាប់កុមារនៅពេលពួកគេមិនអាចឆ្លើយបាននៅសំណួរណាមួយនោះ?
- គ្រូនាំកុមារអាននៅពាក្យខ្លះដែលជាចំណេះដឹងថ្មី **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី** កុមារឆ្លើយ) **?មេរៀនអ្វីដែរ ?** (ទៅតាមគំនិតរបស់គេម្នាក់ៗ
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពី ប្រៀបធៀប**" សត្វមាន់ សត្វទា "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។
-

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**ល្បែងសេរី**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦)**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

## ថ្ងៃទី៧

**ម៉ោងទី១** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

ចលនាចរន្ត៖ "ដើរ រត់ លោត បោះ" (ដើរលើជុំឥដ្ឋ រត់យកបាល់ទៅដល់ទីកំណត់ លោតចូលកងឬរង្វង់ បោះបាល់ចូលកន្ត្រក (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២ ម៉ោងទី១ ខែទី៦)

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

**✱ ទម្លាប់ល្អ៖ចេះជួយធ្វើការងារមនុស្សធំ (នៅផ្ទះ នៅសាលារៀន និងនៅភូមិ)**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## ប្រៀបធៀប ៖ ខ្លីជាង វែងជាង

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីវត្ថុចំនួនពីរមានប្រវែង ខ្លីជាង វែងជាងបានត្រឹមត្រូវ
- កុមារបង្ហាញវត្ថុ ចំនួនពីរមានប្រវែង ខ្លីជាង វែងជាងបានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តដោយសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖**

- បន្ទាត់ចំនួន ២ ( មួយខ្លី មួយវែង )
- ផ្ទាំងក្រដាសមានរូបខ្មៅដៃមួយដើម និងជ័រលុបមួយដុំ
- ខ្នាតបន្ទះក្រដាសតូចវែងចំនួន៣
- ស្កុតកាត់រួចជាស្រេច
- បន្ទាត់២ដើម ខ្លី វែង ខ្មៅដៃ១ដើម ជ័រលុបមួយដុំ ប៊ិច២ដើម ខ្លី វែង

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "U" អង្គុយជារាងរង្វង់ តាមក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបន្ទាត់ចំនួន២ ឱ្យកុមារសង្កេត រួចប្រៀបធៀប ដោយសួរកុមារថា៖ **តើបន្ទាត់ទាំង២នេះ មានអ្វីដែលខុសប្លែកពីគ្នា? កុមារប្រាប់បានពីភាពខុសប្លែកគ្នារវាងបន្ទាត់ទាំង២ តាមគំនិតរបស់គេម្នាក់ៗ**
- គ្រូបិទផ្ទាំងក្រដាសមានរូបជ័រលុបមួយដុំ និងខ្មៅដៃមួយដើម លើក្ដារខៀន

- គ្រូសួរថាៈតើកូនៗធ្វើដូចម្ដេចទើបដឹងថាជ័រលុបនិងខ្មៅដៃមួយណាខ្លីជាង មួយណាវែងជាង ?

**កុមារបង្ហាញហេតុផលបញ្ជាក់ ពីភាពខុសប្លែកគ្នារវាងជ័រលុបនិងខ្មៅដៃ ដោយដាក់ជ័រលុប និងខ្មៅដៃឱ្យផ្ដេកចុះ ឬ បញ្ឈរឱ្យស្មើគ្នា នោះគេនឹងរកឃើញដោយងាយ**

- គ្រូនាំកុមារវាស់ជ័រលុប និងខ្មៅដៃ ដោយប្រើខ្នាតជាបន្ទះក្រដាសតូចវែងវាស់ផ្ដេកដើម្បីកំណត់បញ្ញត្តិខ្លី វែង
- គ្រូវាស់ជ័រលុប និងខ្មៅដៃ ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបវាស់ដោយប្រើខ្នាតជាបន្ទះក្រដាសតូចវែងវាស់ផ្ដេក មួយៗ យឺតៗលើផ្ទាំងក្រដាសរូបជ័រលុប និងខ្មៅដៃ តាមទិសផ្ដេក ឱ្យកុមារសង្កេតនិងនិយាយបណ្ដើរចាប់វាស់ពីកន្លែងចាប់ផ្ដើម រហូតដល់ចប់ (ពេលវាស់ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថាបន្តិចទៀតគ្រូនឹងចែកសម្ភារ និងខ្នាតក្រដាសជាបន្ទះ តូចវែងសម្រាប់វាស់ ដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្ដើរ)។
- គ្រូឱ្យកុមារម្នាក់ក្នុងក្រុមនីមួយៗមកយកសម្ភារ ទៅអនុវត្តតាមការវាស់បង្ហាញរបស់គ្រូ ទៅតាមក្រុមនិមួយៗ ឱ្យបានត្រឹមត្រូវ ដូចទៅនឹងការវាស់ បង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូចាប់ផ្ដើមឱ្យកុមារក្នុងក្រុមវាស់ តាមការណែនាំ ដោយគ្រូដើរពិនិត្យ និងជួយសម្របសម្រួលការវាស់របស់ក្រុម និងជួយបំផុសគំនិតបន្ថែមចំពោះក្រុមខ្លះមិនទាន់យល់
- ពេលកុមារពិភាក្សាប្រៀបធៀបខ្លីជាង វែងជាង គ្រប់ក្រុមរួចហើយ គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជាអក្សរអ៊ុយវិញ។
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលនៃការប្រៀបធៀបខ្លីជាង វែងជាង ដោយឱ្យកុមារតំណាងក្រុមនីមួយៗយកសម្ភារដែលក្រុមខ្លួនបានប្រៀបធៀបមកឈរពីមុខលើកបង្ហញនិងរាយការណ៍លទ្ធផលនៃការពិភាក្សាប្រៀបធៀបសម្ភារខ្លីជាង វែងជាងរបស់ក្រុមខ្លួនម្ដងមួយក្រុមៗ ។ពេលផ្ទៀងផ្ទាត់លទ្ធផលតាមក្រុមនីមួយៗ គ្រូត្រូវ សសើរ លើកទឹកចិត្តដល់ក្រុមណាដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់ក្រុមឡើយ។
- ក្រោយពីបង្ហញលទ្ធផលហើយ គ្រូឱ្យតំណាងក្រុម យកសម្ភារទុកលើតុ របស់គ្រូវិញ

## ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## រឿងនិទានៈ មេអំបៅមួយគូ (និទាន)

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីសកម្មភាពតួអង្គតាមដំណើររឿងបានត្រឹមត្រូវ
- កុមារនិទានរឿង និងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ស្ដាប់រឿង យកគំរូតាមតួអង្គល្អ សហការជួយគ្នា និងនិទានរឿងឱ្យមិត្តភក្តិស្ដាប់

**២. សម្ភារបង្រៀនៈ** ផ្ទាំងរូបរឿងមេអំបៅមួយគូ (៤ឬ៥ផ្ទាំង)

**៣. ការរៀបចំកុមារៈ** អង្គុយជាបណ្ដុំ ជាជួរ

**៤.ដំណើរការបង្រៀនៈ(អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូបំផុសសំនួរៈ គ្រូបង្ហាញផ្ទាំងរូបភាពម្តងមួយៗរួចសួរកុមារថា កូនៗសង្កេតមើលមានរូបភាពអ្វីខ្លះ ? តើរឿងនិទាននេះមានចំណងជើងដូចម្តេច ?( កុមារទាយតាមគំនិតពួកគេម្នាក់ៗ )គ្រូសរុបចំណងជើងដែលកុមារបានទាយហើយសួរថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វី ?
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា សិក្សាសង្គម ចំណងជើងរឿងនិទាន " មេអំបៅមួយគូ " រួចសួរថា មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ ?ដូចច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- ប្រាប់ឈ្មោះអ្នកនិពន្ធៈ រឿងនិទាននេះនិពន្ធដោយអ៊ុំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម
- គ្រូនិទានរឿងដោយប្រើផ្ទាំងរូបភាពឱ្យកុមារស្តាប់ ដោយលើកដាក់សម្លេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នាៈ
  - ក្អាកក្អាយ ៖ សប្បាយរីករាយ រួសរាយ
  - រន្ធត់ ៖ ភ័យស្លុត ញ័ររន្ធត់
  - អង្វរ ៖ ឱ្យយល់ព្រមតាម ឱ្យចុះសម្រុង
- គ្រូបំផុសសំនួរ ៖ តើរឿងនិទាននេះចង់និយាយអំពីអ្វី ?
- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ម្តងទៀត
- គ្រូសួរកុមារថា ក្រោយពីកូនស្តាប់រឿងនេះចប់ តើនៅក្នុងរឿងនេះមានតួអង្គប៉ុន្មាននាក់ ? ហេតុអ្វីបានជាផ្កាកូឡាបនិងផ្កាស្បៃរឿងមិនឱ្យមេអំបៅចូលជ្រក ? ហេតុអ្វីបានជាមេអំបៅទាំងពីរមិនបោះបង់ចោលគ្នា ? តើអ្នកណាបានជួយមេអំបៅទាំងពីរ ?តើតួអង្គណាដែលកូនស្រលាញ់ជាងគេ ?ហេតុអ្វី ?
- គ្រូឱ្យកុមារនិទានឡើងវិញ។

**អត្ថបទរឿង "មេអំបៅមួយគូ "**

ក្នុងសួនមួយមានមេអំបៅមួយគូ មួយមានពណ៌ក្រហម មួយទៀតពណ៌លឿង។ មេអំបៅទាំងពីរជាមិត្តភក្តិជិតស្និទ្ធស្រឡាញ់គ្នាដូចបងប្អូនបង្កើត។ ថ្ងៃណាក៏ដូចថ្ងៃណាមេអំបៅទាំងគូនេះតែងតែបបួលគ្នាហើរធ្វេលធ្វាត់លេងយ៉ាងសប្បាយរីករាយនៅក្នុងសួនច្បារដែលមានផ្កាកូឡាបក្រហម និងផ្កាស្បៃរឿង។ ថ្ងៃមួយមេអំបៅទាំងគូកំពុងតែហិចហើរ ចុះឡើង សើចលេងសប្បាយក្អាកក្អាយក្នុងសួនច្បារ ស្រាប់តែផ្ទៃមេឃប្រែជាងងឹត ភ្លៀងធ្លាក់មកយ៉ាងខ្លាំង ដំណក់ទឹកធំៗ ធ្លាក់មកប៉ះលើស្លឹកឈើលាន់ឮប្រាវៗ ធ្វើឱ្យមេអំបៅទាំងពីរភ័យរន្ធត់។ វាហើរតម្រង់ទៅដើមផ្កាកូឡាបដែលនៅជិតនោះ រួចនិយាយព្រមគ្នាថា ៖ បងកូឡាបអើយ! ស្លាបខ្ញុំទទឹកជោគអស់ហើយ យើងខ្ញុំរងាណាស់! យើងខ្ញុំសុំចូលជ្រកក្រោមមែកផ្ការបស់បងផងណា។

កូឡាបឆ្លើយ ៖ មេអំបៅមានពណ៌ក្រហមដូចផ្កាកូឡាបខ្ញុំ ទើបអាចជ្រកបាន រីឯមេអំបៅពណ៌លឿងហើរទៅវិញទៅខ្ញុំមិនឱ្យជ្រកទេ។

មេអំបៅទាំងគូសម្លឹងមើលមុខគ្នា ហើយមេអំបៅពណ៌ក្រហមនិយាយអង្វរថា ៖ បងកូឡាបអើយ! យើងទាំងពីរជាមិត្តនឹងគ្នាសូមបងមេត្តាឱ្យយើងទាំងពីរនាក់ជ្រកផង។ ផ្កាកូឡាបឆ្លើយដាច់ខាតមិនព្រមឱ្យមេអំបៅពណ៌លឿងចូលជ្រកឡើយ។ មេអំបៅទាំងគូអស់សង្ឃឹមក៏នាំគ្នាហើរទៅសុំផ្កាស្បៃរឿងជ្រកម្តង។

មេអំបៅទាំងគូនិយាយព្រមៗគ្នាថា ៖ បងផ្កាស្បៃរឿងអើយ! ស្លាបខ្ញុំទទឹកជោកអស់ហើយ យើងខ្ញុំរងាណាស់ យើងខ្ញុំសុំចូលជ្រកក្រោមមែកផ្ការបស់បងផងណា។

ផ្កាស្មៅរឿងនិយាយថា ៖ មេអំបៅពណ៌លឿងដូចផ្កាស្មៅរឿងខ្ញុំ ទើបអាចជ្រកបាន រីឯមេអំបៅពណ៌ក្រហម ហើរទៅវិញទៅ ខ្ញុំមិនឱ្យជ្រកទេ។ ទោះបីមេអំបៅទាំងពីរខិតខំអង្វរយ៉ាងណា ក៏ផ្កាស្មៅរឿងអនុញ្ញាតឱ្យតែមេអំបៅពណ៌លឿងជ្រកប៉ុណ្ណោះ។ភ្លៀងធ្លាក់កាន់តែខ្លាំងធ្វើឱ្យស្លាបមេអំបៅកាន់តែទទឹកជោកជាំហើរលែងរួច ធ្លាក់មកលើដី រងាញ័រខ្លួនចំប្រប់ ពុំព្រមបែកគ្នាឡើយ។ មួយសន្ទុះក្រោយមកភ្លៀងក៏រាំង ព្រះអាទិត្យដែលនៅខ្ពស់លើអាកាសក៏បានសម្លឹងមើលចុះក្រោម លោកញញឹមហើយសរសើរមេអំបៅទាំងគូដែលចេះស្រឡាញ់គ្នា។ ដើម្បីស្រោចស្រង់អាយុជីវិតមេអំបៅ លោកបានបញ្ចេញពន្លឺ ផ្ទៃមេឃស្រឡះថៃងថាំង ធ្វើឱ្យស្លាបរបស់មេអំបៅទាំងពីរឆាប់ស្ងួត ហើយទទះស្លាប ហោះហើរឆាបលេងប្រឡែងពេញក្នុងសួនច្បារ។

មេអំបៅទាំងគូនិយាយព្រមៗគ្នាថា ៖ សូមអគុណបងព្រះអាទិត្យខ្លាំងណាស់ យើងខ្ញុំមិនចងកំហឹងនឹងផ្កាកូឡាប និងផ្កាស្មៅរឿងឡើយ ពីព្រោះផ្កាកូឡាប និងផ្កាស្មៅរឿង បានធ្វើឱ្យអារម្មណ៍យើងខ្ញុំស្រស់ថ្លាជានិច្ច។ រីឯផ្កាកូឡាប និងផ្កាស្មៅរឿង ក៏បានសារភាពកំហុសរបស់ខ្លួន ហើយសន្យាថាអំណោះតទៅនឹងខិតខំកែខ្លួនឱ្យល្អប្រសើរ។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## ល្បែង៖ ប្រព័ន្ធគ្រួសារឈ្មោះម្ហូបអាហារ

**១.វត្ថុបំណង៖**

- កុមាររៀបរាប់ពីឈ្មោះអាហារគ្រប់ប្រភេទ បានត្រឹមត្រូវ
- កុមារបង្ហាញឈ្មោះអាហារគ្រប់ប្រភេទ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុម

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរអ៊ុយ "U" ជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ តើរាល់ថ្ងៃម៉ាក់ធ្វើអ្វីកូនហូបខ្លះ? ដូចច្នេះកូនៗទាយមើលថាថ្ងៃនេះគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ ។ ពេលកុមារប្រាប់រួច គ្រូត្រូវសរុបនូវអ្វីដែលពួកគេបានប្រាប់
- គ្រូប្រាប់កុមារ ថ្ងៃនេះគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង "ប្រព័ន្ធគ្រួសារឈ្មោះម្ហូបអាហារ"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអំបាញ់មិញមានកូនណាទាយត្រូវឬទេ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើយសំណួរគ្រូទៀតណា !
- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - គ្រូឱ្យកូនលេងជាមួយគ្រូម្តងមួយក្រុម ឯកូនដែលគ្រូមិនទាន់ឱ្យលេង កូនត្រូវជួយស្តាប់មិត្តភក្តិយើងនិយាយ

- ក្រុមដែលគ្រូនាំលេងមុនគេ ត្រូវមកឈរជារង្វង់នៅកណ្ដាលថ្នាក់ ឯកូនដែលគ្រូមិនទាន់ឱ្យលេង ត្រូវអង្គុយនៅកៅអីជុំវិញក្រុមលេង ប្រហែលកន្លះម៉ែត្រ ដើម្បីសង្កេតអ្នកធ្វើខុស
- ដំបូងកូនត្រូវរកអ្នកចាប់ផ្ដើមនិយាយមុនគេ (កូនៗត្រូវឯកភាពយល់ព្រមកំណត់ឱ្យមិត្តភក្តិណាម្នាក់ជាអ្នកចាប់ផ្ដើមមុនគេ )
- ពេលគ្រូឱ្យសញ្ញាចាប់ផ្ដើម កូនដែលត្រូវចាប់ផ្ដើមមុនគេ ត្រូវនិយាយឈ្មោះម្ហូបអាហារមួយមុខ រួចហើយអ្នកនៅឈរស្ដាំដៃត្រូវប្រាប់ឈ្មោះម្ហូបអាហារមួយមុខទៀតផ្សេងពីគ្នា រួចបន្តទៅអ្នកបន្ទាប់ទៀត បើកូនណាប្រាប់ឈ្មោះម្ហូបអាហារដូចអ្នកមុនដែរនោះ កូនជាអ្នកចាញ់ ហើយកូនត្រូវដកចេញពីក្រុមទៅឈរនៅមួយកន្លែង ហើយកូនដែលនៅក្នុងក្រុម ត្រូវធ្វើរបៀបនេះបន្តរហូតដល់អ្នកចុងក្រោយ ។
- ពេលក្រុមកូនបានបញ្ចប់ការលេងហើយ ត្រូវប្ដូរឱ្យក្រុមកូនផ្សេងទៀតមកលេងម្ដង ហើយក្រុមកូនទៅអង្គុយវិញ ដើម្បីជួយសង្កេតអ្នកធ្វើខុស

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្ដងទៀត)
- គ្រូត្រូវរៀបចំកុមារមួយក្រុម ឱ្យឈរជារង្វង់នៅកណ្ដាលថ្នាក់ ឯកុមារក្រុមផ្សេងទៀតឱ្យអង្គុយជុំវិញក្រុមដែលត្រូវលេង ចាំជួយសង្កេត និងស្ដាប់អ្នកធ្វើខុស
- មុននឹងនាំកុមារលេង គ្រូត្រូវប្រាប់កុមារក្នុងក្រុមឱ្យរកឈ្មោះម្ហូបអាហារម្នាក់ឱ្យបានមួយមុខ
- គ្រូនាំកុមារលេងម្ដងមួយក្រុមៗ ហើយគ្រូជាអ្នកឱ្យសញ្ញាចាប់ផ្ដើម។ ចំពោះការជ្រើសរើសកុមារចាប់ផ្ដើមនិយាយមុនគេនោះ គ្រូអាចជាអ្នកកំណត់ ឬឱ្យកុមារក្នុងក្រុមជាអ្នកសម្រេច ឬឱ្យកុមារប៉ាវរកអ្នកឈ្នះ (បើកុមារមានចំនួនតិច) ក៏បាន
- គ្រូនាំកុមារលេងដោយប្ដូរក្រុមលេង គឺក្រុមលេងរួចឱ្យទៅអង្គុយវិញ ឯក្រុមអង្គុយឱ្យមកលេងម្ដងវិញ លេងមួយម្ដងផ្លៀងផ្លាត់មួយម្ដង
- គ្រូនាំកុមារលេងបន្តបន្ទាប់រហូតអស់ក្រុម រហូតចប់ម៉ោង
- ពេលបញ្ចប់ការលេងគ្រប់ក្រុម គ្រូឱ្យកុមារទៅអង្គុយក្រុមជំវិញ ហើយអ្នកដែលចាញ់ទាំងអស់ត្រូវមកឈរពីមុខ រង់ចាំមិត្តភក្តិទាំងអស់ឱ្យធ្វើសកម្មភាពផ្សេងៗ ដូចជា ច្រៀង រាំ ដើរទា ដើរបង្ហាញម៉ូត ឬសកម្មភាពផ្សេងៗទៀត ។

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

### ល្បែងៈ លោកមឹកម្រាមដៃ (រំលឹក)

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២ ខែ៦ ម៉ោងទី៦)

**ថ្ងៃទី៨**

**ម៉ោងទី១** (រយៈពេល ៣០នាទី)

**មុខវិជ្ជាៈ ចិត្តចលភាព**

ល្បែងចលនា ៖ បោះផ្លូលកូនកោយ (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៣ ខែ៦ ម៉ោងទី១)

**អនុវត្តតេស្តលើកទី២**

**ថ្ងៃទី៩**

**ម៉ោងទី១ រយៈពេល៖ ៣០នាទី**

**មុខវិជ្ជាៈ ចិត្តចលភាព**

ហាត់ប្រាណតាមរឿងនិទាន ៖ យើងអុំទូកលេង (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៤ ខែ៦ ម៉ោងទី១)

**អនុវត្តតេស្តលើកទី២**

**ថ្ងៃទី១០**

**ម៉ោងទី១ រយៈពេល៖ ៣០នាទី**

**មុខវិជ្ជាៈ ចិត្តចលភាព**

ហាត់ប្រាណតាមរឿងនិទាន ៖ បូណា និងនារីនាំគ្នាទៅលេងចម្ការស្វាយ (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៥ ខែ៦ ម៉ោងទី១)

**អនុវត្តតេស្តលើកទី២**

# ថ្ងៃទី១១

## ម៉ោងទី១ រយៈពេល៖ ៣០នាទី

## មុខវិជ្ជា៖ ចិត្តចលភាព

ចលនាមូលដ្ឋាន៖ "គប់" (គប់បាល់ឬវត្ថុផ្ដួលកំប៉ុង គប់បាល់ឬវត្ថុឱ្យចំណុច គប់បាល់ឬវត្ថុយកចម្ងាយ)

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបគប់បាល់តាមការណែនាំ បានត្រឹមត្រូវ
- កុមារគប់បាល់មានលំនឹងតាមការណែនាំ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន អំណត់ ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បាល់ កំប៉ុង

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុម ឱ្យកុមារឈរជាជួរ ករណីកុមារច្រើនអាចចែកជា៦ក្រុម ដោយ២ក្រុមធ្វើ១សកម្មភាព

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងដំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរ ទៅតាមទីកន្លែងដែលគ្រូបានកំណត់
- **គ្រូឱ្យកុមារធ្វើចលនាខ្យល់បក់** (ខ្យល់បក់តិចៗ ខ្យល់បក់ខ្លាំងៗ ទៅមុខ ទៅក្រោយ) ឥឡូវនេះកូនៗចាំធ្វើចលនាខ្យល់បក់តាមគ្រូទាំងអស់គ្នា កូនលើកដៃឡើងទៅលើ ពេលឮគ្រូប្រាប់ថាខ្យល់បក់តិចៗ កូនៗត្រូវរេដៃទៅឆ្វេងរួចទៅស្ដាំតិចៗ ពេលឮគ្រូប្រាប់ថាខ្យល់បក់ខ្លាំងៗ កូនៗត្រូវរេដៃទៅឆ្វេងរួចទៅស្ដាំខ្លាំងៗ ពេលឮគ្រូប្រាប់ថាខ្យល់បក់ទៅមុខ កូនត្រូវបោះដៃឱនទៅមុខមួយៗ ពេលគ្រូប្រាប់ថាខ្យល់បក់ទៅក្រោយ កូនត្រូវបោះដៃទៅក្រោយមួយៗ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាមូលដ្ឋាននីមួយៗ ដោយគ្រូគប់បាល់បង្ហាញតាមសកម្មភាពនីមួយៗ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្ដងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗ៖
  - ក្រុមទី១៖ គប់បាល់ឬវត្ថុផ្ដួលកំប៉ុង
  - ក្រុមទី២៖ គប់បាល់ឬវត្ថុឱ្យចំចំណុច
  - ក្រុមទី៣៖ គប់បាល់ឬវត្ថុយកចម្ងាយ
- បន្ទាប់ពីកុមារបានគប់បាល់តាមរបៀបខាងលើរួច គ្រូឱ្យក្រុមនីមួយៗប្ដូរសកម្មភាពគប់បាល់តាមសញ្ញារបស់គ្រូ
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានធ្វើគ្រប់សកម្មភាព
- **គ្រូសួរកុមារ៖**
  - **តើមុននេះ កូនៗបានធ្វើសកម្មភាពអ្វីខ្លះ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា **ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព អំពី៖ ចលនាមូលដ្ឋានគប់"គប់បាល់ឬវត្ថុផ្ដួលកំប៉ុង គប់បាល់ឬវត្ថុឱ្យចំចំណុច គប់បាល់ឬវត្ថុយកចម្ងាយ"**
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណា

ឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បាន ត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត )

- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- កូនៗហត់ទេ? ដើម្បីឱ្យមានកម្លាំងកូនធ្វើដូចម្តេច? (កុមារឆ្លើយហិតផ្កា) ហើយផ្កាអីក្រអូបជាងគេ? គេដាំនៅឯណា? ដើមវាទាប ឬខ្ពស់ ? ដូចនេះគ្រូនាំកូនទៅបេះផ្កាហិតដោយដកដង្ហើមវែងៗ (កូនៗយកដៃធ្វើសកម្មភាពបេះផ្កា យកមកដាក់ជិតច្រមុះរួចហិត ហើយដកដង្ហើមចូល ចេញឱ្យវែងៗ? កុមារឆ្លើយថាក្រអូប) គ្រូឱ្យកុមារហិតផ្កាឱ្យបានពីរ ឬបីដងដោយដកដង្ហើមវែងៗ ។

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

*** ទម្លាប់ល្អ៖ ពេលឃើញអ្នកដទៃជ្រុះសម្ភារ ត្រូវរើសជូនគាត់វិញ**

- គ្រូនិទានរឿងខ្លី៖ ថ្ងៃមួយជាថ្ងៃសម្រាករៀនបូណានិងនារី ក៏បបួលគ្នាដើរលេងនៅសួនច្បារ។ ពេលពួកគេកំពុងរត់លេងស្រាប់តែឃើញមីងសំគាត់យួរផ្លែប៉ោមមួយស្បោង ហើយក៏ធ្លាយស្បោងជ្រុះផ្លែប៉ោមមកដី។ នារីឃើញដូចនេះ ក៏ហៅបូណាឱ្យមកជួយរើសប៉ោមមីងសំ ប៉ុន្តែបូណានៅតែរត់លេងដដែល។ នារីមិនចាំបូណា ទេនាងក៏ទៅជួយរើសផ្លែប៉ោមមីងសំ ទាល់តែអស់ពីលើដី ទើបរត់ទៅលេងវិញ។
- គ្រូសួរកុមារ៖ តើនារីនិងបូណា កូនគិតថានារីជាកូនដូចម្តេច?ហេតុអ្វី? បូណាជាកូនដូចម្តេច? ហេតុអ្វី? តើកូនធ្វើតាមអ្នកណា?ហេតុអ្វី?
- គ្រូឱ្យកុមារសាកល្បងអនុវត្ត៖ ដោយឱ្យកុមារម្នាក់កាន់ខ្មៅដៃច្រើនដើម និងកុមារបួននាក់ជាអ្នកនាំគ្នាលេង ពេលគ្រូឱ្យសញ្ញាចាប់ផ្តើមកុមារម្នាក់ដែលមានកាន់ខ្មៅដៃក៏ចាប់ផ្តើមដើរពីទីដែលគ្រូកំណត់។ ហើយកុមារបួននាក់ទៀតក៏ចាប់ផ្តើមនាំគ្នាលេងដែរ។ កុមារម្នាក់ដែលកាន់ខ្មៅដៃដើរនោះ ពេលដើរបានបន្តិចក៏ជ្រុះខ្មៅដៃពីដៃធ្លាក់ទៅដី។ ឯកុមារបួននាក់ទៀតដែលកំពុងនាំគ្នាលេង ឃើញដូច្នោះពួកគេក៏មកជួយរើសខ្មៅដៃមិត្តភក្តិទាល់តែអស់ ឯកុមារម្នាក់នោះក៏អរគុណមិត្តភក្តិ ទាំងបួននាក់នោះដែរ។
- គ្រូណែនាំបន្ថែម៖ ពេលកូនៗទៅណាឬនៅឯណាក៏ដោយបើឃើញមានអ្នកណាម្នាក់ធ្វើឱ្យជ្រុះរបស់អ្វីមួយ ពួកកូនត្រូវតែនាំគ្នាជួយរើសពួកគាត់ឱ្យអស់មិនត្រូវដើរហួសនោះទេ។

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ គណិតវិទ្យា

### ល្បែង៖ បង្កើតសំណុំចំនួនតូចៗពី៥ ដល់១៥

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបបង្កើតសំណុំចំនួនតូចៗពី ៥ ដល់១៥ បានត្រឹមត្រូវ
- កុមារបង្ហាញចំនួនសំណុំតូចៗពី ៥ ដល់១៥ បានត្រឹមត្រូវ
- កុមារខិតខំ សហការគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖** -ចំនួនចំណុច ៥ ដល់១៥ សន្លឹក - គ្រាប់គ្រួសចំនួន៤៥ គ្រាប់

**៣. ការរៀបចំកុមារ៖** - អង្គុយជារាងអក្សរ(U)- អង្គុយតាមក្រុមតូចៗ ជារង្វង់

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូបំផុសសំណួរ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជា៖គណិតវិទ្យា អំពីល្បែង៖បង្កើតសំណុំចំនួនតូចៗ ពី ៥ ដល់១៥(គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនទាំងអស់គ្នា)
- បង្ហាញប័ណ្ណចំណុចដែលមានចំនួនពី៥ ដល់១៥ឱ្យកូនសង្កេត និងរាប់ចំនួននៅក្នុងប័ណ្ណនោះម្តងមួយៗ **គ្រូណែនាំពីរបៀបលេង**
- គ្រូឱ្យកុមារលេងជាក្រុមតូចៗហើយក្នុងក្រុមនីមួយៗត្រូវបានគ្រាប់គ្រួសចំនួន១៥ គ្រាប់ហើយកូនដាក់នៅកណ្តាលវង់
  - ពេលគ្រូលើកប័ណ្ណចំនួនចំណុច មានចំនួនប៉ុន្មាន កូនក្នុងក្រុមត្រូវចាប់គ្រាប់គ្រួសនោះផ្តុំទៅតាមចំនួនដែលគ្រូបានលើកទៅជាមួយដុំៗ
  - ពេលក្រុមនីមួយៗផ្តុំបានហើយ កូនប្រាប់គ្រូ តើកូនផ្តុំបានប៉ុន្មានដុំហើយមាននៅសល់ឬមិនសល់? ពេលកូនធ្វើហើយកូនត្រូវពិនិត្យមើលឡើងវិញ ហើយពេលកូនៗរើសគ្រាប់គ្រួស កូនត្រូវចែកគ្នា កុំដណ្តើមគ្នា កូនធ្វើម្នាក់ម្តង។ ពេលគ្រូលើកចំនួនផ្សេងៗទៀតកូនត្រូវធ្វើដូចគ្នាដែរ។
- ឱ្យកុមារ១ឬ២នាក់និយាយឡើងវិញពីអ្វីដែលគ្រូណែនាំ(បើកុមារនិយាយមិនបានទេត្រូវនិយាយប្រាប់ឡើងវិញម្តងទៀត)
- ចែកកុមារជា៣ក្រុម រួចឱ្យទៅអង្គុយជារង្វង់តាមកន្លែងដែលគ្រូបានរៀបចំ
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅអនុវត្ត
- កុមារអនុវត្តទៅតាមក្រុម គ្រូដើរសម្របសម្រួលពេលលើកប័ណ្ណចំនួនចំណុចហើយ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលម្តងមួយក្រុមៗ ហើយមុននឹងផ្ទៀងផ្ទាត់ត្រូវឱ្យតំណាងក្រុមនិយាយប្រាប់ពីអ្វីដែលពួកគេធ្វើបាន ហើយឱ្យក្រុមដទៃជួយកែលម្អបើករណីធ្វើខុស
- គ្រូនាំកុមារលេងរបៀបនេះបន្តបន្ទាប់ រហូតដល់ម៉ោង ដោយលើកចំនួនប័ណ្ណឆ្លាស់គ្នា មិនតាមលំដាប់ ។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ ជីតាខ្ញុំ (ពេលទី១)

**១. វត្ថុបំណង៖**

- កុមារប្រាប់បាន ពី របៀបច្រៀង និងធ្វើកាយវិការតាមបទច្រៀង បានត្រឹមត្រូវ
- កុមារច្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបានត្រឹមត្រូវ
- កុមារស្រឡាញ់ចូលចិត្តច្រៀង និងសហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** -គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "U"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- កូនទាំងអស់គ្នា កូនៗមានស្គាល់សត្វអ្វីខ្លះនៅផ្ទះរបស់កូន?

- អញ្ចឹងថ្ងៃនេះគ្រូច្រៀងចម្រៀងបទ "ជីតាខ្ញុំ" ឱ្យកូនស្តាប់និងធ្វើការវិការមួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃបទចម្រៀង
- ឥឡូវនេះគ្រូ ពន្យល់ពាក្យពិបាក និងអត្ថន័យនៃបទចម្រៀង(ប្រសិនបើមាន)
  - បទចម្រៀងនេះគឺចង់អប់រំកុមារឱ្យចេះធ្វើកាយវិការនិងគ្រាប់តាមសម្លេងសត្វដែលយើងចិញ្ចឹម
- គ្រូអានអត្ថបទមួយឃ្លាម្តងៗ ឱ្យកុមារស្តាប់រហូតដល់ចប់ចម្រៀង
- គ្រូនាំកុមារកម្តៅសម្លេង (គ្រាប់តាម សម្លេងឡាឡាឡាឡាឡាឡាឡា ឡាឡាឡាឡាឡា ឡាឡាឡាឡាឡាឡាឡាឡាឡាឡាឡាឡា )
- ឥឡូវកូនៗទាំងអស់គ្នាច្រៀងនិងធ្វើកាយវិការតាមគ្រូទាំងអស់គ្នាណា គ្រូនាំកុមារច្រៀងនិងធ្វើកាយវិការម្តងមួយឃ្លាៗ
- ដូច្នេះកូនៗច្រៀងនិងធ្វើកាយវិការឡើងវិញម្តងទៀតជាមួយគ្រូ
- ម្តងនេះគ្រូច្រៀងតិចៗហើយកូនទាំងអស់គ្នាច្រៀងឱ្យឮៗ
- គ្រូសួរកុមារ តើអំបាញ់មិញកូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈចម្រៀង មេរៀន "ជីតាខ្ញុំ "អ្នកនិពន្ធដោយលោកអំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**ចម្រៀង៖ "ជីតាខ្ញុំ"**

| | | |
|---|---|---|
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមមាន់អ៊ីយ៉ាអ៊ីយ៉ាយ៉ូ |
| យំឮតត តតឯណោះ | យំឮតត តតឯណោះ | ឯណោះក៏តតឯណាៗ ក៏តត តត។ |
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមទា អ៊ីយ៉ាអ៊ីយ៉ាយូ |
| យំឮកាបកាបឯណោះ | យំឮកាបកាបឯណោះ | ឯណោះក៏កាប ឯណាៗ ក៏កាប កាប។ |
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមគោ អ៊ីយ៉ាអ៊ីយ៉ាយូ |
| យំឮម៉ម៉ឯណោះ | យំឮម៉ម៉ឯណោះ | ឯណោះក៏ម៉ ឯណាៗ ក៏ម៉ម៉។ |
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមជ្រូក អ៊ីយ៉ាអ៊ីយ៉ាយូ |
| យំឮអ៊ូកអ៊ូកឯណោះ | យំឮអ៊ូកអ៊ូកឯណោះ | ឯណោះក៏អ៊ូក ឯណាៗ ក៏អ៊ូក អ៊ូក។ |

**របៀបធ្វើកាយវិការតាមបទចម្រៀង**

- ជីតាខ្ញុំ(យកដៃស្តាំមកដាក់លើទ្រូង)គាត់នៅឯស្រែ(លាតដៃទៅមុខរវេធ្វងរស្តាំ)
- អ៊ីយ៉ាអ៊ីយ៉ាយ៉ូ(យកម្រាមចង្អុលដៃស្តាំឆ្វេងរចុះឡើងៗ)
- នៅឯស្រែគាត់ចិញ្ចឹមមាន់(យកម្រាមដៃស្តាំចង្អុលទៅមុខ)
- យំឮតត តតឯណោះ យំឮតត តតឯណោះ ឯណោះក៏តតឯណាៗ ក៏តត តត(យកដៃទាំង២ដាក់ខ្ទប់ជិតមាត់រវេធ្វងរស្តាំ)
- ជីតាខ្ញុំគាត់នៅឯស្រែ(ធ្វើកាយវិការដូចខាងលើ) អ៊ីយ៉ាអ៊ីយ៉ាយ៉ូ(ធ្វើកាយវិការដូចខាងលើ) នៅឯស្រែគាត់ចិញ្ចឹមទា(ធ្វើកាយវិការដូចខាងលើ)
- យំឮកាបកាបឯណោះ យំឮកាបកាបឯណោះ ឯណោះក៏កាប ឯណាៗ ក៏កាប កាប(យកដៃទាំង២ផ្គាប់ផ្គុំគ្នាត្រឹមមាត់រវេធ្វងរស្តាំ)

- ជីតាខ្ញុំគាត់នៅឯស្រែ(ធ្វើកាយវិការដូចខាងលើ) អ៊ីយ៉ាអ៊ីយ៉ាយ៉ូ(ធ្វើកាយវិការដូចខាងលើ) នៅឯស្រែគាត់ចិញ្ចឹមគោ(ធ្វើកាយវិការដូចខាងលើ
- យំឮម៉ម៉ឯណោះយំឮម៉ម៉ឯណោះ ឯណោះក៏ម៉ ឯណាៗ ក៏ម៉ម៉(យកដៃទាំង២ដាក់ខ្ទប់ជិតមាត់រេឆ្វេងស្ដាំ)
- ជីតាខ្ញុំគាត់នៅឯស្រែ(ធ្វើកាយវិការដូចខាងលើ) អ៊ីយ៉ាអ៊ីយ៉ាយ៉ូ(ធ្វើកាយវិការដូចខាងលើ) នៅឯស្រែគាត់ចិញ្ចឹមជ្រូក(ធ្វើកាយវិការដូចខាងលើ)
- យំឮអ៊ូកអ៊ូកឯណោះ យំឮអ៊ូកអ៊ូកឯណោះ ឯណោះក៏អ៊ូក ឯណាៗ ក៏អ៊ូក អ៊ូក(យកដៃស្ដាំប៉ះចុងច្រមុះរេឆ្វេងស្ដាំ)

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

### ល្បែង ៖ សង្កេតរូបភាពដែលដូចគ្នា

**១. វត្ថុបំណង៖**

- កុមារប្រាប់ឈ្មោះរូបភាពដែលមានលក្ខណៈដូចគ្នាបានត្រឹមត្រូវ
- កុមារបង្ហាញរូបភាពដែលមានលក្ខណៈដូចគ្នាបានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាពចំនួន៣ផ្ទាំង ហ្វឺតចំនួន៣ដើម ស្កុត កន្ត្រៃ

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារង្វង់តាមក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញផ្ទាំងរូបភាពដែលគ្រូបានរៀបចំទុក រួចឱ្យកុមារប្រាប់ឈ្មោះក្នុងរូបភាពនោះ
- គ្រូណែនាំពីរបៀបលេង
  - គ្រូឱ្យកូនលេងជាក្រុមដោយមួយក្រុមៗមានផ្ទាំងរូបភាពមួយសន្លឹកនិងប៊ិចហ្វឺតមួយដើម
  - ពេលក្រុមកូនបានរូបភាពមួយសន្លឹកនេះហើយកូននាំគ្នាសង្កេតនៅក្នុងផ្ទាំងរូភាពនេះ មើលរូបភាពណាដែលដូចគ្នា កូនត្រូវយកប៊ិចហ្វឺតមកគូសរង្វង់ជុំវិញរូបភាពនោះ។ពេលកូនសង្កេតត្រូវចែកគ្នាសង្កេតម្ដងម្នាក់កុំដណ្ដើមគ្នា។
  - ពេលក្រុមកូនណាធ្វើរួចហើយ ត្រូវយកមកបិទនៅលើក្ដារខៀនតាមកន្លែងដែលគ្រូបានរៀបចំឱ្យ ហើយយកប៊ិចហ្វឺតទៅទុកលើតុគ្រូវិញ។
- ឱ្យកុមារ១ឬ២នាក់និយាយឡើងវិញពីរបៀបដែលក្រុមត្រូវធ្វើតាមការណែនាំរបស់គ្រូ
- ឱ្យកុមារទៅអង្គុយ នៅតាមក្រុម តាមកន្លែង ដែលគ្រូបានរៀបចំ
- ឱ្យតំណាងក្រុមឡើងមកយកសម្ភារទៅអនុវត្តនៅតាមក្រុម
- តាមក្រុមនីមួយៗអនុវត្ត ហើយគ្រូជាអ្នកសម្របសម្រួល
- ពេលកុមារធ្វើចប់គ្រប់ក្រុមហើយឱ្យពួកគេទៅអង្គុយកន្លែងដើមវិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗដែលបានបិទលើក្ដារខៀន ដោយឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញពីអ្វីដែលក្រុមបានធ្វើ(ធ្វើម្ដងមួយក្រុមៗ)។
- **គ្រូសួរកុមារ៖**

- កូនៗទាំងអស់គ្នាសប្បាយទេ?**តើមុននេះ កូនៗបានសង្កេតរករូបភាពអ្វី**?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ?មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ

- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែងមេរៀន** "សង្កេតរករូបភាពដែលដូចគ្នា"
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលនាព

### ល្បែង៖ លាក់ម្រាមដៃ

**១.វត្ថុបំណង៖**

- កុមាររៀបរាប់ពីរបៀបលាក់ម្រាមដៃបានត្រឹមត្រូវ
- កុមារប្រាប់ពីវិធីលាក់ម្រាមដៃបានត្រឹមត្រូវ
- កុមារព្យាយាម អំណត់ ស្វាហាប់ ប្រុងប្រយ័ត្ន រហ័សរហួន និងសប្បាយរីករាយ

**២.សម្ភារបង្រៀន៖** គ្មាន

**៣-ការរៀបចំកុមារ៖**កុមារអង្គុយជារាងអក្សរ អ៊ុយ "U" កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤.ដំណើរការបង្រៀន៖(អនុវត្តនៅក្នុងជំហានទី៣)**

-គ្រូឱ្យកុមារអង្គុយតាមក្រុមតូចៗជារង្វង់

-គ្រូសួរកុមារតើកូនដឹងទេថា ថ្ងៃនេះគ្រូនាំកូនលេងល្បែងអ្វី?កុមារឆ្លើយតាមគំនិតគេម្នាក់ៗ

-គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា

**-គ្រូណែនាំពីរបៀបលេង៖**

- គ្រូឱ្យកូនៗលេងជាក្រុមតូចៗហើយក្រុមនីមួយៗត្រូវប៉ាវរកអ្នកឈ្នះធ្វើជាមេ
- ដំបូងកូនដែលធ្វើមេគេត្រូវខ្ទាស់ម្រាមដៃស្តាំនិងម្រាមដៃឆ្វេងខ្ទាស់ចូលគ្នាដោយលាក់ម្រាមដៃណាមួយនៅក្នុងប្រអប់ដៃ(អាចលាក់ម្រាមដៃម្តង២ក៏បានមិនប្រកាន់ឆ្វេងស្តាំ)កុំឱ្យអ្នកដ៏ទៃទៀតឃើញ បើកូនណាទាយត្រូវកូននោះត្រូវធ្វើមេម្តង កូនដែលទាយខុស ត្រូវមិត្តភក្តិឱ្យធ្វើជាដង្កូវទឹកដោយប្រើចលនាម្រាមដៃម្តងមួយៗកំរើកចុះឡើងដូចដង្កូវទឹក ហើយមិនអនុញ្ញាតឱ្យកូននោះទាយទៀតទេ

- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តនិយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់បើនិយាយមិនទាន់ច្បាស់លាស់ទេត្រូវឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែមិនទាន់ពេញលេញនោះទេ គ្រូត្រូវនិយាយសារឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមតូចៗហើយឱ្យអង្គុយជារង្វង់ទៅតាមកន្លែងដែលគ្រូបានរៀបចំទុក
- គ្រូចាប់ផ្តើមឱ្យសញ្ញាដើម្បីក្រុមនីមួយៗប៉ាវរកអ្នកឈ្នះ
- ពេលក្រុមនីមួយៗរកបានអ្នកចាប់ផ្តើមហើយគ្រូឱ្យកុមារនាំគ្នាអនុវត្ត

- គ្រូដើរសម្របសម្រួលគ្រប់ក្រុមនិងជួយកែតម្រូវក្រុមណាដែលលេងខុស
- នៅពេលក្រុមនីមួយៗលេងដល់អ្នកចុងក្រោយគ្រូនឹងកុមារនាំគ្នាផ្ទៀងផ្ទាត់លទ្ធផលដើម្បីរកអ្នកឈ្នះនិងអ្នកចាញ់
- នាំកុមារលេងនិងផ្ទៀងផ្ទាត់របៀបនេះរហូតដល់ម៉ោង គ្រាន់តែលេងចប់មួយជងផ្ទៀងផ្ទាត់មួយជងនិងត្រូវប៉ាវរកអ្នកចាប់ផ្តើមសារជាថ្មីពេលលេងបន្ត។

# ថ្ងៃទី១២

## ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

### ចលនាចរន្ត៖ "ដើរ-រត់-លោត-គប់" (ដើរកែងជើងទៅមុខ រត់ចុងជើងទៅមុខ លោតជើង២ទៅមុខ គប់វត្ថុយកចម្ងាយ)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបធ្វើចលនា**ដើរ រត់ លោត គប់** តាមលំដាប់លំដោយ បានត្រឹមត្រូវ
- កុមារធ្វើចលនា**ដើរ រត់ លោត គប់** តាមលំដាប់លំដោយ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន សហការ អំណត់ ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បាល់

**៣. ការរៀបចំកុមារ៖** ចែកកុមារជា៣ក្រុម ឱ្យកុមារឈរជាជួរតាមក្រុម (ធ្វើសកម្មភាពម្តង១ក្រុម ដោយធ្វើគ្រប់សកម្មភាពទាំងអស់)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរ ទៅតាមទីកន្លែងដែលគ្រូបានរៀបចំរួចតាមសកម្មភាពនីមួយៗ
- គ្រូលើកសម្ភារបង្ហាញកុមារ រួចសួរថា តើនេះជាអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់គេ បើកុមារឆ្លើយខុស គ្រូសម្របសម្រួលចម្លើយដែលត្រឹមត្រូវ
- តើមានកូនៗណាខ្លះធ្លាប់ហែលទឹកឬទេ? ដូចនេះកូនទាំងអស់គ្នាធ្វើចលនាហែលទឹកជាមួយគ្រូ ដោយលើកដៃស្តាំបោះទៅមុខ ដៃឆ្វេងបោះទៅក្រោយ ដោយផ្លាស់ប្តូរគ្នាទៅមកដូចអ្នកហែលទឹកឱ្យបានច្រើនដង
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាទាំងអស់តាមលំដាប់លំដោយ ដោយគ្រូធ្វើសកម្មភាពបង្ហាញកុមារមុន
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- **គ្រូចែកកុមារជា៣ក្រុម ដោយក្រុមនីមួយៗត្រូវអនុវត្តគ្រប់សកម្មភាពទាំងអស់៖**
  - ក្រុមទី១៖ **ដើរកែងជើងទៅមុខ រួចរត់ចុងជើងទៅមុខ បន្ទាប់មកលោតជើងពីរទៅមុខ និងចុងក្រោយយក បាល់គប់វត្ថុយកចម្ងាយ តាមលំដាប់លំដោយបន្តបន្ទាប់គ្នារហូតអស់គ្រប់សកម្មភាព**
  - ក្រុមទី២៖ **ពេលក្រុមទី១ធ្វើចប់គ្រប់សកម្មភាពហើយ ក្រុមទី២ត្រូវបន្តធ្វើដូចក្រុមទី១ដែរ**
  - ក្រុមទី៣៖ **ពេលក្រុមទី២ធ្វើចប់គ្រប់សកម្មភាពហើយ ក្រុមទី៣ត្រូវបន្តធ្វើដូចក្រុមទី១ដែរ**
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានធ្វើគ្រប់សកម្មភាព
- **គ្រូសួរកុមារ៖**
  - **តើមុននេះ កូនៗបានធ្វើសកម្មភាពអ្វីខ្លះ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? អំពីអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា **ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព អំពី៖ ចលនាចរន្ត ដើរ រត់ លោត គប់ " ដើរកែងជើងទៅមុខ រត់ចុងជើងទៅមុខ លោតជើងពីរទៅមុខ គប់វត្ថុយកចម្ងាយ "**

- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត )
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- គ្រូនាំកុមារផ្លុំប៉េងប៉ោងដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃទាំងពីរធ្វើជាប៉េងប៉ោង ហើយផ្លុំដោយដកដង្ហើមចូល ចេញឱ្យវែងៗ ដល់ប៉េងប៉ោងធំរហូតដល់បែកឮសូរផ្ទុង) គ្រូសួរកុមារថាតើកូនៗផ្លុំប៉េងប៉ោងសប្បាយទេ? កុមារឆ្លើយ គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្តែង ។

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

### ទម្លាប់ល្អ៖ ពេលឃើញអ្នកដទៃជ្រុះសម្ភារ ត្រូវរើសជូនគាត់វិញ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** រយៈពេល៖ ៣០នាទី

## មុខវិជ្ជាៈ ភាសាខ្មែរ

### ល្បែង ៖ គូសភ្ជាប់ពាក្យទៅនឹងអក្សរដែលរៀនរួច ន ប ផ ព

**១. វត្ថុបំណង៖**

-កុមារប្រាប់ពីរបៀបគូសភ្ជាប់ពាក្យទៅនឹងតួអក្សរ ន ប ផ ព បានត្រឹមត្រូវ

-កុមារគូសភ្ជាប់តួអក្សរដែលដូចគ្នា បានត្រឹមត្រូវ

-កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងអក្សរអ៊ុតរួច ៣ផ្ទាំង ហ្វឺតសរសេរក្តារខៀន ស្កុត កន្ត្រៃ

**៣. ការរៀបចំកុមារ៖**

- ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ " ∪" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូបង្ហាញផ្ទាំងពាក្យនិងតួអក្សរ ដែលគ្រូបានរៀបចំទុកនៅតាមទីកន្លែងរួចជាស្រេច (ផ្ទាំងពាក្យនិងតួអក្សរចំនួន៤តួ ដាក់ឆ្លាស់លាយគ្នាជាមួយអក្សរផ្សេងៗទៀតនៅលើក្រដាសតែ១ និងហ្វឺត) ហើយសួរកុមារថា តើសម្ភារទាំងអស់នេះមានអ្វីខ្លះ?
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនៗលេងជាក្រុម ដោយក្នុងមួយក្រុមមានផ្ទាំងពាក្យនិងតួអក្សរ១សន្លឹក និងហ្វឺត១ដើម
  - ពេលក្រុមកូនបានផ្ទាំងពាក្យនិងតួអក្សរនេះហើយ កូននាំគ្នាសង្កេតពាក្យនិងតួអក្សរដែលដូចគ្នា កូនត្រូវយកប៊ិកហ្វឺតមកគូសភ្ជាប់លើតួអក្សរទៅនិងពាក្យដែលមានអក្សរដូចគ្នា ពេលកូនសង្កេតត្រូវចែកគ្នាសង្កេតកុំដណ្តើមគ្នាណា

- ពេលក្រុមកូនណាធ្វើរួចហើយ កូនត្រូវយកមកបិតលើក្តារខៀនតាមកន្លែងដែលគ្រូបានរៀបចំឱ្យ ហើយយកបិកហ្វឹតទៅទុកនៅតុគ្រូវិញ រួចកូនទៅអង្គុយតាមកន្លែងដើមវិញ
- ក្រុមណាដែលហើយមុនគេ ត្រូវទះដៃចំនួន៣ដង

- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបដែលក្រុមត្រូវធ្វើតាមការណែនាំ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- ឱ្យកុមារទៅអង្គុយនៅតាមក្រុម តាមកន្លែងដែលគ្រូបានរៀបចំ ដោយគ្រូរៀបចំកុមារជា៣ក្រុម
- ឱ្យតំណាងក្រុមឡើងមកយកសម្ភារទៅអនុវត្ត
- តាមក្រុមនីមួយៗអនុវត្ត ហើយគ្រូជាអ្នកដើរសម្របសម្រួល
- ពេលកុមារធ្វើចប់គ្រប់ក្រុមហើយ ឱ្យពួកគេទៅអង្គុយជារួមវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដែលបានបិតលើក្តារខៀន ដោយឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញពីអ្វីដែលក្រុមបានធ្វើ ( ធ្វើម្តងមួយក្រុម)
- គ្រូលើកសរសើរចំពោះក្រុមដែលធ្វើរួចមុនគេ ចំពោះក្រុមធ្វើហើយក្រោយគេ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? **តើមុននេះ កូនៗបានលេងល្បែងអ្វី**? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង មេរៀន** "គូសភ្ជាប់ពាក្យទៅនឹងតួអក្សរ ន ប ផ ព"
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### គំនូរ៖ សត្វទា

**១វត្ថុបំណង៖.**

-កុមារប្រាប់ពីរបៀបគូរសត្វទាបានត្រឹមត្រូវ

កុមារកាន់ខ្មៅដៃ-គូរសត្វទាដោយទប់លំនឹងបានត្រឹមត្រូវ

កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់-សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

**២.សម្ភារបង្រៀន៖**

☞**សម្ភារសម្រាប់គ្រូ៖**

-ផ្ទាំងក្រដាសដែលមានគូរសត្វទាចំនួន១សន្លឹក

-ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)

-ខ្មៅដៃចំនួន១ដើម,ស្កុតចំនួន១ដុំ។

☞**សម្ភារសម្រាប់កុមារ៖**

- ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការ គ្រប់ចំនួនកុមារ ខ្មៅដៃគ្រប់ចំនួនកុមារ

**៣ .ការរៀបចំកុមារ៖** អង្គុយរាងអក្សរ "U "ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤(អនុវត្តនៅក្នុងជំហានទី៣) ដំណើរការបង្រៀន៖ .**

- គ្រូសួរ៖តើនៅផ្ទះកូនមានចិញ្ចឹមសត្វអ្វីខ្លះ? តើសត្វអ្វីដែលយំឮសូរកាបៗ? កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសដែលមានគូរសត្វទារួចជាស្រេចឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ ហើយបិទនៅលើក្តារខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹកទៀត ដែលគ្រូមិនទាន់គូរសត្វទា ឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសនេះគ្រូទុកសម្រាប់គូរ ឱ្យកូនមើលពីរបៀបគូរ។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្តើមគូរពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាសនោះទៅបិទនៅលើក្តារខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបគូរ
- គ្រូណែនាំពីរបៀបគូរនៅលើផ្ទាំងក្រដាសសដែលបានបិទលើក្តារខៀន ដោយគូរបណ្តើរ និយាយប្រាប់កុមារបណ្តើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការគូរ។
- គ្រូប្រាប់កុមារ៖
    - កូនយកខ្មៅដៃគូរសត្វទា ចាប់គូរពីក្បាលទៅមុន ដោយចុចចំណុចដៅមួយ ហើយចាប់គូរពីចំណុចដៅកោងទៅស្តាំចុះមកក្រោម គូរកោងផ្កាប់ រួចគូរទៅលើបន្តិចធ្វើជាកន្ទុយ គូរពីកន្ទុយកោងផ្ងារទាញមកជិតចំណុចដៅ ហើយគូរចំពុះភ្ជាប់នឹងចំណុចដៅ គូរភ្នែក បន្ទាប់មកគូរជើងដោយចាប់គូរពីលើទេមកឆ្វេងមួយ និងទេមកស្តាំមួយ រួចគូរម្រាមជើង
    - បន្ទាប់មកកូនយកខ្មៅដៃកូនគូររូបសត្វទាឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអីអង្គុយគូរ (តាមស្ថានភាពជាក់ស្តែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃគូរ និងមិនទាន់យល់ពីរបៀបគូរ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារ៖ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូរហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់៖ តើមិត្តភក្តិយើងគូរបានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណា

បង្ហាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ

- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ

ម៉ោងទី៥ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ វិទ្យាសាស្ត្រ**

ល្បែង៖ គូសភ្ជាប់សត្វ ទៅនឹងចំណីអាហារ

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

ល្បែងសេរី

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦)

រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ

# ថ្ងៃទី១៣

## ម៉ោងទី១ រយៈពេល៖ ៣០នាទី

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែងចលនា ៖ អោបចង្កេះ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបអោបចង្កេះ បានត្រឹមត្រូវ
- កុមារអោបចង្កេះ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្ន និងសប្បាយរីករាយ និងចេះអធ្យាស្រ័យគ្នា ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឱ្យកុមារឈរជា២ជួរ ស្របគ្នា និងទល់មុខគ្នា។

**៤. ដំណើរការបង្រៀន៖**

- គ្រូឱ្យកុមារឈរជា២ជួរបណ្តោយ និងឱ្យកុមារឈរគម្លាតពីគ្នាសមល្មម និងងាយស្រួលក្នុងការសកម្មភាព
- គ្រូនាំកុមារធ្វើចលនាពត់ម្រាមដៃទៅមុខទៅក្រោយទៅឆ្វេងទៅស្តាំ (យកម្រាមដៃទាំងពីរប្រទាក់គ្នា ហើយបោះទៅមុខត្រង់ពត់ចុះឡើងម្តងទៅមុខ ម្តងទៅក្រោយ ម្តងទៅឆ្វេង ម្តងទៅស្តាំ) ២ ទៅ៣ដង
- គ្រូបង្ហាញទីតាំង និងគំនូសទីសម្រាប់លេងឱ្យកុមារសង្កេត ហើយសួរកុមារថា ចូរកូនទាយទៅមើលថា តើគ្រូនឹងនាំកូនលេង ល្បែងអ្វី ជាមួយនឹងខ្សែបន្ទាត់ដែលគ្រូគូសនេះ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ឈ្មោះល្បែងដែលត្រូវលេងក្នុងពេលនេះ។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់កុមារថា៖ ល្បែងដែលយើងត្រូវលេង គឺ ល្បែងចលនា អោបចង្កេះ។ រួចនាំកុមារអានទាំងអស់គ្នា២ទៅ៣ដង
- គ្រូបន្តណែនាំពីរបៀបលេង និងលក្ខខណ្ឌទៅក្រុមនីមួយៗថា គ្រូនឹងបែងចែកកូនលេងជាពីរក្រុមក្នុងមួយក្រុមៗមានចំនួនស្មើគ្នា។ គ្រូគូសខ្សែបន្ទាត់ត្រង់វែងមួយចំកណ្តាល រួចឱ្យក្រុមកូនទាំងពីរ ឈរទល់មុខគ្នាជាពីរជួរនៅសងខាងខ្សែគំនូស ហើយកូនដែលឈរនៅខាងមុខគេបង្អស់ ត្រូវយកម្រាមដៃកូនមកប្រទាក់គ្នាឱ្យជាប់ ហើយកូនដែលឈរបន្ទាប់ត្រូវអោបចង្កេះតៗគ្នារហូតដល់ក្រោយ។ ពេលគ្រូឱ្យសញ្ញាកូនថា ចាប់ផ្តើមនោះកូនទាំងពីរក្រុមត្រូវទាញបន្តទាំងអស់គ្នាទៅមកៗ។ ប្រសិនបើក្រុមកូនៗណា ទាញក្រុមម្ខាងទៀតឱ្យចូលមកផុតខ្សែដែលគ្រូកំណត់មកដល់ក្រុមរបស់ខ្លួន ក្រុមនោះគឺជាក្រុមឈ្នះ ហើយប្រសិនបើក្រុមណាដែលកំពុងទាញតែត្រូវដួល ឬអោបមិនជាប់ហើយរបូតដៃពីចង្កេះគឺជាក្រុមចាញ់។ ដូច្នេះកូនៗត្រូវប្រុងប្រយ័ត្នទាំងអស់គ្នា។
- គ្រូឱ្យកុមារ ១ ទៅ២នាក់ និយាយឡើងវិញពីរបៀបលេង និងលក្ខខណ្ឌដែលគ្រូបានប្រាប់
- គ្រូចាប់ផ្តើមនាំកុមារលេងទៅតាមរបៀបលេងដែលបានណែនាំរួច និងជួយសម្របសម្រួលពិនិត្យផ្ទៀងផ្ទាត់ការលេង
- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ
- បន្ទាប់លេងរួចហើយ គ្រូនាំកុមារធ្វើចលនាផ្លុំកំទេចកំទីដែលនៅជាប់លើបាតដៃ(លាបាតដៃ បិតមាត់ ហើយបឺតខ្យល់ពីខាងក្នុង រួចបើកមាត់ផ្លុំមកលើបាតដៃ ធ្វើដូចជាផ្លុំកំទេចកំទីដែលជាប់នឹងដៃ) រួចគ្រូសួរកុមារថា តើបាតដៃរបស់កូនស្អាតហើយឬនៅ?
- បន្ទាប់គ្រូសួរម្តងមួយសំណួរឱ្យកុមារឆ្លើយ៖ តើមុននេះ កូនៗបានលេងល្បែងអ្វី? តើកូនធ្វើចលនាអ្វីខ្លះ

ក្នុងល្បែងដែលកូនអំបាញ់មិញនេះ? តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- បន្ទាប់មកទៀត គ្រូប្រាប់បញ្ជាក់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា " អោបចង្កេះ "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

### ទម្លាប់ល្អ៖ ពេលឃើញអ្នកដទៃជ្រុះសម្ភារ ត្រូវរើសជូនគាត់វិញ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ល្បែង ៖ គូសភ្ជាប់សត្វទៅនឹងជម្រក

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបគូសភ្ជាប់សត្វទៅនឹងជម្រកតាមការណែនាំ បានត្រឹមត្រូវ
- កុមារគូសភ្ជាប់សត្វទៅនឹងជម្រកតាមការណែនាំ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការគ្នាក្នុងក្រុម បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាព សត្វទៅនឹងជម្រក អ៊ិតរួច ៥ផ្ទាំង ហ្វឺតសរសេរក្តារខៀន៥ដើម

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជា ពាក់កណ្តាលរង្វង់ និងចែកកុមារជា៥ក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញផ្ទាំងរូបភាពសត្វ នឹងជម្រក ដែលគ្រូបានរៀបចំទុកនៅតាមទីកន្លែងរួចជាស្រេច (ផ្ទាំងរូបភាពសត្វ និងជម្រក ដាក់ឆ្លាស់លាយគ្នានៅលើក្រដាសតែ១ និងហ្វឺត ) ហើយសួរកុមារថា តើសម្ភារទាំងអស់នេះមានអ្វីខ្លះ?(កុមារឆ្លើយតាមការយល់ឃើញរបស់គេម្នាក់ៗ)
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
    - គ្រូឱ្យកូនៗលេងជាក្រុម ដោយក្នុងមួយក្រុមមានផ្ទាំងរូបភាពសត្វ និងជម្រក មួយសន្លឹក និងហ្វឺត១ដើម
    - ពេលក្រុមកូនបានផ្ទាំងរូបភាពសត្វ និងជម្រក ហើយ កូននាំគ្នាសង្កេត ផ្ទាំងរូបភាពសត្វ និងចំណីអាហារ រួចត្រូវយកប៊ិកហ្វឺតមកគូសភ្ជាប់លើរូបភាពសត្វ ទៅនឹងជម្រក របស់សត្វនោះ។ ពេលកូនសង្កេត ត្រូវចែកគ្នាសង្កេតកុំដណ្តើមគ្នាណា ។
    - ពេលក្រុមកូនណាធ្វើរួចហើយ កូនត្រូវយកមកបិទលើក្តារខៀនតាមកន្លែងដែលគ្រូបានរៀបចំឱ្យ ហើយយកប៊ិកហ្វឺតទៅទុកនៅតុគ្រូវិញ
    - ក្រុមណាដែលហើយមុនគេ ត្រូវទះដៃចំនួន៣ដង ក្រុមធ្វើហើយបន្ទាប់ក៏ទះ៣ដងដែរ

- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបដែលក្រុមត្រូវធ្វើតាមការណែនាំ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- ឱ្យកុមារទៅអង្គុយនៅតាមក្រុម តាមកន្លែងដែលគ្រូបានរៀបចំ ដោយគ្រូរៀបចំកុមារជា៥ក្រុម
- ឱ្យតំណាងក្រុមឡើងមកយកសម្ភារទៅអនុវត្ត
- តាមក្រុមនីមួយៗអនុវត្ត ហើយគ្រូជាអ្នកដើរសម្របសម្រួល
- ពេលកុមារធ្វើចប់គ្រប់ក្រុមហើយ ឱ្យពួកគេទៅអង្គុយជារួមវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដែលបានបិទលើក្តារខៀន ដោយឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញពីអ្វីដែលក្រុមបានធ្វើ ( ធ្វើម្តងមួយក្រុម)
- គ្រូលើកសរសើរចំពោះក្រុមដែលធ្វើរួចមុនគេ ចំពោះក្រុមធ្វើហើយក្រោយគេ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- គ្រូសួរកុមារៈ
  - កូនៗទាំងអស់គ្នាសប្បាយទេ ?តើមុននេះ កូនៗបានលេងល្បែងអ្វី ? កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ?មេរៀនអ្វីដែរ ?កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ មេរៀនល្បែង "គូសភ្ជាប់សត្វទៅនឹងជម្រក "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។
-

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពកសាង៖ រៀបវត្ថុតូចៗលើរូបគោ

### ១. វត្ថុបំណង៖

- កុមារប្រាប់បានពីរបៀបរៀបវត្ថុតូចៗលើរូបសត្វគោ បានត្រឹមត្រូវ
- កុមារ រៀបវត្ថុៗលើរូបសត្វគោ បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល

### ២. សម្ភារបង្រៀន៖

- ផ្ទាំងរូបសត្វគោដែលមានបិទវត្ថុតូចពីលើ មួយផ្ទាំងជាគំរូ
- សន្លឹកក្រដាសមានរូបគោ ដែលមិនទាន់រៀបវត្ថុនៅពីលើ ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- វត្ថុតូចៗសម្រាប់បិទតម្រៀបលើរូបសត្វគោ(អាចជាសំបកលៀស គ្រាប់ធញ្ញជាតិ....រៀបជា៤ទៅ៥ឈុត ដាក់ក្នុងកញ្ច្រែង ឬកំប៉ុង អាស្រ័យលើការបែងចែកក្រុមរបស់គ្រូ
- កាវសម្រាប់បិទ

- ស្អុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារ៖** អង្គុយបិទតម្រៀបជាបុគ្គល

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញរូបសត្វគោដែលបានបិតតម្រៀបវត្ថុរួច ឱ្យកុមារប្រាប់ពីរូបនោះ និងយកទៅបិទលើក្តារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូបង្ហាញរូបសត្វគោដែលមិនទាន់បិទតម្រៀបវត្ថុពីលើ ឱ្យកុមារសង្កេត រួចសួរកុមារ នេះជារូបអ្វី?តើមានបិតវត្ថុអ្វីនៅពីលើដែរឬទេ? រួចយកមកបិទលើក្តារខៀនទន្ទឹមនិងរូបគំរូដែលបានបង្ហាញមុន
- គ្រូបង្ហាញសម្ភារដែលត្រូវអនុវត្តដាក់លើតុខាងមុខកុមារ ឱ្យកុមារសង្កេត ហើយសួរកុមារថា តើកូនឃើញអ្វីខ្លះនៅលើតុនេះ? ចូរកូនទាយទៅមើលថា តើគ្រូនឹងនាំកូនធ្វើអ្វីជាមួយសម្ភារទាំងនេះ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយទស្សន៍ទាយរបស់កុមារ ដោយលើកសរសើរចំពោះកុមារដែលទាយត្រូវ ហើយលើកទឹកចិត្តកុមារដែលឆ្លើយមិនទាន់បានត្រឹមត្រូវឱ្យប្រឹងប្រែងបន្ថែមទៀត រួចគ្រូប្រាប់កុមារថា ដូច្នេះថ្ងៃនេះយើងនឹងលេងល្បែងតម្រៀបវត្ថុតូចៗលើរូបគោ។ ហើយនាំកុមារអានទាំងអស់គ្នា២ចប់។
- គ្រូណែនាំពីរបៀបបិតតម្រៀបវត្ថុលើសន្លឹកក្រដាសរូបសត្វគោ ដោយណែនាំបណ្តើរបិតតម្រៀបបណ្តើរ ដើម្បីឱ្យកុមារសង្កេតឱ្យបានច្បាស់ ហើយគ្រូត្រូវឈរធ្វើយ៉ាងណាឱ្យកុមារមើលឃើញគ្រប់ៗគ្នា ដោយនិយាយថា ដំបូងគ្រូយកការមកលាបលើផ្ទៃរូបសត្វទានៃសន្លឹកកិច្ចការនេះ ដោយលាបតិចៗនិងពេញផ្ទៃរូបសត្វទា។ បន្ទាប់មកគ្រូចាប់យកវត្ថុតូចៗនៅកំប៉ុងនេះមកបិតដោយតម្រៀបលើផ្ទៃរូបគោដែលមានលាបការ ឱ្យពេញហើយធ្វើយ៉ាងណាមិនឱ្យហៀរចេញពីផ្ទៃរូបគោឡើយ។
- គ្រូឱ្យកុមារ ១ ទៅ២នាក់ ប្រាប់ឡើងវិញពីរបៀបតម្រៀបវត្ថុតូចៗលើរូបគោ
- គ្រូរៀបចំឱ្យកុមារទាញកៅអីមកអង្គុយជាក្រុមព័ទ្ធជុំវិញតុដែលបានរៀបចំរួច និងឱ្យកុមារពីរនាក់មកយកសម្ភារពីគ្រូទៅចែកមិត្តភក្តិគេតាមក្រុមអនុវត្ត
- គ្រូឱ្យកុមារតាមក្រុមនីមួយៗចាប់ផ្តើមអនុវត្តជាបុគ្គលម្នាក់ៗ ដោយប្រើសម្ភារដែលបានចែកជូន រួមគ្នា
- គ្រូដើរសម្របសម្រួលទៅតាមជួរនីមួយៗដោយជួយកុមារណាដែលមិនទាន់ចេះធ្វើ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់កុមារម្នាក់ៗរួចឱ្យកុមារចេញម្តងមួយក្រុមៗតាមឈរពីមុខមិត្តភក្តិគេដោយកាន់រូបដាក់ត្រឹមដើមទ្រូងដើម្បីបង្ហាញ
- គ្រូសួរកុមារ៖ តើរូបមិត្តភក្តិយើងធ្វើបានត្រឹមត្រូវទេ?តម្រៀបបានស្អាតទេ?
- គ្រូនិយាយប្រាប់កុមារ៖ ពេលក្រុមកូនបង្ហាញរួចហើយកូនកាន់រូបនេះទៅអង្គុយកន្លែងដើមវិញ។
- ពេលនាំកុមារផ្ទៀងផ្ទាត់លទ្ធផល គ្រូមិនត្រូវបង្អាប់កុមារដែលធ្វើមិនទាន់បានល្អនោះទេ។គ្រូត្រូវចេះសរសើរ លើកទឹកចិត្តកុមារឱ្យបានគ្រប់ៗគ្នាដើម្បីឱ្យពួកគេប្រឹងប្រែងបន្តទៀត។
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតទាល់តែគ្រប់កុមារទាំងអស់។
- គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការកុមារម្នាក់ៗជូនគ្រូទុកសម្រាប់ដាក់តាំងស្នាដៃកុមារនៅលើផ្ទាំងស្នាដៃកុមារនៅថ្ងៃបន្ទាប់។
- គ្រូត្រូវដាក់ថ្ងៃខែឆ្នាំអនុវត្តមុខវិជ្ជានិងចំណងជើងនៅក្បាលលើសន្លឹកកិច្ចការ មុននឹងយកទៅដាក់តាំងស្នាដៃកុមារ

**ម៉ោងទី៨** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ គណិតវិទ្យា

## ល្បែង៖ ផ្គុំចំនួនរូបភាពទៅនឹងលេខពី១០ ដល់១៥

**១វត្ថុបំណង៖ .**

កុមារប្រាប់ពីរបៀប**ផ្គុំចំនួនចំណុចទៅនឹងលេខពី១០ដល់១៥** បានត្រឹមត្រូវ

កុមារ**ផ្គុំចំនួនចំណុចទៅនឹងលេខពី១០ដល់១៥** បានត្រឹមត្រូវ

កុមារក្លាហានចូលរួមសហការ ឈ្លាសវៃ រហ័សរហួន ព្យាយាម និងសប្បាយរីករាយ ។

**២សម្ភារបង្រៀន៖ .** ប័ណ្ណចំណុចលេខពី១០ដល់១៥ និងប័ណ្ណចំនួនលេខពី១០ដល់១៥ ចំនួន៣ឈុត

**៣ ការរៀបចំកុមារ .**ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ និង ជាក្រុមតូចជារង្វង់

**៤ដំណើរការបង្រៀន៖ .**

- គ្រូបំផុសសំណួរ៖ កូនដឹងទេថ្ងៃនេះកូនៗអាចទាយបានទេ តើបន្តិចទៀតនេះកូនទាំងអស់គ្នារៀនពីមុខវិជ្ជាអ្វី? អំពីអ្វីដែរ? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ
- គ្រូប្រាប់កុមារថ្ងៃនេះរៀនមុខវិជ្ជាៈបុរេគណិត អំពី**ផ្គុំចំនួនចំណុចទៅនឹងលេខពី១០ដល់១៥**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ រួចសួរកុមារថាតើមុននេះមានកូនណាទាយត្រូវឬទេ? បើមានកូនណាទាយត្រូវ ឱ្យកូនដទៃទៀតទះដៃសរសើរ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ( ជាក្រុម និងទាំងអស់គ្នា)
- គ្រូឱ្យកុមារក្រោកឈរទាំងអស់គ្នា ហើយលាតម្រាមដៃឆ្វេងរួចយកចង្អុលដៃស្តាំរាប់ម្រាមដៃឆ្វេងពី១០ ដល់១៥ គ្រូបង្ហាញសម្ភារដែលត្រូវយកឱ្យកុមារលេង
  - បង្ហាញប័ណ្ណចំនួនចំណុចពី១០ដល់១៥ រួចនាំកុមាររាប់ប័ណ្ណចំនួនចំណុចនោះម្តង១ៗ រួចដាក់លើតុពីមុខកុមារ ធ្វើយ៉ាងណាឱ្យកុមារមើលឃើញ
  - បង្ហាញប័ណ្ណលេខពី១០ដល់១៥ រួចនាំកុមាររាប់ប័ណ្ណលេខនោះម្តង១ៗ រួចដាក់លើតុពីមុខកុមារ ធ្វើយ៉ាងណាឱ្យកុមារមើលឃើញ ។
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
  - គ្រូឱ្យកូនៗលេងទៅតាមក្រុម ហើយក្នុងក្រុមនីមួយៗត្រូវបានសម្ភារទាំងនេះមួយកញ្ចប់ ហើយសម្ភារទាំងនេះគ្រូដាក់ច្របូកច្របល់គ្នា
  - នៅពេលក្រុមកូននីមួយៗបានកញ្ចប់សម្ភារនេះហើយ កូនត្រូវចាក់សម្ភារពីកញ្ចប់នៅកណ្តាល វង់ រួចនាំគ្នាសង្កេតដើម្បីរកប័ណ្ណចំនួនចំណុច និងប័ណ្ណលេខ ដែលមានចំនួនស្មើគ្នាពី១០ដល់១៥ រួចយកមកផ្គុំបញ្ចូលគ្នាម្តងមួយៗ កូនៗត្រូវចេះចែកគ្នារៀប មិនត្រូវដណ្តើមគ្នា ត្រូវចេះរង់ចាំវេន
  - ពេលក្រុមកូននីមួយៗនាំគ្នាផ្គុំប័ណ្ណបញ្ចូលគ្នារួចហើយនោះ កូនៗត្រូវនាំគ្នាពិនិត្យមើលឡើងវិញក្រែងមានរៀបខុស ។
- គ្រូឱ្យកូន១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមអ្វីដែលគ្រូប្រាប់ បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត
- គ្រូចែកកុមារទាំងអស់ជាក្រុម រួចទៅអង្គុយជារង្វង់នៅកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗយកសម្ភារទៅអនុវត្ត

- គ្រូដើរសម្របសម្រួលគ្រប់ក្រុម ហើយជួយណែនាំបន្ថែមចំពោះក្រុមណាដែលមិនទាន់យល់ច្បាស់
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដោយឱ្យកុមារតាមក្រុមផ្ទៀងផ្ទាត់លទ្ធផលគ្នាទៅវិញទៅមក។ នៅពេលផ្ទៀងផ្ទាត់ក្រុមណាមួយ ត្រូវឱ្យម្ចាស់ក្រុមជាអ្នកនិយាយបង្ហាញពីអ្វីដែលក្រុមបានធ្វើ បើរៀបមិនទាន់បានត្រឹមត្រូវ ឱ្យកុមារក្រុមដទៃទៀតជួយកែលម្អ និងនាំកុមាររាប់ចំនួនទាំងនោះ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់ ។ ពេលផ្ទៀងផ្ទាត់រួចគ្រប់ក្រុមហើយ គ្រូត្រូវឱ្យតំណាងក្រុមប្រមូលសម្ភារទៅទុកជូនគ្រូវិញ ហើយនាំគ្នាទៅអង្គុយក្រុមធំវិញ ។
-

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

**ល្បែងសេរី**

**( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦ )**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

# ថ្ងៃទី១៤

## ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមបទចម្រៀងៈ "លេងឈូង"

**១.វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបធ្វើចលនាដើរទៅមុខលោតចាប់ទៅឆ្វេងទៅស្តាំ លោតទៅមុខថយក្រោយចាប់ឈូងបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើចលនាដើរទៅមុខលោតចាប់ទៅឆ្វេងទៅស្តាំ លោតទៅមុខថយក្រោយចាប់ឈូងបានត្រឹមត្រូវ
- កុមារស្វាហាប់ រហ័សរហួន សហការចូលរួមដោយសប្បាយរីករាយ។

**២.សម្ភារបង្រៀនៈ** គ្មាន

**៣.ការរៀបចំកុមារៈ** កុមារឈរជាជួរ(៣ក្រុម)

**៤.ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរ ៣ជួរតាមក្រុមនៅទីធ្លាមុខថ្នាក់រៀន ហើយគ្រូឈរពីខាងមុខកុមារ
- គ្រូនាំកុមារធ្វើចលនាគ្រាប់តាមមនុស្សយន្ត ហើយបញ្ចេញសំឡេង ទ្រឹមៗ (កុមារលើកដៃទាំងពីរឆ្មុមៗម្តងឆ្វេង ម្តងស្តាំ ១ដង ឬ ២ដង
- គ្រូច្រៀងឱ្យកុមារស្តាប់ និងធ្វើចលនាឱ្យកុមារមើលតាមបទចម្រៀងរហូត១ចប់
- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងទាំងអស់គ្នាអាស្រ័យតាមពេលវេលា(២ឬ៣ចប់)
- គ្រូសួរៈ តើកូនៗធ្លាប់បានទៅលេងពិធីបុណ្យចូលឆ្នាំដែរឬទេ? គេលេងល្បែងអ្វីខ្លះ? (កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ)
- ថ្ងៃនេះកូនរៀនមុខវិជ្ជាចិត្តចលភាពអំពី ហាត់ប្រាណតាមបទចម្រៀង ចំណងជើង "លេងឈូង " គ្រូឱ្យកុមារថាតាម១នាក់ ២នាក់តាមក្រុម
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួរ រួចសួរថាកូនៗហត់ទេ?បើហត់តើកូនចង់ធ្វើអ្វី?បើហត់គ្រូនាំកូនញ៉ាំទឹកកូកាទាំងអស់គ្នា គ្រូឱ្យកុមារយកដៃម្ខាងកាន់កំប៉ុងកូកាដៃម្ខាងទៀតកាន់ក្រវិលកំប៉ុងគាស់ ១ ២ ៣ ភីស រួចលើកញ៉ាំទាំងអស់គ្នាឮសូក្អឹកៗៗៗ រួចភើហ្កាស អើកៗ អើក។

☞របៀបធ្វើចលនាៈ

- ច្រៀងមួយចប់បទចម្រៀងលើកទី១ៈ គ្រូឱ្យកុមារធ្វើចលនាលោតចាប់ឈូងទៅឆ្វេងទៅស្តាំ លោតទៅមុខថយក្រោយចាប់ឈូង ទៅតាមបទចម្រៀង ១ចប់
- ច្រៀងមួយចប់បទចម្រៀងលើកទី២ៈ គ្រូឱ្យកុមារធ្វើចលនាដើរទៅមុខលោតចាប់ឈូងទៅឆ្វេងទៅស្តាំ លោតទៅមុខថយក្រោយចាប់ឈូង ទៅតាមបទចម្រៀង ១ចប់

### អត្ថបទចម្រៀង "លេងឈូង "

យើងបោះអឹងអើយឈូងទៅ ថ្លៃអើយឈូងបែកជា៥
ខែចេត្រចូលឆ្នាំអឹងអើយៗ ថ្លៃអើយនាំគ្នាលេងឈូង។
យើងបោះអឹងអើយឈូងទៅ ថ្លៃអើយឈូងទើរលើចុងផ្កា
ពួកយើងកុមារអឹងអើយៗ ថ្លៃនាំគ្នាលេងឈូង។

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

### ទម្លាប់ល្អ៖ ពេលឃើញអ្នកដទៃជ្រុះសម្ភារ ត្រូវរើសជូនគាត់វិញ

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### សម្គាល់តួអក្សរ៖ "ន"

**១វត្ថុបំណង៖ .**

កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ -"ន" បានត្រឹមត្រូវ

កុមារកំណត់បានពីរូបរាងឈ្មោះអក្សរ - "ន" និងរកពាក្យថ្មីផ្ដើមចេញពីអក្សរ "ន" បានត្រឹមត្រូវ

កុមារក្លាហាន និងយកចិត្តទុកដាក់ -ព្យាយាមក្នុងការរកពាក្យថ្មីផ្ដើមពីអក្សរ "ន" ។

**២សម្ភារបង្រៀន៖ .** ផ្ទាំងរូបភាព នាគ នំ ននោង ប័ណ្ណពាក្យ នាគ នំ ននោង និងឃ្លា៖ នាងនួនស្លនោង ប៊ិក ហ្វឺត ស្កុត កាត់រៀបចំឱ្យហើយ។

**៣ការរៀបចំកុមារ៖ .** អង្គុយជាអក្សរ អ៊ុយ "ប"

**៤ដំណើរការបង្រៀន៖ .**

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "**នាគ**" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្ដាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន រួចបង្ហាញប័ណ្ណពាក្យ "**នាគ**" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**នំ**" ដោយរលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារ ខៀន រួចបង្ហាញប័ណ្ណពាក្យ "**នំ**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ននោង**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ននោង**" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្ដិឮពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ននោង**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន ហើយបង្ហាញប័ណ្ណពាក្យ"**ននោង**" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផង ចង្អុលផង
- គ្រូបង្ហាញឃ្លា "**នាងនួនស្លនោង**" អានឱ្យកុមារស្ដាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្តាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្តាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអំបាញ់មិញឮសូរដូចម្តេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

**+ ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នា (ពេលកុមារឡើងមកគូសវង់ជុំវិញអក្សរមានរាងដូចគ្នា បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារបានគូសវង់ដើម្បីផ្ទៀងផ្ទាត់ ។

**+ ប្រាប់ឈ្មោះតួអក្សរ៖**

- សួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "**ន**" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"**ន**" យ៉ាងធំនៅជ្រុងក្តារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"**ន**" នាំកុមារអានអក្សរ"**ន**" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- **គ្រូសរសេរចំណងជើងមេរៀនលើក្តារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)**

**+ ប្រៀបធៀបអក្សរស្រដៀង៖**

-គ្រូសរសេរអក្សរ "ន ទ" នៅលើក្តារខៀន

-គ្រូអានអក្សរ "ន ទ" ឱ្យកុមារស្តាប់ និងសង្កេត

-សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?

-កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

**+ រកពាក្យថ្មីផ្តើមពីអក្សរ"ន"៖**

- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្តាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្តើមពីអក្សរ"ន"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្តារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- គ្រូនាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្តងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"**ន**" ឬទេ? បើមានតួអក្សរក្នុងពាក្យដូចតួអក្សរ "**ន**" នេះ កុមារត្រូវធ្វើសញ្ញា**បាទ/ចាស** (ដោយក្តាប់ដៃស្តាំលើកឡើងត្រឹមភ្នែក រួចធ្វើសញ្ញាបាទ/ចាស ដូចងក់ក្បាល) រួចគ្រូគូសវង់ជុំវិញពាក្យនោះ។ តែបើក្នុងពាក្យនោះមិនមានតួអក្សរ "**ន**" ទេ កុមារត្រូវធ្វើសញ្ញា**ទេ** (ដោយលាដៃស្តាំលើកឡើងត្រឹមភ្នែក រួចគ្រវីចុះឡើង) ដោយគ្រូមិនត្រូវធ្វើអ្វីទាំងអស់ចំពោះពាក្យនោះ។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### ល្បែង៖ ដាក់សញ្ញាតាង

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីឈ្មោះនិងសម្លេងសត្វបានត្រឹមត្រូវ
- កុមារអនុវត្តការដាក់សញ្ញាតាងបានត្រឹមត្រូវ
- កុមារមានការប្រុងប្រយ័ត្ន អំណត់ព្យាយាម រហ័សរហួន និងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖** ប័ណ្ណរូបភាពសត្វចំនួន ១០

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរអ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញប័ណ្ណរូបភាពសត្វចំនួន៤ប្រភេទឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ
- **គ្រូណែនាំពីរបៀបលេង៖**
- គ្រូរៀបប័ណ្ណរូបភាពសត្វទាំងនោះនៅលើក្ដាខៀនជាចង្វាក់ឱ្យកុមារសង្កេត
- ដំបូងគ្រូរៀបប័ណ្ណរូបភាពសត្វមាន់១ បន្ទាប់មករៀបប័ណ្ណរូបភាពសត្វទា២ហើយរៀបប័ណ្ណរូបភាពសត្វឆ្កែ៣និងចុងក្រោយរៀបប័ណ្ណរូបភាពសត្វឆ្មា៤
- បន្ទាប់មកគ្រូលាក់ប័ណ្ណរូបភាពសត្វទាំងនោះ ហើយឱ្យកុមារ២ទៅ៣នាក់ធ្វើជាសម្លេងតាមប័ណ្ណរូបភាពសត្វដែលគ្រូបានរៀបនៅលើក្ដាខៀន
- គ្រូឱ្យកុមារស្ម័គ្រចិត្តឡើងគូរសញ្ញាតាងនៅលើក្ដាខៀន បើកុមារណាធ្វើសម្លេងមិនបានតាមប័ណ្ណរូបភាពដែលគ្រូបានរៀបនោះទេ កុមារនោះគឺជាអ្នកចាញ់ ហើយឱ្យកុមារដែលចាញ់នោះឈប់លេង
- ពេលលេងចប់កុមារដែលចាញ់ទាំងអស់ត្រូវកុមារដែលឈ្នះឱ្យធ្វើសកម្មភាពអ្វីមួយ ដូចជា៖ច្រៀង រាំ ...។
- គ្រូលើកសរសើរកុមារដែលឈ្នះ ចំពោះកុមារដែលចាញ់គ្រូលើកទឹកចិត្តឱ្យខំបន្តទៀត
- គ្រូនាំកុមារលេងពី២ទៅ៣ដង(អាស្រ័យតាមពេលវេលា)។

**ម៉ោងទី៥** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ល្បែង៖ "ធ្វើចំណាត់ថ្នាក់សត្វរស់នៅក្នុងទឹក លើគោក និងលើអាកាស"

**១.វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបរស់នៅរបស់សត្វក្នុងទឹក លើគោក លើអាកាស បានត្រឹមត្រូវ
- កុមារធ្វើចំណាត់សត្វរស់នៅក្នុងទឹក លើគោក លើអាកាស បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២.សម្ភារបង្រៀន៖**

- បន្ទះប័ណ្ណរូបភាពសត្វរស់នៅក្នុងទឹក លើគោក និងលើអាកាស(មួយមុខមានចំនួន៤ប័ណ្ណ)ចំនួន៤ឈុត

៣.ការរៀបចំកុមារ៖ - អង្គុយជារាងពាក់កណ្ដាលរង្វង់ និងឱ្យ អង្គុយជា៣ក្រុម

៤.ដំណើរការបង្រៀន(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបន្ទះប័ណ្ណរូបភាពសត្វរស់នៅក្នុងទឹក លើគោក និងលើអាកាសដោយដាក់នៅលើតុពីមុខកុមារ រួចឱ្យកុមារម្នាក់ជាអ្នកលើកបង្ហាញ ហើយកុមារដទៃទៀតជាអ្នកប្រាប់ឈ្មោះ សត្វរស់នៅក្នុងទឹក លើគោក និងលើអាកាស

- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវមានសម្ភារប័ណ្ណរូបភាពសត្វរស់នៅក្នុងទឹក លើគោក និងលើអាកាសដែលកូនបានបង្ហាញមួយកញ្ចប់ មុននេះ
  - ពេលក្រុមកូននីមួយៗបានសម្ភារទាំងនេះហើយ កូនត្រូវយកសម្ភារចេញពីថង់ដាក់នៅកណ្ដាលវង់ ។ បន្ទាប់មក ពួកកូនក្នុងក្រុមនីមួយៗ នាំគ្នាសង្កេតមើលប័ណ្ណរូបភាពសត្វរស់នៅក្នុងទឹក លើគោក និងលើអាកាសទាំងនោះ ដើម្បីចំណាំ ប៉ុន្តែកូននាំគ្នាមើលឱ្យស្ងៀមស្ងាត់ មិនដណ្ដើមគ្នាមើលទេ
  - នៅពេលគ្រូឱ្យសញ្ញាចាប់ផ្ដើម កូនៗគ្រប់ក្រុមត្រូវនាំគ្នារើសប័ណ្ណរូបភាពសត្វរស់នៅក្នុងទឹក ដាក់មុំៗ ប័ណ្ណរូបភាពសត្វរស់នៅ លើគោក ដាក់១ជុំ និងប័ណ្ណរូបភាពសត្វរស់នៅលើអាកាសដាក់១ជុំ ។ បើក្រុមណារៀបបានរួចរាល់មុនគេ កូនត្រូវទះដៃ៣ជាសញ្ញា ។ បន្ទាប់មកអ្នករៀបរួចបន្តបន្ទាប់ ក៏ទះដៃ៣ដងបន្តបន្ទាប់ដែរ ។ ពេលកូនរៀបសត្វរស់នៅក្នុងទឹក លើគោក និងលើអាកាសដាក់មុំៗ កូនត្រូវធ្វើម្នាក់ម្ដងៗរង់ចាំវេន មិនដណ្ដើមគ្នារញ៉េរញ៉ៃទេ ទើបជាកូនល្អ

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្ដងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
-គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត និងឱ្យក្រុមនីមួយៗចាប់ផ្ដើមអនុវត្តតាមសញ្ញាបញ្ជារបស់គ្រូ
-គ្រូឱ្យក្រុមកុមារនីមួយៗដែលធ្វើរួចហើយទៅអង្គុយនៅក្រុមធំវិញ ក្នុងមួយក្រុមទុកតែកុមារម្នាក់ដើម្បីបង្ហាញលទ្ធផល
- គ្រូនាំកុមារផ្ទៀងផ្ទាត់ម្ដងមួយក្រុមៗ ដោយឱ្យម្ចាស់ក្រុមនីមួយៗជាអ្នកបង្ហាញពីអ្វីដែលពួកគេបានធ្វើ ។ បន្ទាប់មកឱ្យកុមារដែលនៅអង្គុយក្នុងក្រុមធំជាអ្នកវាយតម្លៃ បើមានខុសជួយកែតម្រូវ ។ គ្រូត្រូវនាំផ្ទៀងផ្ទាត់គ្រប់ក្រុមទាំងអស់ ។ ពេលផ្ទៀងផ្ទាត់ចប់ គ្រូត្រូវឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ ។

**គ្រូសួរកុមារ៖**

- អំបាញ់មិញកូនស្គាល់អ្វីខ្លះ? ដូចនេះកូនជួយប្រាប់គ្រូបានទេ តើយើងរៀនមុខវិជ្ជាអ្វី? អំពីអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង " ធ្វើចំណាត់ថ្នាក់សត្វរស់នៅក្នុងទឹក លើគោក និងលើអាកាស "រួចសួរកុមារ អំបាញ់មិញមានកូនណាទាយត្រូវឬទេ ដូចនេះកូនៗដែលទាយត្រូវគឺជាកូនពូកែ កូនឆ្លាត។ រីឯកូនដែលទាយមិនត្រូវក៏ល្អដែរ ដែលក្លាហានក្នុងការនិយាយជាមួយគ្រូ។
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

**ល្បែងសេរី**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦)**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

# ថ្ងៃទី១៥

## ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមរឿងនិទានៈ "ទីណូ ស្រួចនាំគ្នាទៅបេះផ្លែត្រសក់នៅចម្ការ"

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបដើរវាង លោតរំលងតាមខ្លឹមសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារដើរវាង លោតរំលងតាមខ្លឹមសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** ឈរជាជួរ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- គ្រូបំផុសសំនួរៈ តើកូនធ្លាប់ឃើញសត្វចាបហើរដែរឬទេ? ហើរដូចម្ដេច?
- គ្រូនាំកុមារទាំងអស់ធ្វើត្រាប់តាមសត្វចាបហើរ ដោយលាដៃទាំងសងខាងធ្វើជាស្លាបទទះចុះឡើង ជើង និងដងខ្លួនជំទើតចុះឡើងស្របនឹងចង្វាក់ដៃ (ឱ្យបានច្រើនដង)
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន "ទីណូ ស្រួចនាំគ្នាទៅបេះផ្លែត្រសក់នៅចំការ "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូនាំកុមារធ្វើសកម្មភាពខ្លះៗទាក់ទងទៅនឹងខ្លឹមសាររឿងនិទាន ដោយនាំកុមារដើរកាច់ចុះ កាច់ឡើង វាង លោតរំលងថ្លុក
- គ្រូចាប់ផ្តើមនិទានរឿងបណ្តើរនាំកុមារធ្វើសកម្មភាពបណ្តើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយ មិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ (ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្តងទៀត)
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗហាត់ទេ?បើហាត់យើងនាំគ្នាទៅក្នុងសួនបេះផ្កាហិតទាំង អស់គ្នា កូនៗយកដៃធ្វើកាយវិការដូចកាន់ទងផ្កា រួចយកមកដាក់ជិតច្រមុះរួចហិត ទាក់ទងនឹងការដក ដង្ហើមចូល ចេញរួចសួរកុមារៈ តើផ្កានេះក្រអូបទេ? (ធ្វើរបៀបនេះម្តងទៀត)។

### អត្ថបទរឿង "ទីណូ ស្រួចនាំគ្នាទៅបេះផ្លែត្រសក់នៅចំការ "

ស្រួចនិងទីណូជាមិត្តសម្លាញ់នឹងគ្នា គេបានបបួលគ្នាទៅបេះផ្លែត្រសក់នៅឯចំការរបស់ខ្លួន នៅតាមផ្លូវមានបន្លាដុះជាច្រើន ធ្វើឱ្យគេមានការលំបាកជាខ្លាំងក្នុងការធ្វើដំណើរ ពួកគេត្រូវដើរកាច់ចុះ កាច់ឡើងវាងបន្លាទាំងនោះកុំឱ្យមុតជើង។ ពេលពួកគេកំពុងធ្វើដំណើរក៏ប្រទះនឹងថ្លុកទឹកដក់ជាច្រើនកន្លែង នៅតាមផ្លូវគេទាំងពីរនាក់ក៏លោតរំលងថ្លុកទាំងនោះ ពីថ្លុកទឹកមួយទៅថ្លុកទឹកមួយទៀតរហូតដល់អស់ថ្លុក។ សម្លាញ់ទាំងពីរនាក់ ក៏នាំគ្នាសម្រាកបន្តិចឱ្យបាត់ហត់។ បន្ទាប់មកពួកគេក៏នាំគ្នាដើរទៅបេះត្រសក់ញ៉ាំ និងបេះត្រសក់ត្រឡាច ល្ពៅ យកមកផ្ទះវិញ។

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

ទម្លាប់ល្អ៖ ពេលឃើញអ្នកដទៃជ្រុះសម្ភារ ត្រូវរើសជូនគាត់វិញ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

ល្បែង៖ "បង្កើតសំណុំចំនួនតូចៗពី៥ដល់១៥" (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ខែ៦ ម៉ោងទី៣)

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

រឿងនិទាន៖ "ប្រាជ្ញាទីណូ" (អំណាន)

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបកាន់ និងបើកសៀវភៅអានរឿង បានត្រឹមត្រូវ
- កុមារកាន់ បើក និងអាននិទានរឿងនិងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ស្តាប់រឿងយកគំរូតាមតួអង្គល្អ សហការជួយគ្នា និងនិទានរឿងឱ្យមិត្តភក្តិស្តាប់

**២. សម្ភារបង្រៀន៖** សៀវភៅរឿងនិទាន "ប្រាជ្ញាទីណូ"

**៣. ការរៀបចំកុមារ៖** អង្គុយជាបណ្តុំ ជាជួរ

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ៖ គ្រូបង្ហាញក្របសៀវភៅរួចសួរថា តើកូនៗសង្កេតឃើញរូបអ្វីខ្លះ? តើរឿងនេះមានចំណងជើងដូចម្តេច?កុមារទាយតាមគំនិតគេម្នាក់ៗ
- គ្រូសរុបចំណងជើងដែលកុមារបានទាយ
- គ្រូបើកសៀវភៅបង្ហាញរូបភាពម្តងមួយសន្លឹកៗរហូតដល់ចប់សាច់រឿងរួចសួរកុមារថា នៅពេលកូនមើលរូបភាពផ្នែកខាងក្នុងរួចហើយ ដូច្នេះកូនៗមានដូរចំណងជើងមេរៀនទៀតទេ?បើដូរតើមានចំណងជើងដូចម្តេចដែរ?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម ចំណងជើងអំណានរឿង "ប្រាជ្ញាទីណូ" រួចសួរថា មុននេះមានកូនណាឆ្លើយដូចចម្លើយរបស់អ្នកគ្រូដែរឬទេ?ដូច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងជាក្រុមនិងទាំងអស់គ្នា
- ប្រាប់ឈ្មោះអ្នកនិពន្ធរឿងនេះលោកអ៊ុំស្រី តិក ស៊ីផុន និងលោកអ៊ុំស្រី យឹម ចាន់ស្រី ជាអ្នកនិពន្ធឱ្យកុមារថាតាម

- គ្រូអានរឿងនិទានដោយយកដៃចង្អុលតួអក្សរឱ្យកុមារស្តាប់និងសង្កេតដោយមិនបាំងរូបភាព( ធ្វើរបៀបនេះរហូតដល់ចប់សាច់រឿង )
- គ្រូប្រាប់ពាក្យពិបាកនិងពន្យល់ពាក្យពិបាកទាំងនោះរួចឱ្យកុមារអានតាម ជាក្រុមនិងទាំងអស់គ្នា
- ពន្យល់ន័យនៃពាក្យពិបាកក្នុងរឿងនេះមានដូចជា៖
    - មមៃគិត ៖ ដែលនឹកភ្នក,រឿយៗមិនភ្លេច
    - បញ្ឆោត ៖ ធ្វើឱ្យឆោត ឱ្យលង់គំនិតជឿ
    - ពុត ៖ កិច្ចកលមាយា,ការក្លែងបន្លំ
- គ្រូអានរឿងឱ្យកុមារស្តាប់ម្តងទៀត
- ក្រោយពីអំណានរឿងចប់៖គ្រូសួរកុមារតើក្នុងរឿងមានតួអង្គប៉ុន្មាន?តួអង្គណាខ្លះ? តើតួអង្គទាំងនោះឈ្មោះអ្វី?
  ហេតុអ្វីបានជាកញ្ជ្រោងនិងខ្លាហៅទន្សាយទៅជួប? តើទន្សាយធ្វើដូចម្តេចទើបរួចផុតពីការសម្លាប់របស់សត្វទាំងពីរ?ហេតុអ្វី?
- គ្រូអានរឿងឱ្យកុមារស្តាប់ម្តងទៀត
- គ្រូបំផុសសំណួរ៖តើរឿងនេះគេចង់និយាយអំពីអ្វី?
-គ្រូឱ្យកុមារស្ម័គ្រចិត្តឡើងអានរឿងតាមការចងចាំរបស់ពួកគេឡើងវិញ (ពេលកុមារភ្លេចត្រូវឱ្យមិត្តភក្តិនៅជិតប្រាប់ បើមិត្តភក្តិមិនអាចប្រាប់ បានគ្រូជួយប្រាប់)ដោយចង្អុលទៅតាមពាក្យក្នុងសាច់រឿង ។

**អត្ថបទរឿង "ប្រាជ្ញាទីណ្ឌ"**

ថ្ងៃមួយបងកញ្ជ្រោងបាននិយាយប្រាប់បងខ្លាថា៖"បងខ្លាឯងដេកលើគ្រែឱ្យស្ងៀម ធ្វើពុតជាស្លាប់ ខ្ញុំទៅហៅបងទន្សាយមកមើលបងខ្លាឯង។ ពេលទន្សាយមកស្ទាបខ្លួនបងខ្លាឯង បងខ្លាឯងនិងខ្ញុំស្ទុះទៅសង្គ្រប់លើវា។ ហើយយើងសម្លាប់វា យកមកធ្វើជាចំណីអាហាររបស់យើង"។ ខ្លាយល់ព្រមធ្វើតាមយោបល់របស់កញ្ជ្រោង ខ្លាក៏ស្ទុះឡើងទៅដេកលើគ្រែភ្លាម។ ពេលនោះកញ្ជ្រោងរត់ចេញទៅហៅទីណ្ឌកូនទន្សាយ។

តាមផ្លូវទីណ្ឌនឹកមមៃក្នុងចិត្ត ខ្លាចក្រែងកញ្ជ្រោងបញ្ឆោតនាំខ្លួនទៅឱ្យខ្លាស៊ី។ ទីណ្ឌប្រុងខ្លួនជានិច្ចក្រែងមានគ្រោះថ្នាក់។ ទីណ្ឌមកដល់ផ្ទះបងខ្លា ឃើញខ្មោចបងខ្លាពីចម្ងាយក៏រកឧបាយកលនិយាយទៅកាន់កញ្ជ្រោងថា៖ "ខ្ញុំធ្លាប់ឃើញខ្លាងាប់ហាមាត់ ចុះខ្លានេះហេតុម្តេចក៏ងាប់បិទមាត់"? ខ្លាឮទន្សាយថាឱ្យខ្លួនដូចនោះក៏ខំហាមាត់ភ្លាម។ ទីណ្ឌឃើញខ្លាហាមាត់ ទើបដឹងថាខ្លាធ្វើពុតក៏ស្រែកខ្លាំងៗថា៖ " ហាស់ ហា ខ្លាធ្វើពុត!ៗ ! "។

**ម៉ោងទី៥** (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ ភាសាខ្មែរ

## កំណាព្យ៖ "ត្រូវចេះញ៉ាំ"

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំណងជើង និងអត្ថន័យនៃកំណាព្យ "ត្រូវចេះញ៉ាំ" បានត្រឹមត្រូវ។
- កុមារមានសមត្ថភាពសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងលំនាំបទ បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២ . សម្ភារបង្រៀន៖** -គ្មាន

**៣ .ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "ប"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣ )

-ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា

- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទ និងយល់អត្ថន័យ នៃរកពាក្យពិបាក គ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់និយាយពីអ្វី?
  - គ្រូប្រាប់និងពន្យល់ពាក្យពិបាកមានពាក្យ បង្ហុំ មានន័យថាកុំធ្វើអ្វីមួយដោយលឿនពេក ។
  - អត្ថបទកំណាព្យនេះគឺចង់ចណ្តុះទម្លាប់ឱ្យកុមារចេះមានសុជីវធម៌មានរបៀបរៀបរយពេលទទួលទានចំណីអាហារ។
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ
- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអំបាញ់កូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជា៖ភាសាខ្មែរ មេរៀន៖កំណាព្យ "**ត្រូវចេះញ៉ាំ**" អ្នកនិពន្ធដោយលោកអ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាំព្យ "ត្រូវចេះញ៉ាំ "(បទកាកគតិ)**

| | |
|---|---|
| កុំយកស្លាបព្រា | ជ្រាវម្ហូបនានា |
| អោយវល់វក់អស់ | កុំលូកចំណី |
| នឹងដៃអោយសោះ | ព្រោះធ្វើដូច្នោះ |

ខុសពេកកន្លង។

| | |
|---|---|
| លើកកែវទឹកញ៉ាំ | មាត់ពេញវង់ចាំ |
| លេបអស់សិនហោង | ផឹកទាំងបង្ហុំ |
| បាយផងទឹកផង | ផឹកមិនទំនង |

គ្មានអនាម័យ។

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលនាព

ល្បែង៖ "លាក់ម្រាមដៃ" (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ខែ៦ ម៉ោងទី១)

# ថ្ងៃទី១៦

**ម៉ោងទី១** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលនាព

ចលនាមូលដ្ឋាន៖ "គប់" (គប់បាល់ឬវត្ថុផ្តួលកំប៉ុង គប់បាល់ឬវត្ថុឱ្យចំចំណុច គប់បាល់ឬវត្ថុយកចម្ងាយ (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ខែ៦ ម៉ោងទី១)

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

ទម្លាប់ល្អ៖ ត្រូវចេះជួយគ្នាពេលមានគ្រោះថ្នាក់ (នៅសាលារៀន នៅផ្ទះ និងនៅតាមភូមិ)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

ល្បែង៖ "ឡុកឡាក់តាមតួអក្សរពី ក ដល់ ន "

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបលេងល្បែងឡុកឡាក់តួអក្សរពី ក ដល់ ន បានត្រឹមត្រូវ
- កុមារលេងល្បែងឡុកឡាក់តួអក្សរពី ក ដល់ ន បានត្រឹមត្រូវ
- កុមារមានភាពក្លាហាន ម្ចាស់ការ សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបសត្វពស់(៣ផ្ទាំង),មេឡុកឡាក់(៣),កូនកាសពណ៌ផ្សេងៗ(តាមចំនួនកុមារក្នុងក្រុម)

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរអ៊ុយ" U "និង ជាក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់កុមារៈគ្រូមានថង់ខ្មៅមួយមកផ្ញើកូនៗ តើកូនចង់ដឹងទេថានៅក្នុងថង់នោះមានរបស់អ្វីខ្លះ?
- គ្រូឱ្យកុមារម្នាក់មកយកថង់បង្ហាញប្រាប់ដល់មិត្តភក្តិទាំងអស់គ្នា
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - ក្នុងមួយក្រុមគ្រូឱ្យផ្ទាំងរូបសត្វពស់ចំនួន១ផ្ទាំង មេឡុកឡាក់១ និងកូនកាសពណ៌ផ្សេងៗតាមចំនួនកុមារក្នុងក្រុម ដោយកុមារម្នាក់ទទួលបានកូនកាសពណ៌ចំនួន១ គ្រូឱ្យកូនៗក្នុងក្រុមប៉ាវរកអ្នកឈ្នះរួចបោះមេឡុកឡាក់មុនគេ នៅពេលកូនបោះមេឡុកឡាក់ឃើញចំនួនចំណុចចេញមកប៉ុន្មានកូនត្រូវដាក់កូនកាសចំនួនប៉ុណ្ណឹង បើបោះបាន៣ កូនត្រូវរាប់តួអក្សរនៅលើរូបសត្វពស់ចំនួន៣ដែរ ហើយដាក់កូនកាសរបស់កូននៅត្រង់អក្សរនោះ
  - តែបើកូនបោះមេឡុកឡាក់ទៅ ឃើញមេឡុកឡាក់ចេញសញ្ញាខ្វែងលើចំនួនចំណុចប៉ុន្មានកូនត្រូវ

ដកចំនួនកូនកាសដែលដើរលើរូបសត្វពស់តាមចំនួនប៉ុណ្ណឹងវិញ (ដើរបានលើកទី២ ករណីបោះលើកទី១មិនត្រូវដកចេញឡើយ)។

- បើកូនបោះមេឡុកឡាក់មិនឃើញមានចំនួនចំណុចអ្វីឬសញ្ញាអ្វីកូនមិនត្រូវដើរកូនកាសឡើយ រួចកូនត្រូវឱ្យអ្នកបន្ទាប់ខាងស្តាំដៃកូនត្រូវបោះវិញម្តង ធ្វើរបៀបនេះបន្តបន្ទាប់គ្នារហូតដល់ចប់ អ្នកដើរដល់ទីមុនគេទើបជាអ្នកឈ្នះ។ **ក្នុងការលេងកុមារអាចអនុវត្តលេងច្រើនដងអាស្រ័យលើពេលវេលា**

- គ្រូឱ្យកូន១ឬ២នាក់និយាយឡើងវិញពីរបៀបលេងតាមអ្វីដែលគ្រូបានប្រាប់ បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល បើកុមារធ្វើបានគ្រូលើកសរសើរ ចំពោះកុមារធ្វើមិនបានល្អគ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទះបង្អាប់កុមារឡើយ ។
- គ្រូសួរកុមារ តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?ចំណងជើងអ្វី?កុមារឆ្លើយតាមទៅតាមគំនិតរបស់គេម្នាក់ៗ
- ថ្ងៃនេះយើងរៀនមុខវិជ្ជាៈភាសាខ្មែរ អំពីល្បែង "**ឡុកឡាក់តាមតួអក្សរពី ក ដល់ ន**"
- គ្រូនាំកុមារអានមុខវិជ្ជា និង ចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## ចម្រៀងៈ "ជីតាខ្ញុំ"(ពេលទី២)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បាន ពី របៀបច្រៀង និងធ្វើកាយវិការតាមបទចម្រៀង បានត្រឹមត្រូវ
- កុមារច្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀ ងបានត្រឹមត្រូវ
- កុមារស្រឡាញ់ចូលចិត្តច្រៀង និងសហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** -គ្មាន

៣. **ការរៀបចំកុមារៈ** កុមារអង្គុយជាអក្សរ " U"

**៤. ដំណើរការបង្រៀនៈ (អនុវត្តនៅក្នុងជំហានទី៣ )**

- ថ្ងៃនេះគ្រូច្រៀងចម្រៀងបទ "**ជីតាខ្ញុំ**" ឱ្យកូនស្តាប់និងធ្វីកាយវិការ សារឡើងវិញម្តងទៀត
- ដូច្នេះកូនៗច្រៀងនិងធ្វើកាយវិការសារឡើងវិញម្តងទៀតជាមួយគ្រូ
- ម្តងនេះគ្រូច្រៀងបំបាត់ពាក្យខ្លះៗកូនត្រូវច្រៀងបំពេញពាក្យដែលបានបាត់
- កុមារច្រៀងទាំងអស់គ្នា គ្រូជាអ្នកធ្វើកាយវិការ បន្ទាប់មកគ្រូជាអ្នកច្រៀង កុមារជាអ្នកធ្វើកាយវិការម្តង
- ឱ្យកុមារច្រៀងនិងធ្វើកាយវិការទាំងអស់គ្នា តាមបញ្ជារបស់គ្រូ
- គ្រូនាំកុមារច្រៀងនិងធ្វើកាយវិការសារឡើងវិញទាំងអស់គ្នា១ចប់ឬ២ចប់។
- គ្រូសួរកុមារៈ តើអំបាញ់មិញកូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈចម្រៀង មេរៀន "**ជីតាខ្ញុំ**" អ្នកនិពន្ធដោយលោកអ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

### ចម្រៀង៖ "ជីតាខ្ញុំ"

| | | |
|---|---|---|
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមមាន់អ៊ីយ៉ាអ៊ីយ៉ាយ៉ូ |
| យំឮតត តតឯណេះ | យំឮតត តតឯណោះ | ឯណេះក៏តតឯណាៗ ក៏តត តត។ |
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមទា អ៊ីយ៉ាអ៊ីយ៉ាយូ |
| យំឮកាបកាបឯណេះ | យំឮកាបកាបឯណោះ | ឯណេះក៏កាប ឯណាៗ ក៏កាប កាប។ |
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមគោ អ៊ីយ៉ាអ៊ីយ៉ាយូ |
| យំឮម៉ម៉ឯណេះ | យំឮម៉ម៉ឯណោះ | ឯណេះក៏ម៉ ឯណាៗ ក៏ម៉ម៉។ |
| ជីតាខ្ញុំគាត់នៅឯស្រែ | អ៊ីយ៉ាអ៊ីយ៉ាយ៉ូ | នៅឯស្រែគាត់ចិញ្ចឹមជ្រូក អ៊ីយ៉ាអ៊ីយ៉ាយូ |
| យំឮអ៊ូកអ៊ូកឯណេះ | យំឮអ៊ូកអ៊ូកឯណោះ | ឯណេះក៏អ៊ូក ឯណាៗ ក៏អ៊ូក អ៊ូក។ |

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ពិសោធន៍៖ "វត្ថុជ្រាបទឹក និងមិនជ្រាបទឹក"

**១. វត្ថុបំណង៖**

-កុមារប្រាប់ពីឈ្មោះវត្ថុជ្រាបទឹកនិងមិនជ្រាបទឹក បានត្រឹមត្រូវ

កុមារបង្ហាញពីវត្ថុជ្រាបទឹក មិនជ្រាបទឹក និងសន្និដ្ឋាន បានត្រឹមត្រូវ -

កុមារយកចិត្តទុកដាក់ចូលរួម សហការ ព្យាយាម និងទទួលខុសត្រូវក្នុងការអនុវត្តដោយសប្បាយ រីករាយ។-

**២. សម្ភារបង្រៀន៖**

វត្ថុជ្រាបទឹកមាន សំ-ឡី រោមសត្វ ក្រណាត់ខោអាវ ក្រដាស់ ...

... វត្ថុមិនជ្រាបទឹក គម្របដបទឹកសុទ្ធ ស្បោងផ្លាស្ទិច ស្នោ កែវទឹកជ័រ-

**៣ការរៀបចំកុមារ៖** . អង្គុយជាអក្សរអ៊ុយ "ប" អង្គុយជាក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

សំឡី រោមសត្វ )គ្រូដាក់សម្ភារនៅលើតុមុខកុមារ -ក្រណាត់ខោអាវ ក្រដាស់ គម្របដបទឹកសុទ្ធ.សស្បោង ( ផ្លាស្ទិច ស្នោ កែវទឹកជ័រ

គ្រូឱ្យកុមារមួយនាក់ដែលស្ម័គ្រចិត្តមករើស -សម្ភារនៅលើតុម្តងមួយៗដើម្បីបង្ហាញរួចឱ្យមិត្តភក្តិជាអ្នកប្រាប់ ឈ្មោះបើកុមារមិនស្គាល់សម្ភារណាមួយទេគ្រូត្រូវប្រាប់កុមាររួចឱ្យកុមារថាតាម។

គ្រូសួរកុមា -រ

- តើសម្ភារទាំងអស់នេះគ្រូយកមកឱ្យកូនដើម្បីធ្វើអ្វីដែរ?
- កូនសង្កេតមើលសម្ភារទាំងអស់នេះហើយទស្សន៍ទាយ តើសម្ភារណាខ្លះជ្រាបទឹកនិងសម្ភារណាខ្លះមិនជ្រាបទឹក

- គ្រូត្រូវសរសេរចម្លើយរបស់កុមារនៅគៀនក្តារខៀន ណាមួយពេលកុមារឆ្លើយប៉ាន់ស្មានដើម្បីទុកផ្ទៀងផ្ទាត់។

- គ្រូណែនាំកុមារពីរបៀបអនុវត្តទៅតាមក្រុម

- គ្រូឱ្យកូនលេងជាក្រុមតូចៗ ហើយក្នុងមួយក្រុមកូនត្រូវបានសម្ភារទាំងអស់នេះមួយឈុត

- គ្រូប្រាប់កុមារៈ កូនត្រូវយកសម្ភារទាំងអស់នេះទៅដាក់ចំ កណ្តាលរង់ បន្ទាប់មកកូនណាម្នាក់យកសម្ភារ ទាំងនោះមកកាន់ហើយឆ្លើយប្រាប់គ្រូនិងមិត្តភក្តិ ទាំងអស់នោះ ម្តងមួយៗ ។
- កូនត្រូវនាំគ្នាសង្កេតសម្ភារទាំងអស់នោះនៅពេលមិត្តភក្តិយើងឆ្លើយ តើត្រឹមត្រូវនិងឈ្មោះសម្ភារនោះដែលឬទេ ?
- ពេលកូននាំគ្នាអនុវត្តធ្វើយ៉ាងណាកុំដណ្តើមគ្នា កុំរញ៉េរញ៉ៃ កូនត្រូវសង្កេតទាំងអស់គ្នាហើយអនុវត្តម្តងម្នាក់ៗ។

- គ្រូឱ្យកុមារណោម្នាក់ស្ម័គ្រចិត្តឡើងមកនិយាយប្រាប់ពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានត្រឹមត្រូវទេឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែនិយាយមិនបានពេញលេញទេនោះគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលគ្រូបានរៀបចំទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅអនុវត្តពិសោធន៍ តាមក្រុម
- គ្រូ ឱ្យអនុវត្តការពិសោធន៍គ្រប់ក្រុមទាំងអស់នៅពេលតែមួយ
- គ្រូដើរសម្របសម្រួលទៅតាមក្រុមនីមួយៗនិងជួយបំផុសគំនិតបន្ថែមដើម្បីធ្វើឱ្យបានត្រឹមត្រូវ
- គ្រូឱ្យកុមារទៅអង្គុយនៅក្រុមធំវិញហើយនាំគ្នាយកសម្ភារទៅទុកឱ្យគ្រូពេលគេធ្វើរួចគ្រប់ក្រុម
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ពីលទ្ធផលនៃការពិសោធន៍ សំឡី រោមសត្វ ក្រណាត់ខោ) អាវក្រដាស់( គម្របដបទឹកសុទ្ធ ស្បោងផ្លាស្ទិច ស្មៅ កែវទឹកជ័រ.
- គ្រូផ្ទៀងផ្ទាត់និងបូកសរុបលទ្ធផលនៃការពិសោធន៍ទៅនឹងចម្លើយប៉ាន់ស្មានរបស់កុមារ
- គ្រូបូកសរុប និងសន្និដ្ឋានៈ
  - ចំណេះដឹងវិទ្យាសាស្រ្តៈ វត្ថុដែលជ្រាបទឹក ដាក់ក្នុងទឹកសើម ,វត្ថុដែលមិនជ្រាបទឹកដាក់ចូលក្នុងទឹកគឺមិនសើម
  - ចំណេះដឹងភាសា នាំកុមារអានពាក្យថ្មីៗនិងអត្ថន័យនៃពាក្យ ជ្រាបទឹក( ដាក់ចូលក្នុងទឹកវាសើម) មិនជ្រាបទឹកដាក់ចូលក្នុងទឹកមិនសើម
  - ការអប់រំៈ នៅពេលកូនទៅផ្ទះវិញកូនកុំយកវត្ថុដែលជ្រាបទឹកដាក់ចូលក្នុងទឹក នាំទទឹកខូចខាត
- គ្រូសួរកុមារៈ អម្បាញ់មិញកូននាំគ្នាពិសោធន៍អ្វី មុខវិជ្ជាអ្វី? ចំណងជើងអំពីអ្វី?
- នាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន ។( ជាក្រុមនិងទាំងអស់គ្នា )

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## ល្បែងសេរី

## ( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦ )

## រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ

## ថ្ងៃទី១៧

**ម៉ោងទី១** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលនាព

ចលនាចរន្ត៖ "ដើរ-រត់-លោត-គប់" (ដើរកែងជើងទៅមុខ រត់ចុងជើងទៅមុខ លោតជើងពីរទៅមុខ គប់វត្ថុយកចម្ងាយ) (រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១២ ម៉ោងទី១ ខែទី៩)

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

ទម្លាប់ល្អ៖ ត្រូវចេះជួយគ្នាពេលមានគ្រោះថ្នាក់ (នៅសាលារៀន នៅផ្ទះ និងនៅតាមភូមិ)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

ល្បែង៖ "ធ្វើចំណាត់ថ្នាក់សត្វជើងបួន និងសត្វជើងពីរ"

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបធ្វើចំណាត់ថ្នាក់សត្វជើង៤ និងសត្វជើង២ បានត្រឹមត្រូវ
- កុមារធ្វើចំណាត់សត្វជើង៤ និងសត្វជើង២  បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖** បន្ទះប័ណ្ណសត្វជើង៤ និងសត្វជើង២ (មួយមុខមានចំនួន៤ប័ណ្ណ)ចំនួន៤ឈុត

**៣. ការរៀបចំកុមារ៖** អង្គុយជា ពាក់កណ្តាលរង្វង់ និងឱ្យអង្គុយជា៣ក្រុម

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូបង្ហាញបន្ទះប័ណ្ណរូបភាពសត្វជើង៤ និងសត្វជើង២ ដោយដាក់នៅលើតុពីមុខកុមារ រួចឱ្យកុមារម្នាក់ជាអ្នកលើកបង្ហាញ ហើយកុមារដទៃទៀតជាអ្នកប្រាប់ឈ្មោះ សត្វជើង៤ និងសត្វជើង២
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវមានសម្ភារប័ណ្ណរូបភាពសត្វជើង៤ និងសត្វជើង២ ដែលកូនបានបង្ហាញមួយកញ្ចប់ មុននេះ
  - ពេលក្រុមកូននីមួយៗបានសម្ភារទាំងនេះហើយ កូនត្រូវយកសម្ភារចេញពីថង់ដាក់នៅកណ្តាលវង់ ។ បន្ទាប់មក ពួកកូនក្នុងក្រុមនីមួយៗ នាំគ្នាសង្កេតមើលប័ណ្ណរូបភាពសត្វជើង៤ និងសត្វជើង២ ទាំងនោះដើម្បីចំណាំ ប៉ុន្តែកូននាំគ្នាមើលឱ្យស្ងៀមស្ងាត់ មិនដណ្តើមគ្នាមើលទេ
  - នៅពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនៗគ្រប់ក្រុមត្រូវនាំគ្នារើសប័ណ្ណរូបភាពទាំងនោះដាក់ម្តុំៗ ដោយ

ប័ណ្ណរូបភាពសត្វជើង៤ ដាក់១ដុំ និងប័ណ្ណរូបភាព សត្វជើង២ ដាក់១ដុំ ។ បើក្រុមណារៀបបានរួចរាល់មុនគេ កូនត្រូវទះដៃ៣ដងជាសញ្ញា ។ បន្ទាប់មកអ្នករៀបរួចបន្តបន្ទាប់ ក៏ទះដៃ៣ដងបន្តបន្ទាប់ដែរ ។ ពេលកូនរៀបប័ណ្ណរូបភាពសត្វជើង៤ និងសត្វជើង២ដាក់មុំៗ កូនត្រូវធ្វើម្នាក់ម្តងៗរង់ចាំវេន មិនដណ្តើមគ្នារញ៉េរញ៉ៃទេ ទើបជាកូនល្អ

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត និងឱ្យក្រុមនីមួយៗចាប់ផ្តើមអនុវត្តតាមសញ្ញាបញ្ជារបស់គ្រូ
- គ្រូឱ្យក្រុមកុមារនីមួយៗដែលធ្វើរួចហើយទៅអង្គុយនៅក្រុមធំវិញ ក្នុងមួយក្រុមទុកតែកុមារម្នាក់ដើម្បីបង្ហាញលទ្ធផល
- គ្រូនាំកុមារផ្ទៀងផ្ទាត់ម្តងមួយក្រុមៗ ដោយឱ្យម្ចាស់ក្រុមនីមួយៗជាអ្នកបង្ហាញពីអ្វីដែលពួកគេបានធ្វើ ។ បន្ទាប់មកឱ្យកុមារដែលនៅអង្គុយក្នុងក្រុមធំជាអ្នកវាយតម្លៃ បើមានខុសជួយកែតម្រូវ ។ គ្រូត្រូវនាំផ្ទៀងផ្ទាត់គ្រប់ក្រុមទាំងអស់ ។ ពេលផ្ទៀងផ្ទាត់ចប់ គ្រូត្រូវឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ ។
- គ្រូសួរកុមារៈ
  - អំបាញ់មិញកូនស្គាល់អ្វីខ្លះ? ដូចនេះកូនជួយប្រាប់គ្រូបានទេ តើយើងរៀនមុខវិជ្ជាអ្វី? អំពីអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង " ធ្វើចំណាត់ថ្នាក់សត្វជើង៤ និងសត្វជើង២ " រួចសួរកុមារ អំបាញ់មិញមានកូនណាទាយត្រូវឬទេ ដូចនេះកូនៗដែលទាយត្រូវគឺជាកូនពូកែ កូនឆ្លាត។ រីឯកូនដែលទាយមិនត្រូវក៏ល្អដែរ ដែលក្លាហានក្នុងការនិយាយជាមួយគ្រូ។
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

### គំនូរៈ "ផាត់ពណ៌រូបសត្វទា"

## ១. វត្ថុបំណងៈ

- កុមារប្រាប់ពីរបៀបផាត់ពណ៌រូបសត្វទាបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃពណ៌ ផាត់ពណ៌រូបសត្វទាដោយទប់លំនឹងបង្វិលតាមរូបបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

## ២. សម្ភារបង្រៀនៈ

☞ **សម្ភារសម្រាប់គ្រូៈ**

-ផ្ទាំងក្រដាសដែលមានរូបសត្វទាផាត់ពណ៌រួចចំនួន១សន្លឹក

-ផ្ទាំងក្រដាសរូបសត្វទាដែលមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)

-ខ្មៅដៃពណ៌ចំនួន២ដើម(២ពណ៌),ស្កុតចំនួន១ដុំ។

☞ **សម្ភារសម្រាប់កុមារៈ**

-ផ្ទាំងក្រដាសរូបសត្វទាមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃពណ៌សម្រាប់កុមារ

**៣ការរៀបចំកុមារៈ .** អង្គុយរាងអក្សរ "ប "ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤ .ដំណើរការបង្រៀនៈ(អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូសួរៈ តើនៅផ្ទះកូនមានចិញ្ចឹមសត្វអ្វីខ្លះ? តើសត្វអ្វីដែលយំឮសូរកាបៗ? (ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសរូបដែលមានរូបសត្វទាផាត់ពណ៌រួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្តារខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសរូបសត្វទា១សន្លឹកទៀត ដែលគ្រូមិនទាន់ផាត់ពណ៌ឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារៈ ផ្ទាំងក្រដាសរូបនេះគ្រូទុកសម្រាប់ផាត់ពណ៌ឱ្យកូនមើលពីរបៀបផាត់ពណ៌។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្តើមផាត់ពណ៌ពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាសរូបនោះទៅបិទនៅលើក្តារខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបផាត់ពណ៌
- គ្រូណែនាំពីរបៀបផាត់ពណ៌នៅលើផ្ទាំងក្រដាសរូបសត្វទាដែលបានបិទលើក្តារខៀន ដោយផាត់ពណ៌បណ្តើរ និយាយប្រាប់កុមារបណ្តើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការផាត់ពណ៌។
- គ្រូប្រាប់កុមារៈ
  - កូនយកខ្មៅដៃពណ៌មកផាត់រូបសត្វទាដោយចាប់ផ្តើមផាត់ក្បាលសត្វទាជាមុនសិន បន្ទាប់ផាត់ផ្នែកដងខ្លួន ជើង ដោយទាញពីលើចុះក្រោមនិងមិនឱ្យផាត់ចេញក្រៅរូបសត្វទាឡើយ។ កូនៗត្រូវផាត់បន្តិចៗរបៀបនេះឱ្យពេញរូបផ្ទៃសត្វទា។ (តាមរូបគំនូរផាត់ពណ៌របស់គ្រូដាក់ស្តែង)
  - បន្ទាប់មកកូនយកខ្មៅដៃពណ៌កូនផាត់ពណ៌រូបសត្វទាឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃពណ៌ សម្រាប់កូនផាត់ពណ៌ទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយផាត់ពណ៌ (តាមស្ថានភាពជាក់ស្តែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃពណ៌ផាត់ និងមិនទាន់យល់ពីរបៀបផាត់ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងលើសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារៈ ពេលកូនផាត់រួចហើយកូនយកខ្មៅដៃពណ៌ទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារផាត់ហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់ៈ តើមិត្តភក្តិយើងផាត់បានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ

**ម៉ោងទី៥** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## ល្បែងៈ "បំពេញលេខតាមចន្លោះពី ៥ ដល់ ១៥"

**១វត្ថុបំណងៈ .**

កុមារប្រាប់ពី របៀបបំពេញលេខតាមចន្លោះពី៥ដល់១៥ បានត្រឹមត្រូវ

-កុមារបំពេញលេខតាមចន្លោះពី៥ដល់១៥ បានត្រឹមត្រូវ

-កុមារក្លាហាន -ចូលរួមសហការ ឈ្លាសវៃ រហ័សរហួន ព្យាយាម និងសប្បាយរីករាយ ។

**២សម្ភារបង្រៀនៈ .** បន្ទះលេខចំនួន៣ ប័ណ្ណលេខពី៥ដល់១៥ ចំនួន៣ឈុត ស្កុតកាត់រៀបចំឱ្យហើយ

**៣ ការរៀបចំកុមារៈ .**ឱ្យកុមារអង្គុយជាពាក់កណ្ដាលរង្វង់ និង ជាក្រុមតូចជារង្វង់

**៤ដំណើរការបង្រៀន .**

- គ្រូនិយាយទៅកុមារថាៈ ថ្ងៃនេះគ្រូមានប័ណ្ណលេខជាច្រើន
- គ្រូបង្ហាញបន្ទះលេខដែលមានលេខមិនពេញលេញនិង ប័ណ្ណលេខ តើមានបន្ទះ និង ប័ណ្ណលេខអ្វីខ្លះ ?
- គ្រូបង្ហាញបន្ទះលេខ និងប័ណ្ណលេខ
- ថ្ងៃនេះគ្រូនិងយកមុខវិជ្ជាៈបុរេគណិតមានចំណងជើងថាៈ**ល្បែង បំពេញលេខតាមចន្លោះពី៥ដល់១៥**
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
    - កូនត្រូវអង្គុយជារង្វង់ ទៅតាមក្រុមរបស់កូន ដែលគ្រូបានរៀបចំ
    - កូនត្រូវប្រាប់ឈ្មោះលេខនៅពេលគ្រូលើកបង្ហាញផ្ទាំងលេខនិងប័ណ្ណលេខទាំងអស់នោះហើយកូនត្រូវដាក់ផ្ទាំងលេខទាំងនោះនៅចំកណ្ដាលរង្វង់ក្រុម បន្ទាប់មកកូនប៉ាវរកអ្នកចាប់ផ្ដើម ដើម្បីជ្រើសរើស ប័ណ្ណលេខដាក់បំពេញមុនគេត្រង់កន្លែងដែលមិនទាន់មានលេខ នៅពេលកូនបំពេញលេខចន្លោះបានហើយ កូនត្រូវឱ្យមិត្តភក្តិក្នុងក្រុមកូនជ្រើសរើសប័ណ្ណលេខមកដាក់បំពេញកន្លែងដែលបាត់រហូតដល់ពេញចន្លោះនោះបន្តបន្ទាប់គ្នា
- គ្រូឱ្យកូន១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមអ្វីដែលគ្រូប្រាប់ (បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្ដងទៀត)
- គ្រូរៀបកុមារទាំងអស់លេងជាក្រុមតូចជារង្វង់ឱ្យក្រុមជួយផ្ទៀងផ្ទាត់ ដោយឱ្យតំណាងក្រុមយកបន្ទះប័ណ្ណលេខរបស់ក្រុមដែលបំពេញរួចមកបង្ហាញជារួមហើយអានទាំងអស់គ្នា
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល (បើកុមារតាមក្រុមណាធ្វើបានល្អគ្រូលើកសរសើរ ឬ ចំពោះក្រុមកុមារណាធ្វើមិនបានល្អគ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ)
-

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## ល្បែងសេរី

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦)**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

# ថ្ងៃទី១៨

## ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែងចលនា៖ "បោះបាល់ប្រណាំងគ្នាឱ្យអស់ពីកន្ត្រក"

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបបោះបាល់ឱ្យចូលកន្ត្រកបានត្រឹមត្រូវ
- កុមារបោះបាល់ចូលកន្ត្រកប្រណាំងគ្នា បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្ន និងសប្បាយរីករាយ និងចេះអធ្យាស្រ័យគ្នា ។

**២. សម្ភារបង្រៀន៖**

- កន្ត្រកដែលមានពណ៌ខុសគ្នា( ចំនួនអាស្រ័យលើការបែងចែកក្រុមរបស់គ្រូ)
- កូនបាល់ចំនួន១០ឬច្រើនជាងនេះ ចំនួន២ឈុត

**៣. ការរៀបចំកុមារ៖** ឱ្យកុមារឈរជា២ជួរ ស្របគ្នា

**៤. ដំណើរការបង្រៀន៖**

- គ្រូឱ្យកុមារឈរជា២ជួរបណ្តោយ និងឱ្យកុមារឈរគម្លាតពីគ្នាសមល្មម និងងាយស្រួលក្នុងការសកម្មភាព
- គ្រូនាំកុមារធ្វើច្រៀង និងធ្វើកាយវិការហាត់ប្រាណតាមបទចម្រៀងព្រះអាទិត្យទាំងអស់គ្នា ២ ទៅ៣ដង
- គ្រូបង្ហាញបង្ហាញសម្ភារ ឱ្យកុមារសង្កេត ហើយសួរកុមារថា ចូរកូនទាយទៅមើលថា តើគ្រូនឹងនាំកូនលេងល្បែងអ្វី ជាមួយនឹងកូនបាល់ទាំងនេះ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ឈ្មោះល្បែងដែលត្រូវលេងក្នុងពេលនេះ។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់កុមារថា៖ ល្បែងដែលយើងត្រូវលេង គឺ ល្បែងចលនា បោះបាល់ប្រណាំងគ្នាឱ្យចូលកន្ត្រក។ រួចនាំកុមារអានទាំងអស់គ្នា២ទៅ៣ដង
- គ្រូបន្តណែនាំពីរបៀបលេង និងលក្ខខណ្ឌទៅក្រុមនីមួយៗថា គ្រូនឹងនាំកូនលេងល្បែងនេះជាក្រុម ហើយកូនលេងម្តងពីរក្រុម ដោយឈរជាជួរស្របគ្នាទៅតាមទីដែលគ្រូបានកំណត់ឱ្យ។ កូនៗក្រុមនីមួយៗ ត្រូវមានកន្ត្រកទទេមួយ ដែលមានពណ៌ខុសគ្នា ដោយដាក់នៅចម្ងាយ ២.៥ម៉ែត្រ ពីទីតាំងដែលក្រុមនីមួយៗឈរជាជួរ និងមានបាល់មួយកន្ត្រកសម្រាប់បោះរួមគ្នាដោយដាក់នៅចំពីមុខជួររបស់ក្រុមកូនៗទាំង២។ ពេលគ្រូឱ្យសញ្ញាចាប់ផ្តើម ដោយទះដៃ៣ដង កូននៅឈរមុខគេទាំងពីជួរ ត្រូវយកបាល់ពីកន្ត្រក បោះចូលទៅក្នុងកន្ត្រកដែលជារបស់ក្រុមកូន ហើយដើរមកឈរនៅពីក្រោយ។ បន្ទាប់មកកូនឈរបន្តបន្ទាប់ត្រូវយកបាល់បោះដូចកូនទី១ដែរ។ ពេលក្រុមកូនទាំងពីរ បោះបាល់អស់ពីកន្ត្រកហើយត្រូវពិនិត្យមើល ដោយរាប់បាល់នៅក្នុងកន្ត្រករៀងខ្លួន។ បើក្រុមកូនណាបោះបាល់ចូលកន្ត្រកច្រើនជាងគេ គឺជាអ្នកឈ្នះ។ បន្ទាប់មកគ្រូវប្តូរឱ្យក្រុមកូនៗផ្សេងទៀតបានលេងម្តង ដោយអនុវត្តការលេងដូចក្រុមមុនដែរ។
- គ្រូឱ្យកុមារ ១ ទៅ២នាក់ និយាយឡើងវិញពីរបៀបលេង និងលក្ខខណ្ឌដែលគ្រូបានប្រាប់
- គ្រូចាប់ផ្តើមនាំកុមារលេងទៅតាមរបៀបលេងដែលបានណែនាំរួច និងជួយសម្របសម្រួលពិនិត្យផ្ទៀងផ្ទាត់ការលេង
- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀប

ធៀប និងបន្ទុះបង្អាប់កុមារឡើយ
- គ្រូសួរកុមារថា៖ តើកូនហត់ដែរឬទេ? តើកូនស្រេកទឹកដែរឬទេ? គ្រូមានទឹកឱ្យកូនញ៉ាំតែអត់ត្រជាក់ទេ គឺទឹកតែក្ដៅ ដូច្នេះកូនអាចផ្លុំវាឱ្យត្រជាក់ ដើម្បីញ៉ាំបានដែរឬទេ? បន្ទាប់នាំកុមារធ្វើចលនាផ្លុំទឹកតែក្ដៅ (យកម្រាមដៃឆ្វេង ធ្វើដូចជាកាន់ពែង ម្រាមដៃស្ដាំធ្វើដូចជាកាន់ប៉ាន់តែដែលមានទឹកក្ដៅ ហើយធ្វើដូចជាលើកចាក់មកក្នុងពែង បន្ទាប់មកចលនាផ្លុំឱ្យទឹកតែត្រជាក់) រួចគ្រូសួរកុមារថា តើទឹកតែរបស់កូនត្រជាក់ល្មមញ៉ាំហើយឬនៅ? បើត្រជាក់ហើយ តោះយើងផឹកទាំងអស់គ្នា។
- បន្ទាប់គ្រូសួរម្ដងមួយសំណួរឱ្យកុមារឆ្លើយ៖ តើមុននេះ កូនៗបានលេងល្បែងអ្វី? តើកូនធ្វើចលនាអ្វីខ្លះក្នុងល្បែងដែលកូនអំបាញ់មិញនេះ? តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- បន្ទាប់មកទៀត គ្រូប្រាប់បញ្ជាក់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា " បោះបាល់ប្រណាំងគ្នាចូលកន្ត្រក "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)**

### ទម្លាប់ល្អ៖ ត្រូវចេះជួយគ្នាពេលមានគ្រោះថ្នាក់ (នៅសាលារៀន នៅផ្ទះ និងនៅតាមភូមិ)

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ខែ៦ ម៉ោងទី២)**

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

### គំនូរ៖ "គូរចម្លងតាមគំរូលេង ១១"

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីរបៀបគូសចម្លងតាមគំរូលេខ១១ បានត្រឹមត្រូវ
- កុមារ កាន់ខ្មៅដៃគូសចម្លងតាមគំរូលេខ បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀន៖**
- ប័ណ្ណលេខ គំរូមួយសន្លឹក
- សន្លឹកក្រដាសមានសរសេរលេខ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- ខ្មៅដៃសម្រាប់គូរម្នាក់១ ស្មុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារ៖** អង្គុយគូជាបុគ្គល

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណលេខ ឱ្យកុមារប្រាប់ ដោយសួរកុមារថា៖ **តើបណ្ណនេះមានលេខ អ្វីខ្លះ?** រួចគ្រូបិទប័ណ្ណលេខនោះលើក្តារខៀន
- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរលេខ ១១ហើយបិទលើក្តារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបគូរចម្លងតួលេខមួយៗ យឺតៗលើផ្ទាំងក្រដាសលេខ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្តើរចាប់ពីកន្លែងចាប់ផ្តើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថាបន្តិចទៀតគ្រូនឹងចែកក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្តើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូរចម្លងតាមគំរូលេខ១១ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវ ដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូរនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរលេខ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូ ចាប់ផ្តើមឱ្យកុមារគូរចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកប័ណ្ណលេខដែលខ្លួនបានគូរចម្លង មកបិទលើក្តារខៀន បន្ទាប់ពីគូររួច
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្តងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរនៅមុខមិត្តភក្តិ ម្តងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្តិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់ មិត្តភក្តិដែលលើកបង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវ ណែនាំមិត្តភក្តិឱ្យចេះលើកសរសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពកសាង៖ "បត់រូបត្រី"

**១វត្ថុបំណង៖ .**

កុមារប្រាប់បានពី របៀបបត់រូបត្រី បានត្រឹមត្រូវ -

កុមារបត់រូបត្រី បានត្រឹមត្រូវ -

-កុមារព្យាយាមអំណត់ មានបំរុងប្រយ័ត្ន ច្នៃប្រឌិត និងសប្បាយរីករាយ។

**២ សម្ភារបង្រៀន៖ .**

(តាមចំនួនសិស្ស) ក្រដាសពណ៌ពងការ -

- រូបទន្សាយ បត់រួច ចំនួន១
- កន្ត្រៃ ស្កុត..

**៣ការរៀបចំកុមារៈ .** កុមារអង្គុយជាអក្សរ "ប" រួចបែងចែកជាក្រុម

**៤(អនុវត្តនៅក្នុងជំហានទី៣) ដំណើរការបង្រៀនៈ .**

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញរូបត្រីដែលបានបត់រួច ឱ្យកុមារប្រាប់ពីរូបនោះ និងយកទៅបិទលើក្ដារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូបង្ហាញសម្ភារដែលត្រូវអនុវត្តដាក់លើតុខាងមុខកុមារ ឱ្យកុមារសង្កេត ហើយសួរកុមារថា តើកូនឃើញអ្វីខ្លះនៅលើតុនេះ? ចូរកូនទាយទៅមើលថា តើគ្រូនឹងនាំកូនធ្វើអ្វីជាមួយសម្ភារទាំងនេះ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយទស្សន៍ទាយរបស់កុមារ ដោយលើកសសើរចំពោះកុមារដែលទាយត្រូវ ហើយលើកទឹកចិត្តកុមារដែលឆ្លើយមិនទាន់បានត្រឹមត្រូវឱ្យប្រឹងប្រែងបន្ថែមទៀត រួចគ្រូប្រាប់កុមារថា ដូច្នេះថ្ងៃនេះយើងនឹងលេងល្បែងបត់រូបត្រី។ ហើយនាំកុមារអានទាំងអស់គ្នា២ចប់។
- គ្រូរៀបចំឱ្យកុមារទាញកៅអីមកអង្គុយជាក្រុមព័ទ្ធជុំវិញតុដែលបានរៀបចំរួច និងឱ្យកុមារពីរនាក់មកយកសម្ភារពីគ្រូទៅចែកមិត្តភក្តិគេតាមក្រុមអនុវត្តម្នាក់ៗ
- គ្រូណែនាំពីរបៀបបត់ក្រដាសធ្វើរូបត្រី ដើម្បីឱ្យកុមារសង្កេតឱ្យបានច្បាស់ ហើយគ្រូត្រូវឈរធ្វើយ៉ាងណាឱ្យកុមារមើលឃើញគ្រប់ៗគ្នា ហើយឱ្យកុមារអនុវត្តតាមបណ្ដើរ ដោយនិយាយថា
  - បត់ក្រដាសជារាងត្រីកោណ ហើយយកដៃធូតកន្លែងបត់ឱ្យចេញស្នាម រួចលាក្រដាសវិញដោយទុកឱ្យឃើញស្នាមបត់ បន្ទាប់មកកូនបត់ក្រដាសផ្នែកម្ខាងទៀតជារាងត្រីកោណហើយលាចេញដូចមុន
  - ទាញជ្រុងក្រដាសខាងលើបត់មកដាក់លើជ្រុងក្រដាសខាងក្រោមរួចយកដៃធូតកណ្ដាលឱ្យត្រង់បានជាផ្នត់ រួចលាវិញ
  - បត់ក្រដាសជារាងចតុកោណកែង ចំពាក់កណ្ដាល រួចលាហើយរុញផ្នែកកណ្ដាលចូលទាំងសងខាងបានជារាងត្រីកោណ
  - បត់ជ្រុងទាំងសងខាងឡើងលើ ហើយបត់ចុះពាក់កណ្ដាលមកវិញ ធ្វើជាកន្ទុយ ម្ខាងទៀតបត់ធ្វើជាខ្លួន និងក្បាល បន្ទាប់មកយក ខ្មៅដៃមកគូរធ្វើរូបភ្នែកត្រី
- គ្រូដើរសម្របសម្រួលទៅតាមជួរនីមួយៗដោយជួយកុមារណាដែលមិនទាន់ចេះធ្វើ
- គ្រូនាំកុមារទៀងផ្ទាត់លទ្ធផលរបស់កុមារម្នាក់ៗរួចឱ្យកុមារចេញម្ដងមួយក្រុមៗតាមឈរពីមុខមិត្តភក្តិគេដោយកាន់រូបដែលខ្លួនបានបត់ដាក់ត្រឹមដើមទ្រូងដើម្បីបង្ហាញ
- គ្រូសួរកុមារៈ តើមិត្តភក្តិយើងបត់រូបត្រីបានត្រឹមត្រូវទេ?បត់បានស្អាតទេ?
- គ្រូនិយាយប្រាប់កុមារៈ ពេលក្រុមកូនបង្ហាញរួចហើយកូនកាន់រូបនេះទៅអង្គុយកន្លែងដើមវិញ។
- ពេលនាំកុមារផ្ទៀងផ្ទាត់លទ្ធផល គ្រូមិនត្រូវបង្អាប់កុមារដែលធ្វើមិនទាន់បានល្អនោះទេ។គ្រូត្រូវចេះសរសើរ លើកទឹកចិត្តកុមារឱ្យបានគ្រប់ៗគ្នាដើម្បីឱ្យពួកគេប្រឹងប្រែងបន្តទៀត។
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតទាល់តែគ្រប់កុមារទាំងអស់។
- គ្រូឱ្យ កុមារម្នាក់ៗយករូបត្រីដែលបានបត់ មកជូនគ្រូម្នាក់ម្ដង ដោយគ្រូសរសេរកាលបរិច្ឆេទ និងឈ្មោះកុមារលើរូបរបស់កុមារម្នាក់នៅចន្លោះដែលអាចមើលឃើញដើម្បីទុកសម្រាប់ដាក់តាំងស្នាដៃកុមារនៅលើផ្ទាំងស្នាដៃកុមារនៅថ្ងៃបន្ទាប់។

## ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ ភាសាខ្មែរ

## គំនូរៈ "គូរចម្លងតាមគំរូតួអក្សរ ណ ត ថ"

### ១. វត្ថុបំណងៈ

- កុមារប្រាប់បានពីរបៀបគូសចម្លងតាមគំរូតួអក្សរ ណ ត ថ បានត្រឹមត្រូវ
- កុមារ គូសចម្លងតាមគំរូតួអក្សរ ណ ត ថ បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

### ២. សម្ភារបង្រៀនៈ

- បណ្ណតួអក្សរ ណ ត ថ គំរូមួយសន្លឹក
- សន្លឹកក្រដាសមានសរសេរតួអក្សរ ណ ត ថ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- ខ្មៅដៃសម្រាប់គូសម្នាក់១ ស្តុកកាត់រួចជាស្រេច

### ៣. ការរៀបចំកុមារៈ អង្គុយគូសជាបុគ្គល

### ៤. ដំណើរការបង្រៀនៈ (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញប័ណ្ណតួអក្សរ ណ ត ថ ឱ្យកុមារប្រាប់ ដោយសួរកុមារថាៈ **តើប័ណ្ណនេះមានតួអក្សរអ្វីខ្លះ?** រួចគ្រូបិទប័ណ្ណតួអក្សរនោះលើក្តារខៀន
- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរតួអក្សរ ណ ត ថ ដែលមានស្នាមចុច ហើយបិទលើក្តារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបសរសេរម្តងមួយតួអក្សរៗ យឺតៗលើផ្ទាំងក្រដាសតួអក្សរដែលមានស្នាមចុចនោះ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្តើរចាប់ពីកន្លែងចាប់ផ្តើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថាៈ បន្តិចទៀតគ្រូនឹងក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្តើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូសតួអក្សរ ណ ត ថ តាមស្នាមចុច ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវ ដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរតួអក្សរ ណ ត ថ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារចាប់ផ្តើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកប័ណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្តារខៀន បន្ទាប់ពីគូសរួច
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្តងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរ

នៅមុខមិត្តភក្តិ ម្តងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្តិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់ មិត្តភក្តិដែលលើកបង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវនាំណែនាំមិត្តភក្តិឱ្យចេះលើកសសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ

- គ្រូនាំកុមារអានមុខវិជ្ជា ចំណងជើងជាក្រុម និងទាំងអស់គ្នា
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

**ល្បែងសេរី**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦)**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

## ថ្ងៃទី១៩

**ម៉ោងទី១ រយៈពេល៖ ៣០នាទី**

## មុខវិជ្ជា៖ ចិត្តចលនាព

ហាត់ប្រាណតាមបទចម្រៀង៖ "លេងឈូង"(រំលឹក)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១៤ ខែ៦ ម៉ោងទី១)

**ម៉ោងទី២** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

សកម្មភាពប្រចាំថ្ងៃ ៖ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី២)

ទម្លាប់ល្អ៖ ត្រូវចេះជួយគ្នាពេលមានគ្រោះថ្នាក់ (នៅសាលារៀន នៅផ្ទះ និងនៅតាមភូមិ)

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ខែ៦ ម៉ោងទី២)

**ម៉ោងទី៣** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

កំណាព្យ៖ "អ្នកគ្រូយើង"

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំណងជើង និងអត្ថន័យនៃកំណាព្យ "អ្នកគ្រូយើង" បានត្រឹមត្រូវ
- កុមារមានសមត្ថភាពសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងលំនាំបទ បានត្រឹមត្រូវ
- បណ្ដុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ

**២ . សម្ភារបង្រៀន៖** -គ្មាន

**៣ . ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "U"

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣ )**

-ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្ដាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទ និងយល់អត្ថន័យ នៃរកពាក្យពិបាក គ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់និយាយពីអ្វី?
  - គ្រូប្រាប់និងពន្យល់ពាក្យពិបាកមានពាក្យ ថ្នក់ថ្នម មានន័យថាបីបាច់ថែរក្សាដោយយកចិត្តទុកដាក់ ។ កៀកកិត មានន័យថាស្និតស្នាលជិតដិត។
  - អត្ថបទកំណាព្យនេះគឺចង់ឱ្យកុមារចេះរកពាក្យបណ្ដៅ
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ

- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអំបាញ់មិញកូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈភាសាខ្មែរ មេរៀនៈកំណាព្យ "**អ្នកគ្រូយើង**" អ្នកនិពន្ធដោយលោក អ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាព្យ "អ្នកគ្រូយើង "(បទកាកគតិ)**

អ្នកគ្រូយើងអើយ　នៅជិតបង្កើយ　កៀកកិតកុមារ
លួងលោមថ្នាក់ថ្នម　អស់ពីចិន្តា　ប្រៀបបុត្រស្នេហា
　　　　　　　　　រក្សាលើកស្ទួយ ។
ពួកយើងសង្ឃឹម　អ្នកគ្រូញញឹម　រង់ចាំតែជួយ
ដោះស្រាយមុខក្រោយ　មិនឱ្យមានព្រួយ　យើងចិត្តតែមួយ
　　　　　　　　　ស្រឡាញ់អ្នកគ្រូ ។

**ម៉ោងទី៤** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

### ល្បែងៈ "ដាក់សញ្ញាតាង" (រំលឹក)

### (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១៤ ខែ៦ ម៉ោងទី៤)

**ម៉ោងទី៥** (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ

**សន្ទនាៈ "សត្វចិញ្ចឹមកូនដោយទឹកដោះ និងសត្វដែលចិញ្ចឹមកូនដោយចំណីអាហារ"**

**១. វត្ថុបំណងៈ**
- កុមារប្រាប់បានពីប្រភេទសត្វចិញ្ចឹមកូនដោយទឹកដោះនិងសត្វចិញ្ចឹមកូនដោយចំណីអាហារ បានត្រឹមត្រូវ
- កុមាររៀបរាប់ពី ប្រភេទសត្វចិញ្ចឹមកូនដោយទឹកដោះនិងសត្វចចិញ្ចឹមកូនដោយចំណីអាហារ បានក្បោះក្បាយ
- បណ្តុះទម្លាប់កុមារឱ្យយកចិត្តទុកដាក់មានអំណត់និងចូលរួមសហការយ៉ាងសកម្មជាមួយគ្រូនិងកុមារដទៃ

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជាអក្សរ "U" កុមារអង្គុយជាដៃគូ

**៤. ដំណើរការបង្រៀនៈ (អនុវត្តនៅក្នុងជំហានទី៣)**
- គ្រូបំផុសសំណួរៈ- តើថ្ងៃនេះ យើងរៀនពីមុខវិជ្ជាអ្វី?មេរៀនអ្វីកូន?
  (ឱ្យកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនទាំងអស់គ្នា)
- គ្រូណែនាំទៅដល់កុមារទាំងអស់គ្នាសិនដើម្បីអនុវត្តការងារទៅតាមក្រុមដៃគូ

- គ្រូឱ្យកុមារចាប់ដៃគូគ្នាពីរៗនាក់សន្ទនាពីប្រភេទសត្វចិញ្ចឹមកូនដោយទឹកដោះនិងសត្វចិញ្ចឹមកូនដោយចំណីអាហារ( ឧ៖ តើនៅផ្ទះកូនមានចិញ្ចឹមសត្វអ្វីខ្លះ ហើយសត្វទាំងនោះរស់នៅឯណាខ្លះ? ចុះកូនមានដឹងទេថាសត្វអ្វីខ្លះដែរចិញ្ចឹមកូនដោយទឹកដោះតើកូនអាចរៀបរាប់បានឬទេ? ហើយចុះសត្វអ្វីដែរចិញ្ចឹមកូនដោយចំណីអាហារតើកូនអាចរៀបរាប់ប្រាប់មិត្តភក្តិយើងបានទេ?
- គ្រូឱ្យកុមារ១ឬ២នាក់និយាយពីការណែនាំឡើងវិញម្តងទៀតប្រាប់ទៅកុមារទាំងអស់គ្នា
- គ្រូទុកពេលឱ្យកុមារសន្ទនា និងផ្លាស់ប្តូរដៃគូសន្ទនាគ្នាទៅវិញទៅមក
- ហើយនិយាយប្រាប់គ្រូពីលទ្ធផលនៃការសន្ទនា
- កុមារតាមក្រុមដៃគូនីមួយៗចាប់ផ្តើមសន្ទនាគ្នា គ្រូដើរសម្របសម្រួល
- ឱ្យកុមារ១ឬ២គូឡើងនិយាយរៀបរាប់ពីអ្វីដែលកុមារបានដឹងនិងស្គាល់ប្រភេទសត្វចិញ្ចឹមកូនដោយទឹកដោះនិងសត្វចិញ្ចឹមកូនដោយចំណីអាហារ
- គ្រូបូកសរុបរួមនិងប្រាប់កុមារបន្ថែមលើប្រភេទសត្វចិញ្ចឹមកូនដោយទឹកដោះនិងសត្វចិញ្ចឹមកូនដោយចំណីអាហារប្រាប់ ទៅកុមារទាំងអស់គ្នា

**ម៉ោងទី៦** (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**ល្បែងសេរី**

**( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ខែ៦ ម៉ោងទី៦ )**

**រំលឹកមេរៀនប្រចាំថ្ងៃ អនាម័យ រៀបចំខ្លួនទៅផ្ទះ**

# ការគាំទ្រនិងដំណើរការនៃការបង្កើត
# និងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍
# របស់អង្គការគាំពារកុមារខ្មែរ (CYK)
# នៅប្រទេសកម្ពុជា

# មត្តេយ្យសិក្សាសហគមន៍របស់អង្គការគាំពារកុមារខ្មែរ(CYK)

I. **សាវតារគម្រោង៖**

អង្គការគាំពារកុមារភៀសខ្លួន(CYR) ជាអង្គការមិនមែនស្ម័គ្រចិត្តសម្រាប់សាសនា និងមិនមែនរដ្ឋាភិបាល ហើយត្រូវបង្កើតឡើងនៅទីក្រុងតូក្យូក្នុងឆ្នាំ១៩៨០ ដើម្បីឆ្លើយតបនឹងកង្វះខាតដ៏ធ្ងន់ធ្ងររបស់កុមារភៀសខ្លួនកម្ពុជា ដែលរស់នៅប្រទេសថៃ។ អង្គការគាំពារកុមារភៀសខ្លួនបានធ្វើការគាំទ្រមណ្ឌលសម្រាប់សាលាមត្តេយ្យជាច្រើន"ភូមិដ្ឋាននៃក្តីសង្ឃឹម" នៅក្នុងជំរុំភៀសខ្លួនរហូតដល់ពេលដែលជនភៀសខ្លួនទាំងនោះធ្វើមាតុភូមិនិវត្តន៍មកកាន់មាតុប្រទេសវិញ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

អង្គការគាំពារកុមារខ្មែរ(CYK)ដែលជាផ្នែកមួយរបស់អង្គការកុមារភៀសខ្លួនក៏បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៩១។ អង្គការគាំពារកុមារខ្មែរ(CYK)បានគាំទ្រដល់កម្មវិធីថែទាំនិងអប់រំកុមារតូចនៅតាមសហគមន៍ ដើម្បីជាការលើកស្ទួយសុខមាលភាពរបស់កុមារនិង ភាពម្ចាស់ការដោយខ្លួនឯងរបស់មាតាបិតាកុមារទាំងនោះ តាមរយៈសកម្មភាពបង្កើតប្រាក់ចំណូល។ ជាងនេះទៅទៀត អង្គការគាំពារកុមារខ្មែរបានប្រមើលមើលពិភពលោកដ៏ល្អ ដែលមនុស្សរស់នៅ ជាពិសេសគឺសម្រាប់កុមារតូចៗនិងស្ត្រីអាច រីកចំរើនលូតលាស់ ធំធាត់ និងអភិវឌ្ឍខ្លួនឯងបាន ដោយគ្មាន ភាពអត់ឃ្លាន គ្មានភាពក្រីក្រ នេះហើយជាទីដែលមនុស្សរស់នៅ ក្នុងភាពសុខដុមរមនា ដែលអាចកសាងសង្គមកម្ពុជា ជាសង្គមពុទ្ធិនិងវិបុលភាព។

II. **ទស្សនវិស័យ៖**

អង្គការគាំពារកុមារខ្មែរបានប្រមើលពិភពលោកដ៏ល្អ ដែលមនុស្សរស់នៅ ជាពិសេសគឺសម្រាប់កុមារតូចៗ និងស្ត្រី អាចរីកចំរើនលូតលាស់ ធំធាត់ និងអភិវឌ្ឍខ្លួនឯងបានដោយគ្មានភាពអត់ឃ្លាន គ្មានភាពក្រីក្រនេះហើយជាទីដែល មនុស្សរស់នៅក្នុង ភាពសុខដុមរមនា ដើម្បីអាចកសាងសង្គមកម្ពុជាជាសង្គមពុទ្ធិនិងវិបុលភាព។

III. **បេសកកម្ម៖**

អង្គការគាំពារកុមារមានគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍ រាងកាយនិងផ្លូវចិត្តរបស់កុមារដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពលនិងផលិតភាពសម្រាប់ប្រទេសជាតិនាពេលអនាគត។

IV. **គុណតម្លៃ៖**

"កុមារ ជាអនាគតរបស់យើង" ភាពរីករាយរបស់កុមារនៅថ្ងៃនេះអាចនាំមកនូវសន្តិភាពនៅថ្ងៃស្អែក។

V. **គម្រោងមត្តេយ្យសិក្សាសហគមន៍៖**

ចាប់ពីឆ្នាំ២០១១ អង្គការគាំពារកុមារខ្មែរ(CYK) បានពង្រីកគម្រោងអប់រំកុមារតូចរបស់ខ្លួន ដោយបើកឱ្យដំណើរការមត្តេយ្យសិក្សាសហគមន៍ ក្រោមកិច្ចសហប្រតិបត្តិការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង និងមន្ត្រីជំនាញនៃការិយាល័យអប់រំស្រុក អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងសហគមន៍ក្នុងខេត្តទាំងនោះ។

**១. គោលបំណង៖**

ដើម្បីចូលរួមក្នុងការលើកកម្ពស់អនុវិស័យអប់រំកុមារតូចនៅប្រទេសកម្ពុជា អង្គការគាំពារកុមារខ្មែរបាន៖

ក. បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូច ប្រកបដោយគុណភាព និងទាន់ពេលវេលាសម្រាប់កុមារដែលគ្រប់អាយុចូលរៀននៅមត្តេយ្យសិក្សា ជាពិសេសកុមារអាយុ៥ឆ្នាំ(នៅតំបន់ដែលជួបការលំបាក) ដោយផ្តល់ឱកាសឱ្យគាត់មានការអភិវឌ្ឍសមត្ថភាពពេញលេញនិងគ្រប់ផ្នែកគឺគាត់ចេះរួម

រស់នៅជាមួយគ្នា ដោយសុខដុមរម្យនា។ មានទំនាក់ទំនងល្អជាមួយមិត្តភក្តិ ជាមួយមនុស្សធំនៅជុំវិញខ្លួនដោយមានទំនុកចិត្ត។ ការប្រើពាក្យសម្តី និងអត្តចរិតបានសមរម្យ មានភាពក្លាហាន ម្ចាស់ការទទួលខុសត្រូវរាល់ការងារដែលពួកគេបានធ្វើ ចេះរង់ចាំវេន សហការគ្នាក្នុងការធ្វើអ្វីមួយ។ មានភាពស្មោះត្រង់ ចេះចែករំលែកសម្ភារៈលេង នំចំណីឲ្យគ្នាទៅវិញទៅមក។ មានគំនិតច្នៃប្រឌិតក្នុងការលេង ក្នុងការធ្វើអ្វីមួយឲ្យបានសម្រេច។ ចេះរាប់លេខ អានអក្សរ ស្គាល់រាង ពណ៌ ប្រើម្រាមដៃក្នុងការគូររូបផ្សេងៗ បត់រូប សូនរូបជាដើម។ កុមារមានសុខភាពល្អតាមរយៈការធ្វើចលនាពេលហាត់ប្រាណរាល់ព្រឹកនិងការញុំាអាហារសម្រន់ដែលមានគុណភាព

ខ. ចូលរួមចំណែកបង្កើន អត្រាចូលរៀនរបស់កុមារអាយុ៦ឆ្នាំនៅសាលាបឋមសិក្សា និងបន្តគ្រប់ភូមិសិក្សា ប្រកបដោយគុណភាព មិនត្រួតថ្នាក់និងមិនបោះបង់ការសិក្សា។

គ. លើកកម្ពស់ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន សហគមន៍ សប្បុរសជននានាដើម្បីធានាថាមត្តេយ្យសិក្សសហគមន៍ដែលគាំទ្រដោយអង្គការគាំពារកុមារខ្មែរ បំពេញបានយ៉ាងពេញលេញនូវស្តង់ដារ និងនិរន្តរភាពនៃមត្តេយ្យសិក្សាសហគមន៍របស់ក្រសួងអប់រំ យុវជន និងកីឡា។

ឃ. កសាងសមត្ថភាពសម្រាប់សមាជិកគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ស្តីពីការងារមត្តេយ្យសិក្សាសហគមន៍រួមទាំងការកៀរគរធនធាន ដើម្បីឱ្យពួកគាត់អាចកៀរគរធនធានក្នុងមូលដ្ឋានសម្រាប់គាំទ្រដល់មត្តេយ្យសិក្សាសហគមន៍។

ង. លើកកម្ពស់ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមាន (កម្មវិធីអប់រំមាតាបិតា) ក្នុងចំណោមឳពុកម្តាយ និងអាណាព្យាបាលកុមារ។ តាមរយៈកម្មវិធីនេះឪពុកម្តាយនិងអាណាព្យាបាលកុមារទទួលស្គាល់ការអប់រំនិងការថែទាំកូន គឺជាកាតព្វកិច្ចរបស់ពួកគាត់ និងយល់ពីសារៈសំខាន់នៃការសិក្សារបស់កូននៅមត្តេយ្យសិក្សាសហគមន៍។ កែប្រែអត្តចរិតពីមិនសូវយកចិត្តទុកដាក់ជាមួយកូន មកជាការយកចិត្តទុកដាក់ជាមួយកូនរាល់ពេល ដោយផ្តល់អ្វីៗជាតម្រូវការត្រឹមត្រូវរបស់កូន។ យល់ពីវិធីសាស្រ្តនៃការថែទាំនិងចិញ្ចឹមកូនឱ្យបានល្អ។ បង្កើនទំនាក់ទំនងល្អជាមួយគ្រូ ជាមួយសហគមន៍ ក្នុងការជួយបំពេញចំណេះដឹងឱ្យកូន។

ច. ជួយគាំទ្រឪពុកម្តាយ និងអាណាព្យាបាលកុមារ ដើម្បីរកចំណូលបន្ថែម សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ និងរួមចំណែកបង់វិភាគទានដល់មត្តេយ្យសិក្សាសហគមន៍ សម្រាប់ការអប់រំកូនពួកគាត់។

**២. លក្ខខណ្ឌតម្រូវៈ**

- មានតម្រូវការថ្នាក់មត្តេយ្យសិក្សាសហគមន៍ខ្លាំង ដោយសារមិនទាន់មានសេវាមត្តេយ្យនៅក្បែរ ហើយមានកុមារដែលគ្រប់អាយុចូលមត្តេយ្យសិក្សាមានចំនួនច្រើន។
- មានទីតាំងសម្រាប់ប្រើប្រាស់ជាថ្នាក់មត្តេយ្យ ដូចជាថ្នាក់ទំនេរក្នុងសាលាបឋមសិក្សា បន្ទប់ប្រជុំក្នុងភូមិ សាលាបុណ្យ ឬដីទំនេរនៅក្នុងសហគមន៍សម្រាប់សាងសង់។
- មានគ្រូស្ម័គ្រចិត្តក្នុងសហគមន៍សម្រាប់មត្តេយ្យសិក្សាសហគមន៍។
- ក្រុមប្រឹក្សាឃុំដឹកនាំរចនាសម្ព័ន្ធប្រតិបត្តិការ ដោយបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សា សហគមន៍ ជួបប្រជុំជាមួយអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន ផ្សព្វផ្សាយពីគោលបំណងនៃការបង្កើត និងគ្រប់គ្រងដោយខ្លួនឯងនូវថ្នាក់មត្តេយ្យសិក្សាសហគមន៍ ដោយមានការគាំទ្រពីឪពុកម្តាយ។
-ក្រុមប្រឹក្សាឃុំត្រូវគ្រោងថវិកាសម្រាប់ប្រាក់ឧត្ថម្ភគ្រូក្នុងអំឡុងពេលដែលអង្គការគាំទ្រ និងគាំទ្រផ្នែក

ហិរញ្ញវត្ថុ ដូចជាប្រាក់ឧត្ថម្ភគ្រូ លើការងារបង្រៀន/រៀន ការផលិតសម្ភារៈ ការបំប៉នសមត្ថភាពគ្រូ និងការអភិវឌ្ឍន៍ថ្នាក់រៀន ក្រោយពេលវេលាកំណត់នៃជំនួយដែលមានរយៈពេល៣ឆ្នាំ។ លើសពីនេះ ការចំណាយលើការគ្រប់គ្រងផ្សេងទៀតនិងអាហារសម្រន់(ប្រសិនបើចាំបាច់)សម្រាប់កុមារនឹងត្រូវត្រៀមដោយគណៈកម្មការគ្រប់គ្រងនិងឪពុកម្តាយ។

- ថ្នាក់មត្តេយ្យសហគមន៍ត្រូវក្លាយជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ ហើយគ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រងនិងក្រុមប្រឹក្សាឃុំ។ ឪពុកម្តាយនឹងចូលរួមចំណែកតូចមួយដោយចូលរួមបង់វិភាគទានប្រចាំខែក្នុងអំឡុងពេលដែលអង្គការគាំទ្ររយៈពេល៣ឆ្នាំ និងបន្តបង់វិភាគទានដើម្បីបំពេញតម្រូវការសម្ភារៈនៅមត្តេយ្យសិក្សាសហគមន៍ ចាប់ពីឆ្នាំទី៤តទៅ។

**៣. ការរៀបចំបង្កើតនិងដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍៖**

- ជួសជុលបន្ទប់ចាស់ៗនិងបង្គន់អនាម័យ ដោយមានលាបថ្នាំថ្មី ក្រាលការ៉ូ និងសាងសង់បង្គន់អនាម័យប្រសិនបើមិនទាន់មាន និងសាងសង់កន្លែងលាងដៃដែលជាការចូលរួមបដិភាគរបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍លើថ្លៃជាង។
- ករណីសាងសង់ថ្នាក់រៀនថ្មីនិងបង្គន់អនាម័យ ( ត្រូវអនុវត្តតាមស្តង់ដារអប្បបរមារបស់ក្រសួងអប់រំ យុវជន និងកីឡាដែលថ្នាក់មានទំហំ៦ម×៦ម) ប៉ុន្តែសហគមន៍អាចពង្រីកទំហំបន្ថែមបាន ហើយការសាងសង់កន្លែងលាងដៃដែលជាការចូលរួមបដិភាគរបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍លើថ្លៃជាង។ ថ្នាក់រៀនសង់ដោយដាក់សរសរលេចចេញក្រៅដើម្បីងាយស្រួលតុបតែង និងត្រូវមានបង្អួច៧ហើយបង្អួចនីមួយៗត្រូវមានចម្រឹងនិងទ្វារបិទ-បើក មានក្រាលការ៉ូខាងក្នុង និងមានសាបជុំវិញប្រវែងយ៉ាងតិច១ម៉ែត្រ។ បង្គន់អនាម័យត្រូវមានអាងស្តុកទឹក ចានបង្គន់ មានក្រាលការ៉ូខាងក្នុងយ៉ាងហោចណាស់ត្រឹមមាត់អាងស្តុកទឹក និងមានតទឹកចូលក្នុងអាង។
- ផ្តល់ជាកញ្ចប់សម្ភារៈបរិក្ខាដូចជាតុនិងកៅអីសម្រាប់កុមារនិងគ្រូ ទូដាក់ឯកសារគ្រូ ទូរដាក់សម្ភារៈល្បែង ទូរដាក់ស្បែកជើង សម្ភារៈបម្រើឱ្យការងារបង្រៀននិងរៀន សម្ភារៈអនាម័យ សៀវភៅរឿង សៀវភៅវិទ្យាសាស្ត្ររូបភាព សៀវភៅកំណាព្យ សៀវភៅចម្រៀង និងសម្ភារៈល្បែងសិក្សាមួយចំនួន
- ផ្តល់ល្បែងក្រៅថ្នាក់ចំនួន១កំប្លេ (ក្តាររំអិលនិងប៉ាក់បើកធ្វើពីឈើ)។
- ផ្តល់អាហារសម្រន់ដល់កុមារ(នំប្រចាំថ្ងៃ ពងទាឬពងមាន់ស្ងោរ និងទឹកសណ្តែក ចំនួន២ដងក្នុង១ខែ)
- បណ្តុះបណ្តាល និងបំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍តាមស្តង់ដា។
- កសាងសមត្ថភាពដោយបើកវគ្គបំប៉នគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តការងារប្រចាំឆ្នាំរបស់គណៈកម្មការ និងលើកផែនការអនុវត្តបន្ត។
- រៀបចំកម្មវិធីទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍សម្រាប់គ្រូមត្តេយ្យសិក្សាសហគមន៍និងគណៈ កម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។
- រៀបចំកម្មវិធីពិសេសសម្រាប់កុមារ(ទិវាកុមារអន្តរជាតិ១មិថុនា និងកម្មវិធីបញ្ជូនកុមារគ្រប់អាយុ៦ឆ្នាំទៅរៀននៅសាលាបឋមសិក្សា)។
- ចុះពិនិត្យតាមដានការងារគ្រូមត្តេយ្យសិក្សាសហគមន៍ប្រចាំខែ ដោយទីប្រឹក្សាគម្រោងអប់រំកុមារតូចរបស់អង្គការ មន្ត្រីជំនាញថ្នាក់មន្ទីរនិងថ្នាក់ស្រុក និងគ.ក.ន.កឃុំ។
- ចុះពិនិត្យតាមដាននិងវាយតម្លៃរៀងរាល់៣ខែម្តងនៅឆ្នាំបន្ទាប់ ក្រោយពីបានផ្ទេរការទទួលខុសត្រូវលើ

ដំណើរការនិងការគ្រប់គ្រងមត្តេយ្យជូនក្រុមប្រឹក្សាឃុំ និងគណៈកម្មការគ្រប់គ្រង។

- លើកកម្ពស់ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមានតាមយៈកម្មវិធីអប់រំមាតាបិតា និងប្រជុំជាមួយមាតាបិតា/គណៈកម្មការគ្រប់គ្រង ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ ឬសំណូមពរទាក់ទងនឹងមត្តេយ្យសិក្សាសហគមន៍។

## VI. ដំណើរការនៃការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍៖

### ១. មុនពេលដំណើរការថ្នាក់៖

នៅពេលអង្គការគាំពារកុមារខ្មែរ(CYK)បានកំណត់យកខេត្តដែលត្រូវសហការក្នុងការគាំទ្រ មត្តេយ្យសិក្សាសហគមន៍ហើយនោះ នាយិកាអង្គការ បានទៅជួបជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំយុវជន និងកីឡាខេត្ត និងអ្នកទទួលបន្ទុកការងារអប់រំកុមារតូចថ្នាក់មន្ទីរ ដើម្បីបង្ហាញពីគោលបំណងនៃគម្រោងរបស់អង្គការដែលត្រូវអនុវត្តនៅប្រទេសកម្ពុជា និងសិក្សាថាតើអាចទទួលយកបាននិងសហការធ្វើការងារជាមួយគ្នាបានដែរឬទេ? បើសិនជាថ្នាក់មន្ទីរអេ.យ.កខេត្តព្រមព្រៀងហើយនោះក៏ត្រូវកំណត់ជ្រើសរើសស្រុកគោលដៅសម្រាប់អនុវត្ត រួចផ្តល់ព័ត៌មានទៅឱ្យមន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុកគោលដៅទាំងអស់ ដើម្បីផ្តល់ព័ត៌មានបន្តទៅដល់សហគមន៍។ ពេលឯកភាពគ្នាហើយក៏បានធ្វើកិច្ចព្រមព្រៀងរវាងមន្ទីរអេ.យ.កខេត្ត ជាមួយអង្គការគាំពារកុមារខ្មែរ(CYK)។

បន្ទាប់មកសហគមន៍នៅតាមស្រុកគោលដៅនីមួយៗ ធ្វើសំណើរមិនទាន់ជាផ្លូវការមកអង្គការគាំពារកុមារខ្មែរ(CYK)តាមរយៈ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងថ្នាក់ដឹកនាំមន្ទីរអេ.យ.កខេត្ត ដោយភ្ជាប់ជាមួយនូវស្ថិតិកុមារអាយុពី៣ឆ្នាំដល់ក្រោម៦ឆ្នាំក្នុងភូមិគោលដៅដែលចង់បង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍។ ថ្នាក់ដឹកនាំមន្ទីរអេ.យ.កខេត្ត ពេលបានសំណើតាមស្រុកគោលដៅហើយនោះ ក៏សរុបផ្ញើមកនាយិកាអង្គការគាំពារកុមារខ្មែរ(CYK) ដើម្បីស្នើសុំទៅជួយសិក្សាទីតាំងទាំងនោះ ដែលត្រូវផ្តល់អគារថ្មី ឬជួសជុលអគារចាស់។

នាយិកាអង្គការគាំពារកុមារខ្មែរ(CYK) ពេលបានទទួលសំណើរបស់សហគមន៍គ្រប់អស់ហើយក៏បានពិនិត្យមើលសំណើទាំងនោះ ដើម្បីវិភាគរកទីកន្លែងជាអាទិភាពដែលត្រូវចុះទៅសិក្សាទីតាំង។ ពេលចុះសិក្សាទីតាំងមានការចូលរួមពីមន្ត្រីជំនាញអប់រំកុមារតូចថ្នាក់មន្ទីរនិងថ្នាក់ស្រុក ដោយជួបជាមួយគណៈកម្មការដែលសហគមន៍បានរៀបចំទុកមុន និងមេឃុំជាដើម ដើម្បីសួរព័ត៌មានមួយចំនួនដែលទាក់ទងនិងស្ថិតិកុមារ ស្ថានភាពប្រជាជន ការចូលរួមរបស់សហគមន៍និងមាតាបិតាកុមារ ការជ្រើសរើសគ្រូ ពិនិត្យមើលទីកន្លែងដែលត្រូវសាងសង់អគារថ្មីឬជួសជុលអគារចាស់ និងពន្យល់លម្អិតអំពីគម្រោងរបស់អង្គការ ជាពិសេសប្លង់អគារដែលត្រូវសាងសង់ថ្នាក់មត្តេយ្យសិក្សាសហគមន៍។ បន្ទាប់មកគណៈកម្មការត្រូវធ្វើសំណើផ្លូវការដោយមានភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា លិខិតស្នើសុំ តារាងប៉ាន់ស្មានតម្លៃ លិខិតបង្គាប់ការ លិខិតផ្ទេរទីតាំងសម្រាប់ប្រើប្រាស់ជាថ្នាក់មត្តេយ្យ ស្ថិតិកុមារពី០ដល់៥ឆ្នាំក្នុងភូមិចំណុះជាដើម។ល។ ពេលសិក្សាទីតាំងចប់សព្វគ្រប់និងមានសំណើផ្លូវការពីគណៈកម្មការតាមរយៈការិយាល័យអ.យ.កស្រុកនិងមន្ទីរអេ.យ.កខេត្ត ហើយ នាយិកាអង្គការនិងក្រុមការងារគម្រោងអប់រំកុមារតូចពិភាក្សាគ្នានិងវិភាគម្តងទៀត ដើម្បីកំណត់កន្លែងជាអាទិភាពចុងក្រោយ។ រួចដាក់ស្នើសុំទៅទីស្នាក់ការកណ្តាលប្រចាំនៅទីក្រុងតូក្យូប្រទេសប្រជប៉ុន (អង្គការគាំពារកុមារកៀសខ្លួន(CYR)) ដោយភ្ជាប់ជាមួយនូវរបាយការណ៍សិក្សាទីតាំង រូបភាព និងសំណើ។

ក្រោយពីបានឯកភាពគ្នារវាងអង្គការគាំពារកុមារខ្មែរ និងទីស្នាក់ការកណ្តាលលើការជ្រើសរើសទីតាំងសម្រាប់អនុវត្តគម្រោងមត្តេយ្យសិក្សាសហគមន៍ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការចុះជួបជា

មួយគណៈកម្មការនិងជាងសំណង់ម្តងទៀត ដោយមានការចូលរួមរបស់មន្ត្រីជំនាញថ្នាក់មន្ទីរនិងថ្នាក់ស្រុក ដើម្បី ពិភាក្សានិងបញ្ជាក់អំពីទំហំបន្ទប់ អ្នកទទួលខុសត្រូវតាមដានការសាងសង់ឬជួសជុល ការងារជ្រើសរើសគ្រូបង្រៀន ការចូលរួមវិភាគទានរបស់មាតាបិតាកុមារ ការបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ជាដើម។ល។ ករណីឯកភាពគ្នា ត្រូវធ្វើកិច្ចសន្យាស្តីពីការងារគ្រប់គ្រងនិងដំណើរការមត្តេយ្យសិក្សាសហគមន៍ និងចុះហត្ថលេខារវាងគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ជាមួយអង្គការគាំពារកុមារខ្មែរ(CYK)។ បន្ទាប់មកក៏បានជួបជាមួយជាងសំណង់ ដើម្បីពិភាក្សានិងបញ្ជាក់អំពីប្លង់នៃការសាងសង់ឬជួសជុល ចរចារតម្លៃនៃការងារសំណង់ និងដំណាក់កាលនៃការបង់ប្រាក់ដោយឱ្យជាងមានជម្រើសគឺៈ

**ជម្រើសទី១ៈ** បង់ប្រាក់លើកទី១ចំនួន៥០%ពេលចុះហត្ថលេខាលើកិច្ចសន្យា លើកទី២ចំនួន៣០%ពេលការងារបាន៥០%និងលើកចុងក្រោយចំនួន២០% ពេលការងារចប់សព្វគ្រប់ដោយមានការយល់ព្រមទទួលស្គាល់ ដោយគណៈកម្មការ។

**ជម្រើសទី២ៈ** បង់ប្រាក់លើកទី១ចំនួន៧០%ពេលចុះហត្ថលេខាលើកិច្ចសន្យា និងលើកចុងក្រោយចំនួន៣០%ពេលការងារចប់សព្វគ្រប់ដោយមានការយល់ព្រមទទួលស្គាល់ដោយគណៈកម្មការ។

បន្ទាប់ពីសម្រេចឯកភាពគ្នា កិច្ចសន្យារវាងអង្គការគាំពារកុមារខ្មែរ(CYK)និងជាងម៉ៅការសំណង់ត្រូវបានចុះហត្ថលេខា ហើយថវិកាលើកទី១ ត្រូវបានបង់ជូនជាងម៉ៅការសំណង់។ ហើយគណៈកម្មការជាអ្នកចុះអង្កេត ពិនិត្យតាមដានការសាងសង់ឬជួសជុលនិងថតរូប និងរាយការណ៍សកម្មភាពជាងផ្ញើមកអង្គការគាំពារកុមារខ្មែរ(CYK)ជាព័ត៌មាន។

ក្នុងអំឡុងពេលសាងសង់ឬជួសជុល ទីប្រឹក្សារបស់អង្គការក៏ចាប់ផ្តើមបណ្តុះបណ្តាលគ្រូដំបូងមានរយៈពេល២០ថ្ងៃនៅការិយាល័យរបស់អង្គការនៅទីក្រុងភ្នំពេញ។ ក្នុងអំឡុងពេលបណ្តុះបណ្តាលដំបូងនេះ នាយិកាអង្គការតែងតែផ្តល់ឱកាសដល់គ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងដែលស្ម័គ្រចិត្ត ហើយឃុំសង្កាត់បានជ្រើសរើសឱ្យបង្រៀន ប៉ុន្តែមិនមានលទ្ធភាពក្នុងការបណ្តុះបណ្តាល បានចូលរួមទៅតាមសំណើរបស់មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក។ ចំពោះគ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងដែលបានចូលរួមវគ្គបណ្តុះបណ្តាលនោះ នាយិកាអង្គការនិងប្រធានរដ្ឋបាលបានជួយឧត្ថម្ភលើឯកសារ ការផលិតសម្ភារៈសម្រាប់បង្រៀន/រៀន និងតុបតែងថ្នាក់ និងកន្លែងស្នាក់នៅដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងផ្តល់កញ្ចប់សម្ភារៈល្បែងសិក្សាសម្រាប់ថ្នាក់ផងដែរ។ ឯខ្លឹមសារដែលបានបណ្តុះបណ្តាល គឺផ្តោតលើមេរៀនមួយចំនួនដែលជាចំណេះទូទៅទាក់ទងនឹងគ្រូនិងកុមារ និង មេរៀនមួយចំនួនទាក់ទងនឹងជំនាញមត្តេយ្យសិក្សារួមមានៈ តួនាទី និងភារកិច្ចរបស់គ្រូមត្តេយ្យសិក្សាសហគមន៍ របៀបធ្វើផែនការអភិវឌ្ឍន៍ថ្នាក់មត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំ-ខែ ការរៀបចំតុបតែងថ្នាក់រៀនតាមស្តង់ដា ការរៀបចំសៀវភៅ បញ្ជីផ្សេងៗ ការរៀបចំក្រូណូនិងសឺមីទុកដាក់ឯកសារតាមប្រភេទ ការផលិតនិងប្រើប្រាស់សម្ភារឧបទេសតាមកម្មវិធីសិក្សាប្រចាំខែ ការប្រើប្រាស់កម្មវិធីសិក្សាប្រចាំថ្ងៃ-ខែ វិធីសាស្ត្រនៃការបង្រៀនគ្រប់មុខវិជ្ជា របៀបបំពេញខ្លឹមសារក្នុងទម្រង់តារាងផ្សេងៗ និងរបៀបធ្វើតេស្តសម្រាប់កុមារអាយុ៥ឆ្នាំ។ ហើយគ្រូៗក៏បាន ផលិតសម្ភារៈបង្រៀន/រៀនសម្រាប់រយៈពេល១០ខែ និងសម្ភារៈសម្រាប់ តុបតែងថ្នាក់ផងដែរ។

ក្រោយការងារសាងសង់ឬជួសជុលថ្នាក់ បង្គន់អនាម័យ និងកន្លែងលាងដៃ ត្រូវបានបញ្ចប់ជាស្ថាពរ ហើយវគ្គបំបណ្តុះបណ្តាលគ្រូក៏ត្រូវបានបញ្ចប់ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរបាន

សហការជាមួយសមាជិកគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងមន្ត្រីការិយាល័យអប់រំស្រុក និងគ្រូប្រចាំថ្នាក់ អញ្ជើញគ្រូមត្តេយ្យសិក្សារដ្ឋនិងមត្តេយ្យសហគមន៍ដែលនៅក្បែរៗ មកជួយរៀបចំតុបតែងថ្នាក់បំពាក់សម្ភារបង្រៀន/រៀន និងសម្ភារៈបរិក្ខា រួចចាប់ផ្តើមចុះឈ្មោះកុមារ និងការបើកដំណើរការមត្តេយ្យសិក្សាសហគមន៍ទាំងនោះជាផ្លូវការ។

**២. ពេលកំពុងដំណើរការថ្នាក់៖**

ដោយមានការឯកភាពពីថ្នាក់ដឹកនាំមន្ទីរអ.យ.កខេត្ត មន្ត្រីជំនាញថ្នាក់ស្រុក គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍និងមាតាបិតាផង និងដើម្បីឱ្យមាតាបិតាកុមារយល់ថា មត្តេយ្យសិក្សាសហគមន៍គឺជារបស់សហគមន៍ផង អង្គការគាំពារកុមារខ្មែរ(CYK)លើកទឹកចិត្តពួកគាត់ឱ្យចូលរួមបង់វិភាគទានចំនួន ២០០០រៀលពេលចុះឈ្មោះ(តែម្តងគត់) និងបង់ប្រចាំខែ១នាក់៤០០០រៀល ដើម្បីសន្សំទុករយៈពេល៣ឆ្នាំ។ បន្ទាប់ពីអង្គការបញ្ចប់គម្រោងគណៈកម្មការអាចយកប្រាក់សន្សំនេះទៅដំណើរការអភិវឌ្ឍន៍ថ្នាក់មត្តេយ្យសិក្សាសហគមន៍បន្ត។ បន្ទាប់មកគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ បានផ្សព្វផ្សាយដល់មាតាបិតាកុមារពីការយកប្រាក់វិភាគទាន ដោយបញ្ជាក់ច្បាស់ពីមូលហេតុ និងការប្រើប្រាស់ប្រាក់វិភាគទាន។ ការយកប្រាក់វិភាគទាន គឺមានចែងនៅក្នុងពាក្យសុំចុះឈ្មោះចូលរៀន ដូច្នេះពេលមាតាបិតាកុមារមកចុះឈ្មោះឱ្យកូន ពួកគាត់ត្រូវអានពាក្យនេះសិន ហើយគ្រូក៏ពន្យល់បន្ថែមពីការប្រាក់វិភាគទាន។ បើករណីមានមាតាបិតាកុមារមួយចំនួនមិនចេះអក្សរទេនោះ គ្រូត្រូវអានឲ្យពួកគាត់ស្តាប់ បើពួកគាត់ព្រមព្រៀងហើយ គឺត្រូវចុះហត្ថលេខាជាភស្តុតាងនៃការយល់ព្រម។ សម្រាប់មាតាបិតាដែលមិនមានលទ្ធភាពបង់ប្រាក់វិភាគទាននេះ អង្គការមានការងារដេរ បាល់និងតុក្កតាក្រណាត់ជូនប្រចាំខែ ដើម្បីរកប្រាក់ចំណូលបន្ថែមផង និងដើម្បីអាចចូលរួមវិភាគទានសម្រាប់ កូនគាត់ជារៀងរាល់ខែផង។

**២.១. ការចុះពិនិត្យតាមដាន៖**

បន្ទាប់ពីថ្នាក់មត្តេយ្យសិក្សាសហគមន៍ចាប់ផ្តើមដំណើរបង្រៀននិងរៀនបានមួយខែ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ(CYK) មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់មន្ទីរនិងថ្នាក់ស្រុក សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ (គ.ក.នក) ដែលជាតំណាងគណៈកម្មការគ្រប់គ្រង មត្តេយ្យសិក្សាសហគមន៍ បានចុះពិនិត្យតាមដានការអនុវត្តការងាររបស់គ្រូរៀងរាល់ខែ នៅគ្រប់មត្តេយ្យសិក្សាសហគមន៍ក្នុងគម្រោង។ ការចុះពិនិត្យតាមដានគឺផ្តោតលើសូចនាករចំនួន៣៣ដែលជាសូចនាករវាយតម្លៃគ្រូមត្តេយ្យសិក្សាសហគមន៍ចូលស្តង់ដា។ ការចុះពិនិត្យតាមដានខែដំបូងគឺផ្តោតលើការរៀបចំថ្នាក់រៀនតាមស្តង់ដា ការរៀបចំសៀវភៅ និងបញ្ជីផ្សេងការរៀបចំក្រូណូនិងសីមីទុកដាក់ឯកសារតាមប្រភេទ និងការគ្រប់គ្រងកុមារ។ ខែបន្តបន្ទាប់ ចុះពិនិត្យតាមដានលើការអនុវត្តសូចនាករដែលគ្រូត្រូវអនុវត្តឱ្យបានពេញលេញគ្រប់ចំនួន ដើម្បីបំពេញស្តង់ដារហូតដល់អង្គការគាំពារកុមារខ្មែរ(CYK)ត្រូវបានបញ្ចប់គម្រោង។ ចំពោះមន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក គណៈកម្មការគ្រប់គ្រងមត្តេយ្យក៏បានអនុវត្តសូចនាករមួយចំនួនដែលជាការងាររបស់ពួកគាត់ ដើម្បីបំពេញពិន្ទុឱ្យគ្រូផងដែរ។ រាល់ការចុះពិនិត្យតាមដានម្តងៗពេលបញ្ចប់ការសង្កេតក្រុមការងារតែងតែបានប្រជុំជាមួយគ្រូដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តការងារថ្ងៃកំពុងសង្កេត ការអនុវត្តអនុសាសន៍ពីខែមុនដោយបញ្ជាក់ពីចំណុចដែលធ្វើបានល្អ ចំណុចដែលធ្វើមិនទាន់បានល្អ ការជួយបំពេញបន្ថែមនូវអ្វីៗដែលគ្រូធ្វើមិនទាន់បាន ដោះស្រាយនូវរាល់សំណូមពររបស់គ្រូ ផ្តល់អនុសាសន៍សម្រាប់គ្រូអនុវត្តខែបន្ទាប់ដោយសរសេរអនុសាសន៍ក្នុងសៀវភៅអនុសាសន៍របស់គ្រូ និងមានសរសេរកំណត់ហេតុប្រជុំជាក់

លាក់ ដើម្បីទុកជាឯកសារភស្តុតាង។

**២.២. ការបំប៉នសមត្ថភាពគ្រូបន្ថែម៖**

ក្រោយពីក្រុមការងារបានចុះពិនិត្យតាមដានការអនុវត្តការងាររបស់គ្រូគ្រប់កន្លែងជារៀងរាល់ខែ ឃើញថាគ្រូនៅមិនទាន់យល់ច្បាស់ ឬខ្សោយលើមុខវិជ្ជាណាមួយ ឬមានសំណូមពរពីតម្រូវការចាំបាច់របស់គ្រូ និងមានវិធីសាស្ត្រថ្មីៗ អង្គការគាំពារកុមារខ្មែរ(CYK) យកចំណុចទាំងនោះមកបើកជាវគ្គបំប៉នសមត្ថភាពគ្រូបន្ថែមរយៈពេល១០ថ្ងៃ រៀងរាល់ឆ្នាំ។ មុននឹងបើកវគ្គបំប៉នក្រុមការងារជំនាញកុមារតូចថ្នាក់មន្ទីរ និងថ្នាក់ស្រុក និងទីប្រឹក្សាគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ (CYK) បានប្រជុំដើម្បីសម្រេចកំណត់មេរៀនដែលត្រូវយកមកបំប៉នសមត្ថភាពគ្រូបន្ថែម។ ការបំប៉នសមត្ថភាពគ្រូនេះ តែងតែផ្តល់ឱកាសឱ្យគ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងបានចូលរួមតាមសំណើរបស់មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក។ ម្យ៉ាងទៀតអង្គការគាំពារកុមារខ្មែរ(CYK)ក៏បានជួយជាសម្ភារៈនិងឯកសារមួយចំនួនដល់គ្រូមត្តេយ្យសិក្សាសហគមន៍ក្នុងគម្រោងដែរ គ្រាន់តែមិនបានជួយឧបត្ថម្ភអាហារប្រចាំថ្ងៃ។ ក្រោយពីបញ្ចប់វគ្គបំប៉នក្រុមការងារតែងតែបានតាមដានការប្រែប្រួលរបស់គ្រូនៅពេលចុះពិនិត្យតាមដានប្រចាំខែម្តងៗ។

**២.៣. កម្មវិធីចុះទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍៖**

ការជួយអភិវឌ្ឍន៍សមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍ បន្ថែមមិនមែនធ្វើតែតាមវគ្គបំប៉នសមត្ថភាព តាមការចុះពិនិត្យតាមដាន និងតាមការប្រជុំបច្ចេកទេសនោះទេ អង្គការគាំពារកុមារខ្មែរ(CYK)ក៏បានបង្កើតកម្មវិធីទស្សនៈកិច្ចសិក្សារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងគ្រូមត្តេយ្យសិក្សាសហគមន៍ក្នុងគម្រោងជាមួយគ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងដែលអនុវត្តការងារបានល្អ ហើយជាប់ស្តង់ដា។ ការចុះទស្សនៈកិច្ចសិក្សាគឺផ្តោតទៅលើអ្វីដែលជាតម្រូវការចាំបាច់របស់គ្រូមត្តេយ្យសិក្សាសហគមន៍ដែលពួកគាត់មិនអាចធ្វើបាន ឬធ្វើមិនបានល្អ ដូចជាការគ្រប់គ្រងកុមារ ការរៀបចំបរិស្ថានក្នុងនិងក្រៅថ្នាក់រៀន ការងារបង្រៀននិងរៀន ការផលិតសម្ភារឧបទេសសម្បូរបែប របៀបទំនាក់ទំនងជាមួយសហគមន៍ មាតាបិតាកុមារ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ថ្នាក់មត្តេយ្យសិក្សាសហគមន៍ពីមួយឆ្នាំទៅមួយឆ្នាំ។ រាល់ដំណើរការទស្សនៈកិច្ចសិក្សារៀងរាល់ឆ្នាំ ពីក្រុមការងារតែងតែរៀបចំសរសេរជាឯកសារបទពិសោធន៍ ដោយសរសេរលម្អិតពីដំណើរការអនុវត្តបន្តបន្ទាប់ ទៅតាមសកម្មភាព នីមួយៗ ដើម្បីចែកជូនគ្រូយកទៅអនុវត្ត។ ក្រោយពីបានបញ្ចប់ដំណើរចុះទស្សនៈកិច្ចសិក្សា ក្រុមការងារតែងតែបានតាមដានការប្រែប្រួលរបស់គ្រូនៅពេលចុះពិនិត្យតាមដានប្រចាំខែម្តងៗ និងឱ្យពួកគាត់រាយការណ៍នៅពេលពួកគាត់ទៅចូលរួមវគ្គបំប៉ន។

**២.៤. ការងាររបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍៖**

នៅពេលដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ គណៈកម្មការគ្រប់គ្រងគ្រប់កន្លែងកន្លងមកពួកគាត់មិនទាន់យល់ពីការងារមត្តេយ្យសិក្សាសហគមន៍ជាការទទួលខុសត្រូវរបស់ពួកគាត់នោះទេ ពួកគាត់គិតថាជាភារកិច្ចរបស់អ្នកទទួលបន្ទុកការងារអប់រំកុមារតូចថ្នាក់ស្រុកទៅវិញ។ ម្យ៉ាងទៀតពួកគាត់មិនដែលបានធ្វើផែនការសកម្មភាពសម្រាប់អភិវឌ្ឍថ្នាក់មត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំនៅឡើយដែរ គឺធ្វើការងារទៅតាមថវិកាដែលមាន ឬតាមនឹកឃើញ។ ដោយមើលឃើញបញ្ហាទាំងអស់នេះហើយទើបអង្គការគាំពារកុមារខ្មែរ(CYK)បានសហការជាមួយមន្ត្រីជំនាញថ្នាក់មន្ទីរនិងថ្នាក់ស្រុក រៀបចំឱ្យមាន៣សកម្មភាព សម្រាប់ជួយគណៈកម្មការគ្រប់គ្រងមត្តយ្យសិក្សាសហគមន៍ ឱ្យមានសមត្ថភាពពេញលេញ សម្រាប់ជួយថ្នាក់មត្តេយ្យសិក្សា

សហគមន៍ឱ្យមានដំណើរ ការល្អពីមួយឆ្នាំទៅមួយឆ្នាំ។ សកម្មភាពទាំង៣ រួមមានៈ

**២.៤.១. វគ្គបណ្តុះបណ្តាលៈ** រៀងរាល់ឆ្នាំ បានបើកវគ្គបណ្តុះបណ្តាលគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ មានរយៈពេល៥ថ្ងៃ ដោយផ្តោតលើតួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ការអនុវត្តការងាររបស់គ្រូមត្តេយ្យសិក្សាសហគមន៍ របៀបវាយតម្លៃគ្រូ មត្តេយ្យសិក្សាសហគមន៍ផ្អែកលើសូចនាករទាំង៣៣ និងធ្វើផែនការសកម្មភាពរបស់ គណៈកម្មការគ្រប់គ្រង មត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំ-ខែ សម្រាប់យកទៅអនុវត្តជាក់ស្តែងទៅតាមមូលដ្ឋាន រៀងៗខ្លួន និងសាកល្បងធ្វើផែនការថវិកា មួយឬពីរ សកម្មភាពជាគំរូ។

**២.៤.២. ដំណើរការទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ៈ** ផ្តល់ឱកាសឱ្យសមាសភាពគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍មួយកន្លែងចំនួន ៣នាក់ចូលរួមកម្មវិធីទស្សនៈកិច្ចសិក្សា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ជាមួយគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោង ដែលមានដំណើរការបានល្អ ដែលមិនមានអង្គការដៃគូណាជួយ។ ការចុះទស្សនៈកិច្ចសិក្សានេះផ្តោតសំខាន់លើវិធីសាស្ត្រនៃការកៀគរកថវិកា ដើម្បីអភិវឌ្ឍថ្នាក់មត្តេយ្យសិក្សាសហគមន៍ វិធីសាស្ត្រក្នុងការជំរុញឱ្យមាតាបិតាកុមារនិងសហគមន៍ ចូលរួមគាំទ្រថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងការងារមួយចំនួនទៀត ដែលធ្វើឱ្យមត្តេយ្យសិក្សាសហគមន៍រីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។

២.៤.៣. ការប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំៈ បានរៀបចំឱ្យមានការប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តការងាររយៈពេលមួយឆ្នាំ ដោយផ្តល់ឱកាសឱ្យសមាសភាពគណៈកម្មការមួយកន្លែងចំនួន ៣នាក់បានចូលរួមប្រជុំរយៈពេល៣ថ្ងៃ។ ការប្រជុំនេះផ្តោតលើការអនុវត្តការងាររយៈពេលមួយឆ្នាំ ដោយផ្អែកលើផែនការ សកម្មភាពដែលបានគ្រោងទុកប្រចាំឆ្នាំ និងលើកឡើងពីសកម្មភាពដែលបានធ្វើ សកម្មភាពដែលមិនទាន់បានធ្វើ រួចបញ្ជាក់ពីមូលហេតុដែលមិនបានធ្វើ រួមគ្នាដោះស្រាយការលំបាកណាដែលកន្លែងនីមួយៗមិនអាចដោះស្រាយបាន និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំថ្មីបន្តទៀត ដោយផ្អែកលើសកម្មភាពការងារដែលនៅសេសសល់ពីឆ្នាំចាស់ ផ្អែកលើបទពិសោធន៍ទទួលបានពីទស្សនៈកិច្ចសិក្សា និងបន្ថែមសកម្មភាពថ្មីៗមួយចំនួនទៀត។

**២.៥. កម្មវិធីពិសេសសម្រាប់កុមារ និងសកម្មភាពផ្សេងៗក្រៅពីការងារដែលបានរៀបរាប់ខាងលើអង្គការគាំពារកុមារខ្មែរ(CYK)បានអនុវត្តសកម្មភាពផ្សេងៗមួយចំនួនរួមមានៈ**

២.៥.១. ទិវាកុមារអន្តរជាតិ១មិថុនាៈ រៀងរាល់ឆ្នាំអង្គការគាំពារកុមារខ្មែរ(CYK)បានផ្តល់កញ្ចប់ថវិកាដល់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ទាំងអស់ក្នុងគម្រោងដើម្បីរៀបចំពិធីអបអរសាទរទិវាកុមារអន្តរជាតិ១មិថុនា ដើម្បី បង្កើនការយកចិត្តទុកដាក់អនុវត្តសិទ្ធកុមារជាមូលដ្ឋានដោយបង្កលក្ខណៈឱ្យកុមារបានសប្បាយរីករាយអបអរទទួលស្គាល់សិទ្ធពួកគេជាសកល និងចូលរួមគោរពនិងគាំពារសិទ្ធជាអនុសញ្ញាជាតិនិងអន្តរជាតិជាសកលស្តីពីសិទ្ធកុមារ ដោយលប់បំបាត់ចោលនិងមិនរើសអើងចំពោះកុមារពិការ ក្រីក្រ ជនជាតិដើមភាគតិចព្រមទាំងបញ្ឈប់និងប្រឆាំងដាច់ខាតលើការរំលោភបំពាន ការជួញដូរ ការគេងប្រវ័ញ្ច និងការប្រើអំពើហិង្សាលើកុមារគ្រប់រូបភាព។ ដោយមានការសម្របសម្រួលពីក្រុមការងារអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ (CYK) មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់មន្ទីរនិងថ្នាក់ស្រុក មាតាបិតានិងអាណាព្យាបាលកុមារ សមាជិកគណៈកម្មការគ្រប់គ្រង

មត្តេយ្យ គ្រូ និងកុមារ បានចូលរួម ស្តាប់យ៉ាងយកចិត្តទុកដាក់ពីប្រវត្តិនៃទិវាកុមារអន្តរជាតិ និងចូល

រួមលេងល្បែងកំសាន្តនានា ដូចជា ទាញព្រ័ត លោតបាវ ហុចបាល់បន្តគ្នា ជិះសេះប្រណាំងគ្នា មនុស្ស២នាក់ជើង៣ បំបែកប៉េងប៉ោង ដើរលើត្រឡោក ជាដើមនិងហូបអាហារសាមគ្គីយ៉ាងសប្បាយរីករាយ។

២.៥.២.ពីធីបញ្ជូនកុមារគ្រប់អាយុ៦ឆ្នាំទៅបឋមសិក្សា៖ពេលកុមារដែលរៀននៅមត្តេយ្យសិក្សាសហគមន៍ គ្រប់អាយុ៦ឆ្នាំ ពួកគាត់ត្រូវបានបញ្ជូនទៅរៀននៅថ្នាក់ទី១នៃសាលាបឋមសិក្សា អង្គការគាំពារកុមារខ្មែរ(CYK)បានចេញវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាឱ្យពួកគាត់រៀងរាល់ឆ្នាំ ហើយបានរៀបចំធ្វើពិធីដើម្បីប្រគល់វិញ្ញាបនប័ត្រ ជាការលើកទឹកចិត្តដល់ពួកគាត់ និងមាតាបិតាកុមារ។ ពិធីនេះមានការចូលរួមពីក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការ ថ្នាក់ដឹកនាំមន្ទីរអ.យ.កខេត្ត មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក គណៈកម្មការគ្រប់គ្រង មាតាបិតាកុមារ គ្រូ និងកុមារ។

២.៥.៣. ការចែកជូនសម្ភារៈល្បែង៖ អង្គការគាំពារកុមារខ្មែរក៏បានផ្តល់បាល់និងតុក្កតាក្រណាត់ និងសម្ភារឧបទេស/ល្បែងសិក្សា ដូចជា ក្តារផ្គុំរូបឡាន ក្តាររៀបអក្សរក-ខ ផ្ទាំងអក្សរក-ខភ្ជាប់រូបភាព កាតក-ខភ្ជាប់រូបភាព ល្បែងចាប់គូបន្លែ ផ្លែឈើ និងសត្វ ផ្ទាំងព្យញ្ជនៈទាំង៣៣តួ ផ្ទាំងជើងព្យញ្ជនៈទាំង៣៣តួ សៀវភៅមិត្តវិទ្យាសាស្ត្ររូបភាព សៀវភៅរឿង សៀវភៅចម្រៀង និងសៀវភៅកំណាព្យ ជាដើម ជូនកុមារមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍របស់អង្គការមួយចំនួនដែលធ្វើការងារទាក់ទងការថែទាំ អប់រំ និងអភិវឌ្ឍន៍កុមារតូច នៅទូទាំងប្រទេសកម្ពុជា។

## ៣. ក្រោយពេលដំណើរការថ្នាក់៖

ក្រោយពីការគាំទ្ររយៈពេល៣ឆ្នាំ អង្គការគាំពារកុមារខ្មែរ (CYK) បានធ្វើពិធីផ្ទេរការទទួលខុសត្រូវលើដំណើរការនិងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍ជូនទៅគណៈកម្មការគ្រប់គ្រង និងក្រុមប្រឹក្សាឃុំ និងបានប្រគល់ប្រាក់វិភាគទានដែលបានសន្សំទុករយៈពេល៣ឆ្នាំ ជូនតំណាងគណៈកម្មការគ្រប់គ្រងសម្រាប់ប្រើប្រាស់ ដើម្បីបន្តនិរន្តរភាពនិងអភិវឌ្ឍន៍ថ្នាក់មត្តេយ្យនោះ ដោយមានឯកសារបញ្ជាក់ត្រឹមត្រូវ។ ពិធីនេះមានការចូលរួមពីក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការ ថ្នាក់ដឹកនាំមន្ទីរអ.យ.កខេត្ត មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ គណៈកម្មការគ្រប់គ្រង មាតាបិតាកុមារ និងកុមារ មត្តេយ្យសិក្សាសហគមន៍។

ក្រោយពីបានផ្ទេរការទទួលខុសត្រូវលើដំណើរការនិងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍ ជូនគណៈកម្មការគ្រប់គ្រងនិងក្រុមប្រឹក្សាឃុំ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ(CYK) បានចុះពិនិត្យតាមដានចំនួន៤លើកនៅឆ្នាំបន្ទាប់នៅតាមទីតាំងនីមួយៗ ដើម្បីវាយតម្លៃលើដំណើរការនិងការគ្រប់គ្រងបន្តរបស់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ទាំងនោះ ជួយគ្រូបន្ថែមលើការងារបច្ចេកទេសនិងការងាររដ្ឋបាល និងផ្តល់ជា សម្ភារៈបម្រើឱ្យការងារបង្រៀននិងរៀនទៅតាមលទ្ធភាព។

**បញ្ហាប្រឈម**

១. គ្រូមានសមត្ថភាពមិនស្មើគ្នា ដូច្នេះការទទួលយកចំណេះដឹងបន្ថែមតាមរយៈ ការផ្តល់អនុសាសន៍នៅពេលចុះពិនិត្យតាមដាន ក៏ពួកគាត់អភិវឌ្ឍសមត្ថភាពជំនាញ (ការបង្រៀន ការគ្រប់គ្រងកុមារការរៀបចំបរិស្ថានក្នុងនិងក្រៅថ្នាក់ និងការងារទំនាក់ទំនងជាមួយគ្រប់អ្នកពាក់ព័ន្ធ)មិនបានដូចគ្នាដែរ។

២. មេរៀនមួយចំនួនមិនមានសរសេរខ្លឹមសារនៅក្នុងសៀវភៅគ្រូ ជាពិសេសមេរៀនក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ដូច្នេះការបង្រៀនមិនទាន់បានសម្រេចលទ្ធផល ទៅតាមស្តង់ដានៃកំរិតអាយុរបស់កុមារ។

៣.ល្បែងលេងក្រៅថ្នាក់នៅមានចំនួនតិច មិនទាន់សមស្របតាមចំនួនកុមារ ហើយគណៈកម្មការគ្រប់គ្រងខ្វះការច្នៃប្រឌិតសម្ភារៈល្បែងក្រៅថ្នាក់បន្ថែមដែលអាចរកបាននៅមូលដ្ឋានសម្រាប់កុមារលេង ដោយពឹងផ្អែកតែលើ សម្ភារល្បែងក្រៅថ្នាក់ដែលអង្គការផ្តល់ជូនប៉ុណ្ណោះ។

៤. គណៈកម្មការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍មួយចំនួន អនុវត្តការងារមិនបានសម្រេចតាមលទ្ធផលដែលបានគ្រោងទុកក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ដោយសារទេពកោសល្យ ក្នុងការកៀរគរថវិកាសម្រាប់អភិវឌ្ឍថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងជីវភាពរបស់សហគមន៍នៅមានកំរិត។

៥. មាតាបិតាមួយចំនួនមិនយល់អំពីច្បាស់អំពីសារៈសំខាន់នៃការអប់រំកុមារតូច និងមិនសូវយកចិត្តទុកដាក់ក្នុងការចូលរួមប្រជុំនិងគាំទ្រដល់មត្តេយ្យសិក្សាសហគមន៍។

VI. **បូកសរុប**

ចាប់ពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០២៣ អង្គការគាំពារកុមារខ្មែរ(CYK)បានគាំទ្រលើការបើកដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍សរុបចំនួន៣២កន្លែង(៣៤ថ្នាក់) ក្នុងខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង។ ហើយមត្តេយ្យសិក្សាសហគមន៍ទាំងនោះនៅតែដំណើរការបានល្អប្រសើរ ដោយមានការគាំទ្រពីក្រុមប្រឹក្សាឃុំ គណៈកម្មការគ្រប់គ្រង និងមាតាបិតា ក្រោយពីអង្គការបានផ្ទេរការទទួលខុសត្រូវលើដំណើរការ និងការគ្រប់គ្រង ជូនក្រុមប្រឹក្សាឃុំ និងគណៈកម្មការគ្រប់គ្រងទាំងអស់ ត្រឹមចុងខែមីនា ឆ្នាំ២០២៤។ លើកលែងតែមត្តេយ្យ១កន្លែងក្នុងភូមិឈើទាល ស្រុកអង្គស្នួល ខេត្តកណ្តាលដែលត្រូវបានបិទដោយសារអ្នកគ្រូទទួលមរណៈភាពដោយជម្ងឺ ហើយមិនអាចរកគ្រូថ្មីមកជំនួសបាន។ ក្នុងចំណោមមត្តេយ្យសិក្សាសហគមន៍ទាំង៣២កន្លែង(៣៤ថ្នាក់) មានមត្តេយ្យសិក្សាសហគមន៍សរុបចំនួន២៣កន្លែង(២៥ថ្នាក់)ត្រូវបានវាយម្លៃក្លាយជាមត្តេយ្យសិក្សាសហគមន៍ស្តង់ដាត្រឹមឆ្នាំ២០២៤។

ដំណើរការសកម្មភាពដែលបានសរសេរខាងលើនេះបានបង្ហាញអំពីការគាំទ្រ និងដំណើរការនៃការបើកដំណើរការនិងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍របស់អង្គការគាំពារកុមារខ្មែរ (CYK) នៅប្រទេសកម្ពុជា ចាប់តាំង ពីពេលចាប់ផ្តើមគម្រោងរហូតដល់បញ្ចប់គម្រោង។ ឯកសារនេះអាចជាឯកសារយោងសម្រាប់អ្នកដែលមា លទ្ធភាពចង់បង្កើតមត្តេយ្យសិក្សាសហគមន៍ ហើយចង់ដំណើរការឱ្យបានល្អប្រសើរ និងជោគជ័យ។

ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤

អ៊ុម សុផានី
ទីប្រឹក្សាគម្រោងអប់រំកុមារតូច
របស់អង្គការគាំពារកុមារខ្មែរ(CYK)